២- **មន្ទីរពេទ្យ សម្តេចឪ-សម្តេចម៉ែ** គីឡូម៉ែត្រលេខ៦ មានព្រះរាជអំណោយ ៖

+ ទឹកបរិសុទ្ធ PRO VIDA ចំណុះ ១,៥ L ចំនួន ២ កេស
+ កន្សែងជូតដៃ ចំនួន ២ កេស









ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

លិខិតទទួលព្រះរាជទ្រព្យ

ខ្ញុំម្ចាស់ មានសេចក្តីសោមនស្សរីករាយយ៉ាងក្រៃលែង និងសូមថ្លែងអំណរព្រះរាជគុណដ៏ខ្ពង់ខ្ពស់ជាទីបំផុត ដោយបានទទួលទឹកបរិសុទ្ធ**ប្រ៊ូវីដា** ចំណុះ 500ml ចំនួន ១១កេស និងកន្សែងត្រជាក់MG ចំនួន ១១កេសដែលជាព្រះរាជទានដ៏ថ្លៃថ្លារបស់ **សម្តេចព្រះមហាក្សត្រី ព្រះឥរាជមាតាជាតិខ្មែរ** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត នារសៀលថ្ងៃទី ១១ ខែសីហា ឆ្នាំ២០២៥ នៅមន្ទីរពេទ្យគន្ធបុប្ផាទី២ រាជធានីភ្នំពេញ ។

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែសីហា ឆ្នាំ២០២៥

ខ្ញុំម្ចាស់



ឈ្មោះ ប៉ាស្ការ៉ាប្រជ.អ៊ុំ ម៉ាំងឡុង

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

លិខិតទទួលព្រះរាជទ្រព្យ

ទូលព្រះបង្គំជាខ្ញុំ មានសេចក្តីសោមនស្សរីករាយយ៉ាងក្រៃលែង និងសូមថ្លែងអំណរព្រះរាជគុណដ៏ខ្ពង់ខ្ពស់ជាទីបំផុត ដោយបានទទួលទឹកបរិសុទ្ធចំណុះ**ប្រ៊ូវីដា** 1500ml ចំនួន ០២កេស និងកន្សែងត្រជាក់MG ចំនួន ០២កេស ដែលជាព្រះរាជទានដ៏ថ្លៃថ្លារបស់ **សម្តេចព្រះមហាក្សត្រី ព្រះឥរាជមាតាជាតិខ្មែរ** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត នារសៀលថ្ងៃទី ១១ ខែសីហា ឆ្នាំ២០២៥ នៅមន្ទីរពេទ្យបង្អែក **សម្តេចឪ-សម្តេចម៉ែ** សង្កាត់គីឡូម៉ែត្រលេខ៦ រាជធានីភ្នំពេញ ។

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែសីហា ឆ្នាំ២០២៥

ទូលព្រះបង្គំជាខ្ញុំ



វេជ្ជ. ឃី សុខខេង

ថ្ងៃចន្ទ ២រោច ខែស្រាពណ៍ ឆ្នាំម្សាញ់ សប្តស័ក ពុទ្ធសករាជ ២៥៦៩ ត្រូវនឹងថ្ងៃទី១១ ខែសីហា ឆ្នាំ២០២៥

បពិត្រសម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរនៃព្រះរាជាណាចក្រកម្ពុជា ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត!

ទូលបង្គំយើងខ្ញុំ ជាកូនចៅ ចៅទួតទាំងអស់គ្នា សូមព្រះបរមរាជានុញ្ញាត ក្រាបបង្គំថ្វាយ នូវកតញ្ញូតាធម៌ និងអរព្រះរាជគុណ ដ៏ជ្រាលជ្រៅជាទីបំផុត ចំពោះ ព្រះរាជហឫទ័យដ៏ឧត្តុង្គឧត្តមថ្លៃថ្លា ខ្ពង់ខ្ពស់ជាទីបំផុត របស់សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល ដែល ជានិច្চকাল ព្រះអង្គតែងតែគិតគូរយកព្រះទ័យទុក្ខជាក់ ដល់សុខុមាលភាព របស់ កូនចៅ ចៅទួតរបស់ព្រះអង្គ ដែលព្រះអង្គសព្វព្រះរាជហឫទ័យ ប្រទានទឹកបរិសុទ្ធ ប្រូវីជា ចំនួន ១១ កេស និងកន្សែងត្រជាក់ អ៊ីម ជី ចំនួន ១១ កេស ដល់មន្ទីរពេទ្យគន្ធបុប្ផា។

ទូលព្រះបង្គំយើងខ្ញុំទាំងអស់គ្នា សូមលើកអញ្ជលីប្រណមបួងសួងដល់ គុណបុណ្យព្រះរតនត្រ័យ គុណកែវទាំងបី អធិដ្ឋានដល់ព្រះបារមីនៃទេវតាថែរក្សា ព្រះមហាស្វេតច្ឆត្រ និងព្រះឫទ្ធានុភាព នៃព្រះវិញ្ញាណក្ខន្ធ អតីតព្រះមហាក្សត្រ ព្រះមហាក្សត្រីយានីខ្មែរគ្រប់ព្រះអង្គ ព្រមទាំងវត្ថុស័ក្តសិទ្ធិ ក្នុងលោក ជាពិសេសសូមដួងព្រះវិញ្ញាណក្ខន្ធ **ព្រះករុណាព្រះបាទសម្តេច នរោត្តម សីហនុ** ព្រះមហាវីរៈក្សត្រ ព្រះវររាជបិតា ឯករាជ្យ បូរណភាពទឹកដី និងឯកភាពជាតិខ្មែរ «**ព្រះបរមរតនកោដ្ឋ**» សូមតាមជួយទ្រទ្រង់ថែរក្សាការពារ សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ ជាទីសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត សូមព្រះអង្គមានព្រះរាជសុខភាពល្អបរិបូរណ៌ ព្រះជន្មាយុយឺនយូរ ព្រះកាយពលមាំមួន ព្រះបញ្ញាញាណភ្លឺថ្លា ដើម្បីទ្រង់គង់ប្រថាប់ ជាម្លប់ដ៏ត្រជាក់ត្រជុំ ដល់ប្រជារាស្ត្រខ្មែរ លើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា សម្បូរសប្បាយ ថ្កុំថ្កើងរុងរឿងជានិច្চនិរន្តន៍តរៀងទៅ។

មន្ទីរពេទ្យគន្ធបុប្ផាទី ២ រដ្ឋបណ្ឌិតបេអាតរិច្ចើរ



សាស្ត្រាចារ្យ.អ៊ីវ-ម៉ាឡែន

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

មន្ទីរសុខាភិបាល នៃរដ្ឋបាលរាជធានីភ្នំពេញ
ការិយាល័យសុខាភិបាលស្រុកប្រតិបត្តិ មេគន្ធ
មន្ទីរពេទ្យបង្អែក សម្តេចឪ សម្តេចម៉ែ

លិខិតថ្លែងអំណរព្រះរាជគុណ
សូមក្រាបបង្គំទូលថ្វាយ
សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាពសេចក្តី ថ្លៃថ្នូរ និងសុភមង្គល ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត

ទូលព្រះបង្គំជាខ្ញុំ តំណាងមន្ត្រី រាជការ-បុគ្គលិក-កម្មករ បំរើការក្នុងមន្ទីរពេទ្យបង្អែកសម្តេចឪ សម្តេចម៉ែ សូមលំឱនកាយថ្វាយនូវអំណរព្រះរាជគុណយ៉ាងក្រៀលក្រៅជាទីបំផុតចំពោះ **សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ដែលព្រះអង្គសព្វព្រះរាជហឫទ័យប្រោសព្រះរាជទាននូវ ៖

-ទឹកសុទ្ធប្រូវីដា ០២ កេស

-កន្សែងត្រជាក់ MG ០២ កេស

សម្រាប់ ព្រះរាជអំណោយដល់ប្រជារាស្ត្រ ជាកូន ចៅ ចៅទួត របស់ព្រះអង្គដែល មានបញ្ហាសុខភាព មកទទួល សេវាសុខភាព នៅមន្ទីរពេទ្យបង្អែកសម្តេចឪ សម្តេចម៉ែ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ។ ទូលព្រះបង្គំជាខ្ញុំ សូម ចាត់ចែងយកព្រះរាជអំណោយទាំងអស់ទៅ ចែកចាយ ព្យាបាល និងការពារជំងឺ ជូនប្រជារាស្ត្រជា កូន ចៅ ចៅទួត របស់ព្រះអង្គ ដែលកំពង់មានបញ្ហាសុខភាព ។

ទូលព្រះបង្គំជាខ្ញុំ សូមព្រះរាជាអនុញ្ញាតលំឱនកាយឧទ្ទិសបួងសួងដល់ គុណបុណ្យព្រះរតនត្រ័យកែវទាំងបីនិង វត្ថុស័ក្តិសិទ្ធិទាំងអស់ក្នុងលោក ជាអាទិ៍ ទេវតាឆ្នាំថ្មី នឹងយោងមកដល់ ទេវតារក្សាព្រះមហាស្វេតច្ឆត្រ ដួងព្រះវិញ្ញាណក្ខន្ធ អតីតព្រះមហាក្សត្រ ព្រះមហាក្សត្រិយានីខ្មែរគ្រប់ព្រះអង្គ ពិសេសបំផុត ដួងព្រះវិញ្ញាណក្ខន្ធ **ព្រះករុណា ព្រះបរមរតនកោដ្ឋ** សូមព្រះមេត្តាប្រោសព្រះរាជទានព្រះសព្វសាធុការពរមហាប្រសើរថ្វាយ **សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត សូមព្រះអង្គ ប្រកបដោយព្រះពុទ្ធពរទាំង ៤ ប្រការគឺ **អាយុ វណ្ណៈ សុខៈ ពលៈ** កុំបីឃ្លៀងឃ្លាតឡើយ ។

សូម **សម្តេចម៉ែ** ជាអម្ចាស់ជីវិតតម្កល់លើក្បូង ព្រះអង្គប្រោសព្រះរាជមេត្តាទទួលនូវអភិវន្ទកិច្ចនិង កតញ្ញូ កតវេទិតាធម៌ ដ៏ខ្ពង់ខ្ពស់បំផុត អំពីទូលព្រះបង្គំជាខ្ញុំ ។

ថ្ងៃ ចន្ទ២រោច ខែ ស្រាពណ៍ ឆ្នាំ ម្សាញ់ សប្តស័កព.ស ២៥៦៩
ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០២៥
ប្រធានមន្ទីរពេទ្យបង្អែក សម្តេចឪ សម្តេចម៉ែ

វេជ្ជ.អ៊ុន សុភ័ស្ត

ព្រះរាជាណាចក្រកម្ពុជា
ROYAUME DU CAMBODGE

ព្រះបរមរាជវាំង
លេខ:២៣៣ រ.ប.ក
/២៥

សូមព្រះបរមរាជានុញ្ញាតក្រាបបង្គំទូលថ្វាយ
សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ នៃព្រះរាជាណាចក្រកម្ពុជា
ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត

សូមព្រះតេជៈតម្កល់លើត្បូង

ទូលព្រះបង្គំជាខ្ញុំ សូមព្រះបរមរាជានុញ្ញាតក្រាបបង្គំទូលថ្វាយ **សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត សូមព្រះមេត្តាសណ្តាប់ក្រោមល្អងធូលីព្រះបាទ។

យោងតាមព្រះរាជតម្រិះដ៏ខ្ពង់ខ្ពស់ របស់ **សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត នៅរសៀលថ្ងៃទី៩ ខែសីហា ឆ្នាំ២០២៥ ទូលព្រះបង្គំជាខ្ញុំ និងថ្នាក់ដឹកនាំក្រសួងព្រះបរមរាជវាំង បានចុះពិនិត្យសកម្មភាពការងារមន្ត្រីក្រម **សម្តេចឪ** ដែលកំពុងជួយអន្តរាគមន៍ភ្ជួររាស់ដីស្រែរដូវវស្សាជូនបងប្អូនប្រជារាស្ត្រដែលខ្វះខាតមធ្យោបាយភ្ជួររាស់ដីស្រែ ស្ថិតនៅក្នុងឃុំកំពង់ចំឡង ស្រុកស្វាយជ្រំ ខេត្តស្វាយរៀង ។

កិច្ចអន្តរាគមន៍ភ្ជួររាស់ខាងលើនេះ បានចាប់ផ្តើមពីថ្ងៃទី២១ ខែឧសភា ឆ្នាំ២០២៥ រហូតដល់ថ្ងៃទី៩ ខែសីហា ឆ្នាំ២០២៥ សម្រេចបានលទ្ធផល ចំនួន ៧៥១ ហិកតា លើផ្ទៃដីស្រែសរុបចំនួន ១៩៨៧ ហិកតា ដោយប្រើប្រាស់ត្រាក់ទំភ្ជួររាស់ចំនួន ៦ គ្រឿង ។

តាមសភាពជាក់ស្តែងក្នុងតំបន់នេះ មានការរាំងស្ទះដោយមានភ្លៀងធ្លាក់ក្នុងរដូវវស្សា (រយៈពេលពីរឬបីសប្តាហ៍)។ ប៉ុន្តែបងប្អូនប្រជាកសិករសំណូមពរសុំអោយមានការភ្ជួររាស់ជូនគាត់ព្រោះសង្ឃឹមថាក្នុងដើមសប្តាហ៍នេះ ក្រសួងធនធានទឹក និងឧតុនិយមបានប្រកាសថា នឹងមានភ្លៀងធ្លាក់។ តាមពត៌មានពីមន្ត្រីភ្ជួររាស់បញ្ជាក់ថា នៅយប់ថ្ងៃទី៩ និងនៅយប់មិញនេះមានភ្លៀងធ្លាក់ប្រមាណ ២ ម៉ោងនៅលើវាលស្រែនេះ។

នៅក្នុងឱកាសនោះ ទូលព្រះបង្គំជាខ្ញុំ បានពាំនាំនូវព្រះរាជបណ្តាំផ្ញើសួរសុខទុក្ខ សេចក្តីនឹករលឹក និងស្រឡាញ់ដ៏ជ្រាលជ្រៅបំផុត អំពី **សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ទៅជម្រាបជូនបងប្អូនប្រជារាស្ត្រនិងអាជ្ញាធរដែនដីនៅទីនោះថា ប្រទេសកម្ពុជាយើងជាប្រទេសកសិកម្ម ប្រជារាស្ត្រភាគច្រើនប្រកបរបរចិញ្ចឹមជីវិតពឹងផ្អែកលើការធ្វើស្រែចម្ការ។ អាស្រ័យដូចនេះ**ព្រះអង្គ** តែងមានព្រះទ័យទុកដាក់ចំពោះវិស័យកសិកម្មតាំងតែពីដើមរៀងមក និងជាពិសេសការខ្វះខាតមធ្យោបាយភ្ជួររាស់ដីស្រែចំការរបស់បងប្អូនប្រជាកសិករ នៅតាមទីជនបទនានា។ **ព្រះអង្គ**បានប្រោសព្រះរាជទានដំណល់មន្ត្រីក្រម **សម្តេចឪ** នាំយកត្រាក់ទំរ និងប្រេងឥន្ធនៈ ចុះជួយភ្ជួររាស់ដីស្រែជូនបងប្អូនបានទាន់រដូវកាល់បង្កបង្កើនផលក្នុងឆ្នាំនេះ ។

បងប្អូនប្រជារាស្ត្រ និងអាជ្ញាធរដែនដីនៅទីនោះ មានសេចក្តីរីករាយយ៉ាងក្រៃលែង សូមក្រាបបង្គំទូលថ្វាយនូវអំណរព្រះរាជគុណដ៏ខ្ពង់ខ្ពស់ជាទីបំផុត និងសូមថ្វាយព្រះពរ **សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត សូមព្រះអង្គមានព្រះរាជសុខភាព ល្អបរិបូណ៌ព្រះជន្មាយុយឺនយូរ និងព្រះប្រកបតែនឹងព្រះបរមសុខគ្រប់ប្រការដើម្បីគង់ប្រថាប់ ជាមហាម្លប់ដ៏ត្រជាក់ដល់ប្រជារាស្ត្រដែលជាកូនចៅរបស់ព្រះអង្គនៅទូទាំងព្រះរាជាណាចក្រកម្ពុជាជាដរាបតរៀងទៅ ។

ទូលព្រះបង្គំជាខ្ញុំ សូមក្រាបបង្គំទូលថ្វាយភ្ជាប់មកជាមួយនូវៈ រូបថតសកម្មភាពខាងលើ ។

សេចក្តីដូចបានក្រាបបង្គំទូលថ្វាយខាងលើ សូម **សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត សូមព្រះមេត្តាជ្រាបដ៏ខ្ពង់ខ្ពស់បំផុត។

*សេចក្តីគួរពុំគួរ សូម **សម្តេចព្រះមហាក្សត្រី** ព្រះមេត្តាប្រោស ។*
ក្រាបបង្គំទូលថ្វាយ នៅថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០២៥
ក្រោមល្អងធូលីព្រះបាទ

ទូលព្រះបង្គំជាខ្ញុំ គុយ សុផល

អំពីការចុះពិនិត្យសកម្មភាពមន្ត្រីក្រុម **សម្តេចឪ**
ដែលកំពុងជួយអន្តរាគមន៍ភ្ជួររាស់ដីស្រែរដូវវស្សាដល់ប្រជាកសិករខ្វះខាតកម្លាំងអូសទាញ
ស្ថិតនៅក្នុងឃុំកំពង់ចំឡង ស្រុកស្វាយជ្រំ ខេត្តស្វាយរៀង
ថ្ងៃទី៩ ខែសីហា ឆ្នាំ២០២៥
















រូបភាពវាលស្រែដែលមានភ្លៀងធ្លាក់ប្រមាណ២ម៉ោង នៅយប់ថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២៥








ព្រះរាជាណាចក្រកម្ពុជា

ROYAUME DU CAMBODGE

ព្រះបរមរាជវាំង
លេខ:៤៣៦/ ប.ប

សូមព្រះបរមរាជានុញ្ញាតក្រាបបង្គំទូលថ្វាយ
សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ នៃព្រះរាជាណាចក្រកម្ពុជា
ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត

សូមព្រះតេជៈតម្កល់លើត្បូង

ទូលព្រះបង្គំជាខ្ញុំ សូមព្រះបរមរាជានុញ្ញាតក្រាបបង្គំទូលថ្វាយ **សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត សូមព្រះមេត្តាសណ្តាប់ក្រោមល្អងធូលីព្រះបាទ។

យោងតាមព្រះរាជតម្រិះដ៏ខ្ពង់ខ្ពស់ របស់ **សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត នៅរសៀលថ្ងៃទី១២ ខែសីហា ឆ្នាំ២០២៥ ទូលព្រះបង្គំជាខ្ញុំ បាននាំយកព្រះរាជអំណោយដ៏ថ្លៃថ្លាទៅប្រគល់ជូនមន្ទីរពេទ្យ **ហ្គេងម៉ែ** ស្ថិតនៅភូមិព្រៃសខាងកើត សង្កាត់ព្រៃសខណ្ឌដង្កោ រាជធានីភ្នំពេញ មានដូចជា ៖

- ព្រះរាជទ្រព្យ ចំនួន ២០,០០០,០០០ រៀល (១០០កញ្ចប់ ក្នុង១កញ្ចប់ ២០០,០០០រ)
- សារុង ចំនួន ២០០ សារុង
- ទឹកបរិសុទ្ធ PRO VIDA ចំណុះ 0,5 L ចំនួន ១០០ កេស
- កន្សែងជូតដៃ ចំនួន ៦ កេស

នៅក្នុងឱកាសនោះ ទូលព្រះបង្គំជាខ្ញុំ បានពាំនាំមកនូវព្រះរាជបណ្តាំសួរសុខទុក្ខអំពី **សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ជូនដល់បងប្អូនដែលកំពុងសម្រាកព្យាបាលជម្ងឺនៅក្នុងមន្ទីរពេទ្យ **ហ្គេងម៉ែ** និងបានចែកជូនផ្ទាល់នូវព្រះរាជអំណោយដ៏ថ្លៃថ្លា ចំនួន ៧៨នាក់ ដោយក្នុងម្នាក់ៗទទួលបាន ព្រះរាជទ្រព្យ ចំនួន ២០០,០០០រៀល សារុងចំនួន១ និងកន្សែងជូតដៃចំនួន ១ដុំ។ ចំពោះព្រះរាជអំណោយដែលនៅសល់ ពីការចែកជូនបងប្អូនកំពុងសម្រាកព្យាបាល ទូលព្រះបង្គំជាខ្ញុំ បានប្រគល់ជូនលោកប្រធានមន្ទីរពេទ្យទាំងអស់។

បន្ទាប់ពីបានទទួលព្រះរាជអំណោយដ៏ថ្លៃថ្លាខាងលើនេះរួចមក លោកប្រធានមន្ទីរពេទ្យ ក្រុមគ្រូពេទ្យ និងបងប្អូនដែលកំពុងសម្រាកព្យាបាល នៅក្នុងមន្ទីរពេទ្យ **ហ្គេងម៉ែ** ទាំងអស់ មានសេចក្តីរីករាយយ៉ាងក្រៃលែងដោយមិននឹកស្មានថាបានទទួលព្រះរាជអំណោយដ៏ថ្លៃថ្លានេះ និងសូមក្រាបបង្គំទូលថ្វាយនូវអំណរព្រះរាជគុណដ៏ខ្ពង់ខ្ពស់ជាទីបំផុត និងសូមថ្វាយព្រះពរ **សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត សូមព្រះអង្គមានព្រះរាជសុខភាពល្អបរិបូណ៌ ព្រះជន្មាយុ

ព្រះរាជាណាចក្រកម្ពុជា
ROYAUME DU CAMBODGE

ព្រះបរមរាជវាំង
លេខ:២៣៣ រ.ប.ក
/២៥

សូមព្រះបរមរាជានុញ្ញាតក្រាបបង្គំទូលថ្វាយ
សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ នៃព្រះរាជាណាចក្រកម្ពុជា
ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត

សូមព្រះតេជៈតម្កល់លើត្បូង

ទូលព្រះបង្គំជាខ្ញុំ សូមព្រះបរមរាជានុញ្ញាតក្រាបបង្គំទូលថ្វាយ **សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត សូមព្រះមេត្តាសណ្តាប់ក្រោមល្អងធូលីព្រះបាទ។

យោងតាមព្រះរាជតម្រិះដ៏ខ្ពង់ខ្ពស់ របស់ **សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត នៅរសៀលថ្ងៃទី៩ ខែសីហា ឆ្នាំ២០២៥ ទូលព្រះបង្គំជាខ្ញុំ និងថ្នាក់ដឹកនាំក្រសួងព្រះបរមរាជវាំង បានចុះពិនិត្យសកម្មភាពការងារមន្ត្រីក្រម **សម្តេចឪ** ដែលកំពុងជួយអន្តរាគមន៍ភ្ជួររាស់ដីស្រែរដូវវស្សាជូនបងប្អូនប្រជារាស្ត្រដែលខ្វះខាតមធ្យោបាយភ្ជួររាស់ដីស្រែ ស្ថិតនៅក្នុងឃុំកំពង់ចំឡង ស្រុកស្វាយជ្រំ ខេត្តស្វាយរៀង ។

កិច្ចអន្តរាគមន៍ភ្ជួររាស់ខាងលើនេះ បានចាប់ផ្តើមពីថ្ងៃទី២១ ខែឧសភា ឆ្នាំ២០២៥ រហូតដល់ថ្ងៃទី៩ ខែសីហា ឆ្នាំ២០២៥ សម្រេចបានលទ្ធផល ចំនួន ៧៥១ ហិកតា លើផ្ទៃដីស្រែសរុបចំនួន ១៩៨៧ ហិកតា ដោយប្រើប្រាស់ត្រាក់ទំភ្ជួររាស់ចំនួន ៦ គ្រឿង ។

តាមសភាពជាក់ស្តែងក្នុងតំបន់នេះ មានការរាំងស្ទះដោយមានភ្លៀងធ្លាក់ក្នុងរដូវវស្សា (រយៈពេលពីរឬបីសប្តាហ៍)។ ប៉ុន្តែបងប្អូនប្រជាកសិករសំណូមពរសុំអោយមានការភ្ជួររាស់ជូនគាត់ព្រោះសង្ឃឹមថាក្នុងដើមសប្តាហ៍នេះ ក្រសួងធនធានទឹក និងឧតុនិយមបានប្រកាសថា នឹងមានភ្លៀងធ្លាក់។ តាមពត៌មានពីមន្ត្រីភ្ជួររាស់បញ្ជាក់ថា នៅយប់ថ្ងៃទី៩ និងនៅយប់មិញនេះមានភ្លៀងធ្លាក់ប្រមាណ ២ ម៉ោងនៅលើវាលស្រែនេះ។

នៅក្នុងឱកាសនោះ ទូលព្រះបង្គំជាខ្ញុំ បានពាំនាំនូវព្រះរាជបណ្តាំផ្ញើសួរសុខទុក្ខ សេចក្តីនឹករលឹក និងស្រឡាញ់ដ៏ជ្រាលជ្រៅបំផុត អំពី **សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ទៅជម្រាបជូនបងប្អូនប្រជារាស្ត្រនិងអាជ្ញាធរដែនដីនៅទីនោះថា ប្រទេសកម្ពុជាយើងជាប្រទេសកសិកម្ម ប្រជារាស្ត្រភាគច្រើនប្រកបរបរចិញ្ចឹមជីវិតពឹងផ្អែកលើការធ្វើស្រែចម្ការ។ អាស្រ័យដូចនេះ**ព្រះអង្គ** តែងមានព្រះទ័យទុកដាក់ចំពោះវិស័យកសិកម្មតាំងតែពីដើមរៀងមក និងជាពិសេសការខ្វះខាតមធ្យោបាយភ្ជួររាស់ដីស្រែចំការរបស់បងប្អូនប្រជាកសិករ នៅតាមទីជនបទនានា។ **ព្រះអង្គ**បានប្រោសព្រះរាជទានដំណល់មន្ត្រីក្រម **សម្តេចឪ** នាំយកត្រាក់ទំរ និងប្រេងឥន្ធនៈ ចុះជួយភ្ជួររាស់ដីស្រែជូនបងប្អូនបានទាន់រដូវកាល់បង្កបង្កើនផលក្នុងឆ្នាំនេះ ។

បងប្អូនប្រជារាស្ត្រ និងអាជ្ញាធរដែនដីនៅទីនោះ មានសេចក្តីរីករាយយ៉ាងក្រៃលែង សូមក្រាបបង្គំទូលថ្វាយនូវអំណរព្រះរាជគុណដ៏ខ្ពង់ខ្ពស់ជាទីបំផុត និងសូមថ្វាយព្រះពរ **សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត សូមព្រះអង្គមានព្រះរាជសុខភាព ល្អបរិបូណ៌ព្រះជន្មាយុយឺនយូរ និងព្រះប្រកបតែនឹងព្រះបរមសុខគ្រប់ប្រការដើម្បីគង់ប្រថាប់ ជាមហាម្លប់ដ៏ត្រជាក់ដល់ប្រជារាស្ត្រដែលជាកូនចៅរបស់ព្រះអង្គនៅទូទាំងព្រះរាជាណាចក្រកម្ពុជាជាដរាបតរៀងទៅ ។

ទូលព្រះបង្គំជាខ្ញុំ សូមក្រាបបង្គំទូលថ្វាយភ្ជាប់មកជាមួយនូវៈ រូបថតសកម្មភាពខាងលើ ។

សេចក្តីដូចបានក្រាបបង្គំទូលថ្វាយខាងលើ សូម **សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត សូមព្រះមេត្តាជ្រាបដ៏ខ្ពង់ខ្ពស់បំផុត។

*សេចក្តីគួរពុំគួរ សូម **សម្តេចព្រះមហាក្សត្រី** ព្រះមេត្តាប្រោស ។*
ក្រាបបង្គំទូលថ្វាយ នៅថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០២៥
ក្រោមល្អងធូលីព្រះបាទ

ទូលព្រះបង្គំជាខ្ញុំ គុយ សុផល

អំពីការចុះពិនិត្យសកម្មភាពមន្ត្រីក្រុម **សម្តេចឪ**
ដែលកំពុងជួយអន្តរាគមន៍ភ្ជួររាស់ដីស្រែរដូវវស្សាដល់ប្រជាកសិករខ្វះខាតកម្លាំងអូសទាញ
ស្ថិតនៅក្នុងឃុំកំពង់ចំឡង ស្រុកស្វាយជ្រំ ខេត្តស្វាយរៀង
ថ្ងៃទី៩ ខែសីហា ឆ្នាំ២០២៥
















រូបភាពវាលស្រែដែលមានភ្លៀងធ្លាក់ប្រមាណ២ម៉ោង នៅយប់ថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២៥








ព្រះរាជាណាចក្រកម្ពុជា

ROYAUME DU CAMBODGE

ព្រះបរមរាជវាំង
លេខ:៤៣៦/ ប.ប

សូមព្រះបរមរាជានុញ្ញាតក្រាបបង្គំទូលថ្វាយ
សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ នៃព្រះរាជាណាចក្រកម្ពុជា
ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត

សូមព្រះតេជៈតម្កល់លើត្បូង

ទូលព្រះបង្គំជាខ្ញុំ សូមព្រះបរមរាជានុញ្ញាតក្រាបបង្គំទូលថ្វាយ **សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត សូមព្រះមេត្តាសណ្តាប់ក្រោមល្អងធូលីព្រះបាទ។

យោងតាមព្រះរាជតម្រិះដ៏ខ្ពង់ខ្ពស់ របស់ **សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត នៅរសៀលថ្ងៃទី១២ ខែសីហា ឆ្នាំ២០២៥ ទូលព្រះបង្គំជាខ្ញុំ បាននាំយកព្រះរាជអំណោយដ៏ថ្លៃថ្លាទៅប្រគល់ជូនមន្ទីរពេទ្យ **ហ្គេងម៉ែ** ស្ថិតនៅភូមិព្រៃសខាងកើត សង្កាត់ព្រៃសខណ្ឌដង្កោ រាជធានីភ្នំពេញ មានដូចជា ៖

- ព្រះរាជទ្រព្យ ចំនួន ២០,០០០,០០០ រៀល (១០០កញ្ចប់ ក្នុង១កញ្ចប់ ២០០,០០០រ)
- សារុង ចំនួន ២០០ សារុង
- ទឹកបរិសុទ្ធ PRO VIDA ចំណុះ 0,5 L ចំនួន ១០០ កេស
- កន្សែងជូតដៃ ចំនួន ៦ កេស

នៅក្នុងឱកាសនោះ ទូលព្រះបង្គំជាខ្ញុំ បានពាំនាំមកនូវព្រះរាជបណ្តាំសួរសុខទុក្ខអំពី **សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ជូនដល់បងប្អូនដែលកំពុងសម្រាកព្យាបាលជម្ងឺនៅក្នុងមន្ទីរពេទ្យ **ហ្គេងម៉ែ** និងបានចែកជូនផ្ទាល់នូវព្រះរាជអំណោយដ៏ថ្លៃថ្លា ចំនួន ៧៨នាក់ ដោយក្នុងម្នាក់ៗទទួលបាន ព្រះរាជទ្រព្យ ចំនួន ២០០,០០០រៀល សារុងចំនួន១ និងកន្សែងជូតដៃចំនួន ១ដុំ។ ចំពោះព្រះរាជអំណោយដែលនៅសល់ ពីការចែកជូនបងប្អូនកំពុងសម្រាកព្យាបាល ទូលព្រះបង្គំជាខ្ញុំ បានប្រគល់ជូនលោកប្រធានមន្ទីរពេទ្យទាំងអស់។

បន្ទាប់ពីបានទទួលព្រះរាជអំណោយដ៏ថ្លៃថ្លាខាងលើនេះរួចមក លោកប្រធានមន្ទីរពេទ្យ ក្រុមគ្រូពេទ្យ និងបងប្អូនដែលកំពុងសម្រាកព្យាបាល នៅក្នុងមន្ទីរពេទ្យ **ហ្គេងម៉ែ** ទាំងអស់ មានសេចក្តីរីករាយយ៉ាងក្រៃលែងដោយមិននឹកស្មានថាបានទទួលព្រះរាជអំណោយដ៏ថ្លៃថ្លានេះ និងសូមក្រាបបង្គំទូលថ្វាយនូវអំណរព្រះរាជគុណដ៏ខ្ពង់ខ្ពស់ជាទីបំផុត និងសូមថ្វាយព្រះពរ **សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត សូមព្រះអង្គមានព្រះរាជសុខភាពល្អបរិបូណ៌ ព្រះជន្មាយុ

យ៉ីនយូរ និងព្រះប្រកបតែនឹងព្រះបរមសុខគ្រប់ប្រការ ដើម្បីគង់ប្រថាប់ជាមហាម្លប់ដ៏ត្រជាក់ដល់ប្រជារាស្ត្រ ដែលជាកូនចៅ ចៅទួតរបស់ព្រះអង្គនៅទូទាំងព្រះរាជាណាចក្រកម្ពុជា ជាដរាបតរៀងទៅ។

ទូលព្រះបង្គំជាខ្ញុំ សូមក្រាបបង្គំទូលថ្វាយភ្ជាប់មកជាមួយនូវៈ រូបថត និងលិខិតថ្លែងអំណរព្រះរាជគុណ។

សេចក្តីដូចបានក្រាបបង្គំទូលថ្វាយខាងលើ សូម **សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត សូមព្រះមេត្តាជ្រាបដ៏ខ្ពង់ខ្ពស់បំផុត។

*សេចក្តីគួរពុំគួរ សូម **សម្តេចព្រះមហាក្សត្រី** ព្រះមេត្តាប្រោស ។*
ក្រាបបង្គំទូលថ្វាយ នៅថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០២៥
ក្រោមល្អងធូលីព្រះបាទ

ទូលព្រះបង្គំជាខ្ញុំ គុយ សុផល

អំពីការនាំយកព្រះរាជអំណោយដ៏ថ្លៃថ្លា

ទៅប្រគល់ជូនមន្ទីរពេទ្យ **ហ្គួងម៉ៃ** ស្ថិតនៅភូមិព្រៃសខាងកើត សង្កាត់ព្រៃស ខណ្ឌដង្កោ រាជធានីភ្នំពេញ នៅរសៀលថ្ងៃទី១២ ខែសីហា ឆ្នាំ២០២៥

















ម៉ាស៊ីនបាញ់កាំរស្មីគីមី ព្យាបាលមហារីក






ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

លិខិតទទួលព្រះរាជទ្រព្យ

ទូលព្រះបង្គំជាខ្ញុំ មានសេចក្តីសោមនស្សរីករាយយ៉ាងក្រៃលែង និងសូមថ្លែងអំណរព្រះរាជគុណដ៏ខ្ពង់ខ្ពស់ជាទីបំផុត ដោយបានទទួលព្រះរាជទ្រព្យដ៏ថ្លៃថ្លា របស់ **សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត នារសៀលថ្ងៃទី ១២ ខែសីហា ឆ្នាំ២០២៥ នៅមន្ទីរពេទ្យ **ហ្គួចម៉ែ** សង្កាត់ព្រែស ខណ្ឌដង្កោ រាជធានីភ្នំពេញ ដូចខាងក្រោម ៖

១- ព្រះរាជទ្រព្យ	ចំនួន	១០០ កញ្ចប់ (ក្នុង១កញ្ចប់ ២០០.០០០រ)
២- សារុង	ចំនួន	២០០ សារុង
៣- ទឹកបរិសុទ្ធប្រូវីដា	ចំនួន	១០០ កេស
៤- កន្សែងត្រជាក់MG	ចំនួន	០៦ កេស

រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែសីហា ឆ្នាំ២០២៥

ទូលព្រះបង្គំជាខ្ញុំ

ព្រះរាជាណាចក្រកម្ពុជា
មន្ទីរពេទ្យ ហ្គួចម៉ែ
គ្រប់គ្រងសុខាភិបាល

ឈ្មោះ.ជំនួយ ស៊ូ ស៊ីថាណ្ណា

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

មន្ទីរពេទ្យ ហ្គង ម៉ែ

សូមក្រាបបង្គំទូលថ្វាយ

សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ
ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល
ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត!

បពិត្រ សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ *ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត!*

ទូលព្រះបង្គំជាខ្ញុំទាំងអស់គ្នា ជាថ្នាក់ដឹកនាំ មន្ត្រីរាជការ និងបុគ្គលិកទាំងអស់នៃ **មន្ទីរពេទ្យ ហ្គង ម៉ែ** មានសេចក្តីរីករាយឥតឧបមាដោយបានទទួលនូវព្រះរាជអំណោយដ៏ថ្លៃថ្លា ជា **សារ៉ុង ចំនួន ២០០, កន្សែងក្រដាក់ MG ចំនួន ៦ កេស, ទឹកបរិសុទ្ធ ប្រូវីជា ចំនួន ១០០ កេស** និងថវិកា ចំនួន **២០ ,០០០, ០០០ រៀល** អំពី **សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ដែលព្រះអង្គទ្រង់ សព្វព្រះរាជហឫទ័យប្រោសព្រះរាជទានចំពោះ **អ្នកជំងឺដែលកំពុងសម្រាកព្យាបាលនៅមន្ទីរពេទ្យ ហ្គង ម៉ែ** ។

ទូលព្រះបង្គំជាខ្ញុំទាំងអស់គ្នា សូមព្រះបរមរាជានុញ្ញាត ថ្លែងអំណរព្រះរាជគុណ និងចងចាំជានិច្ចនូវព្រះរាជគុណូបការៈដ៏ថ្លៃថ្លារបស់ **សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ដែលព្រះអង្គសព្វព្រះរាជហឫទ័យប្រោសព្រះរាជទាននូវព្រះរាជអំណោយដ៏ថ្លៃថ្លា ជល់អ្នកជំងឺដែលកំពុងសម្រាកព្យាបាលនៅមន្ទីរពេទ្យ ដែលនេះបានបង្ហាញពីព្រះទ័យយកចិត្តទុកដាក់ចំពោះកូន ចៅ ចៅទួត របស់ព្រះអង្គ ដែលកំពុងសម្រាកព្យាបាល ឱ្យធាប់បានជាសះស្បើយ និងត្រលប់ទៅគេហដ្ឋានវិញ ។

ទូលព្រះបង្គំជាខ្ញុំទាំងអស់គ្នា សូមព្រះបរមរាជានុញ្ញាតដ៏ខ្ពង់ខ្ពស់ សូមលើកហត្ថប្រណម្យបួងសួង ជល់គុណបុណ្យព្រះរតនៈត្រ័យ គុណកែវទាំងបី និងឫទ្ធិបារមីវត្ថុសក្តិសិទ្ធិក្នុងលោក ទេវតាថែរក្សាព្រះមហាស្វេតឆត្រ បុណ្យបារមីនៃដួងព្រះវិញ្ញាណក្ខន្ធអតីតព្រះមហាក្សត្រ ព្រះមហាក្សត្រីយានីខ្មែរគ្រប់ព្រះអង្គ ជាពិសេសបុណ្យបារមីនៃដួងព្រះវិញ្ញាណក្ខន្ធ **ព្រះបរមរតនកោដ្ឋ** សូមព្រះអង្គតាមជួយថែរក្សាប្រោសព្រំថ្វាយ **សម្តេចព្រះមហាក្សត្រី** សូមព្រះអង្គទ្រង់ប្រកបដោយព្រះពុទ្ធពរដ៏ឧត្តុងឧត្តមថ្លៃថ្លាទាំងបួនប្រការ គឺ៖ **អាយុ វណ្ណៈ សុខៈ និងពលៈ** ជាកិរិយោភាពតរៀងទៅ ។

សូម **សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ទ្រង់ព្រះមេត្តាទទួលនូវអភិវន្ទកិច្ច និងការគោរពដ៏ខ្ពង់ខ្ពស់បំផុតពីទូលព្រះបង្គំជាខ្ញុំទាំងអស់គ្នា ។

ថ្ងៃអង្គារ ៣រោច ខែស្រាពណ៍ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
ក្រាបបង្គំទូលថ្វាយនៅរាជធានីភ្នំពេញ ថ្ងៃទី១២ ខែសីហា ឆ្នាំ២០២៥

ដោយភ្នែកមន្ទីរពេទ្យ

សាស្ត្រ. ជំនួយ ស៊ូ ស៊ីផាល្លា

Correspondance de très hautes Personnalités

កាកបាទក្រហមកម្ពុជា

សូមក្រាបបង្គំទូលថ្វាយ

សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ

ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល

ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត

បពិត្រ សម្តេចព្រះវររាជមាតាជាតិខ្មែរ ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត

ខ្ញុំម្ចាស់ មានសេចក្តីសោមនស្សរីករាយយ៉ាងក្រៃលែង ដោយបានទទួលនូវទឹកបរិសុទ្ធម៉ាកប្រ៊ីដា ចំនួន ៣៥០កេស ពី **សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ដែលព្រះអង្គសព្វព្រះរាជហឫទ័យដ៏ថ្លៃថ្លាប្រោសព្រះរាជទាន ចំពោះកាកបាទក្រហមកម្ពុជា។

ខ្ញុំម្ចាស់ សូមលំឱនកាយសម្តែងនូវអំណរព្រះរាជគុណដ៏ខ្ពង់ខ្ពស់បំផុត ហើយខ្ញុំម្ចាស់ សូមព្រះបរមរាជានុញ្ញាតប្រើប្រាស់ព្រះរាជូបត្ថម្ភទឹកបរិសុទ្ធម៉ាកប្រ៊ីដាខាងលើនេះ សម្រាប់ចែកជូនប្រជាពលរដ្ឋដែលរងគ្រោះដោយសារខ្សល់កន្ត្រាក់នៅខេត្តកោះកុង ចំនួន ៣១០គ្រួសារ។ ព្រះរាជគុណូបការៈដ៏ថ្លៃថ្លា របស់ **សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ** តែងតែប្រោសព្រះរាជទាននូវភាពកក់ក្តៅដល់ខ្ញុំម្ចាស់ និងសហការី នៃកាកបាទក្រហមកម្ពុជា ដើម្បីបម្រើជាតិ មាតុភូមិ និងប្រជារាស្ត្រកម្ពុជា។

ខ្ញុំម្ចាស់ សូមលើកហត្ថប្រណម្យឧទ្ទិសបួងសួងដល់គុណបុណ្យព្រះរតនត្រ័យ តេជៈបារមីនៃវត្ថុស័ក្តិសិទ្ធិនានាក្នុងលោក និងដួងព្រះវិញ្ញាណក្ខន្ធអតីតព្រះមហាក្សត្រ ព្រះមហាក្សត្រិយានីខ្មែរគ្រប់ព្រះអង្គ ជាពិសេសដួងព្រះវិញ្ញាណក្ខន្ធ **ព្រះករុណា ព្រះមហាវីរក្សត្រ ព្រះបរមរតនកោដ្ឋ** សូមជួយអភិបាលប្រោះព្រំគ្រងរក្សា **សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត សូមព្រះអង្គមានព្រះបរមសុខគ្រប់ប្រការ ជាម្លប់ដ៏ត្រជាក់ត្រជុំសម្រាប់ប្រជារាស្ត្រគ្រប់ៗរូប នៅទូទាំងព្រះរាជាណាចក្រកម្ពុជា តរៀងទៅ។

ថ្ងៃពុធ ១៣រោច ខែអាសាឍ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
ក្រាបបង្គំទូលថ្វាយ នៅរាជធានីភ្នំពេញ ថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២៥

ប្រធាន

សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន

សូមក្រាបបង្គំទូលថ្វាយ
សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ
ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល

បពិត្រ សម្តេចព្រះវររាជមាតាជាតិខ្មែរ ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត!

ទូលព្រះបង្គំជាខ្ញុំមានសេចក្តីរីករើបរីករាយឥតឧបមា ដោយបានទទួលព្រះរាជទានព្រះរាជទ្រព្យដ៏ខ្ពង់ខ្ពស់បំផុតអំពី **សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ចំនួន **៥០.០០០ ដុល្លារអាមេរិក** ដែលជាព្រះរាជទានដ៏ឧត្តុង្គឧត្តម សម្រាប់ជាព្រះរាជូបត្ថម្ភដល់វីរកងទ័ពដែលបំពេញការកិច្ចនៅជួរមុខ ដើម្បីបុព្វហេតុការពារបូរណភាពទឹកដី និងអធិបតេយ្យជាតិកម្ពុជា និងសុខសុវត្ថិភាពប្រជាពលរដ្ឋនៅតាមបណ្តោយព្រំដែន ។

ទូលព្រះបង្គំជាខ្ញុំ សូមព្រះបរមរាជានុញ្ញាតសម្តែងនូវអំណរព្រះរាជគុណដ៏ខ្ពង់ខ្ពស់បំផុត និងអំណរព្រះរាជគុណដ៏ខ្ពង់ខ្ពស់បំផុត និងសូមសម្តែងថ្វាយនូវការប្តេជ្ញាចិត្ត ខិតខំបំពេញកាតព្វកិច្ចបម្រើ **ជាតិ សាសនា ព្រះមហាក្សត្រ** ក្រោមម្លប់តេជៈសម្ភារបូទ្ធាបារមីនៃ **អង្គព្រះមហាក្សត្រ** និង **សម្តេចព្រះមហាក្សត្រី ព្រះវររាជ មាតាជាតិខ្មែរ** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ដែលជានិច្চকាលព្រះអង្គតែងតែប្រោសព្រះរាជូបត្ថម្ភដល់រាជរដ្ឋាភិបាល តាំងពីដើមរៀងមក និងប្រទាននូវការគាំទ្រចំពោះទូលព្រះបង្គំជាខ្ញុំ ។

ទូលព្រះបង្គំជាខ្ញុំ សូមព្រះបរមរាជានុញ្ញាតបួងសួងដល់គុណបុណ្យព្រះរតនត្រ័យ កែវទាំងបី ទេវតាថែរក្សាព្រះមហាស្វេតច្ឆត្រ ព្រះវិញ្ញាណក្ខន្ធអតីតព្រះមហាក្សត្រ ព្រះមហាក្សត្រិយានីខ្មែរគ្រប់ព្រះអង្គ សូមព្រះមេត្តាប្រសិទ្ធពរជ័យ បវរសួស្តី មហាប្រសើរ ថ្វាយ **សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត សូមព្រះអង្គមានព្រះរាជសុខភាពល្អពេញបរិបូរណ៌ ព្រះកាយពលមាំមួន ព្រះជន្មាយុយឺនយូរ ដើម្បីគង់ប្រថាប់ជាមហាម្លប់ដ៏ត្រជាក់ជល់ប្រជារាស្ត្រ ជាកូនចៅ ចៅទួត របស់ព្រះអង្គនៅទូទាំងព្រះរាជាណាចក្រកម្ពុជាជាយូរអង្វែងតរៀងទៅ ។

សូម **សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ព្រះមេត្តាទទួលនូវអភិវន្ទនកិច្ច និងកតញ្ញូតាធម៌ដ៏ខ្ពង់ខ្ពស់បំផុត អំពីទូលព្រះបង្គំជាខ្ញុំ៕

ថ្ងៃអង្គារ ៨កើត ខែស្រាពណ៍ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
ក្រាបបង្គំទូលថ្វាយនៅរាជធានីភ្នំពេញ ថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២៥

នាយករដ្ឋមន្ត្រី

សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត

កាកបាទក្រហមកម្ពុជា

សូមក្រាបបង្គំទូលថ្វាយ

សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ
ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល
ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត

បពិត្រ សម្តេចព្រះវររាជមាតាជាតិខ្មែរ *ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត*

ខ្ញុំម្ចាស់ និងសហការីទាំងអស់ នៃកាកបាទក្រហមកម្ពុជា មានសេចក្តីសោមនស្សរីករាយយ៉ាងក្រៃលែង ដោយបានទទួលចង្កៀងប្រើថាមពលពន្លឺព្រះអាទិត្យ ចំនួន ១០០គ្រឿង ដែលជាព្រះរាជទានដ៏ឧត្តុង្គឧត្តម របស់ **សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ចំពោះកាកបាទក្រហមកម្ពុជា សម្រាប់ចែកជូនដល់ប្រជារាស្ត្រភៀសសឹកដែលជម្លៀសមកកាន់ទីជម្រកសុវត្ថិភាព។

តាងនាមថ្នាក់ដឹកនាំ សមាជិក សមាជិកា មន្ត្រី បុគ្គលិកទាំងអស់ នៃកាកបាទក្រហមកម្ពុជា ខ្ញុំម្ចាស់ សូមព្រះបរមរាជានុញ្ញាតថ្លែងអំណរព្រះរាជគុណដ៏ខ្ពង់ខ្ពស់បំផុតថ្វាយ **សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ដែលតែងតែលើកទឹកចិត្តដល់ខ្ញុំម្ចាស់ ដើម្បីខិតខំបំពេញភារកិច្ចដឹកនាំសកម្មភាពកាកបាទក្រហមកម្ពុជា បានទទួលនូវជោគជ័យថ្មីៗទៀតសម្រាប់ជាឧត្តមប្រយោជន៍ជូនជាតិ មាតុភូមិ និងប្រជារាស្ត្រ នៅទូទាំងព្រះរាជាណាចក្រកម្ពុជា។

ខ្ញុំម្ចាស់ សូមបួងសួងគុណបុណ្យព្រះរតនត្រ័យ តេជៈបារមីវត្ថុស័ក្តិសិទ្ធិនានាក្នុងលោក ទេវតាថែរក្សាព្រះមហាស្វេតច្ឆត្រ និងព្រះបារមីព្រះវិញ្ញាណក្ខន្ធអតីតព្រះមហាក្សត្រ ព្រះមហាក្សត្រិយានីខ្មែរគ្រប់ព្រះអង្គ សូមព្រះមេត្តាប្រោសព្រះរាជទានព្រះពរជ័យមង្គល បវរមហាប្រសើរថ្វាយ **សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត សូមព្រះអង្គប្រកបដោយព្រះបរមសុខគ្រប់ប្រការ គង់ជាមហាម្លប់ដ៏ត្រជាក់ សម្រាប់ប្រជារាស្ត្រកម្ពុជា ជាកូនចៅ ចៅទួតរបស់ព្រះអង្គជ្រកកោនតរៀងទៅ។

សេចក្តីគួរពុំគួរ សូម **សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ព្រះមេត្តាប្រោសព្រះរាជទានទោស។

ថ្ងៃ ១៨ ខែភ្នំ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
ក្រាបបង្គំទូលថ្វាយនៅរាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែកក្កដា ឆ្នាំ២០២៥

ប្រធាន

សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន

កាកបាទក្រហមកម្ពុជា

សូមក្រាបបង្គំទូលថ្វាយ

សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ

ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល

ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត

បពិត្រ សម្តេចព្រះវររាជមាតាជាតិខ្មែរ ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត

ខ្ញុំម្ចាស់ មានសេចក្តីសោមនស្សរីករាយយ៉ាងក្រៃលែង ដោយបានទទួលនូវក្រដាសសើមម៉ាកMG ចំនួន ២០កេស ឆៃប៉ូវ ៥០០គីឡូក្រាម ត្រសក់ចាវ ៣៥០គីឡូក្រាម ពី **សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ដែលព្រះអង្គសព្វព្រះរាជហឫទ័យដ៏ថ្លៃថ្លាប្រោសព្រះរាជទានចំពោះកាកបាទក្រហមកម្ពុជា។

ខ្ញុំម្ចាស់ សូមលំឱនកាយសម្តែងនូវអំណរព្រះរាជគុណដ៏ខ្ពង់ខ្ពស់បំផុត ហើយខ្ញុំម្ចាស់ សូមព្រះបរមរាជានុញ្ញាតប្រើប្រាស់ព្រះរាជូបត្ថម្ភដ៏ឧត្តុង្គឧត្តមខាងលើនេះ សម្រាប់ចែកជូនប្រជានុរាស្ត្រជាជនភៀសសឹក។ ព្រះរាជគុណូបការៈដ៏ថ្លៃថ្លា របស់ **សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ** តែងតែប្រោសព្រះរាជទាននូវភាពកក់ក្តៅដល់ខ្ញុំម្ចាស់ និងសហការី នៃកាកបាទក្រហមកម្ពុជា ដើម្បីបម្រើជាតិ មាតុភូមិ និងប្រជារាស្ត្រកម្ពុជា។

ខ្ញុំម្ចាស់ សូមលើកហត្ថប្រណម្យឧទ្ទិសបួងសួងដល់គុណបុណ្យព្រះរតនត្រ័យ តេជៈបារមីនៃវត្ថុស័ក្តិសិទ្ធិនានាក្នុងលោក និងដួងព្រះវិញ្ញាណក្ខន្ធអតីតព្រះមហាក្សត្រ ព្រះមហាក្សត្រិយានីខ្មែរគ្រប់ព្រះអង្គ ជាពិសេសដួងព្រះវិញ្ញាណក្ខន្ធ **ព្រះករុណា ព្រះមហាវីរក្សត្រ ព្រះបរមរតនកោដ្ឋ** សូមជួយអភិបាលប្រោះព្រំគ្រងរក្សា **សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត សូមព្រះអង្គមានព្រះបរមសុខគ្រប់ប្រការ ជាម្លប់ដ៏ត្រជាក់ត្រជំសម្រាប់ប្រជានុរាស្ត្រគ្រប់ៗរូប នៅទូទាំងព្រះរាជាណាចក្រកម្ពុជា តរៀងទៅ។

ថ្ងៃចន្ទ ១០កើត ខែស្រាពណ៍ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
ក្រាបបង្គំទូលថ្វាយ នៅភ្នំពេញ ថ្ងៃទី៤ ខែសីហា ឆ្នាំ២០២៥

ប្រធាន

សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន

កាកបាទក្រហមកម្ពុជា

សូមក្រាបបង្គំទូលថ្វាយ

សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ

ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល

ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត

បពិត្រ សម្តេចព្រះវររាជមាតាជាតិខ្មែរ ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត

ខ្ញុំម្ចាស់ មានសេចក្តីសោមនស្សរីករាយយ៉ាងក្រៃលែង ដោយបានទទួលនូវព្រះរាជូបត្ថម្ភនូវថវិកា ចំនួន 15.000 USD (មួយម៉ឺនប្រាំពាន់ដុល្លារសហរដ្ឋអាម៉េរិក) ពី **សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ** ព្រះប្រធានកិត្តិយស កាកបាទក្រហមកម្ពុជា ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ដែលព្រះអង្គសព្វព្រះរាជហឫទ័យដ៏ថ្លៃថ្លាប្រោសព្រះរាជទាន ចំពោះកាកបាទក្រហមកម្ពុជា។

ខ្ញុំម្ចាស់ សូមលំឱនកាយសម្តែងនូវអំណរព្រះរាជគុណដ៏ខ្ពង់ខ្ពស់បំផុត ហើយខ្ញុំម្ចាស់ សូមព្រះបរមរាជានុញ្ញាតប្រើប្រាស់ព្រះរាជូបត្ថម្ភដ៏ឧត្តុង្គឧត្តមខាងលើនេះ ជាប្រយោជន៍សម្រាប់ចែកជូនប្រជារាស្ត្រជាជនភៀសសឹក ដែលកំពុងត្រូវការឱ្យជួយ។ ព្រះរាជគុណូបការៈដ៏ថ្លៃថ្លា របស់ **សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ** តែងតែប្រោសព្រះរាជទាននូវភាពកក់ក្តៅដល់ខ្ញុំម្ចាស់ និងសហការី នៃកាកបាទក្រហមកម្ពុជា ដើម្បីបម្រើជាតិ មាតុភូមិ និងប្រជារាស្ត្រកម្ពុជា។

ខ្ញុំម្ចាស់ សូមលើកហត្ថប្រណម្យឧទ្ទិសបួងសួងដល់គុណបុណ្យព្រះរតនត្រ័យ តេជៈបារមីនៃវត្ថុស័ក្តិសិទ្ធិនានាក្នុងលោក និងដួងព្រះវិញ្ញាណក្ខន្ធអតីតព្រះមហាក្សត្រ ព្រះមហាក្សត្រិយានីខ្មែរគ្រប់ព្រះអង្គ ជាពិសេសដួងព្រះវិញ្ញាណក្ខន្ធ **ព្រះករុណា ព្រះមហាវីរក្សត្រ ព្រះបរមរតនកោដ្ឋ** សូមជួយអភិបាលប្រោះព្រំគ្រងរក្សា **សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត សូមព្រះអង្គមានព្រះបរមសុខគ្រប់ប្រការ ជាម្លប់ដ៏ត្រជាក់ត្រជំសម្រាប់ប្រជារាស្ត្រគ្រប់ៗរូប នៅទូទាំងព្រះរាជាណាចក្រកម្ពុជា តរៀងទៅ។

ថ្ងៃអង្គារ ១១កើត ខែស្រាពណ៍ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
ក្រាបបង្គំទូលថ្វាយ នៅរាជធានីភ្នំពេញ ថ្ងៃទី៥ ខែសីហា ឆ្នាំ២០២៥

ថ្លែងនាម

សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ព្រឹទ្ធសភា

សូមក្រាបបង្គំទូលថ្វាយ
សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ
ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល

បពិត្រ សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត!

ជាបឋមទូលព្រះបង្គំជាខ្ញុំ និងភរិយា សូមថ្លែងអំណរព្រះរាជគុណប្រកបដោយសមានចិត្តសោមនស្សរីករាយជាអតិបរមា ថ្វាយ **សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត** ដែលទ្រង់សព្វព្រះរាជហឫទ័យ ប្រោសព្រះរាជទាននូវព្រះរាជសារចុះថ្ងៃទី១ ខែសីហា ឆ្នាំ២០២៥ ផ្តាំដ៏ស្រស់ល្អមួយកន្ត្រក និងព្រះពរជ័យ ក្នុងឱកាសនៃខួបកំណើតរបស់ទូលព្រះបង្គំជាខ្ញុំ។

ឆ្លៀតក្នុងឱកាសដ៏វិសេសវិសាលនេះ ទូលព្រះបង្គំជាខ្ញុំ សូមព្រះបរមរាជានុញ្ញាត ថ្លែងអំណរព្រះរាជគុណថ្វាយ **សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត** ដែលជានិច្ចកាលព្រះអង្គតែងតែប្រោសព្រះរាជទាននូវព្រះព្រហ្មវិហារធម៌ដ៏ឧត្តុង្គឧត្តម ដល់ទូលព្រះបង្គំជាខ្ញុំ និងក្រុមគ្រួសារ ដែលជាព្រះរាជគុណដ៏មហាធំធេងមិនអាចរកវត្ថុអ្វីមកប្រៀបផ្ទឹមបានឡើយ។

តបចំពោះព្រះរាជគុណូបការៈ និងព្រះព្រហ្មវិហារធម៌ដ៏ខ្ពង់ខ្ពស់បំផុតរបស់ **សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត** ទូលព្រះបង្គំជាខ្ញុំ និងភរិយា សូមព្រះបរមរាជានុញ្ញាតបួងសួងដល់គុណបុណ្យព្រះរតនត្រ័យ កែវទាំងបី ទេវតាថែរក្សាព្រះមហាស្វេតច្ឆត្រ ព្រះវិញ្ញាណក្ខន្ធអតីតព្រះមហាក្សត្រ ព្រះមហាក្សត្រិយានីខ្មែរគ្រប់ព្រះអង្គ សូមព្រះមេត្តា ប្រសិទ្ធ ពរជ័យ បវរសួស្តី មហាប្រសើរ ថ្វាយ **សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត** សូមព្រះអង្គមានព្រះរាជសុខភាពល្អពេញបរិបូរណ៌ ព្រះកាយពលមាំមួន ព្រះជន្មាយុយឺនយូរ ដើម្បីគង់ប្រថាប់ជាមហាម្លប់ដ៏ត្រជាក់ដល់ប្រជារាស្ត្រជាកូនចៅ ចៅទួតរបស់ព្រះអង្គនៅទូទាំងព្រះរាជាណាចក្រកម្ពុជាជាយូរអង្វែងតរៀងទៅ។

សូម **សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត** ទ្រង់ប្រោសព្រះរាជមេត្តាទទួលនូវអភិវន្ទនកិច្ច និងកតញ្ញុតវេទិតាធម៌ដ៏ខ្ពង់ខ្ពស់បំផុតពីទូលព្រះបង្គំជាខ្ញុំ និងភរិយា។

ថ្ងៃចន្ទ ១០កើត ខែស្រាពណ៍ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
ក្រាបបង្គំទូលថ្វាយនៅរាជធានីភ្នំពេញ ថ្ងៃទី ៤ ខែសីហា ឆ្នាំ២០២៥

ប្រធានព្រឹទ្ធសភា
និងជាប្រធានក្រុមឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ



សម្តេចព្រះមហាសង្ឃរាជ
នៃគណៈធម្មយុត្តិកនិកាយ នៃព្រះរាជាណាចក្រកម្ពុជា
លេខ:.....០៧៥/២៥.....ស.គ.ព /សជណ

<u>សូមថ្វាយព្រះពរ</u>

សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ
ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល

សូមព្រះអង្គទ្រង់ព្រះរាជទានព្រះមេត្តាជ្រាប។

អាត្មាភាព សូមព្រះបរមរាជានុញ្ញាតថ្វាយព្រះពរ **សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ ជាអម្ចាស់** សូមទ្រង់ព្រះរាជមេត្តាជ្រាបដ៏ខ្ពង់ខ្ពស់បំផុត នៅថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០២៥ វេលាម៉ោង ៦:០០ នាទីព្រឹក អាត្មាភាពនឹងរៀបចំកម្មវិធីដង្ហែ **"ព្រះបរមរាជ្ជីព្រះករុណាព្រះបរមរតនកោដ្ឋ"** ទៅតម្កល់គោរពបូជាក្នុង **ព្រះបរមចេតិយ** វត្តព្រៃពោធ ស្ថិតក្នុងភូមិព្រៃពោធ ឃុំព្រៃពោធ ស្រុកកំពង់ត្របែក ខេត្តព្រៃវែង នាពេលខាងមុខនេះ។

សេចក្តីដូចបានថ្វាយព្រះពរខាងលើនេះ សូម **សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ ជាអម្ចាស់** ទ្រង់ព្រះរាជមេត្តាជ្រាបជាព័ត៌មានដ៏ខ្ពង់ខ្ពស់បំផុត។

អាត្មាភាព សូមលើកតម្កល់ព្រះរាជមហាកុសលដ៏វិសេសថ្លៃថ្លានេះថ្វាយចំពោះ **ព្រះករុណាព្រះបរមរតនកោដ្ឋ** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុតរបស់ប្រជារាស្ត្រខ្មែរ សូមព្រះអង្គទ្រង់គង់ជាព្រះបរមសុខក្សេមក្សាន្តក្នុងព្រះបរមសុគតិភពកុំបីឃ្លៀងឃ្លាតឡើយ។ សូមថ្វាយព្រះពរ **សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ ជាអម្ចាស់** សូមព្រះអង្គទ្រង់បានប្រកបដោយព្រះពុទ្ធពរជ័យមង្គលដ៏វិសេសថ្លៃថ្លាបំផុត ទ្រង់ព្រះរាជជន្មវស្សាយឺនយូររាប់រយព្រះវស្សា ព្រះរាជកាយពលសួស្ថិមាំមួន ព្រះរាជសុខុមាលភាពល្អបរិបូណ៌ ព្រះរាជបញ្ញាញាណភ្លឺថ្លាវាងវៃ ដើម្បីស្តេចទ្រង់គង់ប្រថាប់ជាជួងព្រលឹងជាតិខ្មែរ និងជាមហាម្លប់ដ៏សែនត្រជាក់ដល់កូនចៅ-ចៅទួតរបស់ព្រះអង្គអស់កាលជានិច្ចនិរន្តរ៍តរៀងទៅ ។

ថ្ងៃពុធ ១២កើត ខែស្រាពណ៍ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
ធ្វើនៅវត្តបទុមធម្មប្បវត្តិ, ថ្ងៃទី០៦ ខែសីហា ឆ្នាំ២០២៥

អាត្មាភាព សម្តេចព្រះអតិសីលសុត្តន្តរហាសង្ឃរាជាធិបតី កិត្តិឧទ្ទេសបណ្ឌិត
សម្តេចព្រះមហាសង្ឃរាជ នៃគណៈធម្មយុត្តិកនិកាយ នៃព្រះរាជាណាចក្រកម្ពុជា
និងជាព្រះប្រធានគណៈសង្ឃនាយក នៃគណៈធម្មយុត្តិកនិកាយ នៃព្រះរាជាណាចក្រកម្ពុជា
សូមថ្វាយព្រះពរ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សម្តេចព្រះមហាសង្ឃរាជ
នៃគណៈធម្មយុត្តិកនិកាយ នៃព្រះរាជាណាចក្រកម្ពុជា
លេខ:.....ស.គ.ធ/លជអ

សូមថ្វាយព្រះពរអរព្រះរាជគុណា

សម្តេចព្រះមហាក្សត្រី នរោត្តម មុនីនាថ សីហនុ
ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល

សូមព្រះអង្គទ្រង់ព្រះរាជទានព្រះមេត្តាជ្រាប។

អាត្មាភាព សូមថ្លែងអំណរព្រះរាជគុណយ៉ាងជ្រាលជ្រៅជាទីបំផុតថ្វាយចំពោះ **សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ ជាអម្ចាស់** ដែលព្រះអង្គទ្រង់សព្វព្រះរាជហឫទ័យប្រោសព្រះរាជទាន **ព្រះរាជទ្រព្យ** ចំនួន ៥,០០០ ដុល្លារ (ប្រាំពាន់ដុល្លារសហរដ្ឋអាមេរិកគត់) ព្រះរាជូបត្ថម្ភព្រះកម្មវិធីដង្ហែ **"ព្រះបរមរដ្ឋាព្រះករុណាព្រះបរមរតនកោដ្ឋ"** យាងតម្កល់សម្រាប់គោរពបូជាក្នុង **ព្រះបរមចេតិយ** វត្តព្រៃពោធ ស្ថិតក្នុងភូមិព្រៃពោធ ឃុំព្រៃពោធ ស្រុកកំពង់ត្របែក ខេត្តព្រៃវែង នៅថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០២៥ នាពេលខាងមុខនេះ។

អាត្មាភាព សូមលើកឡើងនូវព្រះរាជមហាកុសលជំនឿសែសថ្លៃថ្លាបំផុតនេះ ឧទ្ទិសថ្វាយចំពោះដួងព្រះវិញ្ញាណក្ខន្ធ **"ព្រះករុណាព្រះបរមរតនកោដ្ឋ"** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុតរបស់ប្រជារាស្ត្រខ្មែរ សូមព្រះអង្គទ្រង់គង់ជាព្រះបរមសុខក្សេមក្សន្តក្នុងព្រះបរមសុគតិភពឋានសួគ៌ឋានគិព្វានកុំបីឃ្លៀងឃ្លាតឡើយ និងសូមលើកថ្វាយព្រះពរ **សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ ជាអម្ចាស់** សូមព្រះអង្គទ្រង់បានប្រកបដោយព្រះពុទ្ធពរជ័យដ៏វិសេសថ្លៃថ្លាបំផុត ទ្រង់មានព្រះរាជជន្មវស្សាយឺនយូរាប់រយព្រះវស្សា ព្រះរាជកាយពលសម្បូរមាំមួន ព្រះរាជសុខុមាលភាពល្អបរិបូណ៌ ព្រះរាជបញ្ញាញាណភ្លឺថ្លាវាងវៃ ដើម្បីស្តេចទ្រង់គង់ជាដួងព្រលឹងជាតិខ្មែរ និងជាមហាម្លប់ដ៏សែនត្រជាក់ជល់ប្រជារាស្ត្រខ្មែរជាកូនចៅ-ចៅទួតរបស់ព្រះអង្គអស់កាលជានិច្ចនិរន្តរ៍តរៀងទៅ ។

ថ្ងៃចន្ទ ២រោច ខែស្រាពណ៍ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
ធ្វើនៅវត្តបទុមធម្មយុត្ត, ថ្ងៃទី១១ ខែសីហា ឆ្នាំ២០២៥

សម្តេចព្រះអភិសិរីសកុលសង្ឃរាជាធិបតី អ៊ិត្ថិឥន្ទ្រសបណ្ឌិត
សម្តេចព្រះមហាសង្ឃរាជ នៃគណៈធម្មយុត្តិកនិកាយ
នៃព្រះរាជាណាចក្រកម្ពុជា និងជាប្រធានគណៈសង្ឃនាយក
នៃគណៈធម្មយុត្តិកនិកាយ នៃព្រះរាជាណាចក្រកម្ពុជា

កាកបាទក្រហមកម្ពុជា

សូមក្រាបបង្គំទូលថ្វាយ
សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ
ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល
ព្រះប្រធានកិត្តិយស កាកបាទក្រហមកម្ពុជា
ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត

*បពិត្រ **សម្តេចព្រះវររាជមាតាជាតិខ្មែរ** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត*

ខ្ញុំម្ចាស់ និងសហការីទាំងអស់ នៃកាកបាទក្រហមកម្ពុជា មានសេចក្តីសោមនស្សរីករាយក្រៃលែង សូមព្រះបរមរាជានុញ្ញាតក្រាបបង្គំទូលថ្វាយ **សម្តេចព្រះវររាជមាតាជាតិខ្មែរ** ព្រះប្រធានកិត្តិយស កាកបាទក្រហមកម្ពុជា សូមមេត្តាព្រះសណ្តាប់ស្តីអំពីការប្រើប្រាស់ព្រះរាជទ្រព្យ ជាច្រើនរួមមាន៖ ថវិកា, ក្រដាសសើម, ឆៃប៉ូវ និងត្រសក់ត្រាំ ដែលជាព្រះរាជអំណោយដ៏ថ្លៃថ្លារបស់ **សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ** ជូនកាកបាទក្រហមកម្ពុជា សម្រាប់ចែកជូនគ្រួសារភៀសសឹក តាមបណ្តោយព្រំដែនកម្ពុជា-ថៃ។

ខ្ញុំម្ចាស់ បានចាត់ឱ្យសហការី នាំយកព្រះរាជទ្រព្យដ៏ឧត្តុង្គឧត្តមខាងលើនេះ ចែកជូនគ្រួសារងគ្រោះទាំងនោះ ទៅតាមទីកន្លែងដូចខាងក្រោម៖

១- <u>មុខព្រួញខេត្តព្រះវិហារ</u> បានចុះសួរសុខទុក្ខ និងចែកជូនដោយផ្ទាល់ដល់គ្រួសារភៀសសឹក ចំនួន ៥៥០គ្រួសារ ដែលមាន២ទីតាំង ដោយទីតាំងទី១ ចំនួន ៣៣៤គ្រួសារ នៅក្នុងវត្តឆែប ឃុំឆែបមួយ និងទីតាំងទី២ ចំនួន ២១៦គ្រួសារ នៅវត្តដងផ្លិត ឃុំឆែបពីរ នៃស្រុកឆែប ខេត្តព្រះវិហារ កាលពីថ្ងៃទី៥ ខែសីហា ឆ្នាំ២០២៥។

២- <u>មុខព្រួញខេត្តឧត្តរមានជ័យ</u> បានចុះសួរសុខទុក្ខ និងចែកជូនដោយផ្ទាល់ដល់គ្រួសារភៀសសឹក ចំនួន ២៩៨គ្រួសារ មកពីស្រុកបន្ទាយអំពិល និងក្រុងសំរោង ដែលកំពុងស្នាក់នៅក្នុងវត្តភ្នំដី ក្នុងស្រុកចុងកាល់ ខេត្តឧត្តរមានជ័យ កាលពីថ្ងៃទី៦ ខែសីហា ឆ្នាំ២០២៥។

ក្នុងនាមប្រជារាស្ត្រដែលបានទទួលផល ខ្ញុំម្ចាស់ សូមលំឱនកាយក្រាបថ្វាយអំណរព្រះរាជគុណដ៏ជ្រាលជ្រៅបំផុតថ្វាយ **សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ** ចំពោះព្រះរាជអំណោយដ៏ឧត្តុង្គឧត្តមខាងលើនេះ ដែលបានជួយសម្រាលទុក្ខលំបាករបស់ប្រជារាស្ត្រងាយរងគ្រោះ និងជាសក្ខីកម្មនៃព្រះរាជហឫទ័យគិតគូរដល់សុខទុក្ខប្រជារាស្ត្រនៅគ្រប់កាលៈទេសៈ។

ខ្ញុំម្ចាស់ផ្ទាល់ និងសហការី នៃកាកបាទក្រហមកម្ពុជា សូមលំឱនកាយក្រាបថ្វាយអំណរព្រះរាជគុណដ៏ថ្លៃថ្លានេះថ្វាយ **សម្តេចព្រះវររាជមាតាជាតិខ្មែរ** និង **ព្រះករុណាព្រះមហាក្សត្រ ជាអម្ចាស់ជីវិតលើត្បូង** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត និងសូមលើកហត្ថប្រណម្យបួងសួងដល់វត្ថុស័ក្តិសិទ្ធិក្នុងលោក ទេវតាថែរក្សាព្រះមហាស្វេតច្ឆត្រ ព្រះបារមីនៃអតីតព្រះមហាក្សត្រ ព្រះមហាក្សត្រិយានីខ្មែរគ្រប់ព្រះអង្គ សូមប្រោសព្រះរាជទាន ប្រោះព្រំនូវទឹកអម្រឹត ប្រសិទ្ធពរជ័យ សិរីសួស្តី ថ្វាយ **សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ** ព្រះប្រធានកិត្តិយស កាកបាទក្រហមកម្ពុជា និង **ព្រះករុណាព្រះមហាក្សត្រ** នៃព្រះរាជាណាចក្រកម្ពុជា ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត សូមព្រះអង្គទាំងទ្វេ ព្រះ

ប្រកបដោយព្រះពុទ្ធពរទាំង ៤ ប្រការ គឺ **អាយុ វណ្ណៈ សុខៈ ពលៈ** កុំបីឃ្លៀងឃ្លាតឡើយ ដើម្បីគង់ប្រថាប់ជាម្លប់ដ៏ត្រជាក់ដល់ប្រជារាស្ត្រកម្ពុជា ជារៀងរហូតតទៅ។

ក្រាបបង្គំទូលថ្វាយ នៅថ្ងៃអង្គារ ៣ ១៣៩ ខែស្រាពណ៍ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែសីហា ឆ្នាំ២០២៥

ប្រធាន

សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន

ប្រជាពលរដ្ឋសឹក នៅខេត្តឧត្តរមានជ័យ និងខេត្តព្រះវិហារ ទទួលបាន ថវិកា និងគ្រឿងបរិភោគជាព្រះរាជអំណោយដ៏ថ្លៃថ្លារបស់ ម្ចាងម៉ែ







កាកបាទក្រហមកម្ពុជា

សូមក្រាបបង្គំទូលថ្វាយ
សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ
ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល
ព្រះប្រធានកិត្តិយស កាកបាទក្រហមកម្ពុជា
ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត

*បពិត្រ **សម្តេចព្រះវររាជមាតាជាតិខ្មែរ** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត*

ខ្ញុំម្ចាស់ និងសហការីទាំងអស់ នៃកាកបាទក្រហមកម្ពុជា មានសេចក្តីសោមនស្សរីករាយក្រៃលែង សូមព្រះបរមរាជានុញ្ញាតក្រាបបង្គំទូលថ្វាយ **សម្តេចព្រះវររាជមាតាជាតិខ្មែរ** ព្រះប្រធានកិត្តិយស កាកបាទក្រហមកម្ពុជា សូមមេត្តាព្រះសណ្តាប់ស្តីអំពីការប្រើប្រាស់ព្រះរាជទ្រព្យ ជាទឹកពិសាបរិសុទ្ធ និងចង្កៀងសូឡា ដែលជាព្រះរាជអំណោយដ៏ថ្លៃថ្លារបស់ **សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ** ដល់កាកបាទក្រហមកម្ពុជាសម្រាប់ចែកជូនដល់គ្រួសាររងគ្រោះដោយខ្យល់កន្ត្រាក់នៅខេត្តកោះកុង និងគ្រួសារភៀសសឹក តាមបណ្តាយព្រំដែនកម្ពុជា-ថៃ។

ខ្ញុំម្ចាស់ បានចាត់ឱ្យសហការី នាំយកព្រះរាជទ្រព្យដ៏ឧត្តុង្គឧត្តមខាងលើនេះ ចែកជូនដល់គ្រួសាររងគ្រោះទាំងនោះទៅតាមមុខព្រួញដូចខាងក្រោម៖

១- ថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០២៥ បាននាំយកទឹកពិសារបរិសុទ្ធម៉ាកប្រ៊ីវីដា ចំនួន ៣៥០កេស ដែលជាព្រះរាជអំណោយដ៏ថ្លៃថ្លារបស់ **ម្ហួងម៉ែ ជារម្ចាស់** ចែកជូនដល់គ្រួសាររងគ្រោះដោយខ្យល់កន្ត្រាក់ចំនួន ៣១៨គ្រួសារ នៅស្រុកស្រែអំបិល នៃខេត្តកោះកុង។ រួមជាមួយព្រះរាជអំណោយទឹកបរិសុទ្ធនេះ កាកបាទក្រហមកម្ពុជា ក៏បានផ្តល់ជូនគ្រឿងឧបភោគ-បរិភោគ មានដូចជា អង្ករ, មី, ត្រីខ, ទឹកបរិសុទ្ធ, ទឹកស៊ីអ៊ីវ និងថវិកា ផងដែរ។

២- ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០២៥ បាននាំយកចង្កៀងសូឡាចំនួន **៥០សម្រាប់** ប្រគល់ជូនសាខាកាកបាទក្រហមកម្ពុជាខេត្តព្រះវិហារ និង**៥០សម្រាប់**ទៀត ប្រគល់ជូនសាខាកាកបាទក្រហមកម្ពុជា ខេត្តឧត្តរមានជ័យ ដែលចង្កៀងសូឡាទាំងនោះ បានរៀបចំដាក់បំភ្លឺនៅក្នុងមណ្ឌលសុវត្ថិភាពគ្រួសារភៀសសឹក។

ក្នុងនាមប្រជារាស្ត្រដែលបានទទួលផល ខ្ញុំម្ចាស់ សូមលំឱនកាយក្រាបថ្វាយអំណរព្រះរាជគុណដ៏ជ្រាលជ្រៅបំផុតថ្វាយ **សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ** ចំពោះព្រះរាជអំណោយដ៏ឧត្តុង្គឧត្តមខាងលើនេះ ដែលបានលើកកម្ពស់ជីវភាពរស់នៅ ព្រមទាំងជួយសម្រាលទុក្ខលំបាករបស់ប្រជារាស្ត្រងាយរងគ្រោះ និងជាសក្ខីកម្មនៃព្រះរាជហឫទ័យគិតគូរដល់សុខទុក្ខប្រជារាស្ត្រនៅគ្រប់កាលៈទេសៈ។

ខ្ញុំម្ចាស់ផ្ទាល់ និងសហការី នៃកាកបាទក្រហមកម្ពុជា សូមលំឱនកាយក្រាបថ្វាយអំណរព្រះរាជគុណដ៏ថ្លៃថ្លានេះថ្វាយ **សម្តេចព្រះវររាជមាតាជាតិខ្មែរ** និង **ព្រះករុណាព្រះមហាក្សត្រ ជារម្ចាស់ជីវិតលើត្បូង** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត និងសូមលើកហត្ថប្រណម្យបួងសួងដល់វត្ថុស័ក្តិសិទ្ធិក្នុងលោក ទេវតាថែរក្សាព្រះមហាស្វេតច្ឆត្រ ព្រះបារមីនៃអតីតព្រះមហាក្សត្រ ព្រះមហាក្សត្រិយានីខ្មែរគ្រប់ព្រះអង្គ សូមប្រោសព្រះរាជទានប្រោះព្រំនូវទឹកអម្រឹត ប្រសិទ្ធពរជ័យ សិរីសួស្តីថ្វាយ **សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ** ព្រះប្រធានកិត្តិយសកាកបាទក្រហមកម្ពុជា និង **ព្រះករុណាព្រះមហាក្សត្រ**

នៃព្រះរាជាណាចក្រកម្ពុជា ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់ប៉ផុត សូមព្រះអង្គទាំងទ្វេ ព្រះប្រកបដោយព្រះពុទ្ធពរ ទាំង ៤ ប្រការ គឺ **អាយុ វណ្ណៈ សុខៈ ពលៈ** កុំបីឃ្លៀងឃ្លាតឡើយ ដើម្បីគង់ប្រថាប់ជាម្លប់ដ៏ត្រជាក់ដល់ ប្រជារាស្ត្រកម្ពុជាជារៀងរហូតតទៅ។

ក្រាបបង្គំទូលថ្វាយ នៅថ្ងៃអង្គារ ៣ កើត ខែស្រាពណ៍ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែសីហា ឆ្នាំ២០២៥

ប្រធាន

សម្តេចអគ្គិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន

ប្រជាពលរដ្ឋនិងសិស្សភៀសសឹក ក្នុងមណ្ឌលសុវត្ថិភា នៅខេត្តព្រះវិហារ កំពុងប្រើប្រាស់ចង្កៀងសូឡា ជាព្រះរាជអំណោយដ៏ថ្លៃថ្លារបស់ ម្ចាងម៉ែ





ប្រជាពលរដ្ឋភៀសសឹក ក្នុងមណ្ឌលសុវត្ថិភា នៅខេត្តឧត្តរមានជ័យ កំពុងប្រើប្រាស់ចង្កៀងសូឡា ជាព្រះរាជអំណោយដ៏ថ្លៃថ្លារបស់ ម្ចាងម៉ែ





ប្រជាពលរដ្ឋរងគ្រោះដោយខ្យល់កន្ត្រាក់ នៅខេត្តកោះកុង ទទួលបានទឹកសុទ្ធ ជាព្រះរាជអំណោយរបស់ម្ចាងម៉ែ រួមជាមួយអំណោយការីយបាទក្រហមកម្ពុជា





Photos - Historiques

Visit of Norodom Sihanouk, Prince of Cambodia to Yugoslavia, 1956.

























H 2













H 3













H 4



Visit of Norodom Sihanouk, Prime Minister of Cambodia to FNR Yugoslavia, November 25 – December 3, 1959.































Meeting of Josip Broz Tito and Prince Norodom Sihanouk, Head of State of Cambodia during the 15th Session of the UN General Assembly, New York, 1960.



Reception of Prince Norodom Sihanouk, Head of State of Cambodia in Pula, August 24, 1961.















Josip Broz Tito, President of FNR Yugoslavia and Prince Norodom Sihanouk, Head of State of Cambodia during the tour of the 5th International Technology Fair at the Belgrade Fair, August 28, 1961.







Head of State of Cambodia, Prince Norodom Sihanouk arrives at the First Conference of Heads of State or Government of Non-Aligned Countries, Belgrade, September 1, 1961.



Head of State of Cambodia, Prince Norodom Sihanouk at the First Conference of Heads of State or Government of Non-Aligned Countries, Belgrade, September 1961.





Participants of the First Conference of Heads of State or Government of Non-Aligned Countries, Belgrade, September 1961.



Head of State of Cambodia, Norodom Sihanouk with other participants at the opening of the Zagreb Fair, Zagreb, September 9, 1961.



Josip Broz Tito, President of SFR Yugoslavia and Prince Norodom Sihanouk, Head of State of Cambodia during Tito's official visit to Cambodia, Phnom Penh, January 17, 1968.















Reception of Prince Norodom Sihanouk, President of the Revolutionary Movement of Cambodia by Josip Broz Tito, President of FNR Yugoslavia during the Fourth Conference of Non-Aligned Countries, Algiers, September 3, 1973.



Visit of Prince Norodom Sihanouk, President of the Revolutionary Movement of Cambodia to SFR Yugoslavia, June 9, 1973.













Visit of Prince Norodom Sihanouk, President of the Revolutionary Movement of Cambodia to SFR Yugoslavia, July 15, 1972.









Visit of Prince Norodom Sihanouk, Head of State of Cambodia to SFR Yugoslavia, December 16, 1975.







Visit of Prince Norodom Sihanouk to SFR Yugoslavia, October 4, 1981.









Visit of Prince Norodom Sihanouk to SFR Yugoslavia, Belgrade, August 11, 1982.



Prince Norodom Sihanouk visiting the Ohrid Summer Festival, Ohrid, August 1982.



Visit of Prince Norodom Sihanouk, President of Democratic Kampuchea to SFR Yugoslavia, January 16–21, 1987.











Visit of Prince Norodom Sihanouk to SFR Yugoslavia, October 11–14, 1987.







Photos-Souvenirs du
CAMBODGE du SANGKUM REASTR NIYUM
(1955 - 1969)

PALACE DE BOKOR





← គិលានដ្ឋានបូគោ

Bokor possède l'une des plus belles infirmeries du Cambodge



↑ ស្ពានថ្មីនេះ ប្រវែង ១០៩ម.។ ល្វែងកណ្តាលធ្វើដោយលោហធាតុ មានប្រវែង ៣០ ម. ។ Long de 109 mètres, ce pont est constitué en son milieu par une travée métallique (système Bailey) de 30 mètres .

↓ នៅលើផ្លូវថ្នល់ទៅត្បែងមានជ័យ - Sur la route de T..bèng Meanchey .



A LA FACULTÉ DE ARTS PLASTIQUES
នៅមហាវិទ្យាល័យសិល្បៈចម្លាក់គន្លះ

ក្នុងសិល្បៈចម្លាក់គំនូរ យើងមិនត្រឹមតែធ្វើឱ្យមានភាពរស់រវើកឡើងវិញ នូវសិល្បៈជាប្រពៃណីដ៏ សម្បូរបែបនេះទេ យើងត្រូវតែចេះរចនា និង បង្កើតថ្មីថែមទៀត នូវសិល្បៈនេះ ។ គិនៅក្នុងគំនិតនេះហើយ ដែលត្រូវបង្ហាត់បង្រៀនទិសិត យើងខាងគំនូរ ចម្លាក់ ជាងមាសជាងប្រាក់ ខាងចាក់លុប្ត ពម្បាញ ខាងឆ្នុកម្រក្សាណ៍ ។ល។

Les arts plastiques et graphiques: non seulement une riche tradition qu'il s'agit de faire revivre mais aussi des formes d'expression nouvelles à créer et qui doivent se nourrir de la tradition ancienne. C'est dans cet esprit que sont formés les étudiants en dessin, peinture, sculpture, orfèvrerie, moulage, affiche, tissage, broderie, laquage et bientôt ceux des sections de céramique, reliure, gravure et cuir.



កាលយក្សឈ្មោះ ពិរាជ លួចចាប់ព្រះនាង សេតា ត្រូវព្រះរាម និងព្រះលក្ស្មណ៍ធ្វើយាជ





Les rayons de jouets
et d'articles de sport. ↑
→
↓



Documents



Lok Chau Khun Pomme Peang (au milieu)
avec à sa droite, S.M. la Reine-Mère
Norodom Monineath Sihanouk,
et à sa gauche, S.A.R. la Princesse Sisowath Nanette Méthavy,
sœur aînée de la Reine-Mère.
Pékin, République Populaire de Chine 1972

Temple of Preah Vihear. 1963
Prasat Preah Vihear



សម្តេចព្រះមហាក្សត្រី ព្រះនរោត្តមមាតាជាតិខ្មែរ
នរោត្តម មុនិនាថ សីហនុ
នៃព្រះរាជាណាចក្រកម្ពុជា
គួបព្រះជំនាន់ឥស្សរជនកិច្ចនៅប្រាសាទ ព្រះវិហារ នៅឆ្នាំ ១៩៦៣

Doc 2

សមាគមកាយឫទ្ធិនារីកម្ពុជា

ក្រោមព្រះរាជអធិបតីសម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ នរោត្តម មុនិនាថ សីហនុ

Girl Guides Association of Cambodia

Under the High Patronage of Her Majesty Queen Mother Norodom Monineath Sihanouk of Cambodia

លេខ: ០.ញ០/២៥/សកនក

សូមក្រាបបង្គំទូលថ្វាយ
សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ
ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល
ព្រះប្រធានកិត្តិយស នៃសមាគមកាយឫទ្ធិនារីកម្ពុជា
ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត

របាយការណ៍សង្ខេប
ស្តីពីសកម្មភាពរបស់សមាគមកាយឫទ្ធិនារីកម្ពុជា
ចាប់ពីថ្ងៃទី០១ ខែមេសា ឆ្នាំ២០២៥ ដល់ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៥

ខ្ញុំម្ចាស់សូមព្រះបរមរាជានុញ្ញាត សូមក្រាបបង្គំទូលថ្វាយ នូវរបាយការណ៍សង្ខេបស្តីពីសកម្មភាពរបស់សមាគមកាយឫទ្ធិនារីកម្ពុជា ចាប់ពីថ្ងៃទី០១ ខែមេសា ឆ្នាំ២០២៥ ដល់ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៥ ដែលមានសកម្មភាពដូចខាងក្រោម ៖

I. ការសច្ចាបញ្ញលសមាជិកថ្មី

នៅថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០២៥ សមាគមកាយឫទ្ធិនារីកម្ពុជា បានប្រារព្ធពិធីសច្ចាបញ្ញលសមាជិកថ្មីលើកទី៣៣ នៅខេត្តកំពត ក្រោមអធិបតីភាពខ្ញុំម្ចាស់ និងមានការអញ្ជើញចូលរួមជាកិត្តិយសពីសំណាក់សមាជិកាគណៈកម្មាធិការប្រតិបត្តិនៃសមាគមកាយឫទ្ធិនារីកម្ពុជា ប្រធានកិត្តិយស ប្រធាននិងអនុប្រធានក្រុមប្រឹក្សាសមាគមកាយឫទ្ធិនារីកម្ពុជាសាខារាជធានីភ្នំពេញ ខេត្តសៀមរាប ខេត្តកំពត ខេត្តបាត់ដំបង ខេត្តកណ្តាល និងខេត្តមណ្ឌលគិរី ដោយមានសមាជិកសច្ចាថ្មីសរុបចំនួន ៣៧១រូប និងសមាជិកាសកម្មប្តូរកន្សែងចំនួន ៨១រូប។

ចាប់ពីអាណត្តិខ្ញុំម្ចាស់បានជាប់ឆ្នោតជាអគ្គស្នងការកាលពីថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០២១ រហូតមកដល់បច្ចុប្បន្ននេះ សមាគមកាយឫទ្ធិនារីកម្ពុជាបានប្រារព្ធពិធីសច្ចាបញ្ញលសមាជិកថ្មីចំនួន ១៣លើក មានសមាជិកចូលរួមសច្ចាថ្មីសរុបចំនួន ៧,៧៧៦រូប ដូច្នេះចំនួនសមាជិកកាយឫទ្ធិនារីកម្ពុជាសរុបទូទាំងប្រទេសបច្ចុប្បន្នមានចំនួន ៨,៤៨០រូប និងបានបង្កើតសាខាសមាគមចំនួន ០៧ ស្របតាមគោលការណ៍ជាធរមាននៅតាមបណ្តាខេត្តដូចជា សាខារាជធានីភ្នំពេញ ខេត្តសៀមរាប ខេត្តកំពត ខេត្តបាត់ដំបង ខេត្តពោធិ៍សាត់ ខេត្តកណ្តាល និងខេត្តមណ្ឌលគិរី។

II. គម្រោងសកម្មភាពប្រចាំឆ្នាំ

ដូចបានកំណត់នៅក្នុងផែនការ សមាគមកាយឫទ្ធិនារីកម្ពុជា មានសកម្មភាពក្នុងប្រទេសជាប្រចាំ ចំនួន ០៥គម្រោង ដូចខាងក្រោម៖

១. គម្រោងអប់រំបណ្តុះបណ្តាល ផ្តោតទៅលើកម្មវិធីបណ្តុះបណ្តាលភាសាអង់គ្លេស កុំព្យូទ័រ កម្មវិធីតម្រង់ទិសការងារនិងអាជីព កម្មវិធីជជែកដេញដោលមតិ កម្មវិធីចំណេះដឹងហិរញ្ញវត្ថុ ការផ្តល់អាហារូបករណ៍សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត ការចូលរួមវគ្គបណ្តុះបណ្តាលផ្សេងៗ និងកម្មវិធីបណ្តុះក្រុមយុវតីស្ម័គ្រចិត្ត ឱ្យមានភាពក្លាហាន មានទេពកោសល្យ និងអភិវឌ្ឍសមត្ថភាពក្នុងភាពជាអ្នកដឹកនាំ។

២.គម្រោងចូលរួមថែរក្សាបរិស្ថាន ផ្តោតលើការបង្រៀនបណ្តុះគ្រាប់ពូជ ការចូលរួមដាំដើមឈើ ដើមកោងកាង វិធីចម្រោះទឹកស្អាត ការលើកកម្ពស់គុណភាពទឹក ការសម្អាតបរិស្ថានសហគមន៍ និងសាលារៀន ការគ្រប់គ្រងសំណល់រឹងនិងសំណល់ប្លាស្ទិក ការរៀនដាំបន្លែលើទឹកនិងរុក្ខជាតិតាំងលម្អ ការដាំដំណាំធម្មជាតិតាមផ្ទះនិងសាលារៀន បច្ចេកទេសកាត់បន្ថយដើមឈើតាមបែបកសិកម្ម ការរៀនធ្វើជីកំប៉ុស ទស្សនកិច្ចសិក្សាស្វែងយល់ពីសួនបន្លែធម្មជាតិ អាងប្រព្រឹត្តិកម្មទឹកកខ្វក់ ទីលានចាក់សំរាមស្តង់ដា កែច្នៃសំណល់ទៅជាអុសបរិស្ថាន និងការកែច្នៃសំណល់ក្រដាសទៅជាចម្លាក់បុរាណ យុទ្ធនាការ "ចាស់អ្នក ថ្មីខ្ញុំ" ការសំអាតតាមដងផ្លូវ និងទម្លាប់គេហកិច្ចល្អ៦យ៉ាង។

៣.គម្រោងសុខភាព និងសុវត្ថិភាព ផ្តោតលើការថែទាំនិងព្យាបាលសុខភាពមាត់ធ្មេញនិងភ្នែក អនាម័យលើខ្លួនប្រាណ ការសង្គ្រោះបឋម ការជួយសង្គ្រោះពេលមានបញ្ហាក្នុងទឹក ការយល់ដឹងពីច្បាប់ចរាចរណ៍និងសុវត្ថិភាពតាមដងផ្លូវ ផលប៉ះពាល់នៃការប្រើប្រាស់គ្រឿងញៀន ការយល់ដឹងពីជម្ងឺគ្រុនឈាមនិងគ្រុនចាញ់ ជម្ងឺទឹកនោមផ្អែម ជម្ងឺជាត់ ការបង្ការជំងឺព្រូន ផលប្រយោជន៍នៃវ៉ាក់សាំងការពារជម្ងឺមហារីកមាត់ស្បូន ផលប៉ះពាល់នៃការប្រើប្រាស់បារីអេឡិចត្រូនិច សុវត្ថិភាពក្នុងការប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិតនិងបណ្តាញសង្គម ផលវិបាកនៃសុខភាពបណ្តាលមកពីការបរិភោគភេសជ្ជៈនិងអាហារដែលមានជាតិស្ករ ផលវិបាកនៃការប្រើប្រាស់ប្លាស្ទិកជាមួយអាហារក្តៅ និងបញ្ហាសុខភាពស្បែក។

៤.គម្រោងវប្បធម៌ សិល្បៈ ប្រពៃណី និងហត្ថកម្ម ស្វែងយល់អំពីវប្បធម៌ សិល្បៈ ប្រពៃណីខ្មែរ មានការចូលរួមពិធីវប្បធម៌ជាតិ ពិធីបុណ្យចូលឆ្នាំប្រពៃណីជាតិខ្មែរ ពិធីបុណ្យកាន់បិណ្ឌ ពិធីបុណ្យមាឃបូជានិងអុជទៀនចម្លងប្រទីប ពិធីបុណ្យស្រោចស្រពសុគន្ធវារី ពិធីបុណ្យវិសាខបូជា ពិធីស្រង់ព្រះ រៀបចំចង្ហាន់ប្រគេនព្រះសង្ឃនិងស្វាធ្យាយ រៀនបត់បាយសី ការសាងសង់តុក្កតាយក្ស រៀនដេរថ្នេរអំបោះ រៀនកែច្នៃជំនៀក្រណាត់ ធ្វើបូរចងសក់ មូលដ្ឋានគ្រឹះនៃការគូរគំនូរ ការបត់ផ្កាពីក្រដាស ស្បែ និងលួសកម្ទី រៀនបត់ប្រទីប គោមផ្កាយ រៀនវេចនំប្រពៃណីខ្មែរ ធ្វើបង្អែម ធ្វើនំបឺហ្គឺ រៀនឆ្លាក់ផ្លែឈើ រៀនធ្វើកន្លាស់ព័ក្ស ហាត់រាំរបាំបុរាណ តន្ត្រីបុរាណ និងយល់ដឹងពីក្បួនខ្នាតនៃការស្លៀកក្បិនខ្មែរ ។

៥.គម្រោងការចូលរួមសកម្មភាពផ្សេងៗ មានដូចជា ចូលរួមគោរពព្រះវិញ្ញាណក្ខន្ធព្រះបរមរតនកោដ្ឋ ចូលរួមទិវាបុណ្យឯករាជ្យជាតិ ចូលរួមពិធីបុណ្យសង្ឃទាន ចូលរួមព្រះរាជពិធីបដិបត្តិសមាធិ ចូលរួមកម្មវិធីបុណ្យជាតិសំខាន់ៗ កម្មវិធីបងស្រីនិងប្អូនស្រី កម្មវិធីសប្បុរសធម៌ កម្មវិធីរាត្រីសមោសរ ការបោះជំរំប្រចាំឆ្នាំ ទស្សនកិច្ចសិក្សាតាមស្ថាប័នរដ្ឋនិងឯកជន និងដំណើរកំសាន្តផ្សេងៗ។

III. ទស្សនាតាការងារ

១. គម្រោងការអប់រំបណ្តុះបណ្តាល

ក. សាខារាជធានីភ្នំពេញ

សមាគមកាយឫទ្ធិនារីកម្ពុជា សាខារាជធានីភ្នំពេញ បានបន្តអនុវត្តលើគម្រោងអប់រំបណ្តុះបណ្តាលរៀងរាល់ចុងសប្តាហ៍រួមមាន ៖

- ថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២៥ សមាជិកាសកម្ម នៃសមាគមកាយឫទ្ធិនារីកម្ពុជាសាខារាជធានីភ្នំពេញ បានចូលរួមប្រកួតក្នុងកម្មវិធី "ជជែកដេញដោលយុវជនថ្នាក់ជាតិ ២០២៥" វគ្គជម្រុះជុំទី២ និងទទួលជ័យជំនះឆ្ពោះទៅកាន់វគ្គជម្រុះជុំទី៣ តាមរយៈអនឡាញ។
- ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២៥ សមាជិកាសកម្ម នៃសមាគមកាយឫទ្ធិនារីកម្ពុជាសាខារាជធានីភ្នំពេញ បានចូលរួមប្រកួតក្នុងកម្មវិធី "ជជែកដេញដោលយុវជនថ្នាក់ជាតិ ២០២៥" វគ្គជម្រុះជុំទី៣និងទទួលជ័យជំនះឆ្ពោះទៅកាន់វគ្គពាក់កណ្តាលផ្តាច់ព្រ័ត្រនៅមជ្ឈមណ្ឌលម៉ានី KAMPUS ។
- ថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២៥ សមាជិកាសកម្មនៃសមាគមកាយឫទ្ធិនារីកម្ពុជាសាខារាជធានីភ្នំពេញ បានចូលរួមប្រកួតក្នុងកម្មវិធី "ជជែកដេញដោលយុវជនថ្នាក់ជាតិ ២០២៥" វគ្គពាក់កណ្តាលផ្តាច់ព្រ័ត្រ នៅមជ្ឈមណ្ឌលម៉ានី KAMPUS ។

ខ. សាខាខេត្តសៀមរាប

សមាគមកាយឫទ្ធិនារីកម្ពុជា សាខាខេត្តសៀមរាប បានបន្តអនុវត្តលើគម្រោងអប់រំបណ្តុះបណ្តាលរៀងរាល់ចុងសប្តាហ៍រួមមាន ៖

- ថ្នាក់ភាសាអង់គ្លេស : សម្រាប់សមាជិកាសកម្មក្រុមកន្ទុំរុយ ចំនួន ១៣០រូប
- ថ្នាក់កុំព្យូទ័រ : សម្រាប់សមាជិកាសកម្មក្រុមកន្ទុំរុយ និងក្រុមវឌ្ឍនានារី ចំនួន ៤២រូប
- ថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២៥ សមាគមកាយឫទ្ធិនារីកម្ពុជាសាខាខេត្តសៀមរាប បានបង្កើតថ្នាក់សិក្សាកុំព្យូទ័រ សម្រាប់សមាជិកាសកម្មក្រុមកន្ទុំរុយ ចំនួន ២៥រូប នៅទីស្នាក់ការសមាគមកាយឫទ្ធិនារីកម្ពុជាសាខាខេត្តសៀមរាប។

គ. សាខាខេត្តកំពត

សមាគមកាយឫទ្ធិនារីកម្ពុជាសាខាខេត្តកំពត បានបន្តអនុវត្តលើគម្រោងអប់រំបណ្តុះបណ្តាលរៀងរាល់ចុងសប្តាហ៍រួមមាន ៖

- ថ្នាក់ភាសាអង់គ្លេស : សម្រាប់សមាជិកាសកម្មក្រុមកន្ទុំរុយ ក្រុមវឌ្ឍននារី និងក្រុមកាយឫទ្ធិនារី ចំនួន ១២០រូប
- ថ្នាក់កុំព្យូទ័រ : សម្រាប់សមាជិកាសកម្មក្រុមវឌ្ឍននារី និងក្រុមកាយឫទ្ធិនារីចំនួន ៣៣រូប
- ថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២៥ សមាគមកាយឫទ្ធិនារីកម្ពុជាសាខាខេត្តកំពត បានរៀបចំសិក្ខាសាលាលើកទី៣ លើកម្មវិធីតម្រង់ទិសការងារ និងអាជីព ក្រោមប្រធានបទ "ការស្វែងយល់អំពីអាជីព និងការកំណត់គោលដៅការងារ" សម្រាប់សមាជិកាសកម្មសាខាខេត្តកំពត ចំនួន៥០រូប។

ឃ. សាខាខេត្តបាត់ដំបង

សមាគមកាយឫទ្ធិនារីកម្ពុជាសាខាខេត្តបាត់ដំបង បានបន្តអនុវត្តលើគម្រោងអប់រំបណ្តុះបណ្តាលរៀងរាល់ចុងសប្តាហ៍រួមមាន ៖

- ថ្នាក់ភាសាអង់គ្លេស : សម្រាប់សមាជិកាសកម្មក្រុមកន្ទុំរុយ ក្រុមវឌ្ឍននារី និងក្រុមកាយឫទ្ធិនារី ចំនួន ៣២រូប
- ថ្នាក់កុំព្យូទ័រ : សម្រាប់សមាជិកាសកម្មក្រុមវឌ្ឍននារី និងក្រុមកាយឫទ្ធិនារីចំនួន ១៥រូប
- ថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០២៥ សមាគមកាយឫទ្ធិនារីកម្ពុជាសាខាខេត្តបាត់ដំបង បានរៀបចំកម្មវិធីចែករំលែកចំណេះដឹងអំពីវិធីសាស្ត្រ Mentoring ជូនដល់អ្នកសម្របសម្រួល (Mentor) ចំនួន ២៥រូប សម្រាប់កម្មវិធី "តម្រង់ទិសការងារ និងអាជីព"។
- ថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២៥ សមាគមកាយឫទ្ធិនារីកម្ពុជាសាខាខេត្តបាត់ដំបង បានរៀបចំសិក្ខាសាលាលើកទី១ លើកម្មវិធីតម្រង់ទិសការងារ និងអាជីព ក្រោមប្រធានបទ "ការស្វែងយល់អំពីខ្លួនឯង និងការងារ" ជូនដល់សមាជិកាសកម្មក្រុមវឌ្ឍននារី ចំនួន ៥០រូប។

ង. សាខាខេត្តពោធិ៍សាត់

សមាគមកាយឫទ្ធិនារីកម្ពុជាសាខាខេត្តពោធិ៍សាត់ បានបន្តអនុវត្តលើគម្រោងអប់រំបណ្តុះបណ្តាលរៀងរាល់ចុងសប្តាហ៍រួមមាន ៖

- ថ្នាក់ភាសាអង់គ្លេស : សម្រាប់សមាជិកាសកម្មក្រុមកន្ទុំរុយ ចំនួន ៤១រូប
- ថ្នាក់ភាសាជប៉ុន : សម្រាប់សមាជិកាសកម្មក្រុមវឌ្ឍននារី និងក្រុមកាយឫទ្ធិនារី ចំនួន ១៦រូប

ច. សាខាខេត្តកណ្តាល

សមាគមកាយឫទ្ធិនារីកម្ពុជាសាខាខេត្តកណ្តាល បានបន្តអនុវត្តលើគម្រោងអប់រំបណ្តុះបណ្តាលរៀងរាល់ចុងសប្តាហ៍រួមមាន ៖

- ថ្នាក់ភាសាអង់គ្លេស : សម្រាប់សមាជិកាសកម្មក្រុមកន្ទុំរុយ និងក្រុមវឌ្ឍននារី ចំនួន ៣២រូប
- ថ្នាក់កុំព្យូទ័រ : សម្រាប់សមាជិកាសកម្មក្រុមវឌ្ឍននារី និងក្រុមកាយឫទ្ធិនារីចំនួន ៣២រូប

ឆ. សាខាខេត្តមណ្ឌលគិរី

សមាគមកាយឫទ្ធិនារីកម្ពុជាសាខាខេត្តមណ្ឌលគិរី បានបន្តអនុវត្តលើគម្រោងអប់រំបណ្តុះបណ្តាលរៀងរាល់ចុងសប្តាហ៍រួមមាន៖

- ថ្នាក់ភាសាអង់គ្លេស : សម្រាប់សមាជិកាសកម្មក្រុមកន្ទុំរុយ ចំនួន ១៥រូប
- ថ្នាក់កុំព្យូទ័រ : សម្រាប់សមាជិកាសកម្មក្រុមវឌ្ឍននារី និងក្រុមកាយឫទ្ធិនារី ចំនួន ១២រូប
- ថ្នាក់គណិតវិទ្យា : សម្រាប់សមាជិកាសកម្មក្រុមវឌ្ឍននារីចំនួន ១០រូប

២. គម្រោងការចូលរួមថែរក្សាបរិស្ថាន

ក.សាខាខេត្តបាត់ដំបង

- ថ្ងៃទី២១ ខែមេសា ឆ្នាំ២០២៥ គ្រូបង្គោល នៃសមាគមកាយឫទ្ធិនារីកម្ពុជាសាខាខេត្តបាត់ដំបង បានដឹកនាំសមាជិកាសកម្មក្រុមកន្ទុំរុយ និងក្រុមវឌ្ឍននារី មកពីសាលាបឋមសិក្សា និងអនុវិទ្យាល័យឈើទាល ក្នុងស្រុកបាណន់ សំអាតបរិស្ថានជុំវិញបន្ទាប់ពីចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរ។
- ថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០២៥ សមាជិកាសកម្មក្រុមកន្ទុំរុយ នៃសមាគមកាយឫទ្ធិនារីកម្ពុជាសាខាខេត្តបាត់ដំបង ចំនួន ២០រូប បានចាប់ផ្តើមការដាំបន្លែ មានដូចជា សណ្តែកកួរ ននោងជ្រុង ននោងមូល និងត្រកួន នៅសាលាបឋមសិក្សាអន្លង់វិល ខេត្តបាត់ដំបង។
- ថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២៥ សមាជិកាសកម្មក្រុមកន្ទុំរុយ នៃសមាគមកាយឫទ្ធិនារីកម្ពុជាសាខាខេត្តបាត់ដំបង ចំនួន ២០រូប បានរៀបចំធ្វើដីសម្រាប់ដាំបន្លែ មានដូចជា ត្រកួន និងស្ពៃក្រញាញ់ នៅសាលាបឋមសិក្សាឈើទាល ខេត្តបាត់ដំបង។
- ថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២៥ សមាជិកាគាំទ្រ និងគ្រូបង្គោល នៃសមាគមកាយឫទ្ធិនារីកម្ពុជាសាខាខេត្តបាត់ដំបង បានដឹកនាំសមាជិកាសកម្មក្រុមកន្ទុំរុយចំនួន ២០រូប ដាំបន្លែ មានដូចជា ត្រកួន ស្ពៃក្រញាញ់ ស្ពៃចង្កឹះ និងសាឡាត់ នៅសាលាបឋមសិក្សាឫស្សី ខេត្តបាត់ដំបង។
- ថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២៥ អ្នកគ្រូបង្គោល នៃសមាគមកាយឫទ្ធិនារីកម្ពុជាសាខាខេត្តបាត់ដំបង បានដឹកនាំសមាជិកាសកម្មក្រុមកន្ទុំរុយចំនួន ២០រូប ថែទាំដំណាំបន្លែដែលបានដាំ នៅសាលាបឋមសិក្សាឫស្សី ខេត្តបាត់ដំបង។
- ថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០២៥ អ្នកគ្រូបង្គោល នៃសមាគមកាយឫទ្ធិនារីកម្ពុជាសាខាខេត្តបាត់ដំបង បានដឹកនាំសមាជិកាសកម្មក្រុមកន្ទុំរុយ ចំនួន ០៥រូប ដាំបន្លែ និងស្រោចដំណាំ នៅសាលាបឋមសិក្សាសិលាមានជ័យ ខេត្តបាត់ដំបង។

ខ.សាខាខេត្តមណ្ឌលគិរី

- ថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២៥ សមាជិកាសកម្មក្រុមវឌ្ឍននារី និងក្រុមកាយឫទ្ធិនារី នៃសមាគមកាយឫទ្ធិនារីកម្ពុជាសាខាខេត្តមណ្ឌលគិរី ចំនួន ១០រូប បានចូលរួមសកម្មភាពសម្អាតបរិស្ថាននៅរមណីយដ្ឋាន តំបន់ទេសចរណ៍ វប្បធម៌ ភ្នំក្រោល។
- ថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០២៥ សមាជិកាសកម្មក្រុមវឌ្ឍននារី នៃសមាគមកាយឫទ្ធិនារីកម្ពុជាសាខាខេត្តមណ្ឌលគិរី ចំនួន ១១រូប បានរួមគ្នាដាំបន្លែស្ពៃ នៅបរិវេណវិទ្យាល័យ ហ៊ុន សែន កែវ សីមា ខេត្តមណ្ឌលគិរី។

៣. គម្រោងសុខភាព និងសុវត្ថិភាព

ក.សាខារាជធានីភ្នំពេញ

- ថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២៥ សមាគមកាយឫទ្ធិនារីកម្ពុជាសាខារាជធានីភ្នំពេញ បានរៀបចំវគ្គបណ្តុះបណ្តាលស្តីពី "វិជ្ជាសង្គ្រោះបឋម" ជូនសមាជិកាសកម្មក្រុមកាយឫទ្ធិនារី ចំនួន ៥០រូប មកពីអង្គការដើម្បីភាពញញឹមនៃកុមារ (PSE) និងវិទ្យាល័យអប់រំពិសេសច្បារអំពៅ។
- ថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២៥ សមាគមកាយឫទ្ធិនារីកម្ពុជាសាខារាជធានីភ្នំពេញ បានរៀបចំវគ្គបណ្តុះបណ្តាលស្តីពី "សុវត្ថិភាពចរាចរណ៍ផ្លូវគោក" ជូនសមាជិកាសកម្មសរុបចំនួន ៦០រូប មកពីអង្គការដើម្បីភាពញញឹមនៃកុមារ (PSE) និងអង្គការមូនិធិកុមារកម្ពុជា (CCF)។
- ថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២៥ សមាគមកាយឫទ្ធិនារីកម្ពុជាសាខារាជធានីភ្នំពេញ បានរៀបចំវគ្គបណ្តុះបណ្តាលស្តីពី "ការយល់ដឹងពីសុវត្ថិភាពចំណីអាហារ និងផលប៉ះពាល់ថង់ប្លាស្ទិក" ជូនសមាជិកាសកម្មសរុបចំនួន ៧៥រូប មកពីអង្គការដើម្បីភាពញញឹមនៃកុមារ (PSE) អង្គការមូនិធិកុមារកម្ពុជា (CCF) និងវិទ្យាល័យអប់រំពិសេសច្បារអំពៅ (សាលាគថ្លង់)។

ខ.សាខាខេត្តសៀមរាប

- ថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២៥ សមាគមកាយឫទ្ធិនារីកម្ពុជាសាខាខេត្តសៀមរាប បានរៀបចំ "វគ្គអប់រំអំពីជំងឺទឹកនោមផ្អែម" ដល់សមាជិកសកម្មក្រុមវឌ្ឍននារី និងក្រុមកាយឫទ្ធិនារី ចំនួន ៣៨រូប។
- ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២៥ សមាគមកាយឫទ្ធិនារីកម្ពុជាសាខាសៀមរាប បានដឹកនាំសមាជិកាសកម្ម សរុបចំនួន ៨៧រូប មកពិនិត្យ និងព្យាបាលជំងឺដោយឥតគិតថ្លៃពីសមាគមគ្រូពេទ្យស្ម័គ្រចិត្តយុវជនសម្តេចតេជោ (TYDA) នៅខេត្តសៀមរាប។

គ.សាខាខេត្តបាត់ដំបង

- ថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២៥ សមាគមកាយឫទ្ធិនារីកម្ពុជាសាខាខេត្តបាត់ដំបង សហការជាមួយមន្ទីរព័ត៌មានខេត្ត រៀបចំវគ្គផ្សព្វផ្សាយស្តីពី "ការប្រើប្រាស់ប្រព័ន្ធអ៊ិនធឺណិត និងបណ្តាញសង្គមប្រកបដោយសុវត្ថិភាព" ដល់សមាជិកាសកម្មក្រុមវឌ្ឍននារី និងកាយឫទ្ធិនារី ចំនួន ៨០រូប។
- ថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០២៥ សមាគមកាយឫទ្ធិនារីកម្ពុជាសាខាខេត្តបាត់ដំបង សហការជាមួយមន្ទីរព័ត៌មានខេត្ត រៀបចំវគ្គផ្សព្វផ្សាយស្តីពី "ការប្រើប្រាស់ប្រព័ន្ធអ៊ិនធឺណិត និងបណ្តាញសង្គមប្រកបដោយសុវត្ថិភាព" ដល់គ្រូបង្គោល និងសមាជិកាសកម្មក្រុមវឌ្ឍននារី ស្រុកកំរៀង ចំនួន ៤០រូប។
- ថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២៥ សមាគមកាយឫទ្ធិនារីកម្ពុជាសាខាខេត្តបាត់ដំបង សហការជាមួយមន្ទីរព័ត៌មានខេត្ត រៀបចំវគ្គផ្សព្វផ្សាយស្តីពី "ការប្រើប្រាស់ប្រព័ន្ធអ៊ិនធឺណិត និងបណ្តាញសង្គមប្រកបដោយសុវត្ថិភាព" ជូនដល់គ្រូបង្គោល និងសមាជិកាសកម្មក្រុមវឌ្ឍននារី ស្រុកមោងឫស្សី ចំនួន ៤០ រូប។

- ថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២៥ សមាគមកាយឫទ្ធិនារីកម្ពុជាសាខាខេត្តបាត់ដំបង សហការជាមួយមន្ទីរព័ត៌មានខេត្ត រៀបចំវគ្គផ្សព្វផ្សាយស្តីពី "ការប្រើប្រាស់ប្រព័ន្ធអ៊ិនធឺណិត និងបណ្តាញសង្គមប្រកបដោយសុវត្ថិភាព" ជូនដល់គ្រូបង្គោល និងសមាជិកាសកម្មក្រុមវឌ្ឍននារី ស្រុកសង្កែ ចំនួន ៤០រូប។
- ថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២៥ សមាគមកាយឫទ្ធិនារីកម្ពុជាសាខាខេត្តបាត់ដំបង សហការជាមួយមន្ទីរសុខាភិបាលខេត្ត បានរៀបចំកម្មវិធីផ្សព្វផ្សាយ ស្តីពី ការថែទាំអនាម័យខ្លួនប្រាណ ការលាងសំអាតដៃ ការថែទាំសុខភាពមាត់ធ្មេញ និងបញ្ជ្រាបការយល់ដឹងអំពីវិធីការពារខ្លួនពីជំងឺកូវីដ១៩ ប្រភេទបម្លែងថ្មី ជូនសមាជិកាសកម្មក្រុមកន្ទុំរុយ មកពីស្រុកបាណន់ ចំនួន ២០រូប និងស្រុកកំរៀង ចំនួន ២០រូប។
- ថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២៥ សមាគមកាយឫទ្ធិនារីកម្ពុជាសាខាខេត្តបាត់ដំបង សហការជាមួយមន្ទីរសុខាភិបាលខេត្ត រៀបចំកម្មវិធីផ្សព្វផ្សាយ ស្តីពី ការថែទាំអនាម័យខ្លួនប្រាណ ការលាងសម្អាតដៃ ការថែទាំសុខភាពមាត់ធ្មេញ និងបញ្ជ្រាបការយល់ដឹងអំពីវិធីការពារខ្លួនពីជំងឺកូវីដ១៩ ប្រភេទបម្លែងថ្មី ជូនសមាជិកាសកម្មក្រុមកន្ទុំរុយចំនួន ២០រូប។
- ថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០២៥ សមាគមកាយឫទ្ធិនារីកម្ពុជាសាខាខេត្តបាត់ដំបង សហការជាមួយមន្ទីរសុខាភិបាលខេត្ត រៀបចំកម្មវិធីផ្សព្វផ្សាយស្តីពី ការថែទាំអនាម័យខ្លួនប្រាណ ការលាងសម្អាតដៃ ការថែទាំសុខភាពមាត់ធ្មេញ និងបញ្ជ្រាបការយល់ដឹងអំពីវិធីការពារខ្លួនពីជំងឺកូវីដ១៩ បម្លែងថ្មី ជូនដល់សមាជិកាសកម្មក្រុមកន្ទុំរុយ សរុបចំនួន ៧០រូប ។

ឃ.សាខាខេត្តពោធិ៍សាត់

- ថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០២៥ សមាគមកាយឫទ្ធិនារីកម្ពុជាសាខាពោធិ៍សាត់ បានដឹកនាំសមាជិកាសកម្ម ចំនួន ៧៨រូប និងគ្រូបង្គោល ចំនួន ១១រូប មកពិនិត្យ និងព្យាបាលជំងឺដោយឥតគិតថ្លៃពីសមាគមគ្រូពេទ្យស្ម័គ្រចិត្តយុវជនសម្តេចតេជោ (TYDA) ក្រោមអធិបតីភាពខ្ពុំម្ចាស់នៅវិទ្យាល័យព្រះម្លូរ ស្រុកបាកាន ខេត្តពោធិ៍សាត់។
- ថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០២៥ សមាជិកាសកម្មក្រុមវឌ្ឍននារី នៃសមាគមកាយឫទ្ធិនារីកម្ពុជាសាខាខេត្តពោធិ៍សាត់ ចំនួន១១រូប មកពីអនុវិទ្យាល័យព្រះសីហនុក្រគរ បានទទួលការបណ្តុះបណ្តាលស្តីពីការបង្ការការពារជំងឺគ្រុនឈាម។
- ថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២៥ សមាជិកាសកម្មក្រុមវឌ្ឍននារី នៃសមាគមកាយឫទ្ធិនារីកម្ពុជាសាខាខេត្តពោធិ៍សាត់ ចំនួន ៣៨រូប បានទទួលការបណ្តុះបណ្តាលពីរបៀបត្រៀមខ្លួនមុនពេលមានរដូវ និងអនាម័យពេលមានរដូវ។

ង.សាខាខេត្តកណ្តាល

- ថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២៥ សមាគមកាយឫទ្ធិនារីកម្ពុជាសាខាខេត្តកណ្តាល បានសហការជាមួយមជ្ឈមណ្ឌលជាតិលើកកម្ពស់សុខភាព នៃក្រសួងសុខាភិបាល រៀបចំកម្មវិធីសិក្សាស្តីពី

"ផលវិបាកនៃការបរិភោគអាហារកែច្នៃ និងភេសជ្ជៈមានជាតិស្ករខ្ពស់" ជូនដល់សមាជិកាសកម្ម សរុបចំនួន ៩៥រូប។

- ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២៥ សមាគមកាយឫទ្ធិនារីកម្ពុជាសាខាខេត្តកណ្តាល សហការជាមួយសមាគមគ្រូពេទ្យស្ម័គ្រចិត្តយុវជនសម្តេចតេជោ (TYDA) រៀបចំកម្មវិធីត្រួតពិនិត្យសុខភាពមាត់ធ្មេញ និងសុខភាពភ្នែក ដោយឥតគិតថ្លៃ ជូនដល់សមាជិកាសកម្ម និងគ្រូបង្គោល សរុបចំនួន ២៤៥រូប ហើយក្នុងនោះសមាជិកាសកម្ម ចំនួន ១៧រូប ត្រូវបញ្ជូនទៅមន្ទីរពេទ្យព្រះអង្គឌួងដើម្បីកាត់វែនតា និងសមាជិកាសកម្ម ចំនួន ០៩រូបទៀត ត្រូវបញ្ជូនទៅមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀតដើម្បីព្យាបាលមាត់ធ្មេញបន្ត។

ច.សាខាខេត្តមណ្ឌលគិរី

- ថ្ងៃទី០១ ខែឧសភា ឆ្នាំ២០២៥ សមាគមកាយឫទ្ធិនារីកម្ពុជាសាខាខេត្តមណ្ឌលគិរី សហការជាមួយមន្ទីរសុខាភិបាលខេត្ត បានរៀបចំកម្មវិធី "យុទ្ធនាការ ញ៉ាំថ្នាំទម្លាក់សត្វល្អិត" ដល់សមាជិកាសកម្មក្រុមកន្ទុំរុយ ចំនួន ១៣រូប នៅសាលាបឋមសិក្សាហ៊ុន សែន សែនមនោរម្យ។
- ថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២៥ សមាគមកាយឫទ្ធិនារីកម្ពុជាសាខាខេត្តមណ្ឌលគិរី បានដឹកនាំសមាជិកាគាំទ្រ ចំនួន ១០រូប គ្រូបង្គោល ចំនួន ០២រូប សហការជាមួយមន្ទីរសុខាភិបាលខេត្តចូលរួមផ្សព្វផ្សាយណែនាំស្តីពី "ការការពារ ជំងឺគ្រុនឈាម និងគ្រុនចាញ់" ដល់សមាជិកាសកម្មក្រុមកន្ទុំរុយ ចំនួន ១៣រូប នៅសាលាបឋមសិក្សាហ៊ុន សែន សែនមនោរម្យ។

៤. គម្រោងវប្បធម៌ សិល្បៈ ប្រពៃណី និងហត្ថកម្ម

ក. សាខារាជធានីភ្នំពេញ

- សមាជិកាសកម្ម នៃអង្គការដើម្បីភាពញញឹមនៃកុមារ (PSE) ចំនួន ៣៤រូប បានបន្តរៀនថ្នាក់រចាំ "កម្រងផ្កាសន្តិភាព" រៀងរាល់ ០២សប្តាហ៍ម្តង។
- សមាជិកាសកម្ម នៃអង្គការដើម្បីភាពញញឹមនៃកុមារ (PSE) ចំនួន ១៦រូប បានបន្តរៀនថ្នាក់តន្ត្រីបុរាណ រៀងរាល់ ០២សប្តាហ៍ម្តង។
- ថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២៥ សមាគមកាយឫទ្ធិនារីសាខារាជធានីភ្នំពេញបានដឹកនាំសមាជិកាសកម្ម មកពីអង្គការដើម្បីភាពញញឹមនៃកុមារ (PSE) និងអង្គការមូលនិធិកុមារកម្ពុជា (CCF) សរុបចំនួន៣២រូប រៀនអំពីរបៀបថ្នែ និងបិទគ្រាប់ធញ្ញជាតិធ្វើជារូបគំនូរផ្សេងៗ នៅអង្គការដើម្បីភាពញញឹមនៃកុមារ។
- ថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០២៥ សមាគមកាយឫទ្ធិនារីកម្ពុជាសាខារាជធានីភ្នំពេញ បានដឹកនាំសមាជិកាសកម្មមកពីអង្គការភាពញញឹមនៃកុមារ (PSE) និងអង្គការមូលនិធិកុមារកម្ពុជា (CCF) សរុបចំនួន ២៨រូប រៀនអំពីរបៀបថ្នែ និងបិទគ្រាប់ធញ្ញជាតិធ្វើជារូបគំនូរផ្សេងៗ នៅអង្គការដើម្បីភាពញញឹមនៃកុមារ។

ខ.សាខាខេត្តសៀមរាប

- ថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២៥ សមាគមកាយឫទ្ធិនារីកម្ពុជាសាខាខេត្តសៀមរាប បានដឹកនាំសមាជិកាសកម្មក្រុមវឌ្ឍននារី និងក្រុមកាយឫទ្ធិនារី ចំនួន ៥០រូប រចនាផ្កាកេសរកូលមយូឆត្រ ធ្វើពីក្រដាស។

គ. សាខាខេត្តកំពត

- សមាជិកាសកម្មក្រុមកន្ទុំរុយ ចំនួន ១៣រូប បានបន្តហាត់របាំនៅរៀងរាល់ចុងសប្តាហ៍។
- ថ្ងៃទី០២ ខែមេសា ឆ្នាំ២០២៥ សមាជិកាសកម្ម នៃសមាគមកាយឫទ្ធិនារីកម្ពុជាសាខាខេត្តកំពត ចំនួន ០៤រូប បានបន្តជួបជុំគ្នា ធ្វើគោមផ្កាយ នៅទីស្នាក់ការសមាគមកាយឫទ្ធិនារីកម្ពុជាសាខាខេត្តកំពត។
- ថ្ងៃទី១០ ខែមេសា ឆ្នាំ២០២៥ សមាគមកាយឫទ្ធិនារីកម្ពុជាសាខាខេត្តកំពត បានដឹកនាំសមាជិកាសកម្ម ចំនួន ២៥រូប រៀបចំតុបតែងទីស្នាក់ការសមាគមកាយឫទ្ធិនារីកម្ពុជាសាខាខេត្តកំពត ព្រមទាំងលេងល្បែងប្រជាប្រិយ រាំកម្សាន្តប្រពៃណី និងទទួលទានអាហារសាមគ្គីជុំគ្នា ដើម្បីអបអរ បុណ្យចូលឆ្នាំថ្មី ប្រពៃណីជាតិខ្មែរ។
- ថ្ងៃទី១១ ខែមេសា ឆ្នាំ២០២៥ សមាគមកាយឫទ្ធិនារីកម្ពុជាសាខាខេត្តកំពត បានដឹកនាំសមាជិកាសកម្មក្រុមកន្ទុំរុយ និងក្រុមវឌ្ឍននារី ចំនួន ២៨រូប ចូលរួមសង្ក្រាន្តឆ្នាំថ្មី ស្រុកឈូក ព្រមទាំងកម្មវិធីចម្រើនព្រះបរិត្ត និងសកម្មភាពកម្សាន្តផ្សេងៗ តាមបែបប្រពៃណីជាតិខ្មែរ។
- ថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០២៥ ក្រុមការងារគម្រោងវប្បធម៌ សិល្បៈ ប្រពៃណី និងហត្ថកម្ម បានដឹកនាំរៀនធ្វើកន្លាស់ព័ក្ស ដល់គ្រូបង្គោល និងសមាជិកាសកម្មក្រុមវឌ្ឍននារី ចំនួន ២៣រូប និងរៀនធ្វើនំបឺហ្គឺ ដល់សមាជិកាសកម្មក្រុមវឌ្ឍននារី និងក្រុមកាយឫទ្ធិនារី ចំនួន២០រូប នៃសមាគមកាយឫទ្ធិនារីកម្ពុជាសាខាខេត្តកំពត។

ឃ. សាខាខេត្តបាត់ដំបង

- សមាជិកាសកម្មក្រុមកន្ទុំរុយ នៃសមាគមកាយឫទ្ធិនារីកម្ពុជាសាខាខេត្តបាត់ដំបង ចំនួន ២០រូប បានបន្តរៀនថ្នាក់គំនូររៀងរាល់ ០២សប្តាហ៍ម្តង។
- ថ្ងៃទី០៣ ខែមេសា ឆ្នាំ២០២៥ សមាគមកាយឫទ្ធិនារីកម្ពុជាសាខាខេត្តបាត់ដំបង បានរាំ "របាំត្រុដិ" ដើម្បីចូលរួមអបអរសាទរពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរ នៅទីស្នាក់ការសមាគមកាយឫទ្ធិនារីកម្ពុជាសាខាខេត្តបាត់ដំបង។
- ថ្ងៃទី០៣ ខែមេសា ឆ្នាំ២០២៥ គ្រូបង្គោល នៃសមាគមកាយឫទ្ធិនារីកម្ពុជាសាខាខេត្តបាត់ដំបង បានដឹកនាំសមាជិកាសកម្មក្រុមវឌ្ឍននារី ចំនួន ០៩រូប តាំងបង្ហាញស្នាដៃរបស់ខ្លួននៅក្នុងកម្មវិធី "ពិព័រណ៍ស្នាដៃសិស្ស នៃវិទ្យាល័យសម្តេចឪ" ដើម្បីចូលរួមអបអរសាទរបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរ។

- ថ្ងៃទី០៩ ខែមេសា ឆ្នាំ២០២៥ គ្រូបង្គោល និងសមាជិកាសកម្ម នៃសមាគមកាយឫទ្ធិនារីកម្ពុជា សាខាខេត្តបាត់ដំបង ចំនួន ៣៥រូប បានរៀនបត់បាយសី និងស្វែងយល់អំពីរណ្តាប់ទទួលទេវតាឆ្នាំថ្មី នៅវត្តវេឡុវនារាម។
- ថ្ងៃទី១១ ខែមេសា ឆ្នាំ២០២៥ គ្រូបង្គោល និងសមាជិកាសកម្ម នៃសមាគមកាយឫទ្ធិនារីកម្ពុជា សាខាខេត្តបាត់ដំបង ចំនួន ១៥រូប បានរៀនបត់បាយសី និងស្វែងយល់អំពីរណ្តាប់ទទួលទេវតាឆ្នាំថ្មី។
- ថ្ងៃទី១៣ ខែមេសា ឆ្នាំ២០២៥ សមាជិកាសកម្ម នៃសមាគមកាយឫទ្ធិនារីកម្ពុជាសាខាខេត្តបាត់ដំបង ចំនួន ០៤រូប បានរៀបចំសម្អាតទីស្នាក់ការសមាគម និងរៀបចំគ្រឿងសក្ការៈ ដើម្បីត្រៀមទទួលទេវតាឆ្នាំថ្មី។
- ថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២៥ ក្រុមការងារគម្រោងវប្បធម៌ សិល្បៈ ប្រពៃណី និងហត្ថកម្ម បានដឹកនាំសមាជិកាសកម្ម ចំនួន ០៤រូប ចែករំលែកចំណេះដឹងលើការគូរគំនូរលើកញ្ចក់ និង Post card ជូនសមាជិកាសកម្មក្រុមកន្ទុំរុយ នៃសមាគមកាយឫទ្ធិនារីកម្ពុជាសាខាបាត់ដំបង ចំនួន ៣០រូប និងរៀនធ្វើកន្លាស់ព័ក្ស ដល់សមាជិកាសកម្មក្រុមវឌ្ឍននារី ក្រុមកាយឫទ្ធិនារី និងគ្រូបង្គោល ចំនួន ២០រូប និងរៀនធ្វើដំណាប់ម្ជាស់ កីហ្សា និងសាំងវ៉ិច ជូនសមាជិកាសកម្មក្រុមវឌ្ឍននារី និងក្រុមកាយឫទ្ធិនារី ចំនួន ២៥រូប។
- ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២៥ ដើម្បីអបអរទិវាសិទ្ធិកុមារអន្តរជាតិ ១មិថុនា ប្រធានកិត្តិយស និងប្រធានក្រុមប្រឹក្សាសមាគមកាយឫទ្ធិនារីកម្ពុជាសាខាខេត្តបាត់ដំបង បានដឹកនាំយុវតីស្ម័គ្រចិត្តចំនួន ៤០រូប និងសមាជិកាគាំទ្រ ចំនួន ៤០រូប ចម្អិនបឺហ្គឺសាច់មាន់ ដំឡូងបំពង មាន់បំពង និងតែទឹកដោះគោ ជូនដល់ប្អូនៗនៅបុរីកុមារកំព្រាទី១ និងទី២ សរុបចំនួន ១១៥រូប។

ង. សាខាខេត្តពោធិ៍សាត់

- ថ្ងៃទី០៣ ខែមេសា ឆ្នាំ២០២៥ គ្រូបង្គោល និងសមាជិកាសកម្មក្រុមកន្ទុំរុយ ចំនួន ១៨រូប នៃសមាគមកាយឫទ្ធិនារីកម្ពុជាសាខាខេត្តពោធិ៍សាត់ បានរៀនបត់ផ្កាឈូកក្រដាស។
- ថ្ងៃទី១០ ខែមេសា ឆ្នាំ២០២៥ គ្រូបង្គោល និងសមាជិកាសកម្ម នៃសមាគមកាយឫទ្ធិនារីកម្ពុជាសាខាខេត្តពោធិ៍សាត់ ចំនួន ២៩រូប បានរៀនបត់ផ្កាឈូក និងស្វែងយល់អំពីរណ្តាប់ទទួលទេវតាឆ្នាំថ្មី។
- ថ្ងៃទី០១ ខែឧសភា ឆ្នាំ២០២៥ គ្រូបង្គោល នៃសមាគមកាយឫទ្ធិនារីកម្ពុជាសាខាខេត្តពោធិ៍សាត់ បានបង្រៀនពីរបៀបចិតផ្លែម្ជាស់ ដល់សមាជិកាសកម្មចំនួន ២៥រូប។

ច. សាខាខេត្តកណ្តាល

- សមាជិកាសកម្ម នៃសមាគមកាយឫទ្ធិនារីកម្ពុជា ស្រុកកៀនស្វាយ សាខាខេត្តកណ្តាល ចំនួន ៦៦រូប បានបន្តរៀនដេរប៉ាក់រៀងរាល់ ០២សប្តាហ៍ម្តង។

- សមាជិកាសកម្ម នៃសមាគមកាយឫទ្ធិនារីកម្ពុជា ស្រុកល្វាឯម សាខាខេត្តកណ្តាល ចំនួន ៣៣រូប បានបន្តរៀនដេរប៉ាក់រៀងរាល់ ០២សប្តាហ៍ម្តង។
- សមាជិកាសកម្ម នៃសមាគមកាយឫទ្ធិនារីកម្ពុជា ក្រុងអរិយក្សត្រ សាខាខេត្តកណ្តាល ចំនួន ៤០រូប បានបន្តរៀនដេរប៉ាក់រៀងរាល់ ០២សប្តាហ៍ម្តង។
- ថ្ងៃទី១១ ខែឧសភា ឆ្នាំ២០២៥ សមាជិកាសកម្ម ក្រុងអរិយក្សត្រ ស្រុកកៀនស្វាយ និងស្រុកល្វាឯម នៃសមាគមកាយឫទ្ធិនារីកម្ពុជាសាខាខេត្តកណ្តាល ចំនួន ៦៣រូប បានជួបជុំគ្នាតាមក្រុមដើម្បីបន្តរៀនចាក់អំបោះ កាត់ដេរ បត់ផ្ការំដួល ព្រមទាំងបានរៀនធ្វើបង្អែមចាហួយ ចាក់ជារូបផ្ការំដួល និងរូបលម្អផ្សេងៗ។
- ថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២៥ សមាជិកាសកម្ម រួមជាមួយគ្រូបង្គោល និងសមាជិកាគាំទ្រ ចំនួន ១៨រូប នៃសមាគមកាយឫទ្ធិនារីកម្ពុជាសាខាខេត្តកណ្តាល បានចូលរួមកម្មវិធីសមាធិកុមារ នៅវត្តនិគ្រោធវ័ន ហៅវត្តគល់ទទឹង។

ឆ. សាខាខេត្តមណ្ឌលគិរី

- ថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០២៥ ប្រធានក្រុមប្រឹក្សា នៃសមាគមកាយឫទ្ធិនារីកម្ពុជាសាខាខេត្តមណ្ឌលគិរី រួមទាំងសមាជិកាគាំទ្រចំនួន ០៤រូប និងគ្រូបង្គោល ចំនួន ០១រូប បានបង្រៀនតុបតែងផ្ការស្រស់ ទៅជាផ្ទាំងបាច់ផ្កា និងរូបភាពបេះដូង ជល់សមាជិកាសកម្មក្រុមកន្ទុំរុយចំនួន ១១រូប នៅសាលាបឋមសិក្សា ហ៊ុន សែន សែនមនោរម្យ។
- ថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២៥ សមាជិកាគាំទ្រ ចំនួន ០៧រូប និងគ្រូបង្គោល ចំនួន ០២រូប នៃសមាគមកាយឫទ្ធិនារីកម្ពុជាសាខាខេត្តមណ្ឌលគិរី បានបង្ហាត់បង្រៀនបត់លួសកាំម្ញី ជាផ្កាឈូក ផ្កាទូលីប ផ្កាឡាវែនដឺ ផ្ការំយោល ផ្កាកុលាប និងផ្កាផ្សេងៗទៀត រួមទាំងកែច្នៃផ្ការស្រស់ ជាកន្ត្រកផ្កា ជល់សមាជិកាសកម្មក្រុមវឌ្ឍននារី ចំនួន ១២រូប ស្ថិតនៅវិទ្យាល័យ ហ៊ុន សែន កែវសីមា។

៥.គម្រោងការចូលរួមសកម្មភាពផ្សេងៗ

- ថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០២៥ សមាគមកាយឫទ្ធិនារីកម្ពុជា បានផ្តល់វគ្គផ្សព្វផ្សាយស្តីពីការបង្កើតក្រុមឃុវតីស្ម័គ្រចិត្តសម្រាប់សមាគមកាយឫទ្ធិនារីកម្ពុជាសាខាខេត្តសៀមរាប ដោយមានសមាសភាពសមាជិកាសកម្មចូលរួមសរុបចំនួន ៣៥រូប។
- ថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០២៥ សមាគមកាយឫទ្ធិនារីកម្ពុជាសាខាខេត្តបាត់ដំបង បាននាំយកនូវថវិកា អង្ករ និងសម្ភារប្រើប្រាស់មួយចំនួន ព្រមទាំងនាំយកថវិកា និងសម្ភារសិក្សា ដែលជាអំណោយផ្ទាល់របស់លោកជំទាវ ម៉ែត វ៉ាវីចិត្រ សុខលូ ប្រធានកិត្តិយស នៃសមាគមកាយឫទ្ធិនារីកម្ពុជាសាខាខេត្តបាត់ដំបង ប្រគល់ជូនឃុវតី ពៅ ពិសី សមាជិកាសកម្មក្រុមវឌ្ឍននារី ព្រមទាំងក្រុមគ្រួសារ ដែលបានទទួលរងគ្រោះអគ្គិភ័យ ឆេះផ្ទះទាំងស្រុង កាលពីយប់ថ្ងៃទី០២ ខែឧសភា ឆ្នាំ២០២៥ កន្លងមកនេះ។

- ថ្ងៃទី១១ ខែឧសភា ឆ្នាំ២០២៥ សមាគមកាយឫទ្ធិនារីកម្ពុជា បានប្រារព្ធពិធីសប្បុរសធម៌ចែករំលែកនូវស្នាមញញឹម និងក្តីស្រឡាញ់ ជូនដល់សមាជិកសមាគមមូលនិធិត្រីចក្រយានកម្ពុជា ក្រោមអធិបតីភាព ខ្ញុំម្ចាស់ នៅសាលារាជធានីភ្នំពេញ ដោយមានការចូលរួមពីសមាជិកា សមាជិកសមាគមកាយឫទ្ធិនារីកម្ពុជា និងសមាជិកសមាគមមូលនិធិត្រីចក្រយានកម្ពុជា ភ្ញៀវកិត្តិយសសរុបចំនួន ៥៩៥រូប។
- ថ្ងៃទី១១ ខែឧសភា ឆ្នាំ២០២៥ សមាគមកាយឫទ្ធិនារីកម្ពុជា បានផ្តល់វគ្គផ្សព្វផ្សាយស្តីពីការបង្កើតក្រុមយុវតីស្ម័គ្រចិត្តសម្រាប់សមាគមកាយឫទ្ធិនារីកម្ពុជាសាខាខេត្តបាត់ដំបង និងសាខាខេត្តពោធិ៍សាត់ ដោយមានសមាសភាពចូលរួមសរុបចំនួន ១១៥ រូប។
- ថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០២៥ សមាគមកាយឫទ្ធិនារីកម្ពុជាសាខារាជធានីភ្នំពេញ បានរៀបចំវគ្គផ្សព្វផ្សាយស្តីពីការបង្កើតក្រុមយុវតីស្ម័គ្រចិត្ត ដល់សមាជិកាសកម្មសរុបចំនួន ៥៧រូប នៅអង្គការដើម្បីភាពញញឹមនៃកុមារ។
- ថ្ងៃទី២៤ ខែឧសភា ឆ្នាំ ២០២៥ សមាគមកាយឫទ្ធិនារីកម្ពុជា បាននាំយកអំណោយ របស់ខ្ញុំម្ចាស់ចែកជូនដល់សមាជិកាសកម្មស្រុកឈូក ចំនួន ៥៨រូប គ្រូបង្គោលចំនួន ០៤រូប និងមេដឹកនាំក្រុមចំនួន ០១រូប នៃសមាគមកាយឫទ្ធិនារីកម្ពុជាសាខាខេត្តកំពត។
- ថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២៥ សមាគមកាយឫទ្ធិនារីកម្ពុជា បានផ្តល់វគ្គផ្សព្វផ្សាយស្តីពីការបង្កើតក្រុមយុវតីស្ម័គ្រចិត្ត សម្រាប់សមាគមកាយឫទ្ធិនារីកម្ពុជាសាខាខេត្តកណ្តាល ដល់សមាជិកាសកម្មសរុបចំនួន ៥៨រូប។
- ថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២៥ សមាគមកាយឫទ្ធិនារីកម្ពុជា បានផ្តល់វគ្គផ្សព្វផ្សាយស្តីពីការបង្កើតក្រុមយុវតីស្ម័គ្រចិត្ត សម្រាប់សមាគមកាយឫទ្ធិនារីកម្ពុជាសាខាខេត្តកំពត ដល់សមាជិកាសកម្មសរុបចំនួន ៥០រូប។
- ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២៥ សមាគមកាយឫទ្ធិនារីកម្ពុជាសាខារាជធានីភ្នំពេញ បាននាំយកសម្ភារមួយចំនួន ដែលទទួលបានពីយុទ្ធនាការ "ចាស់អ្នក ថ្មីខ្ញុំ" រួមមានសម្ភារក្មេងលេង សម្ភារសិក្សា ចំនួន ២៥កេស និងសម្លៀកបំពាក់ប្រុសស្រី ចំនួន ២៤១បាវ ជូនដល់សិស្សានុសិស្ស នៃអង្គការមូលនិធិកុមារកម្ពុជា (CCF)។
- ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២៥ សមាគមកាយឫទ្ធិនារីកម្ពុជា បានផ្តល់វគ្គផ្សព្វផ្សាយស្តីពីការបង្កើតក្រុមយុវតីស្ម័គ្រចិត្ត សម្រាប់សមាគមកាយឫទ្ធិនារីកម្ពុជាសាខាខេត្តពោធិ៍សាត់ ដល់សមាជិកាសកម្មសរុបចំនួន ៩៨រូប។
- ថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២៥ សមាគមកាយឫទ្ធិនារីកម្ពុជាសាខាខេត្តសៀមរាប បានរៀបចំការប្រជុំផ្ទេរការងារ និងជួបសំណេះសំណាលជាមួយអ្នកគ្រូបង្គោលទាំង០៦ក្រុង/ស្រុក ដោយមានសមាសភាពចូលរួមសរុបចំនួន ៤០រូប។

៦. សកម្មភាពផ្សេងៗទៀតរបស់សមាគម

- ថ្ងៃទី១៣ ខែមេសា ឆ្នាំ២០២៥ សមាជិកាសកម្មក្រុមវឌ្ឍននារី និងក្រុមកាយឫទ្ធិនារី នៃសមាគមកាយឫទ្ធិនារីកម្ពុជាសាខាខេត្តបាត់ដំបង ចំនួន ១៥រូប បានចូលរួមសម្អាតបរិស្ថាន នៅក្នុងកម្មវិធីសង្ក្រាន្តបាត់ដំបង។
- ថ្ងៃទី១៣ ខែមេសា ឆ្នាំ២០២៥ សមាជិកាសកម្ម នៃសមាគមកាយឫទ្ធិនារីកម្ពុជាសាខាខេត្តបាត់ដំបង ចំនួន ៣០រូប បានចូលរួមពិធីបើក "ព្រឹត្តិការណ៍សង្ក្រាន្តបាត់ដំបង ២០២៥"។
- ចាប់ពីថ្ងៃទី១៣ ដល់ថ្ងៃទី១៦ ខែមេសា ឆ្នាំ២០២៥ សមាជិកាសកម្មក្រុមកាយឫទ្ធិនារី ចំនួន ០៥រូប និងក្រុមវឌ្ឍននារី ចំនួន ១០រូប នៃសមាគមកាយឫទ្ធិនារីកម្ពុជាសាខាខេត្តបាត់ដំបង បានចូលរួមជាយុវជនស្ម័គ្រចិត្ត ក្នុងភូមិបង្អែមខ្មែរអ្នកបាត់ដំបងរបស់កម្មវិធីសង្ក្រាន្តខេត្តបាត់ដំបង។
- ចាប់ពីថ្ងៃទី១៤ ដល់ថ្ងៃទី១៦ ខែមេសា ឆ្នាំ២០២៥ សមាគមកាយឫទ្ធិនារីកម្ពុជាសាខាខេត្តសៀមរាប បានចូលរួមដាក់ស្តង់ពិព័រណ៌ នាឱកាសអង្គរសង្ក្រាន្ត ដែលដាក់បង្ហាញនូវស្នាដៃរបស់សមាជិកាសកម្ម នៅទីតាំង "ភូមិត្នោត" ក្នុងតំបន់ត្រពាំងសេះ មុខប្រាសាទអង្គរវត្ត។
- ថ្ងៃទី១៧ ខែមេសា ឆ្នាំ២០២៥ សមាជិកាសកម្ម នៃសមាគមកាយឫទ្ធិនារីកម្ពុជាសាខាខេត្តបាត់ដំបង ចំនួន ១១រូប បានចូលរួមរៀបចំទុកដាក់សម្ភារ និងសម្អាតបរិស្ថានបន្ទាប់ពីកម្មវិធីសង្ក្រាន្តត្រូវបានបញ្ចប់។
- ថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០២៥ សមាជិកាគាំទ្រ នៃសមាគមកាយឫទ្ធិនារីកម្ពុជាសាខាខេត្តមណ្ឌលគិរី ចំនួន ០៨រូប បាននាំយកថវិកា ដែលទទួលបានពីសមាជិកាគាំទ្រ ឧបត្ថម្ភក្នុងកម្មវិធីអបអរ ខួបលើកទី១៦២ ៨ ឧសភា ២០២៥ ទិវាពិភពលោកកាកបាទក្រហម និងអឌ្ឍចន្ទក្រហម ក្រោមប្រធានបទ "រួមគ្នាស្ម័គ្រចិត្ត ដើម្បីសហគមន៍មានសុខភាពល្អ និងមានភាពធន់នឹងអាកាសធាតុ" នៅសាលាខេត្តមណ្ឌលគិរី។
- ថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២៥ សមាគមកាយឫទ្ធិនារីកម្ពុជាសាខាខេត្តកណ្តាល បាននាំយកថវិការបស់លោកជំទាវ ប៉ាន់ ត្រាប្រណី ប្រធានក្រុមប្រឹក្សាសមាគមកាយឫទ្ធិនារីកម្ពុជាសាខាខេត្តកណ្តាល ប្រគល់ជូន ឯកឧត្តម គួច ចំរើន ប្រធានគណៈកម្មាធិការសាខាកាកបាទក្រហមខេត្តកណ្តាល ក្នុងឱកាសខួបលើកទី១៦២ ៨ ឧសភា ២០២៥ ទិវាពិភពលោកកាកបាទក្រហម និងអឌ្ឍចន្ទក្រហម។
- ថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០២៥ សមាជិកាសកម្ម នៃសមាគមកាយឫទ្ធិនារីកម្ពុជាសាខាខេត្តកំពត ចំនួន ០៧រូប បានចូលរួមសម្តែងរបាំថ្វាយព្រះពរ និងសមាជិកាសកម្ម ចំនួន ២០រូបផ្សេងទៀត បានចូលរួមព្រះរាជពិធីបុណ្យចម្រើនព្រះជន្ម **ព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា** គម្រប់ព្រះជន្ម ៧២ យាងចូល ៧៣ព្រះវស្សា នៅសាលសន្និសីទបូកគោ សាលាខេត្តកំពត។

- ថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២៥ សមាជិកាសកម្ម និងគ្រូបង្គោល នៃសមាគមកាយឫទ្ធិនារីកម្ពុជា សាខាខេត្តបាត់ដំបង ចំនួន ៣០រូប បានចូលរួមកម្មវិធី "២០ ឧសភា ទិវាជាតិនៃការចងចាំ" ដែលរៀបចំដោយរដ្ឋបាលខេត្តបាត់ដំបង។
- ថ្ងៃទី២១ ខែឧសភា ឆ្នាំ២០២៥ សមាជិកាសកម្ម ស្រុកឈូក នៃសមាគមកាយឫទ្ធិនារីកម្ពុជា សាខាខេត្តកំពត ចំនួន ៣២រូប បានចូលរួមកម្មវិធី "២០ ឧសភា ទិវាជាតិនៃការចងចាំ" ក្រោមអធិបតីភាពអភិបាលនៃគណៈអភិបាលស្រុកឈូក។
- ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២៥ សមាជិកាសកម្ម មកពីអង្គការមូលនិធិកុមារកម្ពុជា (CCF) និងអង្គការដើម្បីភាពញញឹមនៃកុមារ (PSE) នៃសមាគមកាយឫទ្ធិនារីកម្ពុជាសាខារាជធានីភ្នំពេញ សរុបចំនួន ៥០រូប បានចូលរួមគាំទ្រជាកម្លាំងចិត្ត ដល់យុវតី ចំនួន ០៥រូប របស់សមាគមកាយឫទ្ធិនារីកម្ពុជា ក្នុងកម្មវិធីជជែកដេញដោលយុវជនថ្នាក់ជាតិ ២០២៥ វគ្គជម្រុះជុំទី៣។
- ថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០២៥ សមាជិកាសកម្ម នៃសមាគមកាយឫទ្ធិនារីកម្ពុជាសាខាខេត្តបាត់ដំបង ចំនួន ៣០រូប បានចូលរួមកម្មវិធី ទិវាជាតិ បង្ការ និងពន្លត់អគ្គិភ័យ ឆ្នាំ២០២៥។
- ថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០២៥ សមាគមកាយឫទ្ធិនារីកម្ពុជាសាខារាជធានីភ្នំពេញ បានដឹកនាំសមាជិកាសកម្មមកពីអង្គការភាពញញឹមនៃកុមារ (PSE) និងអង្គការមូលនិធិកុមារកម្ពុជា (CCF) សរុបចំនួន ៥៥រូប ចូលរួមអបអរសាទរវគ្គផ្តាច់ព្រ័ត្រការប្រកួតក្រុមភ្លេងកាយវិទ្ធិថ្នាក់ជាតិ លើកទី២ ក្រោមប្រធានបទ "ភ្លេងកាយវិទ្ធិ ដើម្បីមហាបវរវិបុលភាព"។
- ថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២៥ សមាជិកាសកម្មក្រុមកាយឫទ្ធិនារី នៃសមាគមកាយឫទ្ធិនារីកម្ពុជា សាខាខេត្តសៀមរាប ចំនួន ១២រូប បានចូលរួមអបអរសាទរ ទិវាពិភពលោកនៃអ្នកបរិច្ចាគឈាម "ផ្តល់ឈាម ផ្តល់ក្តីសង្ឃឹម" នៅខេត្តសៀមរាប។
- ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២៥ សមាជិកាគាំទ្រ នៃសមាគមកាយឫទ្ធិនារីកម្ពុជាសាខាខេត្តមណ្ឌលគិរី ចំនួន ០៤រូប បានចូលរួម អបអរទិវាជាតិអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ លើកទី៨ ឆ្នាំ២០២៥ ក្រោមប្រធានបទ "TVET បង្កើតឱកាសការងារ សាងក្តីសង្ឃឹមដល់យុវជន" នៅសាលាខេត្តមណ្ឌលគិរី។
- ថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២៥ សមាគមកាយឫទ្ធិនារីសាខារាជធានីភ្នំពេញ បានដឹកនាំសមាជិកាសកម្មមកពីអង្គការដើម្បីភាពញញឹមនៃកុមារ (PSE) និងអង្គការមូលនិធិកុមារកម្ពុជា (CCF) សរុបចំនួន ៤២រូប ចូលរួមអបអរសាទរ "ទិវាអន្តរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន។
- ថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២៥ សមាជិកាសកម្ម នៃសមាគមកាយឫទ្ធិនារីកម្ពុជាសាខារាជធានីភ្នំពេញ មកពីអង្គការមូលនិធិកុមារកម្ពុជា (CCF) និងអង្គការដើម្បីភាពញញឹមនៃកុមារ (PSE) សរុបចំនួន ៥០រូប ចូលរួមគាំទ្រជាកម្លាំងចិត្ត ដល់យុវតី ០៥រូប របស់សមាគមកាយឫទ្ធិនារីកម្ពុជា ក្នុងកម្មវិធីជជែកដេញដោលយុវជនថ្នាក់ជាតិ ២០២៥ ក្នុងវគ្គពាក់កណ្តាលផ្តាច់ព្រ័ត្រ។

សូម **សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ នុឯសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល** ទ្រង់ព្រះមេត្តាទទួលជ្រាបនូវរបាយការណ៍ចាប់ពីថ្ងៃទី០១ ខែមេសា ឆ្នាំ២០២៥ ដល់ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៥ ដោយសេចក្តីអនុគ្រោះបំផុត។

សេចក្តីគួរពុំគួរ សូម **សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ** ព្រះមេត្តាប្រោសទទួលនូវស្វាមីភ័ក្តិដ៏ស្មោះស្ម័គ្រ និងសេចក្តីគោរពដ៏ខ្ពង់ខ្ពស់បំផុតអំពីខ្ញុំម្ចាស់។

ថ្ងៃ សុក្រ ៩កើត ខែ អាសាឍ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
ក្រាបបង្គំទូលថ្វាយនៅរាជធានីភ្នំពេញ ថ្ងៃទី ៤ ខែកក្កដា ឆ្នាំ២០២៥

សមាគមអ្នកយុវនារីកម្ពុជា
អគ្គលេខាធិការ

GIRL GUIDES ASSOCIATION OF CAMBODIA

ពេជ ចន្ទមុន្នី

អំពីការដង្ហែទៀនចំណាំព្រះវស្សាព្រះរាជទ្រព្យ
និងគ្រឿងរណ្តាប់រណ្តា ទៅវេរថ្វាយ-ប្រគេនព្រះសង្ឃតាមទីអារាម-មណ្ឌលចំនួន ៧
ដែលបានតម្កល់ "**ព្រះបរមអដ្ឋិ ព្រះករុណាព្រះបរមរតនកោដ្ឋ**"
កាលពីថ្ងៃទី ១៩, ២០, ២១, ២៤ និង២៦ ខែកក្កដា ឆ្នាំ២០២៥

១ - មណ្ឌលព្រះកម្មដ្ឋានព្រះករុណាព្រះមហាក្សត្រ **សីហមុនី** ស្ថិតនៅក្រុងសៀមរាប ខេត្តសៀមរាប នៅព្រឹកថ្ងៃទី ១៩ ខែកក្កដា ឆ្នាំ២០២៥

















២ - វត្តជិនវ័នសីមារាម ស្ថិតក្នុងក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ នៅព្រឹកថ្ងៃទី ២០ ខែកក្កដា ឆ្នាំ២០២៥











៣ - វត្តព្រះពុទ្ធត្រ័យរតន៍មង្គល ស្ថិតនៅក្រុងប៉ៃលិន ខេត្តប៉ៃលិន នៅព្រឹកថ្ងៃទី ២១ ខែកក្កដា ឆ្នាំ២០២៥











៤- វត្តបទុមធម្មយុត្ត ស្ថិតនៅខណ្ឌដូនពេញ រាជធានីភ្នំពេញ នៅព្រឹកថ្ងៃទី ២៤ ខែកក្កដា ឆ្នាំ២០២៥











៥ - វត្តធម្មវិន័យ ស្ថិតនៅស្រុកព្រៃកប្បាស ខេត្តតាកែវ នៅព្រឹកថ្ងៃទី ២៤ ខែកក្កដា ឆ្នាំ២០២៥











៦- វត្តព្រះធម៌កំពូលត្រែភព ស្ថិតនៅស្រុកមុខកំពូល ខេត្តកណ្តាល នៅព្រឹកថ្ងៃទី ២៦ ខែកក្កដា ឆ្នាំ២០២៥











៧- វត្តព្រះឥន្ទសាមគ្គីធម៌ ស្ថិតនៅស្រុកអង្គស្នួល ខេត្តកណ្តាល នៅព្រឹកថ្ងៃទី ២៦ ខែកក្កដា ឆ្នាំ២០២៥



















រូបភាពស្តីពីស្ថានភាពបងប្អូនប្រជារាស្ត្រជាជនភៀសសឹកដោយសារសង្គ្រាមតាម
ព្រំដែនកម្ពុជា-ថៃ ដែលអាជ្ញាធរដែនដីបានធ្វើការបន្លាស់ទីមកកន្លែងសុវត្ថិភាព ស្ថិតនៅចំនួន ៤ កន្លែង
(វត្តបាត់ផ្តៅ ចំនួន ៣.៦៧៣ គ្រួសារ, វត្តភ្នំដី ចំនួន ១១០ គ្រួសារ, វត្តគោល ចំនួន ៧៨ គ្រួសារ និង
អនុវិទ្យាល័យគោកស្ពាន ចំនួន ១៦ គ្រួសារ) **សរុបចំនួន ៣.៨៧៧ គ្រួសារ**
ក្នុងស្រុកចុងកាល់ ខេត្តឧត្តរមានជ័យ





















រូបភាពស្តីពីគណៈប្រតិភូជាន់ខ្ពស់កម្ពុជា ដឹកនាំដោយ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** អញ្ជើញចូលរួមកិច្ចប្រជុំពិសេស ជួបចរចាគ្នារវាងកម្ពុជា និងថៃ ដើម្បីបទឈប់បាញ់គ្នាជាបន្ទាន់រវាងប្រទេសទាំងពីរ។ កិច្ចប្រជុំនេះសហការរៀបចំដោយសហរដ្ឋអាមេរិក និងម៉ាឡេស៊ី ដោយមានការចូលរួមពីតំណាងចិនផងដែរ។

ប្រទេសម៉ាឡេស៊ី ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២៥









ព្រះរាជាណាចក្រកម្ពុជា
ROYAUME DU CAMBODGE

ព្រះបរមរាជវាំង

សូមព្រះបរមរាជានុញ្ញាត ក្រាបបង្គំទូលថ្វាយ
សម្តេចព្រះមហាកុរុត្តី ព្រះចរោះមហាសាជាតិខ្មែរ នៃព្រះរាជាណាចក្រកម្ពុជា
ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត សូមព្រះមេត្តាជ្រាបដ៏ខ្ពង់ខ្ពស់បំផុត។

ខ្ញីមសារសេចក្ដី :

ខ្ញុំម្ចាស់ សូមព្រះបរមាជានុញ្ញាត ក្រាបបង្គំទូលថ្វាយ **សម្តេចព្រះមហាកុរុត្តី ព្រះចរោះមហាសាជាតិខ្មែរ** នៃព្រះរាជាណាចក្រកម្ពុជា ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត អំពីសកម្មភាពក្រុមការងារ ស.ស.យ.ក. បម្រើការនៅព្រះបរមរាជវាំង និងតំណាងអោយសប្បុរសជនទាំងក្នុងស្រុក និងពីក្រៅប្រទេសទាំងអស់ បាននាំយកនូវ ស្បៀងអាហារ ថ្នាំសង្កូវ និងសម្ភារប្រើប្រាស់មួយចំនួនជូនដល់គ្រួសារជនភៀសសឹក កងទ័ព និងកងទ័ពកំពុងសម្រាកព្យាបាលនៅមន្ទីរពេទ្យខេត្តសៀមរាប ព្រមទាំងទៅគោរពវិញ្ញាណក្ខន្ធសពកងទ័ពដែលបានពលីជីវិតក្នុងសឹកសង្គ្រាមដើម្បីការពារទឹកដីខ្មែរពីចោរសៀមដែលឈ្លានពានកម្ពុជាចាប់តាំងពីថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២៥មក។

ក្រោមការដឹកនាំដោយ **សម្តេចព្រះព្រហ្មរតនមុនី ពិន សែម សិរីសុវណ្ណោ** ក្រុមការងារបាននាំយកអំណោយទៅចែកជូនជនភៀសសឹក កងទ័ព និងគ្រួសារកងទ័ពពលីនៅក្នុងខេត្តសៀមរាប ដូចខាងក្រោម:

- **ថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០២៥**

  ១-ជនភៀសសឹក ១០៣៥គ្រួសារ នៅវត្តហេមវន្ទអរញ្ញវា (ហៅវត្តស្រែណូយ) ភូមិស្រែណូយ ឃុំវ៉ារិន្ទ ស្រុកវ៉ារិន្ទ ខេត្តសៀមរាប

  ២-ជនភៀសសឹក ២៩១គ្រួសារ នៅវត្តសុវណ្ណបទុម ភូមិដូល ឃុំវ៉ារិន្ទ ស្រុកវ៉ារិន្ទ ខេត្តសៀមរាប

  ៣-កងទ័ព ជួរមុខចំនួន២កងពល កងពលលេខ២ និងកងពលលេខ៣

- **ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០២៥**

  ៤-សួរសុខទុក្ខកងទ័ពកំពុងសម្រាកព្យាបាលនៅមន្ទីរពេទ្យខេត្ត ចំនួន៣៦នាក់ របួសធ្ងន់៨នាក់

  ៥-ចូលរួមគោរពវិញ្ញាណក្ខន្ធសពកងទ័ពពលីជីវិត ចំនួន០៣នាក់

- **ថ្ងៃទី១ ខែសីហា ឆ្នាំ២០២៥**

  ៦-ជនភៀសសឹក ៨០០ គ្រួសារ នៅវត្តអរញ្ញគីរីមុនីសុខុម (ហៅវត្តស្វាយលើ) និងជនភៀសសឹកចំនួន ១១៣៥ គ្រួសារ នៅវត្តខេមរភូមិន្ទរស្មីសាមគ្គីវត្តារាម (ហៅអូតាកុក) ក្នុងស្រុកស្វាយលើ ខេត្តសៀមរាប។

ខ្ញុំម្ចាស់ សូមព្រះបរមរាជានុញ្ញាតភ្ជាប់នូវរបាយការណ៍រូបភាព។

ខ្ញុំម្ចាស់ សូមក្រាបបង្គំទូលថ្វាយ **សម្តេចព្រះមហាកុរុត្តី ព្រះចរោះមហាសាជាតិខ្មែរ** នៃព្រះរាជាណាចក្រកម្ពុជា ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត សូមព្រះមេត្តាជ្រាប តាមសព្វព្រះរាជហឫទ័យដ៏ខ្ពង់ខ្ពស់បំផុត។

សេចក្ដីគួរពុំគួរ សូម សម្តេចព្រះមហាកុរុត្តី ព្រះមេត្តាជ្រោស ។
ក្រាបបង្គំទូលថ្វាយ នៅថ្ងៃទី៤ ខែសីហា ឆ្នាំ២០២៥
ក្រោមល្អងធូលីព្រះបាទ

ខ្ញុំម្ចាស់ ឆង់ បញ្ញា

ជូនជំនួយដល់ កងពលលេខ៦ តំបន់ខេត្តឧត្តរមានជ័យ

ថ្ងៃទី ៣០ ខែកក្កដា ឆ្នាំ២០២៥





ជូនជំនួយដល់ ជនកៀសសឹក ១០៣៥គ្រួសារ
នៅវត្ត ហោម វ័ន្ន អរញ្ញ វ (ហៅវត្ត ស្រែណូយ) ឃុំវ៉ារិន ស្រុកវ៉ារិន ខេត្តសៀមរាប

ថ្ងៃទី ៣០ ខែកក្កដា ឆ្នាំ២០២៥















ជូនជំនួយដល់ ជនភៀសសឹក ២៩១គ្រួសារ
នៅវត្ត សុវណ្ណបុទម ភូមិរំដួល ឃុំវ៉ារិន ស្រុកវ៉ារិន ខេត្តសៀមរាប
ថ្ងៃទី ៣០ ខែកក្កដា ឆ្នាំ២០២៥















ជូនជំនួយដល់ កងពលលេខ៣ តំបន់ខេត្តព្រះវិហារ

ថ្ងៃទី ៣០ ខែកក្កដា ឆ្នាំ២០២៥







ចុះសួរសុខទុក្ខ វីរៈជនកងទ័ពដែលសម្រាកព្យាបាលនៅមន្ទីរពេទ្យខេត្តសៀមរាប ចំនួន៣៦នាក់ របួសធ្ងន់៨នាក់

ថ្ងៃទី ៣១ ខែកក្កដា ឆ្នាំ២០២៥
















ចូលរួមគោរពវិញ្ញាណក្ខ័ន្ធសពកងទ័ពពលីជីវិត ចំនួន០៣នាក់

ថ្ងៃទី ៣១ ខែកក្កដា ឆ្នាំ២០២៥








ជូនជំនួយដល់ ជនភៀសសឹក ៨០០គ្រួសារ នៅវត្តអារញ្ញគីរីមុនីសុខុម (ហៅវត្តស្វាយលើ) និង ជនភៀសសឹកចំនួន១១៣៥គ្រួសារ នៅវត្តខេមរភូមិន្ទរស្មីសាមគ្គីរុក្ខារាម (ហៅអូតាកុក) ភូមិអភិវឌ្ឍន៍ ឃុំកន្ទួត ស្រុកស្វាយលើ ខេត្តសៀមរាប

ថ្ងៃទី ១ ខែសីហា ឆ្នាំ២០២៥









CAMBODIA






















ព្រះរាជាណាចក្រកម្ពុជា
ROYAUME DU CAMBODGE

ព្រះបរមរាជវាំង

来华。

祝政躬康泰、诸事顺遂。

中华人民共和国主席

2025年7月8日于北京

金边
柬埔寨王国
诺罗敦·西哈莫尼国王
诺罗敦·莫尼列·西哈努克太后

尊敬的国王陛下和太后陛下：

承蒙你们来函祝贺我生日，谨表示诚挚谢意。

我十分珍视同两位陛下的深厚情谊。今年4月我访问柬埔寨期间，柬方给予我热情款待和周到安排。我同两位陛下亲切会面、畅叙友谊，亲身感受到柬埔寨王室和人民对中国人民发自内心的友好感情，留下美好深刻回忆。

我高度重视中柬关系发展，愿同国王陛下一道努力，赓续中柬传统友谊，不断充实中柬“钻石六边”合作架构，推动新时代全天候中柬命运共同体建设走深走实，给两国人民带来更多福祉。

期待国王陛下来华出席纪念中国人民抗日战争暨世界反法西斯战争胜利80周年活动，并欢迎两位陛下随时

(Translation)

His Majesty Preah Bat Samdech Preah Boromneath NORODOM SIHAMONI
King of Cambodia
Her Majesty Samdech Preah Mahaksatrey NORODOM MONINEATH SIHANOUK
Queen Mother of Cambodia
Phnom Penh

Beijing, 8 July 2025

Your Majesties,

I would like to express my heartfelt gratitude for Your Majesties' letter of congratulation on the occasion of my birthday.

I highly value the deep friendship with Your Majesties. During my visit to Cambodia in April this year, the Cambodian side accorded me warm hospitality and thoughtful arrangements. It is a great pleasure to meet with Your Majesties and enjoy a most pleasant exchange on China-Cambodia friendship and I personally felt the heartfelt friendship of the Royal Family and the Cambodian people towards the Chinese people, leaving me with fond and profound memories.

I attach great significance to development of China-Cambodia relations. I am ever ready to work with Your Majesty to carry forward the traditional friendship between China and Cambodia and continuously enrich the China-Cambodia diamond cooperation framework with six priority areas with a view to advancing the building of an all-weather China-Cambodia community with a shared future in the new era and bringing more benefits to our two peoples.

I am looking forward to Your Majesty's presence at the commemorative events marking the 80th anniversary of the victory in the Chinese People's War of Resistance Against Japanese Aggression and the World Anti-Fascist War. Your Majesties are most welcome to visit China at any time.

May Your Majesties enjoy good health and continuous success.

XI Jinping(Signed)
President of the People's Republic of China

ព្រះរាជាណាចក្រកម្ពុជា
ROYAUME DU CAMBODGE

ព្រះបរមរាជាំង
លេខ :៤៤៩ រ.រ. របក
/៦៥

សូមព្រះបរមរាជានុញ្ញាត ក្រាបបង្គំទូលថ្វាយ
សម្តេចព្រះមហាក្សត្រី ព្រះឥរាជមាតាជាតិខ្មែរ
នៃព្រះរាជាណាចក្រកម្ពុជា ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត

សូមព្រះតេជៈតម្កល់លើត្បូង

ទូលព្រះបង្គំជាខ្ញុំ សូមព្រះបរមរាជានុញ្ញាត ក្រាបបង្គំទូលថ្វាយ **សម្តេចព្រះមហាក្សត្រី ព្រះឥរាជមាតាជាតិខ្មែរ** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត សូមព្រះមេត្តាទ្រង់ជ្រាបក្រោមល្អងធូលីព្រះបាទ ។

យោងតាមព្រះរាជតម្រិះដ៏ខ្ពង់ខ្ពស់ របស់ **សម្តេចព្រះមហាក្សត្រី ព្រះឥរាជមាតាជាតិខ្មែរ** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត នៅព្រឹកថ្ងៃទី ៦-៧ ខែសីហា ឆ្នាំ២០២៥ ទូលព្រះបង្គំជាខ្ញុំ និងអ្នកឧកញ៉ាភក្តីព្រះស្តេចហេង គឹមគុណ នាយកធម្មការ-សាសនា និងក្រុមបាគូ ព្រមទាំងថ្នាក់ដឹកនាំក្រសួងព្រះបរមរាជវាំង បានរៀបចំប្រារព្ធពិធីបួងសួង **សូមសុខសន្តិភាពជូនព្រះរាជាណាចក្រកម្ពុជា** នៅតាមទីសក្ការដ្ឋាននានា សូមក្រាបបង្គំទូលថ្វាយដូចខាងក្រោម ៖

១- ព្រះអង្គដងកើ នៅខាងមុខព្រះបរមរាជវាំង
២- **ព្រះបរមរូប ព្រះករុណាព្រះបាទសម្តេច ព្រះនរោត្តម សីហនុ** (សេៈសៈ) ក្នុងបរិវេណព្រះវិហារព្រះកែវមរកត ព្រះបរមរាជវាំង
៣- ព្រះអង្គធំចូលបរិនិព្វាន នៅលើខ្នងភ្នំគូលែន ខេត្តសៀមរាប
៤- ព្រះអង្គគោកធ្លក នៅអភិរក្សដ្ឋានអង្គរ ខេត្តសៀមរាប
៥- ព្រះអង្គចេក-ព្រះអង្គចម, លោកយាយទេព និងរូបសំណាកមេទ័ពទាំង១២ នៅមុខព្រះរាជដំណាក់ នៃខេត្តសៀមរាប ។

នៅក្នុងឱកាសប្រារព្ធពិធីបួងសួងទាំងពីរថ្ងៃខាងលើ ជាកិច្ចចាប់ផ្តើមប្រារព្ធពិធី នៅតាមទីកន្លែងនីមួយៗ ទូលព្រះបង្គំជាខ្ញុំ បានថ្វាយគ្រឿងសក្ការបូជា តាមទីសក្ការដ្ឋាននានា ទាំងនៅក្នុងរាជធានីភ្នំពេញ និងទាំងនៅខេត្តសៀមរាប។

ជាកិច្ចបន្តនៃកម្មវិធីបួងសួងទាំងពីរថ្ងៃ អ្នកឧកញ៉ាភក្តីព្រះស្តេចហេង គឹមគុណ នាយកធម្មការ-សាសនា និងលោកអាចារ្យ បានសូត្រប្រកាសឧទ្ទិសបួងសួងទៅដល់ដួងព្រះវិញ្ញាណក្ខន្ធអតីត ព្រះករុណាព្រះមហាក្សត្រាធិរាជ សម្តេចព្រះមហាក្សត្រីយានី សម្តេចព្រះវររាជនីគ្រប់ៗព្រះអង្គ និងដួងវិញ្ញាណក្ខន្ធ នៃទសបារមីគ្រប់ៗព្រះអង្គ ព្រមទាំងដួងវិញ្ញាណក្ខន្ធបារមីមេទ័ពខ្មែរដែលខ្លាំងក្លាពូកែចេះចាំក្បួនតម្រាការពារទឹកដីស្រុកខ្មែរគ្រប់ទិស គ្រប់តំបន់ទោះនៅព្រៃភ្នំនិគមជនបទ សូមយាង-អញ្ជើញ មកប្រោះព្រំព្រះរាជសព្វសាធុការពរថ្វាយ **ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត និង **សម្តេចព្រះមហាក្សត្រី ព្រះឥរាជមាតាជាតិខ្មែរ** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត សូមទ្រង់គង់ នៅជាព្រះបរមសុខក្សេមក្សាន្ត ព្រះកាយពលមាំមួន ឫទ្ធិសិទ្ធិស័ក្តិ សូមស្តេចមានព្រះជន្មវស្សាយឺនយូរ គង់ក្នុងព្រះបរមសិរីរាជសម្បត្តិបិតបៀរចីរកាលតរៀងទៅ ដើម្បីគង់ជាមហាម្លប់ដ៏ត្រជាក់ត្រជំដល់បណ្តាប្រជានុរាស្ត្រ របស់ព្រះអង្គក្នុងព្រះរាជាណាចក្រកម្ពុជា តរៀងទៅ។

ដោយតេជានុភាពនៃការប្រារព្ធពិធីបួងសួងទាំងពីរថ្ងៃខាងលើនេះ សូមអតីតព្រះករុណាព្រះមហាក្សត្រាធិរាជ សម្តេចព្រះមហាក្សត្រីយានី គ្រប់ៗព្រះអង្គ ប្រទានពរសព្វសារធុការជូនដល់ថ្នាក់ដឹកនាំស្ថាប័នកំពូលទាំង៣របស់ជាតិ មាន **ព្រឹទ្ធសភា រដ្ឋសភា និងរាជរដ្ឋាភិបាល** ជាពិសេស សូមប្រទានពរជ័យជូនដល់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយឧត្តមសេនីយ៍ផុតលេខផ្កាយមាស៥ ជាប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា ជាប្រធានក្រុមឧត្តមប្រឹក្សាផ្ទាល់ **ព្រះមហាក្សត្រ** ដែលជាថ្នាក់ដឹកនាំកំពូលជាតិដ៏ឆ្នើមប៉ិនប្រសព្វប្រកបដោយទេពកោសល្យដ៏ឧត្តុង្គឧត្តម និងសូមប្រទានពរជ័យជូនដល់ សម្តេចមហាបវរធិបតី

ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដែលជាថ្នាក់ដឹកនាំកំពូលជាតិដ៏ឆ្នើម នៃព្រះរាជាណាចក្រកម្ពុជា សូមបានសេចក្តីសុខសេចក្តីចម្រើន នឹងទទួលបានជោគជ័យគ្រប់ភារកិច្ចដឹកនាំទាំងអស់ជូនជាតិមាតុភូមិ និងសូមបានឈ្នះអស់លើសត្រូវឈ្លានពានសៀម លើគ្រប់សមរភូមិប្រយុទ្ធជួរមុខតាម បណ្តោយព្រំដែន និងសូមបានឈ្នះអស់ទាំងសមរភូមិនយោបាយ ការទូត ឈ្នះអស់ទាំងសមរភូមិផ្លូវច្បាប់ លើឆាកអន្តរជាតិ ព្រមទាំងឈ្នះអស់ក្នុងសឹកសង្គ្រាមពីបច្ចាមិត្ត ផងដែរ ។

ដោយតេជានុភាពនៃការថ្វាយដង្ហាយនេះ សូមអតីតព្រះករុណាព្រះមហាក្សត្រាធិរាជ សម្តេចព្រះមហាក្សត្រីយានីគ្រប់ៗព្រះអង្គ ប្រទានសព្វសាធុការពរដល់ព្រះរាជាណាចក្រកម្ពុជា អោយទទួលបានសេចក្តីសុខ សេចក្តីចម្រើន និងសូមអោយសត្រូវឈ្លានពានសៀមទាំងនោះ ដល់នៅក្តីបាក់បបខ្លបខ្លាច និងបរាំសរាំសចេញឆ្ងាយពីទឹកដីព្រះរាជាណាចក្រកម្ពុជា ចាប់តាំងពីពេលនេះតរៀងទៅ ។

ការប្រារព្ធពិធីបួងសួងនៅរាជធានីភ្នំពេញ ថ្នាក់ដឹកនាំ-មន្ត្រីព្រះរាជខុទ្ទកាល័យ បានអញ្ជើញចូលរួម និងការប្រារព្ធពិធីបួងសួងនៅខេត្តសៀមរាប ឯកឧត្តមអគ្គនាយកអាជ្ញាធរជាតិអប្សរា និងឯកឧត្តមអភិបាលរងខេត្តសៀមរាប បានអញ្ជើញចូលរួម។

ក្នុងកិច្ចប្រារព្ធពិធីបួងសួងខាងលើ បានរៀបចំក្រុមរាំព្រះរាជទ្រព្យសម្តែងថ្វាយ នៅមុខ**ព្រះបរមរូបព្រះករុណាព្រះបាទសម្តេចព្រះនរោត្តម គង់ឆើអស្ងារ៉ា** (សេៈស) និងក្រុមភ្លេងពិណពាទ្យប្រគំថ្វាយតាមទីសក្ការដ្ឋាននីមួយៗ ផងដែរ ។

<u>សូមព្រះបរមរាជានុញ្ញាតថ្វាយភ្ជាប់មកជាមួយនូវ</u> : រូបថត ស្តីអំពីការរៀបចំពិធីបួងសួងខាងលើ ។

ទូលព្រះបង្គំជាខ្ញុំ សូមព្រះបរមរាជានុញ្ញាត **សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត សូមព្រះមេត្តាជ្រាប តាមសព្វព្រះរាជហឫទ័យដ៏ខ្ពង់ខ្ពស់បំផុត ។

សេចក្តីគួរពុំគួរ សូមព្រះមេត្តាព្រោសព្រះរាជទានទោស។
សូមក្រាបបង្គំទូលថ្វាយ នៅព្រះបរមរាជវាំង ថ្ងៃទី ០៨ ខែ សីហា ឆ្នាំ២០២៥
ក្រោមល្អងធូលីព្រះបាទ

ទូលព្រះបង្គំជាខ្ញុំ គុយ សុផល

អំពីការរៀបចំពិធីបួងសួង
សូមសុខសន្តិភាពជូនព្រះរាជាណាចក្រកម្ពុជា
នៅក្នុងរាជធានីភ្នំពេញ នាព្រឹកថ្ងៃទី ០៦ ខែសីហា ឆ្នាំ២០២៥

- ទីសក្ការដ្ឋានព្រះអង្គដងកើ









- ព្រះបរមរូប ព្រះករុណាព្រះបាទសម្តេចព្រះនរោត្តម គង់លើអស្វរាជ (សេះស)



















អំពីការរៀបចំពិធីបួងសួង **សូមសុខសន្តិភាពជូន**
ព្រះរាជាណាចក្រកម្ពុជា នៅតាមទីសក្ការដ្ឋាន ចំនួន ៥ កន្លែង ស្ថិតក្នុងខេត្តសៀមរាប
នៅថ្ងៃទី៧ ខែសីហា ឆ្នាំ២០២៥

១- ទីសក្ការដ្ឋានព្រះអង្គធំនៅលើភ្នំគូលែន















២- ទីសក្ការដ្ឋានព្រះអង្គគោកធ្លក












៣- ទីសក្ការដ្ឋានព្រះអង្គចេកព្រះអង្គចម








៤- ទីសក្ការដ្ឋានលោកយាយទេព





៥- ទីសក្ការដ្ឋានរូបសំណាកមេទ័ព នៅខាងមុខព្រះរាជដំណាក់ខេត្តសៀមរាប


















រោយការណ៍សកម្មភាពចុះចែកអំណោយ

រោយការណ៍សកម្មភាពចុះចែកអំណោយ

ពីខែមិថុនា ដល់ខែកក្កដា ឆ្នាំ២០២៥

សកម្មភាពសម្រេចបាន

- ថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០២៥ **សម្តេចក្រុមព្រះ នរោត្តម ច័ន្ទ្រពង្ស** ប្រទានសម្លៀកបំពាក់ និងសម្ភារៈផ្សេងៗសម្រាប់ចែកជូនដល់ក្រុមនិស្សិត២០០នាក់នៃសាកលវិទ្យាល័យបញ្ញាសាស្ត្រ ដែលបានមកចូលរួមក្នុងកម្មវិធី **ស្ថាបប៉ាកការឧុស្សាហ៍យ៍លើកទី២** រៀបចំដោយក្រុមដំណើរខ្មែរ នារោងកាពយន្ត លេជេន អូឡាំព្យ៉ា រាជធានីភ្នំពេញ។

- ថ្ងៃអាទិត្យ ទី២០ ខែមិថុនា ឆ្នាំ២០២៥ **សម្តេចក្រុមព្រះ នរោត្តម ច័ន្ទ្រពង្ស** ប្រទានថវិកា១លានរៀលសម្រាប់ឧបត្ថម្ភដល់ការបោះពុម្ពសៀវភៅ វេជនខ្មែរ (ភាគ១) ជាឯកសារស្រាវជ្រាវ និងរៀបរៀងដោយ **លោក ទីរៈ ដាំរ៉ានី** ប្រធានក្រុមដំណើរខ្មែរ និងជាសមាជិកមូលនិធិ។

- វេលាព្រឹកថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០២៥ **សម្តេចក្រុមព្រះ នរោត្តម ច័ន្ទ្រពង្ស** ព្រះប្រធានមូលនិធិ ស្តេចយាងជាព្រះអធិបតីដោយផ្ទាល់ ក្នុងកម្មវិធីមូលនិធិសប្បុរសធម៌ “**រួមគ្នាដើម្បី ១00 គ្រួសារ**” ជាមួយ **សាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា** និងដៃគូសហការជាច្រើន បាននាំយកនូវគ្រឿងឧបភោគបរិភោគ សម្ភារៈប្រើប្រាស់ ព្រមទាំងថវិកាទៅជូនពុកម៉ែបងប្អូន លោកយាយលោកតាដែលចាស់ជរា មានជីវភាពខ្វះខាតចំនួន១00គ្រួសារ នាវត្តកាត់ភ្លុក ភូមិកាត់ភ្លុក ឃុំកាត់ភ្លុក ស្រុកបរសេដ្ឋ ខេត្តកំពង់ស្ពឺ។

- វេលាព្រឹកថ្ងៃពុធ ទី១៦ ខែកក្កដា ឆ្នាំ២០២៥ **សម្តេចក្រុមព្រះ នរោត្តម ច័ន្ទ្រពង្ស** ស្តេចយាងជាព្រះអធិបតីដោយផ្ទាល់ប្រទាននូវព្រះអំណោយដល់គ្រួសារក្រីក្រចំនួន៣៥គ្រួសារ ដែលមានជីវភាពក្រីក្រស្រស់នៅតំបន់ស្ទឹងមានជ័យ ក្នុង**វត្តនន្ទមុនី ធម្មមណ្ឌលវិបស្សនាធុរៈនៃកម្ពុជា** ស្ថិតនៅភូមិដំណាក់ធំ១ សង្កាត់ស្ទឹងមានជ័យ២ ខណ្ឌមានជ័យ រាជធានីភ្នំពេញ។

- នៅថ្ងៃសុក្រ ទី២៥ ខែកក្កដា ឆ្នាំ២០២៥ **សម្តេចក្រុមព្រះ នរោត្តម ច័ន្ទ្រពង្ស** ឧត្តមក្រុមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ និងជាព្រះប្រធានមូលនិធិ បានប្រោសប្រទានសារុងចំនួន ២00 និងខោអាវប្រុសស្រីចំនួន២00 ដល់ **លោក ទីរៈ ដាំរ៉ានី** សមាជិកមូលនិធិបាននាំយកព្រះអំណោយទៅចែកជូនប្រជាជនកៀសសឹក ពីតំបន់សមរភូមិនៅតាមបណ្តាយព្រំដែនខ្មែរ-ថៃ។

- ពីថ្ងៃ២៦ ដល់ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០២៥ **លោក ទីរៈ ដាំរ៉ានី** សមាជិកមូលនិធិ បានដឹកនាំសមាជិកសមាជិកានៃ **មូលនិធិសម្តេចក្រុមព្រះ នរោត្តម ច័ន្ទ្រពង្ស** ចុះចែកអំណោយមូលនិធិនៅតាមជំរំជនកៀសសឹកក្នុងទឹកដីខេត្តឧត្តរមានជ័យ និងខេត្តសៀមរាប។

ព្រះសកម្មភាពនៃកម្មវិធីមូលនិធិសប្បុរសធម៌ "រួមគ្នាដើម្បី ១០០ គ្រួសារ"






ព្រះសកម្មភាព ប្រទានព្រះអំណោយដល់គ្រួសារក្រីក្រនាតំបន់ស្នឹងមានជ័យ






ជូនអំណោយដល់បងប្អូនជនកៀសសឹក













Correspondance d'État

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សូមក្រាបបង្គំទូលថ្វាយជ័យ
សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ
ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល

សម្តេចព្រះមហាក្សត្រី ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត !

ទូលព្រះបង្គំជាខ្ញុំ និងភរិយា ព្រមទាំងក្រុមគ្រួសារ និងបងប្រុស សូមព្រះបរមរាជានុញ្ញាតក្រាបថ្វាយបង្គំ **សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត** ដើម្បីទូលថ្វាយនូវអំណោយជាសារុងឥណ្ឌូនេស៊ីទំហំទទឹង ១.០៥ ម៉ែត្រ និងបណ្តោយ ១.៧០ ម៉ែត្រ ចំនួន ១,០០០ សារុង ទូលព្រះបង្គំយើងខ្ញុំសូមថ្វាយជូន **សម្តេចព្រះមហាក្សត្រី** ជាជង្វាយសម្រាប់ប្រើប្រាស់តាមព្រះអង្គសព្វព្រះរាជហរទ័យ។

ទូលព្រះបង្គំយើងខ្ញុំទាំងអស់គ្នា សូមលើកហត្ថប្រណមឧទ្ទិសបួងសួងដល់គុណបុណ្យព្រះរតនត្រ័យ វត្ថុស័ក្តិសិទ្ធិទាំងឡាយក្នុងលោក សូមតាមបីបាច់ថែរក្សា និងប្រោសប្រទានព្រះរាជសព្វសាធុការពរគ្រប់ប្រការ ថ្វាយ **សម្តេចព្រះមហាក្សត្រី** សូមព្រះអង្គទ្រង់ប្រកបដោយព្រះពុទ្ធពរទាំងបួនប្រការ គឺ **អាយុ វណ្ណៈ សុខៈ ពលៈ** ជានិច្ចនិរន្តន៍តរៀងទៅ។

សូម **សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត** ទ្រង់ព្រះមេត្តាទទួលនូវការគោរពសក្ការៈយ៉ាងជ្រាលជ្រៅពីទូលព្រះបង្គំជាខ្ញុំ **ឌុក ឌៀន** និងភរិយា **ណាវ ឌុក** ព្រមទាំងក្រុមគ្រួសារ និងបងប្រុស **ឌុក ឌីន**។

ក្រាបបង្គំទូលថ្វាយ ថ្ងៃសៅរ៍ ៨រោច ខែជេស្ឋ ឆ្នាំម្សាញ់ សប្តស័ក ពុទ្ធសករាជ ២៥៦៩
ត្រូវនឹងថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០២៥

ទូលព្រះបង្គំជាខ្ញុំ

ឌុក ឌៀន

សូមក្រាបថ្វាយបង្គំ

សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ

ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល

ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត

ក្នុងឱកាសដ៏មហានក្ខត្តឫក្សនៃព្រះរាជពិធីបុណ្យចម្រើនព្រះជន្ម សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរនិងសុភមង្គល ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត នៅថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០២៥ គម្រប់៨៩ព្រះវស្សា ឯងចូល៩០ព្រះវស្សា។ ខ្ញុំម្ចាស់សូមលើកហត្ថាថ្វាយបង្គំបួងសួងដល់គុណបុណ្យព្រះរតនត្រ័យ ទេវតាថែរក្សាព្រះរាជាណាចក្រកម្ពុជា ទេវតាថែរក្សាព្រះមហាស្វេតច្ឆត្រ ទេវតាឆ្នាំម្សាញ់សប្តស័ក ព្រះបារមីអតីតព្រះមហាក្សត្រព្រះមហាក្សត្រីឯានីខ្មែរគ្រប់ព្រះអង្គជាពិសេសព្រះវិញ្ញាណក្ខ័ន្ធ ព្រះករុណាព្រះបាទសម្តេច ព្រះនរោត្តម សីហនុ ព្រះមហាវីរក្សត្រ ព្រះវររាជបិតាឯករាជ្យ បូរណភាពទឹកដីនិងឯកភាពជាតិខ្មែរ ព្រះបរមរតនកោដ្ឋ សូមព្រះអង្គ ប្រទានព្រះពរជ័យបវរ សួស្តីមហាប្រសើរថ្វាយព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត សូមព្រះអង្គប្រកបដោយព្រះរាជសុខភាពល្អ ប្រាស់ចាកព្រះរោគាព្យាធិផងទាំងពួង ព្រះកាយពលមាំមួន ព្រះបញ្ញាញាណភ្លឺថ្លា ព្រះជន្មាយុយឺនយូរ គង់ប្រថាប់ជាម្លប់ដ៏ត្រជាក់ដល់ប្រជារាស្ត្រខ្មែរជាកូន ជាចៅ ចៅទួតព្រះអង្គជ្រកកោនជានិច្ចនិរន្តរ៍តរៀងទៅ។

សូមក្រាបបង្គំទូលថ្វាយប៉ារីស ថ្ងៃ១៤ ខែមិថុនា ឆ្នាំ២០២៥

ខ្ញុំម្ចាស់សូមក្រាបថ្វាយបង្គំក្រោមល្អងធូលីព្រះបាទ

សរ សាវ៉ឹត



ជាតិ សាសនា ព្រះមហាក្សត្រ

ឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ

សូមក្រាបបង្គំទូលថ្វាយ
សម្តេចព្រះមហាក្សត្រី ***នរោត្តម មុនិនាថ សីហនុ***
ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុកមង្គល
ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត

បពិត្រក្រាបបង្គំទូល ***សម្តេចព្រះមហាក្សត្រី*** *ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត*

ទូលព្រះបង្គំ ជាខ្ញុំសូមព្រះរាជានុញ្ញាត សូមក្រាបបង្គំអរព្រះគុណដ៏ជ្រាលជ្រៅដោយមានការរំកើបនិងរីករាយបំផុត ដែល ***សម្តេចព្រះមហាក្សត្រី*** *ជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុតបានព្រះរាជទានសៀវភៅ* ***«ព្រះរាជពិធីខួបទី ២០ នៃការគ្រងព្រះបរមសិរីរាជសម្បត្តិ ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ជាអម្ចាស់ជីវិតលើត្បូង»*** *ជាទីគោរពសក្ការៈ និងស្រលាញ់ដ៏ខ្ពង់ខ្ពស់បំផុត ជល់ទូលព្រះបង្គំ និងភរិយា (ជាខ្ញុំបំរើរបហាជានិយមតាំងពីដំនាន់សង្គមរាស្ត្រនិយម ជាពិសេស ដោយលាឈប់ពីការងារស្តីទីនៅប្រទេសបារាំង ដើម្បីចូលរួមរណសិរ្ញរួបរួមជាតិកម្ពុជា(FUNK) នៅប៉េកាំង របស់ **ព្រះបរមរតនកោដ្ឋ ព្រះករុណាព្រះបាទសម្តេចព្រះនរោត្តមសីហនុ** អស់រយៈពេល៥ឆ្នាំ១៩៧០-១៩៧៥ ក្រោយពីផ្ដួលរំលំ នល់ ថ្ងៃ១៨ ខែមីនា ឆ្នាំ១៩៧០)។*

ទូលព្រះបង្គំជាខ្ញុំ និងភរិយាសូមព្រះបរមរាជានុញ្ញាតអភិវន្ទន៍ខ្ញុំនកាយវាចាចិត្តក្រាបបង្គំ សម្តែងនូវសេចក្តីអំណរសោទរដោយស្មោះត្រង់បំផុតអស់ពីដួងចិត្ត និងសូមសម្តែងថ្វាយនូវកតញ្ញុតា និងកតិវេទិតាធម៌ដ៏ជ្រាលជ្រៅបំផុត ក្នុងមនោសញ្ចេតនាសោមនស្សរីករាយបំផុតថ្វាយ ***ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង*** *ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ក្នុងការគ្រោងព្រះបរមសិរីរាជសម្បត្តិក្នុងរយៈពេលជាង២០ឆ្នាំកន្លងមក នៃព្រះរាជសកម្មភាពដ៏ឧត្តុង្គឧត្តមប្រកបដោយទសពិធរាជធម៌ និងព្រះព្រហ្មវិហារធម៌ដ៏ទូលំទូលាយចំពោះប្រជារាស្ត្រទូទាំងប្រទេស និង ព្រះរាជអគ្គមគ្គុទ្ទេសក៍ដ៏វិសេសវិសាលថ្លៃថ្លាបំផុត នាំមកនូវសុខសន្តិភាព ឯកភាពជាតិ បូរណ៍ភាពទឹកដី កិត្យានុភាពជាតិ និងការអភិវឌ្ឍប្រទេសកម្ពុជា ឆ្ពោះទៅរកភាពសម្បូរសប្បាយថ្កុំថ្កើនរុងរឿងជារៀងរាល់ថ្ងៃ។*

សៀវភៅ ***«ព្រះរាជពិធីខួបទី ២០ នៃការគ្រងព្រះបរមសិរីរាជសម្បត្តិ ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ជាអម្ចាស់ជីវិតលើត្បូង»*** *ពិតជាបានឆ្លុះបញ្ចាំងអំពីស្នាព្រះហស្ត និងការបូជាកំលាំងព្រះកាយ-ចិត្ត និងព្រះបញ្ញាញាណ គ្រប់គ្រងមាតុភូមិកម្ពុជាដ៏រុងរឿង ព្រមទាំងបន្តនូវព្រះរាជប្រពៃណី និងស្នាព្រះហស្តរុងរឿង ពីព្រះបរមរតនកោដ្ឋក្នុងអតីតកាលដ៏ថ្កើងថ្កានឱ្យបានស្ថិតស្ថេរគង់វង្សជានិច្ចនិរន្តរ៍។ ឆ្លៀតក្នុងឱកាសដ៏វិសេសវិសាល សិរីសួស្តី ជ័យមង្គល ប្រពៃថ្លៃថ្នូរបំផុត ទូលព្រះបង្គំ និងភរិយា សូមព្រះបរមាជានុញ្ញាតដ៏ខ្ពង់ខ្ពស់បំផុត លំឱនកាយក្រាបបង្គំថ្វាយព្រះរាជសព្ទសាធុការពរជ័យបវរមហាប្រសើរ និងសូមលើកហត្ថប្រណមអញ្ជលីសបួងសួងដល់គុណបុណ្យព្រះរតនត្រៃយ៍ ព្រះទសបរមីទេព្តារក្សាព្រះមហាស្វេតច្ឆត្រ វត្ថុស័ក្តិសិទ្ធក្នុងលោក ព្រះឫទ្ធានុភាពបារមីនៃព្រះវិញ្ញាណក្ខ័ន្ធអតីតព្រះមហាក្សត្រ ព្រះមហាក្សត្រីយានីគ្រប់ព្រះអង្គ ជាពិសេសព្រះវិញ្ញាណក្ខ័ន្ធ* ***ព្រះបរមរតនកោដ្ឋ*** *សូមជួយតាមថែរក្សាការពារ ប្រោសប្រទានពរជ័យ* ***ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង*** *ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ប្រកបដោយសិរីមង្គល វិបុលសុខមហាប្រសើរ មានព្រះតេជៈបារមី ពលានុភាពខ្លាំងក្លា ព្រះរាជសុខភាពល្អបរិបូរណ៌ ព្រះកាយពលំមាំមួន ព្រះជន្មាយុយឺនយូរជាងរយព្រះវស្សា និងព្រះរាជបញ្ញាញាណវាងវៃ ទទួលបាននូវមហាជោគជ័យដ៏ត្រចះត្រចង់ ក្នុងព្រះរាជកិច្ចដ៏ឧត្តុង្គឧត្តមជានិមិត្តរូបនៃឯកភាពជាតិ និងនិរន្តរភាពជាតិ គង់ប្រថាប់ក្នុងព្រះបរមសិរីរាជសម្បត្តិជានិច្ចនិរន្តរ៍ ដើម្បីជាម្លប់ដ៏ត្រជាក់ត្រជុំ និងសេចក្តីសុខក្សេមក្សាន្ត សម្បូរសប្បាយថ្កុំថ្កើងរុងរឿងនៃកូនចៅប្រជានុរាស្ត្រទូទាំងព្រះរាជាណាចក្រកម្ពុជាជារៀងរហូត។*

ទូលព្រះបង្គំជាខ្ញុំ និងភរិយា សូម ***សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ*** *ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត សូម* ***ព្រះអង្គ*** *ទ្រង់ប្រកបដោយព្រះរាជសុខភាពល្អបរិបូរណ៌ ព្រះកាយពលរឹងមាំ ព្រះបញ្ញាញាណក្តឹងក្តាន់ ព្រះជន្មាយុយឺនយូរជាងរយព្រះវស្សាជានិច្ចនិរន្តរ៍តរៀងទៅ។*

សូម ***សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ*** *ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ទ្រង់ព្រះមេត្តាប្រោសទទួលនូវអភិវន្ទកិច្ចដ៏ខ្ពង់ខ្ពស់បំផុតអំពី [illegible]*

[illegible]

ថ្ងៃសុក្រ ១៣កើត ខែពិសាខ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៨
សូមក្រាបបង្គំទូលថ្វាយ នៅរាជធានីភ្នំពេញ ថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០២៥

អ៊ិត្តិបរិក្សបណ្ឌិត ហោ ណាំហុង ***អ៊ូ ហោ***

Sa Majesté la Reine-Mère
NORODOM Monineath-Sihanouk du Cambodge

Maman très vénérée et très bien aimée,

A l'occasion de l'anniversaire de Maman très vénérée et très bien aimée, le 18 juin, l'ensemble de ma famille se joint à moi pour présenter humblement nos très respectueux et très affectueux vœux de santé, de bonheur et de longévité à Maman très vénérée et très bien aimée.

Comme l'immense majorité de nos compatriotes, je formule le vœu que Maman très vénérée et très bien aimée, témoin de l'histoire et figure tutélaire de la Nation, étende pour de nombreuses années encombre Son ombre protectrice sur le Royaume.

Je saisis enfin cette occasion pour exprimer ma très déférente et très profonde reconnaissance à Maman très vénérée et très bien aimée pour Sa haute bienveillance et Sa très grande générosité à mon humble endroit.

Daigne Maman très vénérée et très bien aimée recevoir l'expression renouvelée de mes vœux les plus déférents et les plus affectueux,

Avec mes Très profonds
et Très Affectueux Respects

NORODOM Chakrapong

Phnom Penh, le 13 juin 2025

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សារលិខិតថ្វាយព្រះពរ
សូមក្រាបបង្គំទូលថ្វាយ
សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ
ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត
ក្នុងឱកាសព្រះរាជពិធីបុណ្យចម្រើនព្រះជន្ម

សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត !

ក្នុងឱកាសដ៏មហានក្ខត្តឫក្ស ជាវេលាដ៏ល្អតែមួយក្នុងខែមិថុនា ដែលប្រជារាស្ត្រទូទាំងព្រះរាជាណាចក្រកម្ពុជាប្រារព្ធព្រះរាជពិធីបុណ្យចម្រើនព្រះជន្មគម្រប់៨៩ យាងចូល៩០ព្រះវស្សា ថ្វាយ**សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ទូលព្រះបង្គំជាខ្ញុំនិងភរិយា សូមព្រះបរមាជានុញ្ញាតដ៏ខ្ពង់ខ្ពស់សម្តែងអំណរសាទរ និងសូមគោរពថ្វាយនូវព្រះរាជសព្ទសាធុការពរជ័យ បវរសួស្តី សិរីមង្គល វិបុលសុខមហាប្រសើរគ្រប់ប្រការ ថ្វាយ**សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត សូមព្រះអង្គសមប្រកបដោយព្រះរាជបញ្ញាញាណក្លឹងក្លា ព្រះកាយពលមាំមួន ព្រះរាជសុខភាពល្អបរិបូណ៌ និងព្រះជន្មាយុយឺនយូរ ដើម្បីគង់ប្រថាប់ជាម្លប់ដ៏ត្រជាក់ត្រជំដល់ប្រជារាស្ត្រខ្មែរទូទាំងព្រះរាជាណាចក្រកម្ពុជា។

ក្នុងវេលាដ៏មហានក្ខត្តឫក្សនេះ ទូលព្រះបង្គំជាខ្ញុំនិងភរិយា សូមលំនិនកាយសម្តែងនូវអភិវន្ទន៍កិច្ច និងកតញ្ញូតាធម៌ដ៏ជ្រាលជ្រៅថ្វាយ **សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ដែលជានិច្চកាលព្រះអង្គតែងគង់ប្រថាប់ជាព្រះនិមិត្តរូបដ៏សិរីដ្ឋ នៃឧត្តមានុភាពស្ត្រីនៅក្នុងសង្គមកម្ពុជា។ ក្នុងព្រះរាជតួនាទីដ៏ឧត្តុង្គឧត្តមជាព្រះប្រធានកិត្តិយសនៃ "ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី" ព្រះអង្គតែងយកព្រះទ័យទុកដាក់លើកស្ទួយនូវសិទ្ធិ គុណតម្លៃ សីលធម៌ សេចក្តីថ្លៃថ្នូរ និងការចូលរួមរបស់ស្ត្រីលើគ្រប់វិស័យរបស់សង្គម នាំមកភាពសុខដុមរមនា និងសេចក្តីសុខក្សេមក្សាន្តក្នុងសង្គមជាតិ។

នាឱកាសដ៏វិសេសវិសាលថ្លៃថ្លានេះ ទូលព្រះបង្គំជាខ្ញុំនិងភរិយា សូមព្រះបរមាជានុញ្ញាតលើកហត្ថប្រណម្យបួងសួងដល់ទេវតាថែរក្សាទឹកដីនៃព្រះរាជាណាចក្រកម្ពុជា គុណបុណ្យព្រះរតនត្រ័យ និងវត្ថុស័ក្តិសិទ្ធិទាំងឡាយក្នុងលោក ជាពិសេសបុណ្យបារមីនៃដួងព្រះវិញ្ញាណក្ខន្ធ ព្រះករុណាព្រះបរមរតនកោដ្ឋ សូមព្រះអង្គតាមជួយបីបាច់ថែរក្សាការពារ និងប្រោះព្រំ **សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ព្រមទាំងព្រះរាជវង្សានុវង្ស សូមទ្រង់ប្រកបដោយព្រះពុទ្ធពរទាំងបួនប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

សូម **សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត** ព្រះមេត្តាទទួលនូវគារវកថាដ៏ខ្ពង់ខ្ពស់បំផុតពីទូលព្រះបង្គំជាខ្ញុំនិងភរិយា។

ថ្ងៃចន្ទ ៦រោច ខែជេស្ឋ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
ក្រាបបង្គំទូលថ្វាយនៅរាជធានីភ្នំពេញ ថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២៥
ឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ

សម្តេចពិជ័យសេនា ទៀ បាញ់

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សារថ្វាយព្រះពរ

សូមក្រាបបង្គំទូលថ្វាយសម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ
ព្រះឥរាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល

សម្តេចព្រះមហាក្សត្រី ជាទីសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត !

ក្នុងឱកាសដ៏មហាឧត្តុង្គឧត្តមបំផុតនិងមហាប្រសើរថ្លៃថ្លាប្រកបដោយអត្ថន័យជ្រាលជ្រៅបំផុតនៃព្រះរាជពិធីបុណ្យចម្រើនព្រះជន្មវស្សារបស់ **សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះឥរាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និង សុភមង្គល** ទូលព្រះបង្គំជាខ្ញុំ និងខ្ញុំស្រី **ឡាយ នារី គាត ឈន់** រួមជាមួយក្នុនស្រី **ឈន់ កុឡាបឃុន្ន** ព្រមទាំងមន្ត្រីរាជការក្រោមឱវាទ សូមព្រះបរមរាជានុញ្ញាតក្រាបបង្គំទូលថ្វាយនូវព្រះពរសព្ទសាធុការ ដ៏មហាបវរប្រសើរថ្លៃថ្លាបំផុតជាមួយ នឹងមនោសញ្ចេតនាគោរពដ៏ខ្ពង់ខ្ពស់បំផុត និងទឹកចិត្តស្រឡាញ់យ៉ាងជ្រាលជ្រៅបំផុតចំពោះ **សម្តេចព្រះមហាក្សត្រី**។ សូម **សម្តេចព្រះមហាក្សត្រី** ទ្រង់ប្រកបដោយព្រះសុខភាពល្អបរិបូរណ៌ជាភិយ្យោភាព មានព្រះជន្មាយុយឺនយូរជាងរយព្រះវស្សា ព្រះកាយពលមាំមួនខ្លាំងក្លា ព្រះបញ្ញាញាណ វៃឈ្លាសភ្លឺថ្លា ព្រមទាំងសម្រេចបានមហាជោគជ័យក្នុងព្រះរាជបេសកកម្មជាតិ ជាប្រវត្តិសាស្ត្រ និងតង់ជាម្លប់ដ៏ត្រជាក់ត្រជុំសម្រាប់ប្រជាជនកម្ពុជាទាំងមូលជានិច្ចនិរន្តរ៍ ។

ឆ្លៀតឱកាសដ៏មហានក្ខត្តឫក្សនេះ ទូលព្រះបង្គំយើងខ្ញុំ សូមសម្តែងនូវកតវេទិតា និងកតញ្ញូតាធម៌ដ៏ជ្រាលជ្រៅបំផុត ចំពោះព្រះមហាករុណាទីឃគុណដ៏ថ្លៃថ្លាទាំងឡាយរបស់ **សម្តេចព្រះមហាក្សត្រី** ដែលព្រះអង្គតែងតែយកព្រះរាជហឫទ័យទុកដាក់ព្រះរាជតំរិះគិតគូរឈឺឆ្អាលដល់សុខទុក្ខដល់កូន ចៅ ចៅទួត ចៅលួត ចៅលា របស់ព្រះអង្គ ជាពិសេស ព្រះរាជបេសកកម្មជាតិដ៏ឧត្តុង្គឧត្តម សម្រាប់សុខុមាលភាពរបស់ប្រជាជនកម្ពុជា និងសម្រាប់កិត្យានុភាពនៃព្រះរាជាណាចក្រកម្ពុជា។

ជាមួយកតវេទិតា និង កតញ្ញូតាធម៌ដ៏ជ្រាលជ្រៅបំផុតចំពោះ ព្រះមហាករុណាទីឃគុណដ៏ថ្លៃថ្លាទាំងឡាយនេះ ទូលព្រះបង្គំយើងខ្ញុំ សូមព្រះរាជវរោកាសថ្វាយជាថ្មី នូវទឹកចិត្តគោរពស្រឡាញ់បំផុត និង ភក្តីភាពឥតងាករេ ថ្វាយចំពោះ **សម្តេចព្រះមហាក្សត្រី** ជាទីសក្ការៈ ជាមួយអភិវន្ទនកិច្ចដ៏ខ្ពង់ខ្ពស់បំផុតរបស់ទូលព្រះបង្គំយើងខ្ញុំ

ថ្ងៃចន្ទ ៦រោច ខែជេស្ឋ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
សូមក្រាបបង្គំទូលថ្វាយនៅរាជធានីភ្នំពេញ ថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២៥
ប្រធានកិត្តិយសខ្ពង់ខ្ពស់ក្រុមប្រឹក្សាសន្តិភាពជាតិ

កិត្តិបរិរក្សបណ្ឌិត គាត ឈន់

Ambassade de France

L'Ambassadeur
N° 2025-0237729

Phnom Penh, le 13 juin 2025

Madame,

Au nom de l'ensemble du personnel de l'Ambassade de France, en mon nom et celui de mon épouse, je présente à Votre Majesté, à l'occasion de Son anniversaire, mes vœux les plus vifs de bonheur et de santé. Je forme également les vœux les plus sincères pour l'accomplissement des souhaits de Votre Majesté, pour Sa famille, pour Sa patrie et pour Son peuple.

Je suis infiniment reconnaissant à Votre Majesté d'avoir accepté que le tout nouveau lycée français international de Siem Reap porte Son nom. Le « Lycée français international Norodom Monineath Sihanouk » est un hommage rendu au rôle de Votre Majesté dans les grands moments de l'histoire du Cambodge, ainsi qu'à Son engagement en faveur du bien-être de Son peuple, et en particulier de l'éducation des jeunes Cambodgiennes. Il illustre à merveille la profondeur et la qualité des relations qui unissent nos deux pays.

Je sais l'attachement indéfectible de Votre Majesté à la langue française et, à ce titre, me réjouis que le prochain Sommet de l'Organisation internationale de la Francophonie dont Sa Majesté Feu le Roi Père fut un des fondateurs, soit accueilli par le Cambodge en 2026.

En ces moments de fête, que Votre Majesté me permette d'associer aux vœux que je formule à l'égard de Sa personne, ceux de santé et de longévité que je forme pour le Roi et Sa famille, et ceux de bonheur, de paix et de prospérité que j'adresse au peuple cambodgien.

Jacques Pellet

Sa Majesté la Reine-Mère du Cambodge
Monineath Norodom Sihanouk
Palais Royal

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ព្រឹទ្ធសភា

សារលិខិតថ្វាយព្រះពរ
សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ
ព្រះវររាជមាតាជាតិខ្មែរក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល

សម្តេចព្រះមហាក្សត្រី ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត!

ក្នុងឱកាសសិរីមង្គលមហាប្រសើរ នៃខួបចម្រើនព្រះជន្ម **សម្តេចព្រះមហាក្សត្រី** យាងចូល៩០ព្រះវស្សា ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០២៥ ទូលព្រះបង្គំជាខ្ញុំសូមព្រះរាជានុញ្ញាតលំនិនកាយ ថ្វាយព្រះពរ **សម្តេចព្រះមហាក្សត្រី** ប្រាំប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ និងបដិភាណ ដើម្បីគង់ប្រថាប់ជាម្លប់សម្រាប់ប្រទេសជាតិ និងប្រជាជាតិខ្មែរ។

ទូលព្រះបង្គំជាខ្ញុំ សូមព្រះរាជានុញ្ញាតសម្តែងនូវកតញ្ញូតាធម៌ដ៏ជ្រាលជ្រៅបំផុត ថ្វាយ **សម្តេចព្រះមហាក្សត្រី** ដែលបានលះបង់ព្រះកាយពល ព្រះបញ្ញាញាណ និងព្រះរាជទ្រព្យ ដើម្បីសន្តិភាព វឌ្ឍនភាព សេរីភាព អធិបតេយ្យភាព និងឯកភាពជាតិខ្មែរ។

សូម **សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ទ្រង់ប្រោសព្រះរាជមេត្តាទទួលនូវអភិវន្ទនកិច្ច និងភក្តីភាពដ៏ស្មោះស្ម័គ្របំផុត ពីទូលព្រះបង្គំជាខ្ញុំ និងក្រុមគ្រួសារ ព្រមទាំងសហការី។

ថ្ងៃ សុក្រ ៣រោច ខែជេស្ឋ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០២៥
អនុប្រធានទី២ ព្រឹទ្ធសភា

Vathana

ធន់ វឌ្ឍនា

Embassy of Japan

Phnom Penh, 16 June 2025

Her Majesty the Queen-Mother
NORODOM MONINEATH SIHANOUK
of Cambodia
Royal Palace, Phnom Penh

Your Majesty,

It is with the greatest pleasure that I join the people of the Kingdom of Cambodia in extending to Your Majesty my warmest felicitations on the auspicious occasion of Your Majesty's 89th Birthday Anniversary. I have the great honour to wish Your Majesty's continued good health, happiness, and longevity.

Your Majesty's unwavering kindness and generosity, and Your Majesty's dedicated service to the well-being of the Cambodian people, are widely known and deeply admired. I am also profoundly grateful for Your Majesty's invaluable contribution to the enduring friendship and cooperation between Japan and Cambodia.

Please accept, Your Majesty, the renewed assurances of my highest consideration and respect.

植野篤志

UENO Atsushi
Ambassador Extraordinary
and Plenipotentiary of Japan
to the Kingdom of Cambodia



ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ

សូមក្រាបបង្គំទូលថ្វាយ
សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ
ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល

សម្តេចព្រះវររាជមាតាជាតិខ្មែរ ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត!

ទូលព្រះបង្គំខ្ញុំម្ចាស់ ជាខ្ញុំ សូមព្រះបរមរាជានុញ្ញាត **សម្តេចព្រះមហាក្សត្រីព្រះវររាជមាតាជាតិខ្មែរ** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ក្រាបបង្គំថ្វាយនូវសៀវភៅ «នគរខ្មែរ» ដែលទើបនឹងចេញផ្សាយនាពេលថ្មីៗនេះ ដែលជាការចងក្រង ប្រែសម្រួល និងរៀបរៀងជាភាសាខ្មែរ ដោយ ទូលព្រះបង្គំខ្ញុំម្ចាស់ ជាខ្ញុំ ពីសៀវភៅដើមជាភាសាបារាំងដែលមាន ចំណងជើងថា « Le Royaume du Cambodge » មានន័យថា «ព្រះរាជាណាចក្រកម្ពុជា» ជាស្នាដៃរបស់លោក ហ្សង់ មូរ៉ា (Jean Moura) អតីតទេសាភិបាលបារាំងប្រចាំកម្ពុជា (១៨៦៨-១៨៧៩) ហើយ បោះពុម្ពផ្សាយនាឆ្នាំ១៨៨៣ ដោយគ្រឹះស្ថាន Ernest Leroux នាទីក្រុងប៉ារីស ប្រទេសបារាំង។ សៀវភៅ «នគរខ្មែរ» នេះបានបើកចំហបង្ហូចនៃអតីតកាល ដោយផ្តល់ការយល់ដឹងបន្ថែមទៅលើជីវិតរស់នៅប្រចាំថ្ងៃ បង្ហាញនូវទិដ្ឋភាពនានានៃជីវិតរស់នៅមួយភាគធំរបស់ប្រជារាស្ត្រខ្មែរនាដើមសតវត្សទី១៩ ដែលស្ថិតនៅក្រោមអាណាព្យាបាលរបស់បារាំង ដែលភាគខ្លះនៃទិដ្ឋភាពនិងចំណេះដឹងមួយចំនួនបានបាត់បង់ទៅហើយ រីឯផ្នែកខ្លះទៀតបានប្រែប្រួលពុះពារឆ្លងកាត់ពេលវេលានៅក្បាទុកមកដល់ពេលបច្ចុប្បន្ន។

ទូលព្រះបង្គំខ្ញុំម្ចាស់ ជាខ្ញុំ បានស្រាវជ្រាវប្រៀបធៀបពត៌មានពីប្រភពខុសៗគ្នា ក្នុងស្មារតីដើម្បីធ្វើយ៉ាងណាឱ្យអត្ថបទក្នុងសៀវភៅ «នគរខ្មែរ» នេះអាចមានខ្លឹមសារឆ្លើយតបបានច្រើនបំផុតតាមអ្វីដែលអាចធ្វើទៅបានព្រមទាំងបានស្រាវជ្រាវឯកសារថ្មីៗបន្ថែមស្តីពីប្រវត្តិសាស្ត្រនិងប្រពៃណីទំនៀមទម្លាប់នៃប្រទេសកម្ពុជា នាសតវត្សទី២១ រួមផ្សំជាមួយឯកសារដើមភាគទីមួយរបស់លោក ហ្សង់ មូរ៉ា នាសតវត្សទី១៩ បានធ្វើឱ្យ ទូលព្រះបង្គំខ្ញុំម្ចាស់ ជាខ្ញុំ សម្រេចចិត្តដាក់ចំណងជើង «នគរខ្មែរ» ចំពោះសៀវភៅថ្មីនេះ ។

សេចក្តីដូចបានក្រាបបង្គំទូលថ្វាយខាងលើ ទូលព្រះបង្គំខ្ញុំម្ចាស់ ជាខ្ញុំ សូម **សម្តេចព្រះមហាក្សត្រីព្រះវររាជមាតាជាតិខ្មែរ** ទ្រង់ព្រះមេត្តាជ្រាបតាមសព្វព្រះរាជហឫទ័យ ដោយព្រះទ័យអនុគ្រោះដ៏ខ្ពង់ខ្ពស់បំផុត។

សូម **សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត សូមព្រះមេត្តាទទួលនូវគោរវកក្តីដ៏ស្មោះស្ម័គ្រ និងអភិវន្ទនាការដ៏ខ្ពង់ខ្ពស់បំផុតអំពី ទូលព្រះបង្គំខ្ញុំម្ចាស់ ជាខ្ញុំ។

សេចក្តីគួរពុំគួរ សូម **សម្តេចព្រះមហាក្សត្រ ព្រះវររាជមាតាជាតិខ្មែរ** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត សូមព្រះមេត្តាប្រោសព្រះរាជទានទោសដោយអភ័យ។

ថ្ងៃ ៨ រ ៦ ៣ ខែជេស្ឋ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
សូមក្រាបបង្គំទូលថ្វាយនៅរាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ ៦ ២ ឆ្នាំ២០២៥

រដ្ឋមន្ត្រី

បណ្ឌិតសភាចារ្យ ភឿង សកុណា

សូមក្រាបថ្វាយព្រះបង្គំ
សម្តេចព្រះមហាក្សត្រិយ៍ នរោត្តម មុនិនាថ សីហនុ
ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល
ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត

ទូលព្រះបង្គំខ្ញុំម្ចាស់ សូមព្រះបរមរាជានុញ្ញាតចូលរួមអបអរសាទរ ក្នុងមនោសញ្ចេតនាភក្តីភាព និងស្វាមីភក្ត្រនៅក្នុងឱកាសដ៏មហានក្ខឫក្ស នៃព្រះរាជទិវាចម្រើនព្រះជន្មព្រះវស្សារបស់ព្រះអង្គ នាឆ្នាំជំវរនេះ ។

ព្រះរាជទិវាដ៏ថ្លៃថ្លានេះ ក៏ជាឱកាសដ៏វិសេសវិសាលមួយដើម្បីប្រជារាស្ត្រកូនចៅព្រះអង្គគ្រប់រូបនៃព្រះរាជាណាចក្រកម្ពុជា បានប្រសាទប្រសិទ្ធិពរថ្វាយ និងសំដែងនិងរំលឹកជាថ្មីម្តងទៀត នូវកតញ្ញូតាដ៏ជ្រាលជ្រៅរបស់គេទាំងអស់គ្នា ថ្វាយចំពោះព្រះរាជកិច្ចដ៏ច្រើនអនេក ឥតកាត់ថ្លៃបាន ក្នុងឧត្តមប្រយោជន៍ នៃជាតិ និងប្រជារាស្ត្រកម្ពុជា ដែលត្រូវបានកត់ត្រាទុក ជាឱឡារិកក្នុងប្រវត្តិសាស្ត្រជាតិកម្ពុជាទាំងមូល ។

ជាមួយនិងអំណរព្រះមហន្តគុណដ៏ថ្លៃថ្លា ដូចបានទូលថ្វាយដោយគោរពសក្ការៈខាងលើនេះ ទូលព្រះបង្គំខ្ញុំម្ចាស់ សូមព្រះបរមរាជានុញ្ញាតសំដែងជាពិសេស នូវកតញ្ញូតាដ៏ជ្រាលជ្រៅជាទីបំផុត នៃទូលព្រះបង្គំខ្ញុំម្ចាស់ និងគ្រួសារ ថ្វាយចំពោះព្រះទ័យវិសាលសន្តានប្រកបដោយព្រហ្មវិហារធម៌ ដែលទូលព្រះបង្គំខ្ញុំម្ចាស់ ព្រមទាំងបុត្រ រមែងជានិច្ចជាកាល ទទួលបានពីព្រះរាជប្រោសប្រទាន រួមជាមួយនិងព្រះបរមោវាទដ៏ថ្លៃថ្លាជាទីបំផុត ។

ទូលព្រះបង្គំខ្ញុំម្ចាស់ សូមបួងសួងដល់គុណបុណ្យបារមី ព្រះតេនត្រ័យកែវទាំងបី វត្ថុសក្តិសិទ្ធទាំងឡាយក្នុងលោក មានទេវតាថៃរក្សាស្វេតឆ័ត្រ ទេវតាឆ្នាំថ្មី ព្រះបារមីនៃព្រះអតីតព្រះមហាក្សត្រ ព្រះមហាក្សត្រីយានីគ្រប់ព្រះអង្គ ជាពិសេសដួងព្រះបរមវិញ្ញាណខក្ខន្ធនៃ **ព្រះករុណាព្រះបរមរតនកោដ្ឋ** សូមព្រះអង្គជួយប្រោះព្រំប្រទាននូវព្រៃះសំឰសាធុការពរ និងតាមបីបាច់ថែរក្សាគាំពារ **សម្តេចព្រះមហាក្សត្រិយ៍ ព្រះវររាជមាតា** ជាទីសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត សូមព្រះអង្គបានប្រកបដោយព្រះពុទ្ធពរទាំងបួនប្រការ គឺ **អាយុ វណ្ណៈ សុខៈ ពលៈ** កុំបីឃ្លៀងឃ្លាតឡើយ ។

សូម **សម្តេចព្រះមហាក្សត្រិយ៍** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ព្រះមេត្តាទទួលនូវគោរវកក្តីដ៏ខ្ពង់ខ្ពស់ និងស្មោះស្ម័គ្រអំពីទូលព្រះបង្គំខ្ញុំម្ចាស់ និងបុត្រទាំងអស់ ។

ក្រាបបង្គំទូលថ្វាយនៅរាជធានីភ្នំពេញ, ថ្ងៃទី ១៦ ខែមិថុនា ឆ្នាំ២០២៥

នរោត្តម អរុណរស្មី **ឱឃុនបណ្ឌិតកែវ ពុទ្ធរស្មី**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សហគម សិស្ស-និស្សិត
អាហារូបករណ៍សម្តេចអគ្គមហាសេនាបតី
តេជោ ហ៊ុន សែន និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត
លេខ :០១៤/២៥ ស.ស.ស.អមត

សារលិខិតថ្វាយព្រះពរ
សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ
ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល ក្នុងឱកាសនៃព្រះរាជពិធីបុណ្យ
ចម្រើនព្រះជន្មវស្សា គម្រប់ ៨៩ យាងចូល ៩០ ព្រះវស្សា

សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត

នៅក្នុងឱកាសដ៏មហានក្ខត្តឫក្សឧត្តុង្គឧត្តមថ្លៃថ្លា នៃព្រះរាជពិធីបុណ្យចម្រើនព្រះជន្មវស្សារបស់ **សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល** គម្រប់៨៩ យាងចូល ៩០ ព្រះវស្សា ដែលនឹងប្រព្រឹត្តទៅនាថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០២៥ ខាងមុខនេះ ទូលព្រះបង្គំជាខ្ញុំ តាងនាមថ្នាក់ដឹកនាំ សមាជិក សមាជិកា សមាគមសិស្ស-និស្សិតអាហារូបករណ៍ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** និង**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** និងក្នុងនាមទូលព្រះបង្គំជាខ្ញុំផ្ទាល់ និងស្វាមី សូមព្រះបរមារាជានុញ្ញាតលំនឹងកាយាចាចិត្ត ក្រាបបង្គំសម្តែងថ្វាយនូវព្រះសព្វសាធុការពរជ័យ សិរីមង្គល បៃុលសុខ បវរមហាប្រសើរគ្រប់ប្រការ ប្រកបដោយកតញ្ញូតាធម៌និងកតវេទិតាធម៌យ៉ាង ជ្រាលជ្រៅបំផុតចំពោះព្រះរាជគុណូបការៈក្នុងព្រះរាជសកម្មភាពដ៏ឧត្តុង្គឧត្តមរបស់ **សម្តេចព្រះមហាក្សត្រី** ដែលព្រះអង្គទ្រង់តែងចំណាយព្រះបញ្ញាញាណ ព្រះកាយពល ទឹកព្រះទ័យ និងព្រះអង្គសព្វព្រះរាជហឫទ័យប្រោសព្រះរាជទានព្រះរាជទ្រព្យយ៉ាងច្រើនជាបន្តបន្ទាប់ជួយក្នុងវិស័យមនុស្សធម៌ អប់រំ សុខាភិបាល ការពារជាតិ សាសនា សង្គមកិច្ច កុមារកំព្រា សុខុមាលភាពសង្គម គ្រោះមហន្តរាយនានា និងជីវភាពរស់នៅរបស់ប្រជានុរាស្ត្រ ដើម្បីជាឧត្តមប្រយោជន៍ជូនជាតិមាតុភូមិ និងប្រជាពលរដ្ឋទូទាំងព្រះរាជាណាចក្រកម្ពុជា។

ក្នុងអភិលក្ខិតសម័យជាថ្លៃថ្លានេះ ទូលព្រះបង្គំជាខ្ញុំទាំងអស់គ្នា សូមព្រះបរមារាជានុញ្ញាតលើកហត្ថប្រណម្យបួងសួងដល់គុណបុណ្យព្រះរតនត្រ័យ គុណកែវទាំងបី វត្ថុស័ក្តិសិទ្ធិទាំងឡាយក្នុងលោក ទេវតារក្សាព្រះមហាស្វេតច្ឆត្រ បាមីនៃដង្ហែព្រះវិញ្ញាណក្ខន្ធអតីតព្រះមហាក្សត្រ ព្រះមហាក្សត្រិយានីខ្មែរគ្រប់ព្រះអង្គ ជាពិសេសដង្ហែព្រះវិញ្ញាណក្ខន្ធព្រះករុណាព្រះមហាវីរក្សត្រ ព្រះវររាជបិតា ព្រះបរមរតនកោដ្ឋ និងទេវតាថែរក្សាផ្នាំថ្មី **គោរាគទេវី** សូមព្រះអង្គតាមជួយបីបាច់ថែរក្សាអភិបាលប្រោះព្រំនូវព្រះសព្វសាធុការពរជ័យគ្រប់ប្រការថ្វាយ **សម្តេចព្រះមហាក្សត្រី** សូមព្រះអង្គទ្រង់សមប្រកបដោយព្រះរាជបញ្ញាញាណភ្លឺថ្លា ព្រះកាយពលរឹងមាំ ព្រះរាជសុខភាពល្អបរិបូណ៌ ព្រះជន្មាយុយឺនយូរជាងរយព្រះវស្សា ចាកផុតពីព្រះពោគព្យាធិនានា និងសូមព្រះអង្គទ្រង់ប្រកបដោយព្រះពុទ្ធពរដ៏ឧត្តុង្គឧត្តមថ្លៃថ្នាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ និងពលៈ ជាកិយ្យោភាពតរៀងទៅ។

សូម **សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត** ទ្រង់ព្រះមេត្តាទទួលនូវអភិវន្ទនកិច្ច និងព្រះសេយ្យភក្តីភាពដ៏ខ្ពង់ខ្ពស់បំផុតពីទូលព្រះបង្គំជាខ្ញុំ និងស្វាមី។

ថ្ងៃ សុក្រ ៣រោច ខែជេស្ឋ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
ក្រាបបង្គំទូលថ្វាយនៅរាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែមិថុនា ឆ្នាំ២០២៥

ប្រធានសមាគមសិស្ស-និស្សិតអាហារូបករណ៍
សម្តេចអគ្គមហាសេនាបតីតេជោ-ហ៊ុន សែន និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត

ពេជ ចន្ទមុន្នី

ព្រះរាជាណាចក្រកម្ពុជា
ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

សារលិខិតថ្វាយព្រះពរ
សូមក្រាបបង្គំទូលថ្វាយ
សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ
ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល

បពិត្រសម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត!

ក្នុងឱកាសដ៏មហានក្ខត្តឫក្សនៃព្រះរាជពិធីបុណ្យចម្រើនព្រះជន្មគម្រប់ ៨៩ ព្រះវស្សា យាងចូល ៩០ ព្រះវស្សា ដែលនឹងឈានចូលមកដល់នាថ្ងៃពុធ ៨រោច ខែជេស្ឋ ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៩ ត្រូវនឹងថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០២៥ ខាងមុខនេះ តាងនាមថ្នាក់ដឹកនាំ មន្ត្រីរាជការ បុគ្គលិកក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ព្រមទាំងមន្ត្រីការទូតកម្ពុជាទាំងអស់ ដែលកំពុងបំពេញបេសកកម្មការទូតនៅបរទេស ទូលព្រះបង្គំជាខ្ញុំ និងភរិយា សូមព្រះបរមារាជានុញ្ញាតថ្វាយព្រះសព្វសាធុការពរជ័យ និងកតញ្ញូតាធម៌ដ៏ជ្រាលជ្រៅបំផុតថ្វាយ **សម្តេចព្រះមហាក្សត្រី** ជាទីគោរពសក្ការៈ ដែលព្រះអង្គតែងលះបង់ព្រះកាយពល ព្រះបញ្ញាញាណ និងព្រះរាជទ្រព្យផ្ទាល់របស់ព្រះអង្គ ក្នុងព្រះរាជសកម្មភាពដ៏ឧត្តុង្គឧត្តមលើវិស័យព្រះពុទ្ធសាសនា អប់រំសិក្សាធិការ សង្គមកិច្ច មនុស្សធម៌ សុខុមាលភាព ដើម្បីបុព្វហេតុជាតិមាតុភូមិ និងប្រជារាស្ត្រជាកូន ជាចៅ ចៅទួត ជាទីស្នេហារបស់ព្រះអង្គ។

ក្នុងព្រះរាជវារោកាសជ័យមង្គលដ៏មហាថ្លៃថ្លានេះ ទូលព្រះបង្គំយើងខ្ញុំទាំងអស់គ្នា សូមលើកហត្ថប្រណម្យឧទ្ធិសបួងសួងដល់គុណបុណ្យព្រះរតនត្រ័យកែវទាំងបី វត្ថុស័ក្តិសិទ្ធិទាំងឡាយក្នុងលោក ទេវតារក្សាព្រះមហាស្វេតច្ឆត្រ ព្រះបាមីនៃព្រះវិញ្ញាណក្ខន្ធអតីតព្រះមហាក្សត្រ ព្រះមហាក្សត្រីយានីខ្មែរគ្រប់ព្រះអង្គ និងព្រះបាមីនៃព្រះវិញ្ញាណក្ខន្ធព្រះបរមរតនកោដ្ឋ សូមព្រះមេត្តាប្រោសព្រះរាជសព្វសាធុការពរជ័យគ្រប់ប្រការថ្វាយ **សម្តេចព្រះមហាក្សត្រី** សូមព្រះអង្គទ្រង់ប្រកបដោយព្រះរាជសុខភាពល្អបរិបូរណ៌ ព្រះពលានុភាពរឹងមាំខ្លាំងក្លា ព្រះបញ្ញាញាណភ្លឺថ្លា ព្រះជន្មាយុយឺនយូរជាងរយព្រះវស្សា ដើម្បីគង់ប្រថាប់ជាម្លប់ដ៏ត្រជាក់ត្រជុំ សម្បូរសប្បាយចម្រុងចម្រើនសម្រាប់ជាតិមាតុភូមិ និងប្រជានុរាស្ត្ររបស់ព្រះអង្គជានិច្ចនិរន្តរ៍តរៀងទៅ។

សូម **សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត** ទ្រង់ព្រះមេត្តាប្រោសទទួលនូវគោរវកិច្ចជាទីសក្ការៈដ៏ខ្ពង់ខ្ពស់បំផុតពីទូលព្រះបង្គំជាខ្ញុំ និងភរិយា។

ថ្ងៃ ចន្ទ ៦រោច ខែជេស្ឋ ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៩
ក្រាបបង្គំទូលថ្វាយ នៅរាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែមិថុនា ឆ្នាំ២០២៥

ប្រាក់ សុខុន **ខេង សំអ៊ាដា**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ
លេខ: ១៨៥៦ស/ណ/ស៨៣

សារថ្វាយព្រះពរ

សូមក្រាបបង្គំទូលថ្វាយ
សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ
ព្រះវររាជមាតាជាតិខ្មែរ កុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល

បរពិត្រសម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត!

ទូលព្រះបង្គំតាងនាមថ្នាក់ដឹកនាំ មន្ត្រីរាជការស៊ីវិល មន្ត្រីនគរបាលជាតិ និងមន្ត្រីពន្ធនាគារ នៃក្រសួងមហាផ្ទៃ សូមព្រះបរមរាជានុញ្ញាតសម្តែងនូវអំណរសាទរ ប្រកបដោយសេចក្តីសោមនស្សយ៉ាងក្រៃលែងថ្វាយ **សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ក្នុងឱកាសដ៏នក្ខត្តឫក្សនៃព្រះរាជពិធីបុណ្យចម្រើនព្រះជន្មាយុ **សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ** នាថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០២៥ ខាងមុខនេះ ។

ទូលព្រះបង្គំសូមយកឱកាសដ៏វិសេសវិសាលនេះ លំឱនកាយក្រាបអភិវន្ទប្រកបដោយមនោសញ្ចេតនា និងកតញ្ញូតាធម៌ដ៏ជ្រាលជ្រៅចំពោះព្រះមហាករុណាទិគុណរបស់ **សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ** ដែលជានិច្ចជាកាលព្រះអង្គតែងយកព្រះទ័យទុកដាក់ខ្ពស់បំពេញព្រះរាជកិច្ច អស់ពីកម្លាំងព្រះកាយពល និងព្រះបញ្ញាញាណ ក្នុងព្រះរាជហឫទ័យដ៏សប្បុរសថ្លៃថ្លាចំពោះជាតិមាតុភូមិ និងប្រជារាស្ត្រ ។

ក្នុងឱកាសប្រកបដោយសិរីមង្គលឧត្តុង្គឧត្តមនេះ ទូលព្រះបង្គំសូមលើកហត្ថប្រណម្យបួងសួងដល់គុណបុណ្យព្រះរតនត្រ័យ វត្ថុស័ក្តិសិទ្ធិទាំងឡាយក្នុងលោក ទេវតារក្សាព្រះមហាស្វេតច្ឆត្រ និងទេវតាឆ្នាំថ្មីព្រះនាម **គោរាគៈឆេនី** សូមជួយប្រោះព្រំសព្វសាធុការពរបវរមហាប្រសើរថ្វាយ **សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត សូមព្រះអង្គបានប្រកបដោយព្រះពុទ្ធពរទាំងបួនប្រការគឺ **អាយុ វណ្ណៈ សុខៈ ពលៈ** កុំបីឃ្លៀងឃ្លាតឡើយ ដើម្បីគង់ជាម្លប់ដ៏សុខដុមសម្រាប់ប្រជារាស្ត្រខ្មែរជានិច្ចនិរន្តរ៍តរៀងទៅ ។

សូម **សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ កុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល** មេត្តាទទួលនូវគោរវកក្តីភាពដ៏ខ្ពង់ខ្ពស់បំផុតពីទូលព្រះបង្គំ ។

សេចក្តីគួរពុំគួរ សូមទ្រង់ព្រះមេត្តាប្រោស ។

ថ្ងៃ ចន្ទ ១៨កើត ខែ ផល្គុន ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
សូមក្រាបបង្គំទូលថ្វាយនៅរាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែមិថុនា ឆ្នាំ២០២៥
ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

អតិសន្តិបណ្ឌិត ស សុខា

សម្តេចក្រឡាហោម ស ខេង
ឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ

សារថ្វាយព្រះពរ

សូមក្រាបបង្គំទូលថ្វាយ
សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ
ព្រះវររាជមាតាជាតិខ្មែរ កុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល

បរពិត្រសម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត

ក្នុងឱកាសដ៏មហាសិរីមង្គលថ្លៃថ្លា នៃព្រះរាជពិធីបុណ្យចម្រើនព្រះជន្មាយុ **សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ** នាថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០២៥ ខាងមុខនេះ ទូលព្រះបង្គំសូមព្រះបរមរាជានុញ្ញាតសម្តែងនូវអំណរសាទរ ប្រកបដោយសេចក្តីសោមនស្សក្រៃលែងថ្វាយ **សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ។

ស្ថិតក្នុងវេលាដ៏នក្ខត្តឫក្សវិសេសវិសាលនេះ ទូលព្រះបង្គំសូមលើកហត្ថប្រណម្យបួងសួងដល់គុណបុណ្យព្រះរតនត្រ័យ វត្ថុស័ក្តិសិទ្ធិទាំងឡាយក្នុងលោក មានទេវតាថែរក្សាព្រះមហាស្វេតច្ឆត្រ សូមតាមបីបាច់ថែរក្សា និងប្រោះព្រំនូវសព្វសាធុការពរ សិរីសួស្តី ជ័យមង្គល វិបុលសុខ បវរមហាប្រសើរថ្វាយ **សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត សូមព្រះអង្គបានប្រកបដោយព្រះរាជសុខភាពល្អបរិបូរណ៌ ព្រះកាយពលមាំមួន ព្រះបញ្ញាញាណវាងវៃ ព្រះជន្មាយុយឺនយូរ និងចៀសផុតពីព្រះរោគាព្យាធិទាំងឡាយទាំងពួងកុំបីអាក់ខានឡើយ ដើម្បីបន្តព្រះរាជបេសកកម្មដ៏ឧត្តុង្គឧត្តមគាំទ្រដល់វិស័យអាណាចក្រ និងពុទ្ធចក្រ និងគង់ជាម្លប់ដ៏សុខដុមសម្រាប់ប្រជារាស្ត្រខ្មែរជានិច្ចនិរន្តរ៍តរៀងទៅ ។

សូម **សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ កុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល** មេត្តាទទួលនូវគោរវកក្តីភាពដ៏ខ្ពង់ខ្ពស់បំផុតពីទូលព្រះបង្គំ ។

សេចក្តីគួរពុំគួរ សូមទ្រង់ព្រះមេត្តាប្រោស ។

ថ្ងៃ ចន្ទ ១៨កើត ខែ ផល្គុន ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
សូមក្រាបបង្គំទូលថ្វាយនៅរាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែមិថុនា ឆ្នាំ២០២៥

ស ខេង

មជ្ឈមណ្ឌលឯកសារកម្ពុជា

June 13, 2025

Her Majesty
Samdech Preah Moha Ksatrei Preah Voreak Reach Meada Cheat Khmer
NORODOM MONINEATH SIHANOUK
Queen of Cambodia
The Royal Palace

Your Majesty,

On this wonderful occasion of your Majesty's birthday, I wish to take a moment to reflect on the day prior to the official inauguration ceremony of The Physical Legacy of Sangkum Reastr Niyum, King Father-Queen Mother (Borei O'Svay-Sen Chey). On this day, the sun shone brightly to welcome the historical visit from Her Royal Highness Samdech Norodom Arunrasmey, who represented Your Majesty at the ceremony, showing love and kindness to the people of Cambodia.

This year, I decided to present Your Majesty with a bouquet of pink tulips from the Netherlands. The tulips are surrounded by light green ferns that are meant to represent the relationship between Your Majesty, the People of Cambodia and the Cambodian land.

This relationship is illustrated by the color contrast between the tulips and the green ferns—the color of the tulips representing the love of Your Majesty for the late King Father, NORODOM SIHANOUK and for the Cambodian People and the color of the ferns representing the beauty and fertility of the Cambodian land, which is just now seeing the commencement of the rainy season in Cambodia. Your Majesty's love for the Cambodian People, the ageless beauty of the Cambodian land and the indomitable spirit of the Cambodian people give this country great hope for the future.

With sincere good wishes for your Majesty's good health, happiness, and well-being, and my profound respect.

Sincerely,

Youk Chhang
Executive Director, the Queen Mother Library
& the Documentation Center of Cambodia

Message de voeux à l'occasion de SON AUGUSTE ANNIVERSAIRE le 18 juin 2025

Samdech Preah Voreach Meada, Vénèrée, Bien-Aimée,

A l'occasion de l'Auguste Anniversaire de Samdech Preah Voreach Meada, Vénèrée, Bien-Aimée, marquant Ses quatre-vingt neuvième année, notre petite famille se joint à nous pour présenter très respectueusement, affectueusement à Votre Majesté nos vœux fervents de Santé, de Grande Longévité, de Félicité et de Bonheur sans nuages, aux côtés de Preah karuna Preah Boromneath Preah Reach Both, Vénéré et Bien-Aimé de tout Son peuple.

Les années passent mais LUONG Mê garde une santé de fer, une agilité étonnante et un esprit vivace pour remplir les lourdes charges royales sociales. Toujours aux chevets des deshèrités et de Ses sujets, n'oubliant ni les uns ni les autres, petits ou grands avec la même Haute bienveillance. Incomparable compagne de notre immensément Regretté. Vénéré, Preah Karuna Preah Borom Rattanak Kodh, Samdech Preah Voreach Meada, Vénérée, Bien-Aimée, est le témoin de l'Histoire, reconnue par la République Populaire de Chine même en Lui Octroyant la Grande Médaille de l'Amitié.

Le Cambodge est un pays béni des divinités célestes. Puissent les Tévodas accorder leurs bénédictions à Samdech Preah Voreach Meada, Vénérée, Bien-Aimée, pour une Longue Vie pour le bonheur de Son peuple.

Avec nos très profonds respects et l'expression de notre fidélité indéfectible.

SAY Bory

SUM Nipha

សមាគមកាយឫទ្ធិនារីកម្ពុជា

ក្រោមព្រះរាជអធិបតីសម្តេចព្រះមហាក្សត្រី ព្រះឥរាជមាតាជាតិខ្មែរ នរោត្តម មុនិនាថ សីហនុ

Girl Guides Association of Cambodia

Under the High Patronage of Her Majesty Queen Mother Norodom Monineath Sihanouk of Cambodia

លេខ: ០៨៦.. / ២៥ / សកនក

សារលិខិតថ្វាយព្រះពរ

សូមក្រាបបង្គំទូលថ្វាយ
សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ
ព្រះឥរាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល
និងជាព្រះប្រធានកិត្តិយសនៃសមាគមកាយឫទ្ធិនារីកម្ពុជា

បពិត្រសម្តេចព្រះមហាក្សត្រី ព្រះឥរាជមាតាជាតិខ្មែរ ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត!

នៅក្នុងឱកាសដ៏មហានក្ខត្តឫក្សនៃ **ព្រះរាជពិធីបុណ្យចម្រើនព្រះជន្ម** គម្រប់៨៩ យាងចូល ៩០ព្រះវស្សា ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃពុធ ៨រោច ខែជេស្ឋ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០២៥ ខាងមុខនេះ ខ្ញុំម្ចាស់ តាងនាម គណៈកម្មាធិការប្រតិបត្តិ សមាជិកា និងសមាជិក នៃសមាគមកាយឫទ្ធិនារីកម្ពុជាទាំងអស់ សូមព្រះបរមាជានុញ្ញាត ក្រាបបង្គំថ្វាយព្រះមហាសព្វសាធុការពរជ័យ បវរសួស្តី សិរីមង្គល វិបុលសុខមហាប្រសើរ ថ្វាយ **សម្តេចព្រះមហាក្សត្រី ព្រះឥរាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល និងជាព្រះប្រធានកិត្តិយសនៃសមាគមកាយឫទ្ធិនារីកម្ពុជា** សូមព្រះអង្គមានព្រះពលានុភាពរឹងមាំ ព្រះរាជសុខភាពល្អបរិបូរណ៌ ព្រះបញ្ញាញាណភ្លឺថ្លា ព្រះជន្មាយុយឺនយូរជាងរយព្រះវស្សា ដើម្បីគង់ប្រថាប់ជាម្លប់ដ៏ត្រជាក់ត្រជុំដល់ប្រជានុរាស្ត្រខ្មែរ និងដល់សមាគមកាយឫទ្ធិនារីកម្ពុជា ដើម្បីបានបំពេញនូវព្រះរាជកិច្ចមនុស្សធម៌ដ៏មហាធំធេង ប្រកបដោយទសពិធរាជធម៌ ព្រះរាជគតិបណ្ឌិតវាងវៃ រួមចំណែកដល់ការលើកកម្ពស់ នូវសិទ្ធិសេរីភាព និងសេចក្តីថ្លៃថ្នូររបស់ប្រជានុរាស្ត្រខ្មែរទូទាំងប្រទេស។

ឆ្លៀតក្នុងឱកាសដ៏វិសេសវិសាលនេះ ខ្ញុំម្ចាស់សូមលើកហត្ថប្រណម្យឧទ្ធិសបួងសួងដល់គុណបុណ្យព្រះរតនត្រ័យ គុណកែវទាំងបី វត្ថុស័ក្តិសិទ្ធិក្នុងលោក និងទេវតារក្សាព្រះមហាស្វេតច្ឆត្រ ព្រមទាំងគុណបុណ្យព្រះបារមីនៃដួងព្រះវិញ្ញាណក្ខន្ធអតីតព្រះមហាក្សត្រ ព្រះមហាក្សត្រីយានីខ្មែរគ្រប់ព្រះអង្គ ជាពិសេសបារមី ព្រះវិញ្ញាណក្ខន្ធ **សម្តេចព្រះឥរាជមាតា ព្រះបរមរតនកោដ្ឋ** និងទេវតាគ្រងរក្សា ព្រះរាជាណាចក្រកម្ពុជា តាមអភិបាលថ្វាយ **សម្តេចព្រះមហាក្សត្រី ព្រះឥរាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត។

សូម **សម្តេចព្រះមហាក្សត្រី ព្រះឥរាជមាតាជាតិខ្មែរ** ព្រះមេត្តាទទួលនូវស្វែមីក័ក្តិដ៏ស្មោះស្ម័គ្រ និងសេចក្តីគោរពដ៏ខ្ពង់ខ្ពស់បំផុតអំពីខ្ញុំម្ចាស់។

សេចក្តីគួរពុំគួរ សូម **សម្តេចព្រះមហាក្សត្រី ព្រះឥរាជមាតាជាតិខ្មែរ** ព្រះមេត្តាប្រោសព្រះរាជទានទោស។

ថ្ងៃ ....ចន្ទ.....៦រោច... ខែ..ជេស្ឋ.... ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី ..១៦.. ខែ ..មិថុនា... ឆ្នាំ២០២៥

សមាគមកាយឫទ្ធិនារីកម្ពុជា
អគ្គលេខាធិការ

ពេជ្រ ចន្ទមុន្នី

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សារលិខិតថ្វាយព្រះពរ

សូមក្រាបបង្គំទូលថ្វាយ
សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ
ព្រះឥរាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល

ព្រឹទ្ធសភា
គណៈកម្មការទី៨

បពិត្រ សម្តេចព្រះមហាក្សត្រី ព្រះឥរាជមាតាជាតិខ្មែរ ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត!

ក្នុងឱកាសដ៏មហានក្ខត្តឫក្សសិរីសួស្តីជ័យមង្គល នៃព្រះរាជពិធីបុណ្យចម្រើនព្រះជន្មវស្សា **សម្តេចព្រះមហាក្សត្រី ព្រះឥរាជមាតាជាតិខ្មែរ** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត គម្រប់ ៨៩ យាងចូល ៩០ព្រះវស្សា ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃពុធ ទី១៨ ខែមិថុនា ឆ្នាំ២០២៥ ខាងមុខនេះ ខ្ញុំម្ចាស់ តាងនាម សមាជិក សមាជិកាគណៈកម្មការ សុខាភិបាល សង្គមកិច្ច អតីតយុទ្ធជន យុវនីតិសម្បទា ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងកិច្ចការនារី ព្រឹទ្ធសភា សូមព្រះបរមាជានុញ្ញាតសម្តែងនូវអំណរសោទរ និង សូមគោរពថ្វាយនូវព្រះរាជសព្វសាធុការពរជ័យ បវរសួស្តី សិរីមង្គល វិបុលសុខមហាប្រសើរគ្រប់ប្រការថ្វាយ **សម្តេចព្រះមហាក្សត្រី ព្រះឥរាជមាតាជាតិខ្មែរ** សូមព្រះអង្គទ្រង់មានព្រះកាយពលមាំមួន ព្រះស្មារតីភ្លឺថ្លា ព្រះបញ្ញាញាណភ្លឺថ្លា ព្រះរាជសុខភាពល្អបរិបូរណ៌ ព្រះជន្មាយុយឺនយូរជាងរយព្រះវស្សា ដើម្បីទ្រង់គង់ប្រថាប់ជាមហាម្លប់ដ៏ត្រជាក់ត្រជុំសុខដុមមេនាដល់ប្រជានុរាស្ត្រខ្មែរគ្រប់ៗរូប។

ខ្ញុំម្ចាស់ ទូលព្រះបង្គំយើងខ្ញុំ សូមព្រះបរមាជានុញ្ញាតសម្តែងនូវកតញ្ញូតវេទិតាធម៌យ៉ាងជ្រាលជ្រៅបំផុតថ្វាយ **សម្តេចព្រះមហាក្សត្រី ព្រះឥរាជមាតាជាតិខ្មែរ** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ដែលព្រះអង្គជានិច្চកាលតែងសព្វព្រះរាជហឫទ័យយកអស់ព្រះកាយពល និងព្រះបញ្ញាញាណ បំពេញព្រះរាជបុជនីយកិច្ចសន្សំបុញ្ញកុសលតម្កល់ប្រោសព្រះរាជទានដល់ជនរួមជាតិរបស់ព្រះអង្គប្រកបដោយព្រះទសពិធរាជធម៌ ព្រះព្រហ្មវិហារធម៌និងព្រះមនុស្សធម៌ជាអនេកប្បការដើម្បីជាប្រយោជន៍ជាតិ និងមាតុភូមិ។

ក្នុងវេលាកាសដ៏មហានក្ខត្តឫក្សនេះ ខ្ញុំម្ចាស់ ទូលព្រះបង្គំយើងខ្ញុំ សូមព្រះបរមាជានុញ្ញាតសារជាថ្មីម្តងទៀត លើកហត្ថប្រណម្យបួងសួងដល់ទេវតាថែរក្សាទឹកដី នៃព្រះរាជាណាចក្រកម្ពុជា គុណបុណ្យព្រះរតនត្រ័យ និងវត្ថុស័ក្តិសិទ្ធិទាំងឡាយក្នុងលោក ជាពិសេស បុណ្យបារមីនៃដួងព្រះវិញ្ញាណក្ខន្ធ **ព្រះករុណាព្រះបរមរតនកោដ្ឋ** សូមព្រះអង្គតាមជួយបីបាច់ថែរក្សាអភិបាលប្រោះព្រំនូវព្រះរាជសព្វសាធុការពរជ័យ ព្រះបរមសុខគ្រប់ប្រការថ្វាយ **សម្តេចព្រះមហាក្សត្រី ព្រះឥរាជមាតាជាតិខ្មែរ** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត សូមបានប្រកបដោយព្រះពុទ្ធពរដ៏ប្រពៃថ្លៃថ្លាទាំងបួនប្រការ **គឺអាយុ វណ្ណៈ សុខៈ ពលៈ** ជានិច្চនិរន្តរ៍កុំបីឃ្លៀងឃ្លាតឡើយ។

សូម **សម្តេចព្រះមហាក្សត្រី ព្រះឥរាជមាតាជាតិខ្មែរ** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ព្រះមេត្តាទទួលនូវកេរ្តិ៍ភាពដ៏ស្មោះ និងអភិវន្ទនកិច្চដ៏ខ្ពង់ខ្ពស់បំផុតអំពីខ្ញុំម្ចាស់ ទូលព្រះបង្គំយើងខ្ញុំ។

ថ្ងៃសៅរ៍ ៤រោច ខែជេស្ឋ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០២៥

ប្រធានគណៈកម្មការ

ហាន សំអាន

មូលនិធិស្ត្រីសម្តេចរស្មីសោភ័ណ

SAMDECH RASMI SOBBHANA WOMEN'S FOUNDATION

សូមក្រាបបង្គំទូលថ្វាយ

សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ

ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត

ក្នុងវារៈកាសដ៏មហានក្ខត្តឫក្ស នៃព្រះរាជពិធីបុណ្យចម្រើនព្រះជន្ម **សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត គម្រប់ ៨៩ព្រះវស្សា យាងចូល ៩០ ព្រះវស្សា នាថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០២៥ ខាងមុខនេះ ខ្ញុំម្ចាស់ និងក្រុមគ្រួសារ មានសេចក្តីសោមនស្សរីករាយប្រកបដោយមហាកតិ្តយសដ៏ខ្ពង់ខ្ពស់បំផុត សូមព្រះរាជានុញ្ញាតឧទ្ធិសបួងសួងថ្វាយ ព្រះរាជសព្វសាធុការពរជ័យ សិរីសួស្តី វិបុលសុខ មហាប្រសើរគ្រប់ប្រការថ្វាយ **ហ្លួងម៉ែព្រះវររាជមាតា** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត សូមស្តេចប្រកបដោយព្រះរាជសុខភាពល្អបរិបូរណ៍ ព្រះកាយពលមាំមួន ព្រះជន្មាយុយឺនយូរជាងរយព្រះវស្សា និងជៀសផុតពីព្រះរោគាព្យាធិទាំងឡាយទាំងពួង។

ជាថ្មីម្តងទៀត ខ្ញុំម្ចាស់ និងក្រុមគ្រួសារ សូមឧទ្ធិសបួងសួងដល់ ព្រះបារមីនៃគុណបុណ្យព្រះរតនត្រយ៏ ទេវតារក្សាព្រះមហាស្វេតច្ឆត្រ ព្រះរាជបារមីនៃដួងព្រះវិញ្ញាណក្ខន្ធព្រះបរមរតនកោដ្ឋ សូមមេត្តាជួយបីបាច់ថែរក្សា និងប្រសិទ្ធិពរជ័យ សិរីមង្គល វិបុលសុខគ្រប់ប្រការថ្វាយ **ហ្លួងម៉ែ ព្រះវររាជមាតា** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ដើម្បីស្តេចបន្តព្រះរាជបេសកកម្មដ៏វិសេសវិសាល ក្នុងការទំនុកបម្រុងជួយប្រជារាស្ត្រ ជាពិសេសក្នុងវិស័យមនុស្សធម៌ និងសង្គមកិច្ច ដែលបានជ្រាបចូលដល់ក្រអៅបេះដូងនៃប្រជារាស្ត្រខ្មែរគ្រប់ជំនាន់តរៀងទៅ។

សូម **ហ្លួងម៉ែព្រះវររាជមាតា** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ព្រះរាជមេត្តាទទួលនូវកតញ្ញូតាធម៌ និងកតវេទិតាធម៌យ៉ាងជ្រាលជ្រៅ និងស្មោះស្ម័គ្របំផុតអំពីខ្ញុំម្ចាស់។

ថ្ងៃសៅរ៍ ៨រោច ខែជេស្ឋ ឆ្នាំម្សាញ់ សប្តស័ក ព.ស ២៥៦៩
ក្រាបបង្គំទូលថ្វាយនៅរាជធានីភ្នំពេញ ថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០២៥

ពីកូន

នរោត្តម ម៉ារី

Buddhist Summit

World Buddhist Supreme Conference

1-2, 5-chome Motomachi-dori Chuo-ku Kobe-city Hyogo 650-0022 Japan
Tel: +81-78-367-6618 Fax: +81-78-367-7132
E-mail: wbschq@yahoo.com wbschq@gmail.com

June 18, 2025

H.M. Queen Mother Norodom Monineath Sihanouk
The Kingdom of Cambodia

Letter of Congratulations

Representing the supreme Buddhist leaders of fifty-one member countries across the five continents in the world, we would like to extend our heartfelt congratulations to Your Majesty Queen Mother Norodom Monineath Sihanouk for celebrating the birth anniversary on June 18.

We cordially pray to the Buddha for Your Majesty's good health, longevity, and happiness under the sacred blessings of the Triple Gem.

Sincerely yours in the Dharma,

Most Ven. Dr. Kyuse Enshinjoh
Founder of Buddhist Summit
World Buddhist Supreme Conference
Founder High Priest
Nenbutsushu Sampozan Muryojuji Temple

Most Ven. Dr. Shinkai Kori
President of Buddhist Summit
World Buddhist Supreme Conference
Chief High Priest
Nenbutsushu Sampozan Muryojuji Temple

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សភាពាណិជ្ជកម្មកម្ពុជា
លេខ : ...សភពណ.កជ

សារលិខិតថ្វាយព្រះពរ
សូមក្រាបបង្គំទូលថ្វាយ
សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ
ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល
ក្នុងឱកាសព្រះរាជពិធីបុណ្យចម្រើនព្រះជន្ម គម្រប់៨៩ យាងចូល ៩០ព្រះវស្សា

សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត!

នៅក្នុងទិវាដ៏មហាមង្គលាភិរម្យថ្លៃថ្លា ពោរពេញដោយសេចក្តីអភិរម្យសោមនស្សរីករាយ ទូលព្រះបង្គំជាខ្ញុំ និងភរិយា ព្រមទាំងប្រធានសភាពាណិជ្ជកម្មរាជធានី-ខេត្ត ថ្នាក់ដឹកនាំគ្រប់លំដាប់ថ្នាក់ និងសមាជិក សមាជិកា ទាំងអស់ នៃសភាពាណិជ្ជកម្មកម្ពុជា សូមព្រះបរមារាជានុញ្ញាតលំនិនកាយវាចាចិត្ត គោរពទូលថ្វាយនូវ ព្រះពរជ័យ បវរសួស្តី សិរីមង្គល វិបុលសុខមហាប្រសើរគ្រប់ប្រការថ្វាយ **សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត នាឱកាសព្រះរាជពិធីបុណ្យចម្រើនព្រះជន្មគម្រប់៨៩ព្រះវស្សា យាងចូល៩០ព្រះវស្សា ដែលប្រព្រឹត្តនៅថ្ងៃពុធ ៨រោច ខែជេស្ឋ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០២៥។

ឆ្លៀតក្នុងឱកាសបវរមហាប្រសើរនេះ ទូលព្រះបង្គំជាខ្ញុំទាំងអស់គ្នា សូមគោរពសូបស្ងែង និងចងចាំជានិច្ចចំពោះព្រះរាជស្នាព្រះហស្តដ៏ឧត្តុង្គឧត្តមបំផុតរបស់ **ព្រះអង្គ** ក្នុងការបម្រើជាតិ សាសនា និងប្រជារាស្ត្រ តាមរយៈព្រះរាជសកម្មភាពមនុស្សធម៌ សង្គមកិច្ច វប្បធម៌ សាសនា ប្រកបដោយព្រះគុណធម៌ និងការយកព្រះរាជហឫទ័យទុកដាក់ខ្ពស់ចំពោះស្ថានភាពជីវភាព សុខទុក្ខរបស់ប្រជារាស្ត្រខ្មែរទូទាំងប្រទេស។

ក្នុងវេលាសដ៏មហាសិរីមង្គលប្រពៃថ្លៃថ្លានេះ ទូលព្រះបង្គំជាខ្ញុំទាំងអស់គ្នា សូមព្រះបរមារាជានុញ្ញាត លើកហត្ថប្រណម្យបួងសួងដល់ទេវតា ថៃរក្សាទឹកដីនៃព្រះរាជាណាចក្រកម្ពុជា គុណបុណ្យព្រះរតនត្រ័យ វត្ថុស័ក្តិសិទ្ធិទាំងឡាយក្នុងលោក ទេវតាថៃរក្សាព្រះមហាស្វេតច្ឆត្រ ពិសេសបុណ្យបារមីព្រះករុណា ព្រះមហាវីរក្សត្រ ព្រះវររាជបិតា ព្រះបរមរតនកោដ្ឋ សូមព្រះអង្គតាមជួយថៃរក្សាការពារ និងប្រោះព្រំ ថ្វាយចំពោះ: **សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ** ជាទីសក្ការៈដ៏ខ្ពស់ខ្ពង់បំផុត និងសូម **ព្រះអង្គ** ទ្រង់សមប្រកបដោយព្រះពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ ជាកិរិយ្យាភាពតរៀងទៅ។

សូម **សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ** ទ្រង់ព្រះមេត្តាទទួលនូវសេយ្យកក្តីភាពដ៏ស្មោះស្ម័គ្រ និងអភិវន្ទនាការដ៏ខ្ពង់ខ្ពស់បំផុតពីទូលព្រះបង្គំយើងខ្ញុំ។

ថ្ងៃ សុ ៣ រោច ខែជេស្ឋ ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៩
ក្រាបបង្គំទូលថ្វាយនៅរាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែមិថុនា ឆ្នាំ២០២៥

ប្រធានសភាពាណិជ្ជកម្មកម្ពុជា និង
ជាប្រធានក្រុមប្រឹក្សាពិគ្រោះយោបល់ធុរកិច្ចអាស៊ានសម្រាប់កម្ពុជា

ឧកញ៉ា គិត ម៉ែន

សូមក្រាបថ្វាយបង្គំ
សម្តេចព្រះមហាក្សត្រី នរោត្តម មុនីនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និង សុភមង្គល ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត

សូមទ្រង់ព្រះមេត្តា

ទូលព្រះបង្គំ ខ្ញុំម្ចាស់ សូមក្រាបថ្វាយបង្គំដោយសេចក្តីកតញ្ញូ សូមថ្វាយព្រះពរ ក្នុងឱកាសចំរើនព្រះជន្មវស្សា គំរប់៨៩យាងចូល៩០ព្រះវស្សានាថ្ងៃទី១៨មិថុនា២០២៥នេះ សូមបុណ្យបារមីទេវតាក្នុងលោក និង បារមីដែលថែរក្សាព្រះមហាស្វេតច្ឆត្រ តាមជួយទ្រទ្រង់ព្រះវររាជមាតាជាតិខ្មែរ សមតាមព្រះពុទ្ធពរ ទាំង៥ប្រការ សូមព្រះអង្គទ្រង់បានប្រកបដោយព្រះសុខមាលភាពល្អបរិបូរណ៍ កំចីមាគាបៀតបៀនបាន ព្រះបញ្ញាញាណភ្លឺថ្លា ព្រះកាយពលមាំមួន ឈ្នះអស់មារសត្រូវគ្រប់ទីសទី មានព្រះជន្មជាងរយព្រះវស្សា ដើម្បីជា មហាម្លប់ ដល់កូន ចៅ ចៅទួត ចៅលួត របស់ព្រះអង្គ ឲ្យទាំងព្រះរាជាណាចក្រកម្ពុជាតរៀងទៅ។

ទូលព្រះបង្គំ ខ្ញុំម្ចាស់ សូមបួងសួងបារមីទេវតាក្នុងលោក ទេវតារក្សាព្រះមហាស្វេតច្ឆត្រ សូមលោកតាមការពារថែរក្សា ព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា សូមបានប្រកបតែព្រះសុខមាលភាពល្អបរិបូរណ៍ ព្រះកាយពលមាំមួន ព្រះបញ្ញាញាណវាងវៃ និងជាជំហរ សំរាប់កូនខ្មែរ ជារង្វែងតរៀងទៅ។

សូមក្រាបបង្គំទូលថ្វាយ

ប៉ារីស ថ្ងៃ ទី១៦ មិថុនា ២០២៥

ទូលព្រះបង្គំ
លី សុងជង

ខ្ញុំម្ចាស់
លី សារាធី



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

មហាអយ្យការ អមតុលាការកំពូល

សារថ្វាយព្រះពរ

សូមក្រាបបង្គំទូលថ្វាយ
សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ
ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល
សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត

នៅក្នុងឱកាសជ័យមង្គលក្តួតឫក្ស ប្រកបដោយសិរីសួស្តី បវរថ្លៃថ្លាមហាប្រសើរនៃព្រះរាជពិធីបុណ្យចម្រើនព្រះជន្ម **សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ** គម្រប់ ៨៩ព្រះវស្សា យាងចូល ៩០ព្រះវស្សា ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០២៥ ខ្ញុំម្ចាស់ជាអគ្គព្រះរាជអាជ្ញា នៃមហាអយ្យការអមតុលាការកំពូល និងជាប្រធានក្រុមប្រឹក្សាវិន័យនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម តំណាងឲ្យព្រះរាជអាជ្ញា ក្រឡាបញ្ជី និងមន្ត្រីរាជការទាំងអស់នៃស្ថាប័នអយ្យការគ្រប់ជាន់ថ្នាក់នៅក្នុងព្រះរាជាណាចក្រកម្ពុជា សូមព្រះបរមរាជានុញ្ញាតអភិវន្ទលំនិនកាយវាចាចិត្តក្រាបបង្គំសម្តែងនូវការគោរពកោតសរសើរ និងកតញ្ញូតាធម៌ដ៏ជ្រាលជ្រៅបំផុត ថ្វាយចំពោះ: **សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ** ដែលព្រះអង្គបានលះបង់ព្រះបញ្ញាញាណ ព្រះរាជសកម្មភាពដ៏ឧត្តុង្គឧត្តមថ្លៃថ្លាបំផុត ប្រកបដោយព្រះគុណធម៌ ព្រះមនុស្សធម៌ ក្នុងវិស័យអប់រំសិក្សាធិការ ព្រះពុទ្ធសាសនា សង្គមកិច្ច សុខុមាលភាព ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ និងជាពិសេសព្រះរាជសកម្មភាពជាព្រះប្រធានកិត្តិយសនៃកាកបាទក្រហមកម្ពុជា និងក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី ដែលបានរួមចំណែកយ៉ាងធំធេងក្នុងការលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ និងការលើកកម្ពស់តួនាទីស្ត្រីក្នុងសង្គមកម្ពុជានាពេលកន្លងមក ។

ក្នុងឱកាសដ៏វិសេសវិសាលនេះ ខ្ញុំម្ចាស់ យើងខ្ញុំទាំងអស់គ្នា សូមលើកអញ្ជលីប្រណម្យ បួងសួង ដល់គុណបុណ្យព្រះរតនត្រ័យកែវទាំងបី វត្ថុស័ក្តិសិទ្ធិទាំងឡាយក្នុងលោក ទេវតាថែរក្សាព្រះមហាស្វេតច្ឆត្រ និងព្រះឫទ្ធានុភាពនៃព្រះវិញ្ញាណក្ខន្ធអតីតព្រះមហាក្សត្រ ព្រះមហាក្សត្រីយានីខ្មែរគ្រប់ព្រះអង្គ ជាពិសេសបុណ្យបារមីព្រះកុណា ព្រះមហាវិរក្សត្រ ព្រះវររាជបិតា ព្រះបរមរតនកោដ្ឋ សូមតាមជួយទ្រទ្រង់ថែរក្សាការពារ និងប្រោះព្រំ ប្រទានព្រះពរជ័យ ថ្វាយចំពោះ: **សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ** ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល សូមព្រះអង្គមានព្រះរាជសុខភាពល្អបរិបូរណ៌ ព្រះកាយពលខ្លាំងក្លា ព្រះជន្មាយុយឺនយូរ ព្រះបញ្ញាញាណក្តីថ្លាជានិច្ចនិរន្តរ៍តរៀងទៅ ។

សូម **សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ** ទទួលនូវគោរពភក្តីភាពដ៏ស្មោះស្ម័គ្រ និងសេចក្តីគោរពដ៏ខ្ពង់ខ្ពស់បំផុតពីខ្ញុំម្ចាស់ ។

ថ្ងៃ ៩ស្ញ ៦ឆ្នាំ ខែជេស្ឋ ឆ្នាំរោង សប្តស័ក ព.ស ២៥៦៩
ក្រាបបង្គំទូលថ្វាយនៅរាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែមិថុនា ឆ្នាំ២០២៥
តំណាងស្ថាប័នអយ្យការទូទាំងប្រទេស
អគ្គព្រះរាជអាជ្ញានៃមហាអយ្យការអមតុលាការកំពូល
និងជាប្រធានក្រុមប្រឹក្សាវិន័យនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម

ចាន ណាន

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គុណាការកំពូល

សារលិខិតថ្វាយព្រះពរ

សូមក្រាបបង្គំទូលថ្វាយ
សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ
ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល

បពិតសម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត!

នៅក្នុងឱកាសជ័យមង្គលក្តួតឫក្ស ប្រកបដោយសិរីសួស្តី បវរថ្លៃថ្លាមហាប្រសើរនៃព្រះរាជពិធីបុណ្យចម្រើនព្រះជន្ម **សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ** គម្រប់ ៨៩ព្រះវស្សា យាងចូល ៩០ព្រះវស្សា ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃពុធ ៨រោច ខែជេស្ឋ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០២៥ ខ្ញុំម្ចាស់យើងខ្ញុំជាថ្នាក់ដឹកនាំ ចៅក្រម ក្រឡាបញ្ជី និងមន្ត្រីរាជការទាំងអស់នៃគុណាការកំពូលនៅក្នុងព្រះរាជាណាចក្រកម្ពុជា សូមព្រះបរមរាជានុញ្ញាតអភិវន្ទលំនិនកាយវាចាចិត្តក្រាបបង្គំសម្តែងនូវការគោរពកោតសរសើរ និងកតញ្ញូតាធម៌ដ៏ជ្រាលជ្រៅបំផុតថ្វាយចំពោះ: **សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ** ដែលព្រះអង្គបានលះបង់ព្រះបញ្ញាញាណ ព្រះរាជសកម្មភាពដ៏ឧត្តុង្គឧត្តមថ្លៃថ្លាបំផុត ប្រកបដោយព្រះគុណធម៌ ព្រះមនុស្សធម៌ ក្នុងវិស័យអប់រំសិក្សាធិការព្រះពុទ្ធសាសនា សង្គមកិច្ច សុខុមាលភាព ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ និងជាពិសេសព្រះរាជសកម្មភាពជាព្រះប្រធានកិត្តិយសនៃកាកបាទក្រហមកម្ពុជា និងក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រីដែលបានរួមចំណែកយ៉ាងធំធេងក្នុងការលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ និងការលើកកម្ពស់តួនាទីស្ត្រីក្នុងសង្គមកម្ពុជានាពេលកន្លងមក។

ក្នុងឱកាសដ៏វិសេសវិសាលនេះ ទូលព្រះបង្គំយើងខ្ញុំទាំងអស់គ្នា សូមលើកអញ្ជលីប្រណម្យបួងសួងដល់គុណបុណ្យព្រះរតនត្រ័យ គុណកែវទាំងបី វត្ថុស័ក្តិសិទ្ធិទាំងឡាយក្នុងលោក ទេវតាថែរក្សា ព្រះមហាស្វេតច្ឆត្រ និងព្រះឫទ្ធានុភាព នៃព្រះវិញ្ញាណក្ខន្ធអតីតព្រះមហាក្សត្រ ព្រះមហាក្សត្រីយានីខ្មែរគ្រប់ព្រះអង្គ ជាពិសេសបុណ្យបារមីព្រះកុណា ព្រះមហាវិរក្សត្រ ព្រះវររាជបិតា **ព្រះបរមរតនកោដ្ឋ** សូមតាមជួយទ្រទ្រង់ថែរក្សាការពារ និងប្រោះព្រំ ប្រទានព្រះពរជ័យ ថ្វាយ **សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ** ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល សូមព្រះអង្គមានព្រះរាជសុខភាពល្អបរិបូរណ៌ ព្រះកាយពលខ្លាំងក្លា ព្រះជន្មាយុយឺនយូរ ព្រះបញ្ញាញាណក្តីថ្លាជានិច្ចនិរន្តរ៍តរៀងទៅ។

សូម **សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ទ្រង់ព្រះទទួលនូវគារវភក្តីភាពដ៏ស្មោះស្ម័គ្រ និងសេចក្តីគោរពដ៏ខ្ពង់ខ្ពស់បំផុតទូលព្រះបង្គំយើងខ្ញុំទាំងអស់គ្នា។

ថ្ងៃ ៩ស្ញ ៦ឆ្នាំ ខែជេស្ឋ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
ក្រាបបង្គំទូលថ្វាយនៅរាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែមិថុនា ឆ្នាំ២០២៥
តំណាងស្ថាប័នអយ្យការទូទាំងប្រទេស
ប្រធានគុណាការកំពូល

ជីវ កេង

Embassy of the Republic of the Philippines
Phnom Penh
Kingdom of Cambodia

18 June 2025

Your Majesty,

I have the great honor to convey my deepest respects and the warmest greetings of the Filipino community in Cambodia on the occasion of Your Majesty's 89th birth anniversary.

Your Majesty has spent decades in the service of the Kingdom with exceptional grace and quiet dignity. Inspiring broad support for the Queen Mother's worthy advocacies, the Khmer people visibly derive comfort from Your Majesty's impactful endeavors.

Recalling Her Majesty's warmth and kindness during my courtesy call at the palace on 12 December 2024, I take this occasion to return the blessings of that day with my own heartfelt wishes for the continued happiness and wellbeing of the Queen Mother, His Majesty Preah Bat Samdech Preah Baromneath Norodom Sihamoni, and their beloved Royal Family.

Please receive, Your Majesty, the renewed assurances of my highest esteem.

FLERIDA ANN CAMILLE P. MAYO
Ambassador

HER MAJESTY
Samdech Preah Mahaksatrey
NORODOM MONINEATH SIHANOUK
Queen Mother
The Royal Palace
Phnom Penh, Cambodia

AMBASSADOR

AUSTRALIAN EMBASSY
CAMBODIA

HOM 138-2025

10 June 2025

Her Majesty Queen Mother Norodom Monineath Sihanouk
Preah Vorakreach Meada Cheat Khmer
Royal Palace
Phnom Penh

Your Majesty

On the auspicious occasion of Your Majesty's Birthday Anniversary, I extend my heartfelt congratulations and warmest wishes for Your Majesty's good health, happiness, and longevity.

I have sent to Your Majesty a small token to mark this joyous occasion. I recall that when I saw Your Majesty at the Palace, you shared a generous recollection of your visit to Australia in 1985, and made reference to your love of Australian flowers. I hope this gift will serve as a good reminder of your time in Australia.

May the Kingdom of Cambodia and its people continue to thrive and prosper.

Please accept, Your Majesty, the assurance of my highest consideration and warm regards.

Yours sincerely

Derek Yip
Ambassador of Australia to the Kingdom of Cambodia

ស្តេចត្រាប់បង្កើតទូកថ្មី

សន្មតថាព្រះមហាក្សត្រីនៃនគរមួយ មានឱរសជាតិស្រីតែមួយព្រះអង្គគត់ ព្រះនាងមានព្រះនាមថា ព្រះនាងសុភាវតី ក្នុងមួយព្រះអង្គមានជីវិតរស់នៅក្នុងវាំងដ៏ធំល្អ ជាមួយនឹងមនុស្សបម្រើជាច្រើននាក់ ដែលមានភារកិច្ចខុសៗគ្នា ដើម្បីបម្រើព្រះនាង។ ក្នុងចំណោមមនុស្សទាំងនោះ មានស្ត្រីចាស់ម្នាក់ ដែលមានតួនាទីជាអ្នកថែរក្សាព្រះនាង ចាប់តាំងពីព្រះនាងនៅតូចរហូតដល់ធំឡើង។ ស្ត្រីចាស់នេះមានឈ្មោះថា តាយាយ។ តាយាយមានចិត្តល្អ ស្មោះត្រង់ និងស្រឡាញ់ព្រះនាងដូចជាកូនបង្កើតរបស់ខ្លួនដែរ។ ព្រះនាងក៏ស្រឡាញ់តាយាយខ្លាំងដែរ ព្រោះតាយាយតែងតែនៅជិតព្រះនាងជានិច្ច ហើយតែងតែប្រាប់រឿងនិទានដ៏គួរឱ្យចាប់អារម្មណ៍ជាច្រើនដល់ព្រះនាង។

ក្នុងរដូវក្តៅដ៏ក្តៅគគុកមួយ ព្រះនាងសុភាវតីមានបំណងចង់ទៅលេងនៅតំបន់ឆ្នេរ ដើម្បីសម្រាកកាយ និងស្រស់ស្រាយចិត្ត។ ព្រះនាងក៏ប្រាប់ទៅតាយាយថា ចង់ទៅលេងនៅតំបន់ឆ្នេរ ដើម្បីសម្រាកកាយ និងស្រស់ស្រាយចិត្ត។ តាយាយក៏ប្រាប់ទៅព្រះនាងថា ការទៅលេងនៅតំបន់ឆ្នេរនាពេលនេះ មានការលំបាកច្រើនយ៉ាង ដោយសារតែមានការរាតត្បាតនៃជំងឺកូវីដ-១៩ ដែលធ្វើឱ្យមនុស្សមិនអាចធ្វើដំណើរទៅណាមកណាបានដោយងាយស្រួល ហើយក៏មានការរឹតត្បិតច្រើនយ៉ាងដែលធ្វើឱ្យការធ្វើដំណើរកាន់តែមានការលំបាក។ ប៉ុន្តែព្រះនាងមិនព្រមស្តាប់តាយាយទេ ព្រះនាងនៅតែចង់ទៅលេងនៅតំបន់ឆ្នេរឱ្យបានតែម្តង ដោយសារតែព្រះនាងមានការចង់ដឹងចង់ឃើញច្រើនពេក ហើយក៏ចង់ទៅលេងនៅតំបន់ឆ្នេរដែលមានទេសភាពស្រស់ស្អាត ដែលព្រះនាងមិនធ្លាប់បានទៅលេងពីមុនមក។ ព្រះនាងក៏ប្រាប់ទៅតាយាយថា ព្រះនាងនឹងមិនទៅណាឆ្ងាយទេ ព្រះនាងនឹងទៅតែនៅតំបន់ឆ្នេរដែលនៅជិតៗនេះប៉ុណ្ណោះ ដើម្បីកុំឱ្យមានការលំបាកច្រើនពេក ហើយក៏ដើម្បីកុំឱ្យមានការរឹតត្បិតច្រើនពេកដែរ។ តាយាយក៏ប្រាប់ទៅព្រះនាងថា ការទៅលេងនៅតំបន់ឆ្នេរដែលនៅជិតៗនេះ ក៏មានការលំបាកច្រើនយ៉ាងដែរ ដោយសារតែមានការរឹតត្បិតច្រើនយ៉ាង ដែលធ្វើឱ្យការធ្វើដំណើរកាន់តែមានការលំបាក ប៉ុន្តែព្រះនាងមិនព្រមស្តាប់តាយាយទេ ព្រះនាងនៅតែចង់ទៅលេងនៅតំបន់ឆ្នេរដែលនៅជិតៗនេះ

សារថ្វាយព្រះពរ
សូមក្រាបបង្គំទូលថ្វាយ
សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ
ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល

បពិត្រ សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត!

ទូលព្រះបង្គំយើងខ្ញុំសូមព្រះបរមរាជានុញ្ញាតដ៏ខ្ពង់ខ្ពស់សម្តែងនូវអំណរសាទរនិងសូមគោរពថ្វាយនូវព្រះរាជសព្វសាធុការពរជ័យ បវរសួស្តី សិរីមង្គល វិបុលសុខមហាប្រសើរគ្រប់ប្រការ ថ្វាយ សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរក្នុងឱកាសដ៏មហានក្ខត្តឫក្សនៃព្រះរាជពិធីបុណ្យចម្រើនព្រះជន្មវស្សាគម្រប់ ៨៩ព្រះវស្សា យាងចូល ៩០ព្រះវស្សា នាថ្ងៃពុធទី១៨ ខែមិថុនា ឆ្នាំ២០២៥។

សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ មិនត្រឹមតែជាព្រះមហេសីដែលមានស្នាមីកក្តីដ៏ឧត្តុង្គឧត្តមចំពោះ**ព្រះករុណាព្រះបរមរតនកោដ្ឋ**ជានិច្ចប៉ុណ្ណោះទេ ថែមទាំងជាព្រះវររាជមាតាជាតិខ្មែរដែលប្រកបដោយព្រហ្មវិហារធម៌មានព្រះរាជស្នាព្រះហស្តដ៏ឧត្តុង្គឧត្តមបំផុតក្នុងព្រះរាជបេសកកម្មបម្រើជាតិ សាសនា និងប្រជារាស្ត្រ តាមរយៈព្រះរាជសកម្មភាពមនុស្សធម៌ សង្គមកិច្ច វប្បធម៌ សាសនា និងការយកព្រះរាជហឫទ័យទុកដាក់ខ្ពស់ចំពោះសុខទុក្ខ និងជីវភាពរបស់ប្រជារាស្ត្រខ្មែរទូទាំងប្រទេស និងជាព្រះរាជគំរូដ៏ខ្ពង់ខ្ពស់បំផុតតំណាងឱ្យស្ត្រីកម្ពុជាក្នុងការចូលរួម និងគាំទ្រលើកស្ទួយសមភាពយេនឌ័រ សកម្មភាពមនុស្សធម៌ និងការអភិវឌ្ឍសង្គមជាតិ ដែលទូលព្រះបង្គំយើងខ្ញុំសូមសម្តែងនូវគោរពកោតសូបវ៌ស្ងែងដោយស្មោះអស់ពីដួងចិត្ត។

ក្នុងវាគាសដ៏មហាសិរីមង្គលប្រពៃថ្លៃថ្លានេះ ទូលព្រះបង្គំយើងខ្ញុំ សូមព្រះបរមរាជានុញ្ញាតលើកហត្ថប្រណម្យ បួងសួងដល់ទេវតាថែរក្សាទឹកដីនៃព្រះរាជាណាចក្រកម្ពុជា គុណបុណ្យព្រះរតនត្រ័យ និងវត្ថុស័ក្តិសិទ្ធិទាំងឡាយក្នុងលោក ជាពិសេសបុណ្យបារមីនៃដួងព្រះវិញ្ញាណក្ខន្ធ **ព្រះករុណាព្រះបរមរតនកោដ្ឋ** សូមព្រះអង្គតាមជួយបីបាច់ថែរក្សា ការពារ និងប្រោះព្រំ សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ព្រមទាំងព្រះរាជវង្សានុវង្ស សូមទ្រង់ប្រកបដោយព្រះពុទ្ធពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

សូមព្រះអង្គទ្រង់ មានព្រះរាជកាយពលមាំមួន ព្រះរាជបញ្ញាញាណភ្លឺថ្លាត្រចះត្រចង់ ព្រះរាជសុខភាពល្អបរិបូរណ៌ ព្រះជន្មាយុយឺនយូរ ដើម្បីគង់ប្រថាប់ជាម្លប់ដ៏ត្រជាក់ត្រជំដល់ប្រជារាស្ត្រខ្មែរទូទាំងព្រះរាជាណាចក្រកម្ពុជា។

សូម សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ទ្រង់ប្រោសព្រះរាជទានមេត្តាទទួលនូវគោរវកតញ្ញូតាធម៌ដ៏ខ្ពង់ខ្ពស់បំផុតពីទូលព្រះបង្គំយើងខ្ញុំ។

ថ្ងៃពុធ ៨រោច ខែជេស្ឋ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
ក្រាបបង្គំទូលថ្វាយនៅរាជធានីភ្នំពេញ ថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០២៥

សហស្ថាបនិកក្រុមហ៊ុន វឌ្ឍនៈ គ្រុប

អ្នកឧកញ៉ា សំ អាង អ្នកឧកញ៉ា ឈុន លាង

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
លេខៈ ៤៨ អយក.តសជ

សារលិខិតថ្វាយព្រះពរ
សូមក្រាបបង្គំទូលថ្វាយ
សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ
ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល
ក្នុងឱកាសព្រះរាជពិធីបុណ្យចម្រើនព្រះជន្ម គម្រប់ព្រះជន្ម ៨៩ យាងចូល ៩០ ព្រះវស្សា
សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត

ក្នុងព្រះរាជពិធីបុណ្យចម្រើនព្រះជន្ម គម្រប់ព្រះជន្ម ៨៩ យាងចូល ៩០ ព្រះវស្សា ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី ១៨ ខែ មិថុនា ឆ្នាំ ២០២៥ ទូលព្រះបង្គំយើងខ្ញុំទាំងអស់គ្នា ជាថ្នាក់ដឹកនាំ មន្ត្រីរាជការ សាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ កីឡាករ កីឡាការិនី ព្រមទាំងនិស្សិត សិស្សទាំងអស់នៃក្រសួងអប់រំ យុវជន និងកីឡា សូមព្រះបរមារាជានុញ្ញាតលំនិងកាយសម្តែងនូវអំណរសាទរប្រកបដោយមនោសញ្ចេតនាកែវភ្លៃលែងបំផុតដែល **សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ** តែងតែយកព្រះទ័យទុកដាក់អស់ពីព្រះកាយពល ព្រះបញ្ញាញាណ និងព្រះរាជទ្រព្យ ដើម្បីចូលរួមចំណែកយ៉ាងសកម្មក្នុងការអភិវឌ្ឍសង្គម ជាពិសេសនៅក្នុងវិស័យមនុស្សធម៌ ។

ដើម្បីជាការតបស្នងនូវព្រះមហាករុណាទិគុណដ៏វិសេសវិសាល នៅក្នុងឱកាសដ៏មហានក្ខត្តឫក្សនេះ ទូលព្រះបង្គំយើងខ្ញុំទាំងអស់គ្នា សូមលើកហត្ថប្រណមបួងសួងចំពោះគុណបារមីនៃអតីតព្រះមហាក្សត្រ ព្រះមហាក្សត្រីយានីខ្មែរគ្រប់ព្រះអង្គ តេជៈបារមីនៃទេព្តាថែរក្សាព្រះមហាស្វេតច្ឆត្រ គុណបុណ្យនៃព្រះរតនត្រ័យ និងវត្ថុស័ក្តិសិទ្ធិក្នុងលោកទាំងអស់ សូមព្រះមេត្តាជួយបីបាច់ថែរក្សា និងប្រោះព្រំសព្វសាធុការពរ សិរីសួស្តី ជ័យមង្គល វិបុលសុខ បវរមហាប្រសើរ ថ្វាយ **សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត សូមព្រះអង្គ ប្រកបដោយពុទ្ធពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ ដើម្បីគង់ជាម្លប់ដ៏ត្រជាក់ សម្រាប់ជាទីជ្រកកោនរបស់ប្រជារាស្ត្រខ្មែរគ្រប់រូបរបស់ព្រះអង្គ ជានិច្ចនិរន្តរ៍តរៀងទៅ។

សូម **សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ទ្រង់ព្រះមេត្តាទទួលនូវគោរវកតញ្ញូតាធម៌ និងស្នាមីកក្តីដ៏ខ្ពង់ខ្ពស់បំផុត អំពីទូលព្រះបង្គំយើងខ្ញុំ ទាំងអស់គ្នា។

សេចក្តីគួរ ឬពុំគួរ សូម **សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ទ្រង់ព្រះមេត្តាប្រោសព្រះរាជទានទោសដោយសេចក្តីអនុគ្រោះ។

ថ្ងៃ ចន្ទ ៦រោច ខែ ជេស្ឋ ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៩
ក្រាបបង្គំទូលថ្វាយនៅរាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែមិថុនា ឆ្នាំ២០២៥
ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

កិត្តិបណ្ឌិត ឃុន ឥសាលោ
ឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ

សូមគ្រាបថ្វាយបង្គំ
សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ
ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល
ក្នុងឱកាសបុណ្យចម្រើនព្រះជន្មគម្រប់៨៩ព្រះវស្សា យាងចូល៩០ព្រះវស្សា

ជាទីគោរពស្រឡាញ់ដ៏ស្មោះស្ម័គ្រគិតខ្ពង់ខ្ពស់បំផុត!

ក្នុងឱកាសដ៏មហានក្ខត្តឫក្សឧត្តុង្គឧត្តម នៃព្រះរាជពិធីបុណ្យចម្រើនព្រះជន្មគម្រប់ ៨៩ព្រះវស្សា យាងចូល ៩០ព្រះវស្សារបស់ **សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ** ដែលនឹងឈានមកដល់នៅថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០២៥ ខាងមុខនេះ ទូលព្រះបង្គំយើងខ្ញុំ ឡុង វិសាលោ និងភរិយា ស៊ុន សុថាត ព្រមទាំងកូនៗ មានសេចក្តីសោមនស្សរីករាយឥតឧបមា សូមព្រះបរមារាជានុញ្ញាតលំនិនកាយថ្វាយនូវព្រះរាជសព្វសាធុការពរជ័យ បវរសួស្តី សិរីវឌ្ឍនា ថ្វាយព្រះករុណាថ្លៃវិសេស ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត សូម **សម្តេចព្រះមហាក្សត្រី** ប្រកបដោយព្រះរាជសុខភាពល្អពេញបរិបូរណ៌ ព្រះពលានុភាពមាំមួន ព្រះបញ្ញាញាណក្លឹងក្លា និងចម្រើនព្រះជន្មាយុយឺនយូរ ជាងរយព្រះវស្សា ដើម្បីព្រះអង្គគង់ប្រថាប់ជាមហាម្លប់ដ៏ត្រជាក់ត្រជំសម្រាប់ប្រជានុរាស្ត្រគ្រប់ការកោន តរៀងទៅ ។

ក្នុងអភិមង្គលដ៏វិសេសវិសាលនេះ ទូលព្រះបង្គំយើងខ្ញុំទាំងអស់ សូមព្រះបរមារាជានុញ្ញាតអភិវន្ទ ថ្វាយនូវព្រះរាជកតញ្ញ កតវេទិតាធម៌ និងព្រះវិសុទ្ធគុណដ៏ធំធេងក្រៃលែងចំពោះ **សម្តេចព្រះមហាក្សត្រី** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ដែលព្រះអង្គតែងតែយាងបំពេញព្រះរាជសកម្មភាពជាប្រវត្តិសាស្ត្រ ក្នុងពុទ្ធចក្រនិងអាណាចក្រ ដង្ហែតាមព្រះរាជគន្លងគំរូវីរភាពនៃ **ព្រះករុណា ព្រះមហាវីរក្សត្រ ព្រះបរមរតនកោដ្ឋ** និង **ព្រះករុណា ជាអម្ចាស់ជីវិតលើក្បាល** លើសពីនេះទៅទៀត **សម្តេចព្រះមហាក្សត្រី** ព្រះអង្គតែងតែយាងបំពេញព្រះរាជបូជនីយកិច្ចផ្ញែកមនុស្សធម៌។

ស្ថិតក្នុងឱកាសបុណ្យចម្រើនព្រះជន្មដ៏ឧត្តុង្គឧត្តមនេះ ទូលព្រះបង្គំយើងខ្ញុំទាំងអស់ សូមព្រះបរមារាជានុញ្ញាតលំនិនកាយវាចាចិត្ត បួងសួងដល់បារមី ព្រះមហាស្វេតច្ឆត្រ វត្ថុសិត្តិសិទ្ធិទាំងឡាយក្នុងលោក ព្រះវិញ្ញាណក្ខន្ធអតីតព្រះមហាក្សត្រ ព្រះមហាក្សត្រីយានីខ្មែរគ្រប់ព្រះអង្គ ជាពិសេស ព្រះបារមី ព្រះវិញ្ញាណក្ខន្ធ ព្រះបរមរតនកោដ្ឋ សូមអភិបាលប្រោះព្រំគ្រងរក្សាព្រះអង្គទាំងទ្វេរ មានព្រះពលានុភាពខ្លាំងក្លា ព្រះបញ្ញាញាណក្លឹងក្លា ព្រះកាយពលមាំមួន ព្រះរាជសុខភាពល្អបរិបូរណ៌ ព្រះជន្មាយុយឺនយូរ ដើម្បីគង់ប្រថាប់ជាម្លប់ដ៏ត្រជាក់ត្រជំដល់ប្រជានុរាស្ត្រជាកូនចៅរស់នៅក្នុងសេចក្តីសុខក្សេមក្សាន្តឆ្ពោះទៅកាន់វឌ្ឍនភាពជានិច្ចនិរន្តរ៍ និងចម្រុងចម្រើនថ្កុំថ្កើនទូទាំងព្រះនគរ។

សូម **សម្តេចព្រះមហាក្សត្រី** មេត្តាទទួលការគោរពនិងស្រឡាញ់ដ៏ស្មោះស្ម័គ្រនិងខ្ពង់ខ្ពស់បំផុតពីទូលព្រះបង្គំយើងខ្ញុំទាំងអស់គ្នា៕

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃអង្គារ ៧រោច ខែជេស្ឋ ឆ្នាំម្សាញ់ សប្តស័ក ព.ស ២៥៦៩
ត្រូវនឹងថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២៥

ពីទូលព្រះបង្គំ **កិត្តិបណ្ឌិត ឃុន ឥសាលោ** និងភរិយា **ស៊ុន សុថាត**

គណៈសង្ឃនាយក
នៃព្រះរាជាណាចក្រកម្ពុជា
លេខ:.....ស.ន.ក.ជ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ព្រះរាជសារថ្វាយព្រះពរ
សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ
ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល
ជាទីស្រឡាញ់រាប់អានដ៏ជ្រាលជ្រៅបំផុតក្នុងព្រះធម៌

ក្នុងវរកាសដ៏មហានក្ខត្តឫក្ស នៃព្រះរាជពិធីបុណ្យចម្រើនព្រះជន្ម **សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ** ជាទីគោរពស្រឡាញ់ដ៏ខ្ពង់ខ្ពស់បំផុតក្នុងព្រះធម៌ គម្រប់ ៨៩ព្រះវស្សា យាងចូល ៩០ព្រះវស្សា នាថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០២៥ ខាងមុខនេះ ក្នុងព្រះបរមនាម សម្តេចព្រះអគ្គមហាសង្ឃរាជាធិបតី **ន ន្ត ធ៊ែ ត** សម្តេចព្រះមហាសង្ឃរាជ នៃព្រះរាជាណាចក្រកម្ពុជា គណៈសង្ឃនាយក សម្តេចព្រះសង្ឃ ព្រះមន្ត្រីសង្ឃ ព្រះថេរានុត្ថេរៈ និងអត្មាភាពផ្ទាល់ សូមសម្តែងនូវមនោសញ្ចេតនាសោមនស្សរំកើបរីករាយយ៉ាងក្រៃលែងថ្វាយ **សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ** ជាទីគោរពស្រឡាញ់ដ៏ខ្ពង់ខ្ពស់បំផុតក្នុងព្រះធម៌។

គណៈសង្ឃពុទ្ធសាសនាកម្ពុជា សូមសម្តែងនូវការចងចាំជានិច្ចចំពោះព្រះរាជស្នាព្រះហស្តដ៏ឧត្តុង្គឧត្តមថ្លៃថ្លាបំផុតរបស់ **ម្ហួងម៉ែជាអម្ចាស់** ជាទីគោរពស្រឡាញ់ដ៏ខ្ពង់ខ្ពស់បំផុត ក្នុងព្រះរាជបេសកកម្មបម្រើជាតិ សាសនា និងប្រជារាស្ត្រ តាមរយៈព្រះរាជសកម្មភាពមនុស្សធម៌ សង្គមកិច្ច វប្បធម៌ សាសនា និងការយកព្រះរាជហឫទ័យទុកដាក់ខ្ពស់ចំពោះសុខទុក្ខ និងជីវភាពរបស់ប្រជារាស្ត្រខ្មែរទូទាំងប្រទេស ជាពិសេសយកព្រះរាជហឫទ័យទុកដាក់ខ្ពស់ចំពោះសុខទុក្ខព្រះសង្ឃដែលជាឧត្តមភេទ ជាបុញ្ញក្ខេត្តជាស្រែបុណ្យដ៏ប្រសើរ។ **សម្តេចព្រះមហាក្សត្រី** បានបំពេញព្រះរាជបេសកកម្មដ៏មហាថ្លៃថ្លា ដើម្បីបុព្វហេតុជាតិមាតុភូមិកម្ពុជា ប្រកបដោយព្រះប្រាជ្ញាវិហារធម៌ដ៏ខ្ពង់ខ្ពស់ ព្រះទ័យជ្រះថ្លាបរិសុទ្ធ លះបង់ព្រះរាជកាយពល ស្មារតី និងព្រះរាជបញ្ញាញាណរហូតជាដរាបមក។

ក្នុងឱកាសដ៏មានសិរីមង្គលឧត្តុង្គឧត្តមនេះ គណៈសង្ឃពុទ្ធសាសនាកម្ពុជា សូមបួងសួងដល់គុណបុណ្យ ព្រះរតនត្រ័យ គុណកែវទាំងបី ទេវតាឆ្នាំថ្មីព្រះនាម គោរាគទេវី ទេវតារក្សាព្រះមហាស្វេតច្ឆត្រ ព្រមទាំងព្រះរាជគេជបារមី នៃអតីតព្រះមហាក្សត្រខ្មែរគ្រប់ព្រះអង្គ ជាពិសេសព្រះវិញ្ញាណក្ខន្ធព្រះបរមរតនកោដ្ឋ សូម ព្រះអង្គ បីបាច់ថែរក្សាអភិបាលប្រោះព្រំនូវព្រះរាជសព្វសាធុការពរជ័យ ថ្វាយ **សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ** ជាទីគោរពស្រឡាញ់ដ៏ខ្ពង់ខ្ពស់បំផុតក្នុងព្រះធម៌ សូមប្រកបដោយព្រះរាជសុខភាព ល្អបរិបូរណ៌ ព្រះកាយពលមាំមួន ព្រះបញ្ញាញាណក្លឹងក្លា ព្រះជន្មាយុយឺនយូរ និងប្រកបដោយព្រះពុទ្ធពរដ៏ប្រសើរថ្លៃថ្លាទាំងឡាយបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ ជានិច្ចនិរន្តរ៍កុំបីឃ្លៀងឃ្លាតឡើយ។

សូម **សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល** ទ្រង់ព្រះមេត្តាទទួលនូវសេចក្តីស្រឡាញ់រាប់អានដ៏ជ្រាលជ្រៅបំផុតក្នុងព្រះធម៌ ពីអត្មាភាព៕

ថ្ងៃអង្គារ ៧រោច ខែជេស្ឋ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
ចម្រើនពរថ្វាយនៅរាជធានីភ្នំពេញ ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២៥

សម្តេចព្រះអគ្គមហាសង្ឃរាជាធិបតី អំ លីមហេង

Nation Religion King

Her Majesty, Queen Mother Norodom Monineath Siha nouk
Royal Palace, Phnom Penh
The Kingdom of Cambodia

June **18, 2025**
Born on June 18, 1936, she turns 89 in 2025

Your Majesty,

Happy Birthday!

On this special occasion, I, my family, the global community, and the Cambodian nation join in celebrating your birthday. May your special day bring peace and prosperity to Cambodia, its leaders, and the global community, fostering everlasting harmony.

We wish you continued good health and strength as you guide the nation towards peace, harmony, and prosperity.

With the highest gratitude and respect,

pa nous pan

Hon. Pa Nous Pan
Honorary Consul General
The Royal Consulate of the Kingdom of Cambodia in Texas
2521 Pear Tree Lane
Garland, Texas 75042
E-Mail: pan_southeastasia@yahoo.com
Tel: + 1(469)237-9747

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាល
ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
លេខ.១១៧៣.ក.អ.ក.

ថ្ងៃ៨កើត ខែជេស្ឋ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ, ថ្ងៃទី.....ខែ.....ឆ្នាំ២០២៥

សារលិខិតថ្វាយព្រះពរ
សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ
ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល
បពិត្រសម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត!

តាងនាមថ្នាក់ដឹកនាំ មន្ត្រីរាជការ និងបុគ្គលិក នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ទូលព្រះបង្គំជាខ្ញុំ និងភរិយា សូមព្រះបរមរាជានុញ្ញាត អភិវន្ទលំនិនកាយ វាចាចិត្ត ក្រាបបង្គំថ្វាយនូវព្រះរាជសព្ទសាធុការពរជ័យ បវរសួស្តី សិរីមង្គល វិបុលសុខ មហាប្រសើរគ្រប់ប្រការថ្វាយចំពោះ **សម្តេចព្រះមហាក្សត្រី** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់ ក្នុងឱកាសដ៏មហាសិរីមង្គលាភិរម្យប្រកបដោយក្តីសោមនស្សរីករាយនៃពិធីបុណ្យចម្រើនព្រះជន្មាយុគម្រប់ ៨៩ព្រះវស្សា យាងចូល ៩០ព្រះវស្សា ដែលនឹងឈានចូលមកនាថ្ងៃពុធ ៨រោច ខែជេស្ឋ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០២៥ ខាងមុខ។

ឆ្លៀតក្នុងឱកាសដ៏ប្រពៃថ្លៃថ្លានេះ ទូលព្រះបង្គំ សូមព្រះបរមរាជានុញ្ញាតថ្វាយនូវកតញ្ញូកតវេទិតាធម៌យ៉ាងជ្រាលជ្រៅបំផុតចំពោះព្រះរាជហឫទ័យ និងព្រះរាជសកម្មភាពប្រកបដោយព្រះព្រហ្មវិហារធម៌ ដែលព្រះអង្គបានបំពេញក្នុងវិស័យព្រះពុទ្ធសាសនា សង្គមកិច្ច អប់រំសិក្សាធិការ និងសុខុមាលភាពទូទៅនៃប្រជានុរាស្ត្រជាកូនចៅ ចៅទួតរបស់ព្រះអង្គ ទទួលបាននូវភោពកក់ក្តៅ ត្រជាក់ត្រជំ សុខដុមរមនា ដែលជាព្រះវិភាគទានដ៏មានតម្លៃមិនអាចគណនាបានឡើយ។

ជាថ្មីម្តងទៀត ទូលព្រះបង្គំ សូមលើកហត្ថប្រណមបួងសួងដល់គុណបុណ្យ ព្រះរតនត្រ័យ គុណកែវទាំងបី ទេព្តារក្សាព្រះមហាស្វេតច្ឆត្រ បារមីនៃអតីតព្រះមហាក្សត្រ ព្រះមហាក្សត្រីយានីខ្មែរគ្រប់ព្រះអង្គ ជាពិសេសបុណ្យបារមីនៃជង្គង់ព្រះវិញ្ញាណក្ខន្ធ **ព្រះករុណាព្រះបាទសម្តេចព្រះនរោត្តម សីហនុ ព្រះបរមរតនកោដ្ឋ** និងទេវតាឆ្នាំថ្មី ឆ្នាំម្សាញ់ សូមព្រះមេត្តាប្រោះព្រំព្រះរាជសព្ទសាធុការពរជ័យ បវរសួស្តី សិរីវឌ្ឍនា វិបុលសុខ មហាប្រសើរថ្វាយចំពោះ **សម្តេចព្រះមហាក្សត្រី** សូមទ្រង់ប្រកបដោយព្រះរាជសុខភាពល្អបរិបូរណ៌ ព្រះកាយពលមាំមួនខ្លាំងក្លា ព្រះបញ្ញាញាណភ្លឺថ្លា ព្រះជន្មាយុយឺនយូរជាងរយព្រះវស្សាចាកផុតពីព្រះរោគាព្យាធិទាំងឡាយ និងសូមទ្រង់ប្រកបដោយព្រះពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ និងពលៈ ជានិច្ចនិរន្តរ៍តរៀងទៅ។

សូម **សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ទ្រង់ព្រះមេត្តាទទួលនូវអភិវន្ទកិច្ច និងកតញ្ញូតាធម៌ ដ៏ខ្ពង់ខ្ពស់បំផុតអំពីទូលព្រះបង្គំជាខ្ញុំ និងភរិយា។

ឧបនាយករដ្ឋមន្ត្រី
អនុប្រធានទី១ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

ស៊ុន ចាន់ថុល

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាគណរាជធានីភ្នំពេញ

លេខ:.....ស.ធ.ភ.ព

សារលិខិតថ្វាយព្រះពរ

សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ

ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល

សម្តេចព្រះមហាក្សត្រី ជាទីស្រឡាញ់រាប់អានដ៏ជ្រាលជ្រៅបំផុតក្នុងព្រះហឫទ័យ!

ក្នុងវេលាកាសដ៏មហានក្ខត្តឫក្សនៃព្រះរាជពិធីបុណ្យចម្រើនព្រះជន្ម **សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ** ជាទីស្រឡាញ់ដ៏ខ្ពង់ខ្ពស់បំផុតក្នុងព្រះហឫទ័យ គម្រប់ ៨៩ព្រះវស្សា ឃាងចូល ៩០ព្រះវស្សា នាថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០២៥ ខាងមុខនេះ ក្នុងព្រះបរមនាម **សម្តេចព្រះអគ្គមហាសង្ឃរាជាធិបតី ន ន្ត ង៉ែ ត** សម្តេចព្រះមហាសង្ឃរាជ នៃព្រះរាជាណាចក្រកម្ពុជា និងអាត្មាភាពផ្ទាល់ សូមសម្តែងនូវមនោសញ្ចេតនាសោមនស្សរីករាយយ៉ាងក្រៃលែង និងសូមចម្រើនពរថ្វាយនូវព្រះរាជសព្វសាធុការពរជ័យបវរសួស្តី សិរីមង្គលប្រៃលសុខមហាប្រសើរគ្រប់ប្រការ ថ្វាយ **សម្តេចព្រះមហាក្សត្រី** សូមព្រះអង្គទ្រង់មានព្រះរាជកាយពលមាំមួន ព្រះរាជបញ្ញាញាណភ្លឺថ្លាគ្រចះគ្រចង់ ព្រះរាជសុខភាពល្អបរិបូរណ៌ ព្រះជន្មាយុយឺនយូរ ដើម្បីគង់ប្រថាប់ជាម្លប់ដ៏ត្រជាក់ត្រជំដល់ប្រជារាស្ត្រខ្មែរទូទាំងព្រះរាជាណាចក្រកម្ពុជា។

ព្រះសង្ឃគ្រប់ព្រះអង្គក្នុងរាជធានីភ្នំពេញ និងអាត្មាភាពផ្ទាល់ សូមសម្តែងនូវកោរចងចាំជានិច្ចចំពោះព្រះរាជស្នាព្រះហស្តដ៏ឧត្តុង្គឧត្តមបំផុតរបស់ **ឪ ឡុ ង ម៉ែ ដា អ ម្ចាស់** ជាទីគោរពស្រឡាញ់ដ៏ខ្ពង់ខ្ពស់បំផុត ក្នុងព្រះរាជបេសកកម្មបម្រើជាតិ សាសនា និងប្រជារាស្ត្រ តាមរយៈព្រះរាជសកម្មភាពមនុស្សធម៌ សង្គមកិច្ច វប្បធម៌ សាសនា និងការយកព្រះរាជហឫទ័យទុកដាក់ខ្ពស់ចំពោះសុខទុក្ខ និងជីវភាពរបស់ប្រជារាស្ត្រខ្មែរទូទាំងប្រទេស ជាពិសេសយកព្រះរាជហឫទ័យទុកដាក់ខ្ពស់ចំពោះសុខទុក្ខព្រះសង្ឃដែលជាឧត្តមគេហ ជាបុញ្ញក្ខេត្ត ជាស្រែបុណ្យដ៏ប្រសើរ។ **សម្តេចព្រះមហាក្សត្រី** បានបំពេញព្រះរាជបេសកកម្មដ៏មហាថ្លៃថ្លា ដើម្បីបុព្វហេតុជាតិមាតុភូមិកម្ពុជា ប្រកបដោយព្រះប្រាជ្ញាវៃឆ្លាតធម៌ដ៏ខ្ពង់ខ្ពស់ ព្រះទ័យជ្រះថ្លាបរិសុទ្ធ លះបង់ព្រះរាជកាយពល ស្មារតី និងព្រះរាជបញ្ញាញាណ រហូតជាដរាបមក។

អាត្មាភាព សូមបួងសួងដល់ទេវតាថែរក្សាទឹកដី នៃព្រះរាជាណាចក្រកម្ពុជា គុណបុណ្យព្រះតេនត្រ័យ និងវត្ថុស័ក្តិសិទ្ធិទាំងឡាយក្នុងលោក ជាពិសេសបុណ្យបារមីនៃដួងព្រះវិញ្ញាណក្ខន្ធ ព្រះករុណាព្រះបរមរតនកោដ្ឋ សូមព្រះអង្គតាមបីបាច់ថែរក្សាការពារ និងប្រោះព្រំ **ឪ ឡុ ង ម៉ែ ដា អ ម្ចាស់** ជាទីគោរពស្រឡាញ់ដ៏ខ្ពង់ខ្ពស់បំផុត ព្រមទាំងព្រះរាជវង្សានុវង្ស សូមទ្រង់ប្រកបដោយព្រះពុទ្ធពរទាំងឡាយបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

សូម **សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ** ទ្រង់ព្រះមេត្តាទទួលនូវសេចក្តីស្រឡាញ់រាប់អានដ៏ជ្រាលជ្រៅបំផុតក្នុងព្រះហឫទ័យពីអាត្មាភាព៕

ថ្ងៃអង្គារ៍ ៧រោច ខែជេស្ឋ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
ចម្រើនពរថ្វាយនៅរាជធានីភ្នំពេញ ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២៥

ព្រះមេគណរាជធានីភ្នំពេញ

សម្តេចព្រះពុទ្ធជ័យមុនី បណ្ឌិត ប៊ឹម សន

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាគណ
គណៈធម្មយុត្តិកនិកាយខេត្តកណ្តាល
សម្តេចព្រះមន្តលទេព្វាចារ្យ ឥន្ទ្រ អានេតា
សម្តេចព្រះសង្ឃនាយករង នៃគណៈធម្មយុត្តិកនិកាយ
នៃព្រះរាជាណាចក្រកម្ពុជា
ព្រះមេគណគណៈធម្មយុត្តិកនិកាយខេត្តកណ្តាល

សូមថ្វាយព្រះពរ

សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ

ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល

ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត!

បវិតក្នុងព្រះបរមរាជវរោកាសដ៏ឧត្តុង្គឧត្តមប្រសើរថ្លៃថ្លា ប្រកបដោយដោយសេចក្តីសោមនស្សរីករាយបំផុតនៃព្រះរាជពិធីចម្រើនព្រះជន្មវស្សារបស់ **សម្តេចព្រះមហាក្សត្រី** ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត គម្រប់ ៨៩ ឃាងចូល ៩០ ព្រះវស្សា នៅថ្ងៃពុធ ៨រោច ខែជេស្ឋ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០២៥ ខាងមុខនេះ។

អាត្មាភាពក្នុងនាមព្រះមន្ត្រីសង្ឃសហការី នៃសាលាគណគណៈធម្មយុត្តិកនិកាយខេត្តកណ្តាល ព្រះគ្រូអនុគណ ព្រះគ្រូចៅអធិការ លោកអាចារ្យ គណៈកម្មការ លោកជំនដី លោកតាជី និងពុទ្ធបរិស័ទគ្រប់វត្តនៃគណៈធម្មយុត្តិកនិកាយខេត្តកណ្តាល និងក្នុងនាមអាត្មាភាពផ្ទាល់ សូមព្រះបរមាជានុញ្ញាតសម្តែងអំណរសាទរប្រកបដោយសេចក្តីសោមនស្សរីករាយយ៉ាងក្រៃលែងថ្វាយ **សម្តេចព្រះមហាក្សត្រី** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត។

អាត្មាភាពសូមយកព្រះបរមរាជវរោកាសដ៏មហានក្ខត្តឫក្សនេះ សូត្រព្រះបរិត្តពុទ្ធមន្តបួងសួងដល់គុណបុណ្យព្រះតេនត្រ័យ បារមីទេវតាថែរក្សាទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ទេវតាថែរក្សាព្រះពុទ្ធសាសនា ទេវតាថែរក្សាព្រះមហាស្វេតច្ឆត្រ នៃព្រះមហាក្សត្រីខ្មែរគ្រប់ព្រះអង្គ ព្រមទាំងព្រះទសបារមីទេវតាថែរក្សាគ្រប់ស្ថានទីវត្ថុស័ក្តិសិទ្ធទូទាំងព្រះរាជាណាចក្រកម្ពុជា និងទូទាំងសកលលោក និង**ទេវតាឆ្នាំថ្មីព្រះនាមគោរគទេវី** សូមជួយឃុំគ្រងបីបាច់រក្សាការពារថ្វាយព្រះរាជសព្វសាធុការពរជ័យសិរីមង្គលបវរមុខាបវរមហាប្រសើរថ្វាយចំពោះ **សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ** ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត សូមព្រះអង្គស្តេចទ្រង់បានប្រកបដោយព្រះពុទ្ធពរជ័យដ៏វិសេសថ្លៃថ្លាបំផុត ទ្រង់បានប្រាសចាកនូវព្រះរោគាពាធមានព្រះរាជសុខុមាលភាពល្អបរិបូរណ៌ ព្រះរាជកាយពលមាំមួន ព្រះរាជជន្មវស្សាយឺនយូរគប់រយព្រះវស្សា ព្រះរាជបញ្ញាញាណភ្លឺថ្លាវាងវៃ ព្រះរាជចេស្តាឈ្នះអស់អរិរាជសត្រូវគ្រប់ទិសទី ស្តេចទ្រង់គង់ជាដួងព្រលឹងជាតិខ្មែរ និងជាមហាម្លប់ដ៏ត្រជាក់ដល់ប្រជារាស្ត្រខ្មែរ ជាកូនចៅ ចៅទួត ចៅលួត របស់ព្រះអង្គអស់កាលជានិច្ចនិរន្តរ៍តរៀងទៅ។

ថ្ងៃចន្ទ ៦រោច ខែជេស្ឋ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
ត្រូវនឹងថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២៥
អាត្មាភាពសម្តេចព្រះសង្ឃនាយក
នៃគណៈធម្មយុត្តិកនិកាយនៃព្រះរាជាណាចក្រកម្ពុជា
ព្រះមេគណគណៈធម្មយុត្តិកនិកាយខេត្តកណ្តាល
និងជាព្រះចៅអធិការវត្តព្រះឥន្ទសាមគ្គីធម៌
សូមថ្វាយព្រះពរ

សម្តេចព្រះមន្តលទេព្វាចារ្យ ឥន្ទ្រ-អានេតា

Ambassador
of the Republic of Indonesia
Phnom Penh

Phnom Penh, 17 June 2025

Her Majesty Queen Mother
Norodom Monineath Sihanouk
Kingdom of Cambodia
PHNOMPENH

Your Majesty,

On the auspicious occasion of the 89th Birthday Anniversary of Your Majesty Queen Mother Norodom Monineath Sihanouk, the Indonesian community in Cambodia joins me in wishing Your Majesty four sublime blessings of Lord Buddha: longevity, good health, great happiness and wisdom.

In wishing Your Majesty a solemn celebration, kindly accept the assurances of my highest esteem.

DUTA BESAR REPUBLIK INDONESIA PHNOM PENH

Santo Darmosumarto
Ambassador Extraordinary and Plenipotentiary

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន
លេខ.០០៩៧ ស.ណ.ជ.ប.គ.ញ.

សារលិខិតថ្វាយព្រះពរ
សូមក្រាបបង្គំទូលថ្វាយ
សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ
ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល
នៅក្នុងឱកាសព្រះរាជពិធីបុណ្យចម្រើនព្រះជន្មាយុគម្រប់ ៨៩ ឃានចូល ៩០ ព្រះវស្សា
សម្តេចព្រះមហាក្សត្រី ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត!

ទូលព្រះបង្គំជាខ្ញុំ តាងនាមថ្នាក់ដឹកនាំ មន្ត្រីរាជការស៊ីវិល និងកងកម្លាំងទាំងអស់ នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន និងទូលព្រះបង្គំផ្ទាល់ព្រមទាំងភរិយា សូមព្រះបរមាជានុញ្ញាតសម្តែងគារវកិច្ច ក្នុងមនោសញ្ចេតនារំកើបរីករាយយ៉ាងក្រៃលែង ថ្វាយ **សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត** ក្នុងឱកាសប្រកបដោយអភិសិរីមង្គលនៃព្រះរាជពិធីបុណ្យចម្រើនព្រះជន្មាយុគម្រប់ **៨៩** ឃានចូល **៩០** ព្រះវស្សា របស់ **សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ** ដែលនឹងប្រព្រឹត្តទៅនាថ្ងៃពុធ ៨រោច ខែជេស្ឋ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹង**ថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០២៥** ខាងមុខនេះ។

ទូលព្រះបង្គំយើងខ្ញុំទាំងអស់គ្នា សូមព្រះបរមាជានុញ្ញាតក្រាបបង្គំថ្វាយនូវកតញ្ញូតាធម៌និងកតវេទិតាធម៌យ៉ាងជ្រាលជ្រៅបំផុតចំពោះព្រះរាជគុណូបការៈក្នុងព្រះរាជសកម្មភាពដ៏ឧត្តុង្គឧត្តមរបស់ **សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ** ដែលព្រះអង្គទ្រង់តែងចំណាយព្រះកាយពល ព្រះបញ្ញាញាណ និងព្រះរាជទ្រព្យផ្ទាល់ខ្លួន ក្នុងបុព្វហេតុដើម្បីសេចក្តីសុខក្សេមក្សាន្តចំពោះមាតុភូមិកម្ពុជា ជាពិសេសព្រះអង្គទ្រង់តែងមានទីកព្រះទ័យជ្រះថ្លាបរិសុទ្ធចំពោះវិស័យមនុស្សធម៌ ដោយតែងលើកកម្ពស់សុខុមាលភាពសង្គម និងជីវភាពរស់នៅរបស់ប្រជារាស្ត្រ។

ជាថ្មីម្តងទៀត ឆ្លៀតក្នុងឱកាសដ៏មហាសិរីមង្គលាភិរម្យឧត្តុង្គឧត្តមប្រសើរថ្លៃថ្លានេះ ទូលព្រះបង្គំយើងខ្ញុំទាំងអស់គ្នា សូមលើកហត្ថប្រណម្យបួងសួងដល់ គុណបុណ្យព្រះរតនត្រ័យ គុណកែវទាំងបី វត្ថុស័ក្តិសិទ្ធិទាំងឡាយក្នុងលោក បុណ្យបារមីនៃដួងព្រះវិញ្ញាណក្ខន្ធអតីតព្រះមហាក្សត្រ ព្រះមហាក្សត្រិយានីខ្មែរគ្រប់ព្រះអង្គ ជាពិសេសដួងព្រះវិញ្ញាណក្ខន្ធ **ព្រះករុណាព្រះបាទសម្តេចព្រះបរមរតនកោដ្ឋ** និងទេវតាថែរក្សាឆ្នាំថ្មី ឆ្នាំម្សាញ់ ព្រះនាម **គោរាគទេវី** សូមព្រះអង្គតាមជួយថែរក្សា ការពារ អភិបាល ប្រោះព្រំនូវព្រះសព្វសាធុការពរជ័យគ្រប់ប្រការថ្វាយចំពោះ **សម្តេចព្រះមហាក្សត្រី សម្តេចព្រះវររាជមាតាជាតិខ្មែរ** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត។

សូម **សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល** ទ្រង់ព្រះមេត្តាទទួលនូវគោរវកតញ្ញូភាពដ៏ស្មោះស្ម័គ្រ និងអភិវន្ទនកិច្ចដ៏ខ្ពង់ខ្ពស់បំផុតពីទូលព្រះបង្គំយើងខ្ញុំទាំងអស់គ្នា។

ថ្ងៃ ៨រោច ខែជេស្ឋ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
សូមក្រាបបង្គំទូលថ្វាយព្រះពរនៅរាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែមិថុនា ឆ្នាំ២០២៥

ឧបនាយករដ្ឋមន្ត្រី
ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន

សន្តិបណ្ឌិត.នេត.សាខ្វឹន

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សូមក្រាបបង្គំទូលថ្វាយ
សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ
ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល

បពិត្រ សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត!

ក្នុងព្រះរាជឱកាសជ័មហានក្ខត្តឫក្សឧត្តុង្គឧត្តមនៃព្រះរាជពិធីបុណ្យចម្រើនព្រះជន្មាយុ **សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ** គម្រប់ ៨៩ព្រះវស្សា យាងចូល ៩០ព្រះវស្សា ទូលព្រះបង្គំជាខ្ញុំ និងភរិយា សូមព្រះបរមរាជានុញ្ញាតក្រាបបង្គំទូលថ្វាយនូវព្រះសព្វសាធុការពរជ័យ បវរសួស្តី សិរីវឌ្ឍនា វិបុលសុខ មហាប្រសើរ ថ្វាយ **សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ដែលព្រះអង្គទ្រង់តែងលះបង់ព្រះកាយពល និងព្រះរាជទ្រព្យផ្ទាល់របស់ព្រះអង្គ ក្នុងព្រះរាជសកម្មភាពដ៏ឧត្តុង្គឧត្តមប្រកបដោយទសពិធរាជធម៌ សូមព្រះអង្គទ្រង់ប្រកបដោយព្រះរាជសុខភាពល្អបរិបូណ៌ ព្រះកាយពលមាំមួន ព្រះបញ្ញាញាណភ្លឺថ្លា ព្រះទីឃាយុយឺនយូរ ជាងរយព្រះវស្សា ចាកផុតពីព្រះរោគាព្យាធិទាំងឡាយ ដើម្បីព្រះអង្គទ្រង់គង់ជាម្លប់ដ៏ត្រជាក់ត្រជុំសម្រាប់ប្រជានុរាស្ត្រជាកូន ជាចៅ ចៅទួត ជាទីស្នេហារបស់ព្រះអង្គ។

ក្នុងឱកាសដ៏វិសេសវិសាលនេះ ទូលព្រះបង្គំជាខ្ញុំ និងភរិយា សូមលើកហត្ថប្រណម្យឧទ្ទិសបួងសួងដល់គុណបុណ្យព្រះរតនត្រ័យ គុណកែវទាំងបី វត្ថុស័ក្តិសិទ្ធិទាំងឡាយក្នុងលោក ទេវតារក្សាព្រះមហាស្វេតច្ឆត្រ ព្រមទាំងព្រះឫទ្ធាភាពបុណ្យបារមីនៃដួងព្រះវិញ្ញាណក្ខន្ធអតីតព្រះមហាក្សត្រ ព្រះមហាក្សត្រិយានីខ្មែរគ្រប់ព្រះអង្គ ជាពិសេសបុណ្យបារមី **ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ ព្រះមហាវីរក្សត្រ ព្រះវររាជបិតា ឯករាជ្យ បូរណភាពទឹកដី និងឯកភាពជាតិខ្មែរ ព្រះបរមរតនកោដ្ឋ** សូមព្រះអង្គទ្រង់តាមដួងបីបាច់ថែរក្សា ការពារ អភិបាលត្រងរក្សា **សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ** សូមព្រះអង្គទ្រង់ប្រកបដោយព្រះពុទ្ធពរជ័ប្រពៃថ្លៃថ្លាទាំងបួនប្រការ គឺ **អាយុ វណ្ណៈ សុខៈ** និង**ពលៈ** ជាកិយ៉ោកាពតរៀងទៅ។

សូម **សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត** ព្រះអង្គទ្រង់ប្រោសព្រះរាជមេត្តាទទួលនូវអភិវន្ទនកិច្ច និងភក្តីភាពយ៉ាងជ្រាលជ្រៅបំផុតពីទូលព្រះបង្គំជាខ្ញុំ និងភរិយា។

ថ្ងៃ ៦ ៦កើត ខែជេស្ឋ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
ក្រាបបង្គំទូលថ្វាយនៅរាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែមិថុនា ឆ្នាំ២០២៥

ឧបនាយករដ្ឋមន្ត្រី

សុខ ចិន្តាសោភា

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អគ្គបញ្ជាការដ្ឋាន

សូមក្រាបបង្គំទូលថ្វាយ
សម្តេចព្រះមហាក្សត្រ នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ
ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល

បពិត្រសម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត!

ក្នុងឱកាសប្រកបដោយមហានក្ខត្តឫក្សដ៏ឧត្តុង្គឧត្តម នៃព្រះរាជពិធីបុណ្យចម្រើនព្រះជន្មគម្រប់៨៩ យាងចូល៩០ព្រះវស្សារបស់សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០២៥ តាងនាមថ្នាក់ដឹកនាំអគ្គបញ្ជាការ នាយទាហាន នាយទាហានរង និងពលទាហាន នៃកងយោធពលខេមរភូមិន្ទ និងទូលព្រះបង្គំជាខ្ញុំ ព្រមទាំងភរិយា សូមព្រះបរមរាជានុញ្ញាតលំនិនកាយវាចាចិត្តថ្វាយនូវព្រះសព្វសាធុការពរជ័យ សិរីមង្គល វិបុលសុខ បវរមហាប្រសើរថ្វាយសម្តេចព្រះមហាក្សត្រី **នរោត្តម មុនិនាថ សីហនុ** ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល សូមព្រះអង្គប្រកបដោយព្រះរាជសុខភាពល្អបរិបូណ៌ ព្រះកាយពលមាំមួន ព្រះបញ្ញាញាណភ្លឺថ្លា ព្រះជន្មាយុយឺនយូរ ដើម្បីព្រះអង្គបានបំពេញព្រះរាជតួនាទីដ៏ឧត្តុង្គឧត្តមក្នុងព្រះបរមនាមប្រធានកិត្តិយសកាកបាទក្រហមកម្ពុជា ដែលជានិច្ចកាលតែងតែយោងសាកសួរសុខទុក្ខ និងជួយសម្រួលការលំបាករបស់ប្រជារាស្ត្រ ដែលជាកូនចៅចៅទួតរបស់ព្រះអង្គនៅទូទាំងព្រះរាជាណាចក្រកម្ពុជា។

ទូលព្រះបង្គំយើងខ្ញុំទាំងអស់គ្នា សូមព្រះបរមរាជានុញ្ញាតសម្តែងនូវកតញ្ញូកតវេទិតាធម៌ដ៏ជ្រាលជ្រៅចំពោះព្រះមហាករុណាទិគុណរបស់សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ ដែលកន្លងមកទ្រង់បានយកអស់ព្រះកាយពល ព្រះបញ្ញាញាណ ព្រះរាជទ្រព្យផ្ទាល់ព្រះអង្គ ជួយការងារមនុស្សធម៌និងសង្គមជាតិ។

ជាថ្មីម្តងទៀត ទូលព្រះបង្គំយើងខ្ញុំទាំងអស់គ្នា សូមព្រះបរមរាជានុញ្ញាតលើកហត្ថប្រណម្យបួងសួងដល់វត្ថុស័ក្តិសិទ្ធិទាំងឡាយក្នុងលោក គុណព្រះរតនត្រ័យកែវទាំងបី ឫទ្ធិបារមីនៃដួងព្រះវិញ្ញាណក្ខន្ធអតីតព្រះមហាក្សត្រ ព្រះវិញ្ញាណក្ខន្ធព្រះបរមរតនកោដ្ឋ ព្រះមហាក្សត្រីយានីខ្មែរគ្រប់ព្រះអង្គ ទេវតាថែរក្សាព្រះមហាស្វេតច្ឆត្រ និងទសបារមីទេវតាថែរក្សាឆ្នាំថ្មី សូមព្រះអង្គតាមជួយបីបាច់ថែរក្សា និងប្រោះព្រំសព្វសាធុការពរជ័យគ្រប់ប្រការថ្វាយសម្តេចព្រះមហាក្សត្រី **នរោត្តម មុនិនាថ សីហនុ** ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល សូមទ្រង់ប្រកបដោយពរទាំងឡាយ ប្រាំប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ និងបដិភាណៈ កុំបីឃ្លៀងឃ្លាតឡើយ។

សូម**សម្តេចព្រះមហាក្សត្រ ព្រះវររាជមាតាជាតិខ្មែរ** ព្រះមេត្តាទទួលនូវគោរវកតីភាពដ៏ខ្ពង់ខ្ពស់បំផុតពីទូលព្រះបង្គំយើងខ្ញុំ។

សេចក្តីគួរពុំគួរ សូមទ្រង់ព្រះមេត្តាប្រោសព្រះរាជទានទោស៕

ថ្ងៃ ៥ កើត ខែ ជេស្ឋ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
ក្រាបបង្គំទូលថ្វាយនៅរាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែមិថុនា ឆ្នាំ២០២៥

អគ្គមេបញ្ជាការ

ឧត្តមសេនីយ៍ ទៀ វិញ

សាខាសមាគមនារីកម្ពុជាដើម្បីសន្តិភាព និងអភិវឌ្ឍន៍
Cambodia Women for Peace and Development (CWPD)
A Non-Governmental Organization

លេខ: ៤០/០៦៥ នកសអ/ព.ម

សារលិខិតថ្វាយព្រះពរ
សូមក្រាបបង្គំទូលថ្វាយ
សម្តេច ព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ
ព្រះវររាជមាតាជាតិខ្មែរក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល
បពិត្រសម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត!

ក្នុងឱកាសនៃព្រះរាជពិធីបុណ្យចម្រើនព្រះជន្ម គម្រប់ ៨៩ យាងចូល ៩០ ព្រះវស្សា នាថ្ងៃពុធ ៨រោច ខែជេស្ឋ ឆ្នាំម្សាញ់ សប្តស័ក ព.ស ២៥៦៩ ត្រូវនឹងថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០២៥ខាងមុខនេះ ខ្ញុំម្ចាស់ នាងខ្ញុំទាំងអស់គ្នាជាថ្នាក់ដឹកនាំ និងសមាជិកាសាខាសមាគមនារីកម្ពុជាដើម្បីសន្តិភាព និងអភិវឌ្ឍន៍ ក្រសួងព័ត៌មាន សូមព្រះបរមោជានុញ្ញាតអភិវន្ទលំនិនកាយវាចាចិត្តក្រាបបង្គំសម្តែងថ្វាយនូវមនោសញ្ចេតនារីករាយ និងកតញ្ញូតាធម៌ដ៏ជ្រាលជ្រៅបំផុតចំពោះព្រះគុណបំណាច់ដ៏ធំធេងក្នុងព្រះរាជកិច្ចបំពេញបេសកកម្មដ៏មហាបវរត្រេចៈត្រចង់ក្នុងបុព្វហេតុបម្រើឧត្តមប្រយោជន៍ជូន ជាតិ សាសនា ព្រះមហាក្សត្រ និងសូមក្រាបបង្គំថ្វាយនូវព្រះសព្ទសាធុការពរជ័យបវរសួស្តី សិរីមង្គល មហាប្រសើរថ្វាយចំពោះ **សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត។

ឆ្លៀតក្នុងវេលាដ៏សិរីមង្គលកាលិអម្យប្រពៃថ្លៃថ្លានេះ ខ្ញុំម្ចាស់ នាងខ្ញុំទាំងអស់គ្នា សូមលើកហត្ថទាំងទ្វេប្រណមឧទ្ធិសបួងសួងដល់ព្រះគុណបុណ្យបារមីនៃវត្ថុស័ក្តិសិទ្ធក្នុងលោក ទេវតាថែរក្សាព្រះមហាស្វេតច្ឆត្រ ព្រះវិញ្ញាណក្ខន្ធអតីតព្រះមហាក្សត្រ និងព្រះមហាក្សត្រិយានីគ្រប់ព្រះអង្គ សូមព្រះមេត្តាជួយប្រោះព្រំថ្វាយចំពោះ**សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត សូមព្រះអង្គទ្រង់ប្រកបដោយព្រះបញ្ញាញាណក្លីថ្លា ព្រះកាយពលមាំមួន ព្រះរាជសុខភាពល្អបរិបូរណ៌ និងមានព្រះជន្មាយុយឺនយូរជាងរយព្រះវស្សា ដើម្បីគង់ប្រថាប់ជាម្លប់ដ៏ត្រជាក់ត្រជុំ និងបន្តព្រះរាជសកម្មភាពនានា លើវិស័យមនុស្សធម៌ និងសុខិមាលភាពសង្គមដល់ប្រជានុរាស្ត្រ កូនចៅ ចៅទួត របស់ព្រះអង្គបានសុខក្សេមក្សាន្តជានិរន្តរ៍។

សូមក្រាបថ្វាយបង្គំ**សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុតព្រះមេត្តាទទួលនូវអភិវន្ទន៍កិច្ច និងកតញ្ញូតាធម៌ដ៏ខ្ពង់ខ្ពស់បំផុតពីខ្ញុំម្ចាស់នាងខ្ញុំទាំងអស់គ្នា។

សេចក្តីគួរពុំគួរ សូម ព្រះមេត្តាប្រោស ព្រះរាជទានទោស។

ក្រាបបង្គំទូលថ្វាយនៅថ្ងៃអង្គារ ៨រោច ខែពិសាខ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែឧសភា ឆ្នាំ២០២៥
តំណាងថ្នាក់ដឹកនាំ និងសមាជិកាសាខាសមាគមនារីកម្ពុជា
ដើម្បីសន្តិភាព និងអភិវឌ្ឍន៍ក្រសួងព័ត៌មាន
ប្រធានកិត្តិយស

ឡុយ សីរីរតនៈ នេត្រ តក្រ្កា

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងព័ត៌មាន
លេខ ...៧... ព.ម

សារលិខិតថ្វាយព្រះពរ
សូមក្រាបបង្គំទូលថ្វាយ
សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ
ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល
បពិត្រសម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត!

ក្នុងឱកាសនៃព្រះរាជពិធីបុណ្យចម្រើនព្រះជន្ម គម្រប់ ៨៩ យាងចូល ៩០ ព្រះវស្សា នាថ្ងៃពុធ ៨រោច ខែជេស្ឋ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០២៥ ខាងមុខនេះ ទូលព្រះបង្គំយើងខ្ញុំទាំងអស់គ្នាជាថ្នាក់ដឹកនាំ និងមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់នៃក្រសួងព័ត៌មាន សូមព្រះបរមោជានុញ្ញាតអភិវន្ទលំនិនកាយវាចាចិត្ត ក្រាបបង្គំសម្តែងថ្វាយនូវមនោសញ្ចេតនារីករាយ និងកតញ្ញូតាធម៌ដ៏ជ្រាលជ្រៅបំផុតចំពោះព្រះគុណបំណាច់ដ៏ធំធេងក្នុងព្រះរាជកិច្ចបំពេញបេសកកម្មដ៏មហាបវរត្រេចៈត្រចង់ក្នុងបុព្វហេតុបម្រើឧត្តមប្រយោជន៍ជូន **ជាតិ សាសនា** ព្រះមហាក្សត្រ និងសូមក្រាបបង្គំថ្វាយនូវព្រះសព្ទសាធុការពរជ័យបវរសួស្តី សិរីមង្គល មហាប្រសើរថ្វាយចំពោះ **សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ**។

ឆ្លៀតក្នុងវេលាប្រកបដោយសិរីមង្គលកាលិអម្យដ៏ប្រពៃថ្លៃថ្លានេះ ទូលព្រះបង្គំយើងខ្ញុំទាំងអស់គ្នា សូមលើកហត្ថទាំងទ្វេប្រណមឧទ្ធិសបួងសួងដល់ព្រះគុណបុណ្យបារមី នៃវត្ថុស័ក្តិសិទ្ធិក្នុងលោក ទេវតាថែរក្សាព្រះមហាស្វេតច្ឆត្រ ព្រះវិញ្ញាណក្ខន្ធអតីតព្រះមហាក្សត្រ និងព្រះមហាក្សត្រិយានីគ្រប់ព្រះអង្គ សូមព្រះមេត្តាជួយប្រោះព្រំថ្វាយចំពោះ **សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត សូមប្រកបដោយព្រះបញ្ញាញាណក្លីថ្លា ព្រះកាយពលមាំមួន ព្រះរាជសុខភាពល្អបរិបូរណ៌ និងមានព្រះជន្មាយុយឺនយូរជាងរយព្រះវស្សា ដើម្បីគង់ប្រថាប់ជាម្លប់ដ៏ត្រជាក់ត្រជុំ និងបន្តព្រះរាជសកម្មភាពនានា លើវិស័យមនុស្សធម៌ និងសុខុមាលភាពសង្គម ដល់ប្រជានុរាស្ត្រ កូនចៅ ចៅទួត របស់ព្រះអង្គបានសុខក្សេមក្សាន្តជានិរន្តរ៍។

សូមក្រាបថ្វាយបង្គំ **សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់ព្រះមេត្តាទទួលនូវអភិវន្ទន៍កិច្ច និងកតញ្ញូតាធម៌ដ៏ខ្ពង់ខ្ពស់បំផុតពីទូលព្រះបង្គំយើងខ្ញុំទាំងអស់គ្នា។

ថ្ងៃសុក្រ ៣រោច ខែជេស្ឋ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០២៥
តំណាងថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៃក្រសួងព័ត៌មាន
រដ្ឋមន្ត្រី

នេត្រ តក្រ្កា

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាជាតិរណសិរ្សសាមគ្គី អភិវឌ្ឍន៍មាតុភូមិកម្ពុជា
National Council for Solidarity Front for the
Development of Cambodia Motherland
លេខ :.....១៣៦/..ក.ជ.ស

សូមក្រាបបង្គំទូលថ្វាយ
សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ
ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល

បពិត្រ សម្តេចព្រះវររាជមាតា ជាអម្ចាស់ជីវិតលើត្បូងជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត!

ក្នុងឱកាសអភិលក្ខិតកាលដ៏បវរសួស្តី សិរីមង្គល វិបុលសុខមហាប្រសើរ នៃពិធីបុណ្យចម្រើនព្រះជន្មគម្រប់ ៨៩ យាងចូល ៩០ព្រះវស្សា របស់ **សម្តេចព្រះមហាក្សត្រី** នាពេលខាងមុខនេះ: ខ្ញុំម្ចាស់ ទូលព្រះបង្គំយើងខ្ញុំជាថ្នាក់ដឹកនាំ មន្ត្រី បុគ្គលិក នៃក្រុមប្រឹក្សាជាតិរណសិរ្សសាមគ្គី អភិវឌ្ឍន៍មាតុភូមិកម្ពុជា សូមព្រះបរមាជានុញ្ញាតសំណែនកាយវាចាចិត្ត ក្រាបបង្គំថ្វាយនូវព្រះសព្វសាធុការពរជ័យដោយក្តីរំភើបរីករាយយ៉ាងក្រៃលែងថ្វាយ **សម្តេចព្រះមហាក្សត្រី ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត** សូមទ្រង់ប្រកបដោយព្រះរាជសុខភាពល្អបរិបូរណ៌ ព្រះកាយពលមាំមួន ព្រះបញ្ញាញាណភ្លឺថ្លា ព្រះជន្មាយុយឺនយូរជាងរយព្រះវស្សា ដើម្បីព្រះអង្គគង់ប្រថាប់ជាម្លប់ដ៏ត្រជាក់ត្រជំសុខដុមរមនាដល់ប្រជារាស្ត្រខ្មែរ តរៀងទៅ។

ស្ថិតក្នុងព្រះរាជពិធីបុណ្យចម្រើនព្រះជន្មវឌ្ឍនមង្គលដ៏មហាវិសេសវិសាលថ្លៃថ្លានេះ ខ្ញុំម្ចាស់ ទូលព្រះបង្គំយើងខ្ញុំជាថ្នាក់ដឹកនាំ មន្ត្រី បុគ្គលិក នៃក្រុមប្រឹក្សាជាតិរណសិរ្សសាមគ្គី អភិវឌ្ឍន៍មាតុភូមិកម្ពុជា សូមព្រះបរមាជានុញ្ញាតសំណែនកាយវាចាចិត្តសំដែងថ្វាយនូវព្រះសក្ខីកម្មជាវិជ្ជមានរបស់ **សម្តេចព្រះមហាក្សត្រី** ដែលព្រះអង្គមានព្រះរាជហឫទ័យសណ្តោសប្រោសប្រណីដល់កូនចៅរបស់ព្រះអង្គ និងសូមព្រះបរមាជានុញ្ញាតលើកហត្ថប្រណម្យបួងសួងដល់គុណបុណ្យព្រះរតនត្រ័យកែវទាំងបីវត្ថុស័ក្តិសិទ្ធិក្នុងលោក ទេវតាថែរក្សាព្រះមហាស្វេតច្ឆត្រ និងព្រះបារមីនៃដួងវិញ្ញាណក្ខន្ធ អតីតព្រះមហាក្សត្រ ព្រះមហាក្សត្រីយានីខ្មែរគ្រប់ព្រះអង្គ ជាពិសេសបារមីព្រះវិញ្ញាណក្ខន្ធ «**ព្រះបរមរតនកោដ្ឋ**» សូមប្រោសព្រះរាជទានព្រះរាជសព្វសាធុការពរជ័យថ្វាយ **សម្តេចព្រះមហាក្សត្រី** ទ្រង់ព្រះប្រកបដោយព្រះពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

សូម **សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត** សូមព្រះអង្គទ្រង់ព្រះរាជមេត្តាទទួលនូវអភិវន្ទនកិច្ច និងកតញ្ញូតាធម៌ដ៏ខ្ពង់ខ្ពស់បំផុតពីខ្ញុំម្ចាស់ ទូលព្រះបង្គំយើងខ្ញុំ។

ថ្ងៃ៩កើត ខែជេស្ឋ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
ក្រាបបង្គំទូលថ្វាយនៅឯរាជធានីភ្នំពេញ ថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២៥
តំណាងថ្នាក់ដឹកនាំ មន្ត្រី និងបុគ្គលិក
នៃក្រុមប្រឹក្សាជាតិរណសិរ្សសាមគ្គី អភិវឌ្ឍន៍មាតុភូមិកម្ពុជា
ប្រធាន

សម្តេចកិត្តិសង្គហបណ្ឌិត ម៉ែន សំអន

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី
Cambodian National Council for Women
លេខ :.....២៤០.....ក.ជ.ស

លិខិតថ្លែងអំណរព្រះគុណ

សូមក្រាបបង្គំទូលថ្វាយ
សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ
ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល
ព្រះប្រធានកិត្តិយសនៃក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី

ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត!

ខ្ញុំម្ចាស់តាងនាមប្រធាន អនុប្រធាន សមាជិក សមាជិកា ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី សូមព្រះបរមាជានុញ្ញាត សម្តែងនូវអំណរព្រះមហាករុណាទិគុណយ៉ាងជ្រាលជ្រៅបំផុតថ្វាយ **សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ ព្រះប្រធានកិត្តិយសនៃក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី** ចំពោះព្រះរាជហឫទ័យប្រោសព្រះរាជប្រទានប្រកបដោយព្រះមេត្តាធម៌ ផ្តល់ពេលវេលាដល់គណៈប្រតិភូ ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី បានចូលក្រាបបង្គំគាល់ ថ្វាយព្រះពរ និងទូលថ្វាយបាយការណ៍លទ្ធផលការងារឆ្នាំ២០២៤ និងផែនការសកម្មភាពឆ្នាំ២០២៥ នាថ្ងៃចន្ទ ១៨កើត ខែជេស្ឋ ឆ្នាំម្សាញ់ សប្តស័ក ព.ស ២៥៦៩ ត្រូវនឹងថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០២៥ ព្រមទាំងព្រះរាជទានដំបូន្មានថ្លៃថ្លាបំផុតដល់ប្រតិភូក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី នូវព្រះរាជសង្គាអមព្រះរាជបរមធាយាល័ក្ខណ៍ **សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ** និងសៀវភៅព្រះរាជពិធីខួបទី២០ នៃការគ្រងព្រះបរមសិរីរាជសម្បត្តិ **ព្រះករុណា ព្រះបាទសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា** ជាអម្ចាស់ជីវិតលើត្បូង។

យើងខ្ញុំម្ចាស់ទូលព្រះបង្គំទាំងអស់គ្នា សូមលំនឹងកាយលើកហត្ថប្រណម្យបួងសួង សូមគុណបុណ្យព្រះរតនត្រ័យ គុណកែវទាំងបី ទេវតារក្សា មហាស្វេតច្ឆត្រ ព្រះបារមីនៃព្រះវិញ្ញាណក្ខ័ន្ធ អតីតព្រះមហាក្សត្រ ព្រះមហាក្សត្រីយានីខ្មែរគ្រប់ព្រះអង្គ ជាពិសេស តេជបារមីនៃដួងព្រះវិញ្ញាណក្ខ័ន្ធ **ព្រះបរមរតនកោដ្ឋ** វត្ថុស័ក្តិសិទ្ធិដែលថែរក្សា ព្រះរាជាណាចក្រកម្ពុជា សូមព្រះរាជទាន ព្រះពរជ័យ បវរមហាប្រសើរថ្វាយ **ព្រះករុណា ព្រះបាទសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា** និង **សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល** សូមព្រះអង្គទាំងទ្វេបានប្រកបដោយព្រះរាជសុខភាពល្អបរិបូរណ៌ ព្រះជន្មាយុយឺនយូរ ព្រះកាយពលមាំមួន ដើម្បីព្រះអង្គទ្រង់គង់ប្រថាប់ជាម្លប់ដ៏ត្រជាក់ សម្រាប់ប្រជានុរាស្ត្រ ជាកូនចៅ ចៅទួត របស់ព្រះអង្គ អស់កាលជាអង្វែងតរៀងទៅ។

សេចក្តីគួរពុំគួរ សូម **សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ទ្រង់ព្រះមេត្តាប្រោស និងព្រះមេត្តាទទួលនូវអភិវន្ទនកិច្ចដ៏ខ្ពង់ខ្ពស់បំផុតពីខ្ញុំម្ចាស់ទូលព្រះបង្គំ។

ថ្ងៃ៩កើត ខែជេស្ឋ ឆ្នាំម្សាញ់ សប្តស័ក ព.ស ២៥៦៩
ក្រាបបង្គំទូលថ្វាយនៅរាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែមិថុនា ឆ្នាំ២០២៥

ខ្ញុំម្ចាស់ អ៊ុំ កន្ថាថ៏
ប្រធានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី

Embaixada da República Democrática de Timor-Leste
Phnom Penh

Phnom Penh, 16th June 2025

Her Majesty Queen-Mother
NORODOM MONINEATH SIHANOUK
Kingdom of Cambodia
PHNOM PENH

Dear Your Majesty,

On behalf of the Diplomatic Corps in the Kingdom of Cambodia and my own name, I would like to wholeheartedly express our warmest greeting and best wishes to Your Majesty on the auspicious occasion of **Your Majesty's 89th Royal Birthday, on June 18, 2025**.

Your Majesty unwavering dedication to the Cambodian people has touched the hearts of countless individuals, both within the Kingdom and beyond its borders, and resonate deeply with all who have had the privilege to witness your noble presence.

As Dean of the Diplomatic Corps in the Kingdom of Cambodia, I am honoured to take this opportunity to convey our best wishes for the good health, happiness and abundant blessings for Your Majesty and for the peace and prosperity to the Kingdom of Cambodia.

Please accept, Your Majesty, the renewed assurances of my highest consideration and the respectful esteem of the Diplomatic Corps in Phnom Penh.

Yours Sincerely,

Ermenegildo Kupa Lopes
Ambassador of the Democratic Republic of Timor-Leste
Dean of the Diplomatic Corps
To the Kingdom of Cambodia

Embassy of the United States of America

Phnom Penh, Cambodia

June 16, 2025

Your Majesty:

On behalf of U.S. Embassy Phnom Penh, I am pleased to have the honor to extend our sincerest wishes for Your Majesty's 89th birthday. May Your Majesty's Day be filled with joy and good memories. May Your Majesty be blessed with good health and longevity.

Please accept, Your Majesty, the renewed assurances of our sincerest and highest consideration.

Sincerely,

Bridgette L. Walker

Bridgette L. Walker
Chargé d'Affaires, a.i.

Her Majesty
Queen-Mother Norodom Monineath Sihanouk
Phnom Penh, Kingdom of Cambodia

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ជ្លួសតា

សារលិខិតថ្វាយព្រះពរ
សូមក្រាបបង្គំទូលថ្វាយ
សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ
ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល

សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត!

ក្នុងវរោកាសដ៏មហានក្ខត្តឫក្សមង្គលថ្លៃថ្លាឧត្តុង្គឧត្តម ប្រកបដោយសេចក្តីសោមនស្សរីករាយ នៃព្រះរាជពិធីបម្រើនព្រះជន្ម **សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាពសេចក្តីថ្លៃថ្នូរ និងសុភមង្គល** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត នៃព្រះរាជពិធីបម្រើនព្រះជន្មគម្រប់ **៨៩ព្រះវស្សា យាងចូល ៩០ព្រះវស្សា** ដែលនឹងប្រព្រឹត្ត**ទៅនៅថ្ងៃពុធ ៨រោច ខែជេស្ឋ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០២៥** ខាងមុខនេះ ទូលព្រះបង្គំជាខ្ញុំ និងភរិយា សូមព្រះបរមាជានុញ្ញាតក្រាបបង្គំទូលថ្វាយនូវព្រះរាជសព្ទសាធុការពរជ័យ បវរសួស្តី សិរីវឌ្ឍនា វិបុលសុខមហាមង្គលដ៏ប្រសើរថ្លៃថ្លាបំផុត។

ក្នុងឱកាសដ៏ឧត្តុង្គឧត្តមមហាវិសេសវិសាលនេះ ទូលព្រះបង្គំសូមក្រាបអភិវន្ទសម្តែងកតញ្ញូតាធម៌ដ៏ជ្រាលជ្រៅបំផុតថ្វាយ **សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត** ដែលជានិច្ចកាលព្រះអង្គតែងយកព្រះរាជហឫទ័យទុកដាក់អស់ពីកម្លាំងព្រះកាយពល និងព្រះរាជបញ្ញាញាណក្នុងបុព្វហេតុជាតិមាតុភូមិ។ ព្រះអង្គជាព្រះមាតាជាតិដ៏ឧត្តុង្គឧត្តមនៅក្នុងវិស័យសាសនា អារិយធម៌ វប្បធម៌ សីលធម៌ សប្បុរសធម៌ និងមនុស្សធម៌ ព្រមទាំងបានលើកកម្ពស់គុណតម្លៃរបស់ស្ត្រីឱ្យដើរតួនាទីកាន់តែសំខាន់នៅគ្រប់កម្រិតក្នុងការបូលរួមអភិវឌ្ឍជាតិ និងបានការពារទប់ស្កាត់រាល់ការរើសអើង និងរំលោភបំពានលើស្ត្រី កុមារ និងជនពិការ។ ព្រះរាជកិច្ចដ៏មហាសំខាន់ខាងលើនេះត្រូវបានប្រជារាស្ត្រគ្រប់ស្រទាប់វណ្ណៈ និងអន្តរជាតិគោរពផ្តល់តម្លៃដ៏មហាខ្ពង់ខ្ពស់បំផុត។

ទូលព្រះបង្គំជាខ្ញុំ និងភរិយា សូមព្រះបរមាជានុញ្ញាតលើកហត្ថប្រណម្យបួងសួងដល់វត្ថុស័ក្តិសិទ្ធិទាំងឱឡាយក្នុងលោក គុណបុណ្យព្រះរតនត្រៃកែវទាំងបី ឫទ្ធិបារមីខ្លាំងក្លា ទៅតែជែរក្សាទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ទៅតែរក្សាព្រះមហាស្វេតច្ឆត្រ **ព្រះបារមីអតីតព្រះមហាវីរក្សត្រ ព្រះមហាក្សត្រ ព្រះមហាក្សត្រិយានីខ្មែរគ្រប់ព្រះអង្គ ពិសេសព្រះវិញ្ញាណក្ខន្ធ "ព្រះបរមរតនកោដ្ឋ"** សូមតាមជួយបីបាច់ថែរក្សាអភិបាលប្រោះព្រំប្រទានព្រះរាជសព្ទសាធុការពរជ័យ គ្រប់ប្រការថ្វាយចំពោះ **សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ** សូមទ្រង់បានសមប្រកបដោយព្រះពុទ្ធពរទាំងបួនប្រការ គឺ**អាយុ វណ្ណៈ សុខៈ ពលៈ** កុំបីប្រែក្លាយទៅជាប្រការដទៃឡើយ ដើម្បីព្រះអង្គបានគង់ប្រថាប់ជាម្លប់ដ៏ត្រជាក់ត្រជំសុខដុមសម្រាប់ប្រជារាស្ត្រខ្មែរតរៀងទៅ។

សូម **សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត** ទ្រង់ព្រះមេត្តាទទួលនូវគោរវកតញ្ញូដ៏ខ្ពង់ខ្ពស់បំផុតពីទូលព្រះបង្គំជាខ្ញុំ និងភរិយា ។

ថ្ងៃសុក្រ ៣រោច ខែជេស្ឋ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
សូមក្រាបបង្គំទូលថ្វាយនៅរាជធានីភ្នំពេញ ថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០២៥

អនុប្រធានទី១ ជ្លួសតា

កិត្តិសេដ្ឋាបណ្ឌិត ជាម ច្បៀប

សម្តេចព្រះធម្មលិខិត បណ្ឌិត សៅរ៍ ចន្ទជុល្ល
ព្រះរាជាគណៈថ្នាក់ឯក និងជាឧត្តមប្រឹក្សាគណៈមហានិកាយ
នៃព្រះរាជាណាចក្រកម្ពុជា

សូមចម្រើនពរថ្វាយ
សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ
ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល
ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត!

ក្នុងឱកាសដ៏មហានក្ខត្តឫក្សឧត្តុង្គឧត្តមនៃព្រះរាជពិធីបុណ្យចម្រើនព្រះជន្មគម្រប់ ៨៩ព្រះវស្សាយាងចូល ៩០ព្រះវស្សា របស់ហ្លួងម៉ែជាអម្ចាស់ អាត្មាភាព សូមព្រះបរមាជានុញ្ញាតក្រាបបង្គំថ្វាយព្រះសព្ទសាធុការពរ សិរីវឌ្ឍនា ជយមង្គល វិបុលសុខ បវរមហាប្រសើរ សូមហ្លួងម៉ែជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ស្តេចទ្រង់ព្រះប្រកបដោយព្រះរាជសុខភាពល្អពេញបរិបូណ៌ ព្រះកាយពលមាំមួន ព្រះបញ្ញាញាណវាងវៃ ព្រះទីឃាយុយឺនយូរជាងរយព្រះវស្សា ដើម្បីទ្រង់គង់ជាម្លប់ដល់ ព្រះសង្ឃ ពុទ្ធបរិស័ទជនរួមជាតិ ជាបងប្អូន កូនចៅ ចៅទួត ចៅលួតរបស់ព្រះអង្គ ជ្រកកោនត្រជាក់ត្រជុំសុខសាន្តមនោរមជានិច្ចនិរន្តរ៍តទៅ។

ស្ថិតក្នុងព្រះរាជពិធីបុណ្យចម្រើនព្រះជន្មវឌ្ឍនមង្គលដ៏មហាវិសេសវិសាលថ្លៃថ្លានេះ អាត្មាភាព សូមព្រះបរមាជានុញ្ញាតថ្វាយនូវកតញ្ញូកតវេទិតាធម៌ដ៏ឧត្តុង្គឧត្តមដោយសុទ្ធចិត្តបំផុត ចំពោះហ្លួងម៉ែជាអម្ចាស់ជាទីគោរពស្រលាញ់ស្មើនឹងជីវិត ដែលជានិច្ចកាលស្តេចទ្រង់សព្វព្រះរាជហឫទ័យប្រោសព្រះរាជទាននូវព្រះព្រហ្មវិហារធម៌ដ៏ជ្រាលជ្រៅ ពិសេសទ្រង់បានបំពេញព្រះរាជបុព្វនិយកិច្ចសន្សំបុញ្ញកុសលតម្កល់ប្រោសព្រះរាជបុត្តម្ចាស់ចោះអាត្មាភាព ដើម្បីសាងសង់កុដិសមណសិស្ស គង់ស្នាក់នៅបន្តការសិក្សារៀនសូត្រ និងទ្រទ្រង់វិស័យព្រះពុទ្ធសាសនា និងជនរួមជាតិរបស់ព្រះអង្គប្រកបដោយព្រះទសពិធរាជធម៌ ទ្រង់មានមនុស្សធម៌ដ៏ឧត្តុង្គឧត្តម ត្រជាក់ក្សេមក្សាន្ត នឹងរកវត្ថុអ្វីមកប្រៀបផ្ទឹមពុំបានឡើយ។

អាត្មាភាព សូមបួងសួងដល់វត្ថុសក្តិសិទ្ធិទាំងឱឡាយ លើលោកមានដួងព្រះវិញ្ញាណក្ខន្ធ អតីតព្រះមហាក្សត្រ ព្រះមហាក្សត្រីយានីខ្មែរគ្រប់ព្រះអង្គ និងគុណបុណ្យព្រះរតនត្រៃ ទៅតែរក្សាព្រះមហាស្វេតច្ឆត្រ ទៅតែឆ្នាំថ្មី ពិសេសដួងព្រះវិញ្ញាណក្ខន្ធព្រះករុណាព្រះមហាវីរក្សត្រ ព្រះបរមរតនកោដ្ឋ ជាទីសក្ការៈ សូមទ្រង់បន្តអភិបាលគ្រងរក្សា **សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជ មាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល** សូមស្តេចទ្រង់ប្រកបដោយព្រះពុទ្ធពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

សូម **អនុសម្តេចម៉ែ** ជាអម្ចាស់ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ទ្រង់ព្រះមេត្តាទទួលនូវអតិវន្ទនកិច្ចនិងកតញ្ញូតាធម៌ដ៏ជ្រាលជ្រៅបំផុតអំពីអាត្មាភាព។

ថ្ងៃពុធ ៨រោច ខែជេស្ឋ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
ចម្រើនពាក្យថ្វាយនៅរាជធានីភ្នំពេញ ថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២៥

សម្តេចព្រះធម្មលិខិតបណ្ឌិត **សៅរ៍ ចន្ទជុល្ល**

ជាតិ សាសនា ព្រះមហាក្សត្រ

សម្តេច ឥស្សរាធិទេសបញ្ញា ហោ ណាំហុង
ឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ

សូមគ្រោងបង្គំទូលថ្វាយ
សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ
ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល

បពិត្រសម្តេចព្រះមហាក្សត្រី ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់ចំផុត!

ក្នុងឱកាសដ៏មហានក្ខត្តឫក្សអធិកអធមឧត្តុង្គឧត្តម វិសេសវិសាល សិរីសួស្តី ជ័យមង្គល មហាបវរប្រពៃថ្លៃថ្លានៃព្រះរាជពិធីបុណ្យចម្រើនព្រះជន្ម របស់ ***សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់ចំផុត*** *នាថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០២៥ ខាងមុខនេះ ទូលព្រះបង្គំជាខ្ញុំ និងកវិយា សូមព្រះបរមាជានុញ្ញាតក្រាបលំអោនកាយលើកហត្ថាប្រណមបួងសួងដល់គុណបុណ្យព្រះរតនត្រ័យ វត្ថុស័ក្តិសិទ្ធិទាំងអស់ ក្នុងលោក ទេវតារក្សាស្វែតច្ឆ័ត្រ ព្រមទាំងព្រះបារមីនៃព្រះវិញ្ញាណក្ខ័ន្ធនៃអតីតព្រះមហាក្សត្រ និងព្រះមហាក្សត្រីយានី ជាពិសេសព្រះបារមីនៃ****ព្រះបរមរតនកោដ្ឋ ព្រះបិតាជាតិ*** *សូមជួយថែរក្សាការពារ និងប្រសិទ្ធិសព្ទសាធុការពរបវរសិរីសួស្តី ជ័យមង្គលមហាប្រសើរថ្វាយ* ***សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ*** *សូមមានព្រះរាជសុខភាពល្អបរិបូរណ៌ ព្រះពលានុភាពមាំមួន ព្រះជន្មាយុយឺនយូរជាងរយព្រះវស្សាដើម្បី គង់ប្រថាប់ជាម្លប់ដ៏ត្រជាក់ត្រជុំដល់ប្រជានុរាស្ត្រខ្មែរជាកូន ចៅ ចៅទួត ជាទីស្រឡាញ់របស់****ព្រះអង្គ****ជានិច្ចនិរន្តរ៍រៀងទៅ។*

សម្តេចព្រះមហាក្សត្រី ព្រះមាតាជាតិ *ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ជានិមិត្តរូបដ៏ខ្ពង់ខ្ពស់បំផុត ប្រពៃថ្លៃថ្លាឧត្តុង្គឧត្តមបំផុតនៃស្ត្រីខ្មែរ មានព្រះព្រហ្មវិហារធម៌ដ៏ឧត្តុង្គឧត្តម តែងតែចំណាយព្រះកាយពល ព្រះបញ្ញាញាណ និងព្រះរាជទ្រព្យយ៉ាងច្រើនជាបន្តបន្ទាប់ ក្នុងព្រះរាជសកម្មភាពទ្រទ្រង់នូវវិស័យព្រះពុទ្ធសាសនា អប់រំសិក្សាជំការ សង្គមកិច្ច សុខុមាលភាព ជាពិសេសសព្វព្រះរាជហឫទ័យគង់ជាព្រះប្រធានកិត្តិយសនៃកាកបាទក្រហមកម្ពុជា ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី និងសមាគមកាយឫទ្ធិនារីកម្ពុជា ប្រកបដោយព្រះព្រហ្មវិហារធម៌ដ៏ប្រសើរថ្លៃថ្លា ក្នុងព្រះរាជបេសកកម្មមនុស្សធម៌និងនិងសង្គមកិច្ចដ៏វិសេសវិសាលជួយប្រជានុរាស្ត្រគ្រប់ៗរូប និង លើកកម្ពស់តម្លៃនិងតួនាទីស្ត្រីកម្ពុជាឱ្យមានការយល់ដឹងនិងទទួលស្គាល់កាន់តែខ្លាំងក្លាពីគ្រប់មជ្ឈដ្ឋានជាតិ និងអន្តរជាតិ ព្រមទាំងការលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ដើម្បីភាពសុខដុមរមនាក្នុងសង្គមកាន់តែប្រសើរ។*

នាឱកាសវីកាយប្រពៃថ្លៃថ្លាដ៏ឧត្តុង្គឧត្តមនេះ ទូលព្រះបង្គំជាខ្ញុំ និងកវិយា សូមព្រះបរមាជានុញ្ញាតថ្វាយនូវកតញ្ញូតាធម៌យ៉ាងជ្រាលជ្រៅបំផុត ចំពោះព្រះមហាករុណាទីគុណ និងព្រះរាជហឫទ័យ ដែល ***ព្រះវររាជមាតាជាតិខ្មែរ*** *ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត តែងតែប្រណីសន្តោសចំពោះរូបទូលព្រះបង្គំជាខ្ញុំ និងកវិយា ជារៀងរហូត។*

សូម ***សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ*** *ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុតទ្រង់ព្រះមេត្តាប្រោសទទួលនូវអភិវន្ទកិច្ចដ៏ខ្ពង់ខ្ពស់បំផុតអំពី ក្រុមគ្រួសារ ខ្ញុំ ខ្ញុំ និងកវិយា*

នៅថ្ងៃព្រហស្បតិ៍ ២កេីត ខែជេស្ឋ ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៩
នៅរាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ២០២៥

សម្តេច ឥស្សរាធិទេសបញ្ញា ហោ ណាំហុង ម៉ូនី ហោ

Soit le plus respectueusement soumis à
Sa Majesté Norodom Monineath Sihanouk
Reine-Mère du Cambodge

Luong Mè Très Vénérée,

Daignez, Luong Mè Très Vénérée, accepter nos voeux de santé les plus respectueux à l' occasion de Votre Quatre-vingt-neuvième Anniversaire.

Que cette journée de célébration Vous soit joyeuse et sereine.

Nous demeurons de Votre Majesté, Vos plus Respectueusement dévoués kaun chaus.

Phnom-Penh, le 18 juin 2025

Kh'gnom m'chas,
Christine Penn

Toul Preah Bangkum,
Oum Nuphea

សូមក្រាបថ្វាយបង្គំ
សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ
ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត

ក្នុងឱកាសដ៏មហានក្ខត្តឫក្សប្រកបដោយជ័យមង្គល នៃព្រះរាជពិធីបុណ្យចម្រើនព្រះជន្មាយុ **សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត គម្រប់៨៩ យាងចូល៩០ព្រះវស្សា នាថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០២៥ខាងមុខនេះ ទូលព្រះបង្គំជាខ្ញុំ និងភរិយា សូមព្រះបរមរាជានុញ្ញាតដ៏ខ្ពង់ខ្ពស់បំផុត សូមលំឱនកាយបង្គំទូលថ្វាយ សម្តែងនូវមនោសញ្ចេតនា សោមនស្សរីករាយអបអរសាទរក្នុងទិវាដ៏ឧត្តុង្គឧត្តមនេះ។ សូមលើកហត្ថប្រណម្យបង្គំអញ្ជលីបួងសួងដល់គុណបុណ្យព្រះរតនត្រ័យ តេជៈបារមីនៃវត្ថុស័ក្តិសិទ្ធិទាំងឡាយក្នុងលោក ទេវតាឆ្នាំថ្មី ទេវតាថែរក្សាព្រះនគរកម្ពុជា ទេវតារក្សាព្រះមហាស្វេតច្ឆត្រក្នុងព្រះបរមរាជវាំង ដួងព្រះវិញ្ញាណក្ខន្ធ អតីតព្រះមហាក្សត្រ ព្រះមហាក្សត្រីយានីខ្មែរគ្រប់ព្រះអង្គ ជាពិសេសព្រះបរមវិញ្ញាណក្ខន្ធ ព្រះករុណាព្រះបរមរតនកោដ្ឋ សូមព្រះមេត្តាប្រោសប្រទាននូវសព្វសាធុការពរជ័យសិរីមង្គលវិបុលសុខមហាប្រសើរ ថ្វាយ**សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត សូមមានព្រះរាជសុខភាពល្អបរិបូណ៌ ព្រះទិឃាយុយឺនយូរ ដើម្បីគង់ប្រថាប់ជាម្លប់ដ៏ត្រជាក់ត្រជុំសុខដុមរមនាជាកិយ្យោភាពដល់កូនចៅ ចៅទួតទូទាំងប្រទេស ដរាបតរៀងទៅ។

ដោយគារវភក្តីដ៏ខ្ពង់ខ្ពស់បំផុត និងព្រះមហាករុណាទិគុណដ៏ធំធេង ចំពោះទូលព្រះបង្គំជាខ្ញុំ និងក្រុមគ្រួសារ សូមសម្តែងនូវកតញ្ញូតាធម៌យ៉ាងជ្រាលជ្រៅបំផុត ចំពោះព្រះរាជសកម្មភាព បំពេញព្រះរាជកិច្ចដង្ហែ**ព្រះករុណាព្រះបរមរតនកោដ្ឋ** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត និងបម្រើប្រជាជាតិ មាតុភូមិ ដែលប្រកបដោយទសពិធរាជធម៌ ព្រះព្រហ្មវិហារធម៌ សប្បុរសធម៌ ដល់កូនចៅ ចៅទួតជាប្រជានុរាស្ត្រទូទាំងប្រទេស។

សូម**សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់ ព្រះមេត្តាប្រោសទទួលនូវអភិវន្ទកិច្ច និងកតញ្ញូតាធម៌ដ៏ខ្ពង់ខ្ពស់បំផុត ពីទូលព្រះបង្គំជាខ្ញុំ និងភរិយា។

ក្រាបបង្គំទូលថ្វាយ នៅភ្នំពេញ ថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២៥

ទូលព្រះបង្គំជាខ្ញុំ ខ្ញុំម្ចាស់

ខែក ឡីរ៉ង **នរោត្តម រ៉ាវ៉ែន**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាធម្មនុញ្ញ

សារថ្វាយព្រះពរ

សូមក្រាបបង្គំទូលថ្វាយ
សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ
ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល
ក្នុងឱកាសព្រះរាជពិធីបុណ្យចម្រើនព្រះជន្មគម្រប់ ៨៩ យាងចូល ៩០ ព្រះវស្សា

សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត

ក្នុងឱកាសដ៏មហានក្ខត្តឫក្សមហាប្រសើរនៃព្រះរាជពិធីបុណ្យចម្រើនព្រះជន្មគម្រប់ ៨៩ យាងចូល ៩០ ព្រះវស្សា របស់ **សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ** ថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០២៥ ខាងមុខនេះ ទូលព្រះបង្គំជាខ្ញុំ តាងនាមសមាជិក សមាជិកា ក្រុមប្រឹក្សាធម្មនុញ្ញ និងមន្ត្រីរាជការគ្រប់ជាន់ថ្នាក់នៃអគ្គលេខាធិការដ្ឋាន ក្រុមប្រឹក្សាធម្មនុញ្ញ មានមហាកិត្តិយសប្រកបដោយបីតិសោមនស្សរីករាយជាអនេក សូមព្រះបរមរាជានុញ្ញាតថ្វាយព្រះពរជ័យមង្គល បវរសួស្តី មហាប្រសើរ សូម**សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ** ទ្រង់មានព្រះកាយពលមាំមួន ព្រះរាជសុខភាពល្អបរិបូរ ព្រះបញ្ញាញាណភ្លឺថ្លា ព្រះជន្មាយុយឺនយូរ ដើម្បីគង់ប្រថាប់ជាព្រះមាតាជាតិ ជាម្លប់ដ៏ត្រជាក់សម្រាប់ជាទីជ្រកកោនដល់កូនចៅ ចៅទួតរបស់ព្រះអង្គតរៀងទៅ។

ទូលព្រះបង្គំយើងខ្ញុំទាំងអស់គ្នា ចងចាំជានិច្ចនូវព្រះរាជគុណូបការៈរបស់ **សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ** ក្នុងព្រះរាជតួនាទីដ៏ឧត្តុង្គឧត្តម បូជាព្រះកាយពល ព្រះរាជហឫទ័យ និងព្រះបញ្ញាញាណដង្ហែព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ជួយលើកស្ទួយស្ថិរភាពមនុស្សធម៌ និងសង្គមកិច្ច រួមចំណែកជួយរំលែកគ្រោះកាចសព្វបែបយ៉ាង និងជួយកាត់បន្ថយភាពក្រីក្រក្នុងជុំវិញប្រជានុរាស្ត្រក្រីក្រ និងជួបការលំបាកក្នុងគ្រប់កាលៈទេសៈ។

នៅក្នុងឱកាសដ៏ឧត្តុង្គឧត្តមនេះ ទូលព្រះបង្គំជាខ្ញុំ សូមបួងសួងដល់គុណបុណ្យព្រះរតនត្រៃ វត្ថុស័ក្តិសិទ្ធិក្នុងលោក ទេវតារក្សាព្រះមហាស្វេតច្ឆត្រ បុណ្យបារមីនៃដួងព្រះវិញ្ញាណក្ខន្ធអតីតព្រះមហាក្សត្រ និងព្រះមហាក្សត្រីយានីខ្មែរគ្រប់ព្រះអង្គ ពិសេសទេវតាឆ្នាំថ្មី ព្រះនាម **គោរាគនេទី** មេត្តាជួយរក្សាកិបាលប្រោះព្រំនូវព្រះសព្វសាធុការពរជ័យគ្រប់ប្រការថ្វាយ **សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ** និង**ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង** សូមព្រះអង្គទ្រង់សមប្រកបដោយពុទ្ធពរទាំងបួន ប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

សេចក្តីគួរពុំគួរសូម **សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ព្រះមេត្តាទទួលនូវគោរវកិច្ច កតញ្ញូតាធម៌ និងព្រះមេត្តាទទួលនូវអភិវន្ទន៍ដ៏ខ្ពង់ខ្ពស់បំផុតពីទូលព្រះបង្គំជាខ្ញុំ។

ថ្ងៃ ៨កើត ខែ ជេស្ឋ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
ក្រាបបង្គំទូលថ្វាយនៅរាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ២០២៥

ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ

ឯកឧត្តមបណ្ឌិត អឹម ឈុនលឹម

Sa Majesté la Reine-Mère
NORODOM Monineath Sihanouk du Cambodge

Majesté,

A l'approche de la date de Votre auguste anniversaire, le 18 juin, je me permets de très humblement présenter à Votre Majesté mes très respectueux vœux de bonheur, de parfaite santé, et de longévité.

Puisse Votre Majesté demeurer auprès de Son peuple et étendre Son ombre tutélaire sur le Royaume pour de très nombreuses années encore.

Daigne Votre Majesté recevoir l'expression renouvelée de mes vœux les plus déférents et de mon très profond respect,

Je demeure de Votre Majesté, et de Sa Majesté le Roi, le très humble serviteur

Blaise Kilian

Phnom Penh, le 17 juin 2025

LYCÉE FRANÇAIS
RENÉ DESCARTES
PHNOM PENH • 1951

Votre Majesté

Au nom de l'ensemble de la communauté éducative du Lycée Français René Descartes, je Vous présente mes vœux les plus sincères à l'occasion de Votre 89ème anniversaire.

Nos professeurs et élèves se joignent à moi pour Vous souhaiter santé, bonheur et sérénité.

Permettez-moi d'ajouter qu'il s'agit pour moi du dernier message que j'ai l'honneur de Vous adresser en tant que proviseur du Lycée, à l'issue de mon mandat. Je m'apprête en effet à quitter le Cambodge pour poursuivre mes fonctions en Afrique du Sud.

Je Vous prie de croire, Votre Majesté, en l'assurance de mes hommages les plus respectueux.

Phnom-Penh, le 16 juin 2025

Gilles PERINET
Proviseur du Lycée Français René Descartes

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងពាណិជ្ជកម្ម

សូមក្រាបបង្គំទូលថ្វាយ
សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ
ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល

សម្តេចព្រះមហាក្សត្រី *ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត!*

ក្នុងឱកាសអកិលក្ខិតកាលដ៏មហាសិរីមង្គលថ្លៃថ្លា ប្រកបដោយក្តីសោមនស្សរីករាយនៃពិធីបុណ្យចម្រើនព្រះជន្មគម្រប់ ៨៩ យាងចូល ៩០ ព្រះវស្សា នាថ្ងៃពុធ ៨រោច ខែជេស្ឋ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០២៥ ខាងមុខនេះ ខ្ញុំម្ចាស់ និងក្រុមគ្រួសារ ព្រមទាំងថ្នាក់ដឹកនាំ មន្ត្រីរាជការគ្រប់លំដាប់ថ្នាក់នៃក្រសួងពាណិជ្ជកម្ម សូមលំនឹនកាយ ក្រាបថ្វាយបង្គំ **សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត និងសូមព្រះបរមារាជានុញ្ញាតលំនឹនកាយវាចាចិត្ត ក្រាបបង្គំថ្វាយនូវព្រះសព្វសាធុការពរជ័យ បវរសួស្តី សិរីវឌ្ឍនា មហាប្រសើរគ្រប់ប្រការប្រកបដោយកតញ្ញូតាធម៌ និងកតវេទិតាធម៌ដ៏ឧត្តុង្គឧត្តមដោយសុទ្ធចិត្តបំផុតចំពោះព្រះអង្គ ដែលបានចំណាយព្រះកាយពល និងព្រះបញ្ញាញាណ ក្នុងព្រះរាជសកម្មភាពដ៏ថ្លៃថ្លាប្រកបដោយទសពិធរាជធម៌ លើកស្ទួយវិស័យព្រះពុទ្ធសាសនា អប់រំសិក្សាធិការ សង្គមកិច្ច មនុស្សធម៌ សុខុមាលភាព ជាពិសេសការលើកកម្ពស់តម្លៃ និងតួនាទីរបស់ស្ត្រីក្នុងព្រះរាជាណាចក្រកម្ពុជា។

ខ្ញុំម្ចាស់ ទូលព្រះបង្គំយើងខ្ញុំទាំងអស់គ្នា សូមព្រះបរមារាជានុញ្ញាតជាថ្មីម្តងទៀតលើកហត្ថប្រណម្យបួងសួងដល់គុណបុណ្យព្រះតេនត្រ័យ និងវត្ថុស័ក្តិសិទ្ធិក្នុងលោក ទេវតាថែរក្សាព្រះមហាស្វេតច្ឆត្រ ព្រមទាំងបុណ្យបារមីនៃដួងព្រះវិញ្ញាណក្ខន្ធអតីតព្រះមហាក្សត្រ ព្រះមហាក្សត្រីយានីខ្មែរគ្រប់ព្រះអង្គ និងទេវតាថែរក្សាទឹកដីនៃព្រះរាជាណាចក្រកម្ពុជា សូមតាមជួយថែរក្សាការពារអភិបាល ប្រោះព្រំនូវព្រះសព្វសាធុការពរជ័យគ្រប់ប្រការថ្វាយចំពោះ **សម្តេចព្រះមហាក្សត្រី** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត និងសូមព្រះអង្គទ្រង់ប្រកបដោយព្រះរាជសុខភាពល្អបរិបូណ៌ ព្រះកាយពលមាំមួន ព្រះបញ្ញាញាណភ្លឺថ្លា ព្រះទីឃាយុយឺនយូរជាងរយព្រះវស្សា ដើម្បីគង់ប្រថាប់ជាម្លប់ដ៏ត្រជាក់ត្រជុំសុខដុមមេនាដល់ជាតិមាតុភូមិកម្ពុជា និងប្រជានុរាស្ត្រ ជាកូន ជាចៅ ចៅទួតរបស់ព្រះអង្គជានិច្ចនិរន្តរ៍តរៀងទៅ។

សូម **សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ទ្រង់ព្រះប្រោសព្រះរាជមេត្តាទទួលនូវអែកិវន្ទនកិច្ច និងគារវកក្តីដ៏ស្មោះស្ម័គ្រប់បំផុតពីខ្ញុំម្ចាស់ ទូលព្រះបង្គំយើងខ្ញុំទាំងអស់គ្នា។

ថ្ងៃ ឆ្ងៃ ១រោច ខែជេស្ឋ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
ក្រាបបង្គំទូលថ្វាយដោយជ្រះថ្លាពេញ ថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០២៥

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

ចម និម្មល

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារជាតិនៃកម្ពុជា

លេខ៖ធ.ជ.០២៥.០៨០.និ.សា.

សារលិខិតថ្វាយព្រះពរ
សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ
ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល
នៅក្នុងឱកាសនៃព្រះរាជពិធីបុណ្យចម្រើនព្រះជន្មវស្សា
គម្រប់ ៨៩ព្រះវស្សា ឃាងចូល ៩០ព្រះវស្សា

បពិត្រ សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត

តាងនាមថ្នាក់ដឹកនាំ និងមន្ត្រីបុគ្គលិកធនាគារជាតិនៃកម្ពុជា ខ្ញុំម្ចាស់សូមសម្តែងនូវក្តីសោមនស្សរីករាយឥតឧបមា ក្នុងឱកាសនៃព្រះរាជពិធីបុណ្យចម្រើនព្រះជន្មវស្សា **សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ក្នុងគម្រប់ព្រះជន្ម ៨៩ ឃាងចូល ៩០ ព្រះវស្សា ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃពុធ ៨រោច ខែជេស្ឋ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០២៥ ខាងមុខនេះ។

ក្នុងឱកាសដ៏មហានក្ខត្តឫក្សនេះ ទូលព្រះបង្គំយើងខ្ញុំនិងខ្ញុំម្ចាស់ទាំងអស់គ្នា សូមលើកហត្ថប្រណម្យបូងសួងដល់គុណបុណ្យព្រះរតនត្រ័យ កែវទាំងបី ទេវតាថែរក្សាព្រះមហាស្វេតច្ឆត្រ ព្រះបារមីអតីតព្រះមហាក្សត្រ ព្រះមហាក្សត្រិយានីខ្មែរគ្រប់ព្រះអង្គ សូមប្រោសព្រះរាជទាន ប្រោះព្រំនូវទឹកអម្រឹតប្រសិទ្ធពរជ័យ សិរីសួស្តីថ្វាយ **សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត សូមប្រកបដោយព្រះពុទ្ធពរទាំង៨ប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ដើម្បីព្រះអង្គគង់ប្រថាប់ជាម្លប់ដ៏ត្រជាក់ត្រជុំដល់ប្រជានុកស្ត្រជារៀងរហូតតទៅ។

សូម **សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ទ្រង់ព្រះមេត្តាទទួលនូវអភិវន្ទនកិច្ចដ៏ខ្ពង់ខ្ពស់ពីទូលព្រះបង្គំយើងខ្ញុំនិងខ្ញុំម្ចាស់ទាំងអស់គ្នា។

សេចក្តីគួរពុំគួរ សូម **សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ** ទ្រង់ព្រះមេត្តាប្រោស។

សូមក្រាបបង្គំទូលថ្វាយ ថ្ងៃ[illegible]ខែជេស្ឋ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែមិថុនា ឆ្នាំ២០២៥

ខ្ញុំម្ចាស់ តំណាងមន្ត្រីបុគ្គលិកធនាគារជាតិនៃកម្ពុជា
ទេសាភិបាល

ជា សិរី

ПОСОЛ
РОССИЙСКОЙ ФЕДЕРАЦИИ

ឯកអគ្គរដ្ឋទូតនៃសហព័ន្ធរុស្ស៊ី
ភ្នំពេញ ថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០២៥

សារលិខិតថ្វាយព្រះពរ
សម្តេច ព្រះមហាក្សត្រ នរោត្តម មុនិនាថ សីហនុ
ព្រះវររាជមាតាជាតិខ្មែរ

សម្តេចព្រះមហាក្សត្រ នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត!

តាងនាមមន្ត្រីការទូតនៃស្ថានទូតរុស្ស៊ីប្រចាំព្រះរាជាណាចក្រកម្ពុជា និងនៅក្នុងនាមទូលព្រះបង្គំជាខ្ញុំផ្ទាល់ សូមព្រះបរមរាជានុញ្ញាតគោរពថ្វាយព្រះពរជ័យបវរសួស្តី មហាប្រសើរ ក្នុងឱកាសដ៏មង្គលាភិរម្យថ្លៃថ្លា ប្រកបដោយក្តីអភិរម្យសោមនស្សរីករាយនៃព្រះរាជវរកាសនៃព្រះរាជពិធីចម្រើនព្រះជន្មវស្សាគម្រប់៨៩ព្រះវស្សា។

អស់រយៈពេលជាច្រើនឆ្នាំមកហើយ **សម្តេចព្រះមហាក្សត្រ ព្រះវររាជមាតាជាតិខ្មែរ** ទ្រង់ខិតខំប្រឹងប្រែងដើម្បីពង្រឹងសន្តិភាពនៅក្នុងព្រះរាជាណាចក្រកម្ពុជា និងទ្រង់ធ្វើឲ្យជនងាយរងគ្រោះមានជីវិតកាន់តែល្អប្រសើរ។ **សម្តេចព្រះមហាក្សត្រ ព្រះវររាជមាតាជាតិខ្មែរ** ទ្រង់ធ្វើជាគំរូនៃការថែទាំអំពីប្រជាជននិងភក្តីភាពពិតប្រាកដចំពោះមាតុភូមិ។

នាថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២៥ យើងបានប្រារព្ធខួបអនុស្សាវរីយ៍លើកទី៦៩ នៃការបង្កើតទំនាក់ទំនងការទូតរវាងប្រទេសយើងទាំងពីរ។ ទូលព្រះបង្គំជាខ្ញុំ សូមព្រះបរមរាជានុញ្ញាតសម្តែងនូវការជឿជាក់ថា ប្រទេសរុស្ស៊ីនិងកម្ពុជាតែងតែនិងនៅតែធ្វើជាមិត្តដ៏ល្អប្រសើរដែលត្រៀមខ្លួនជួយឧបត្ថម្ភគ្នាទៅវិញទៅមកនាគ្រាដ៏លំបាកបំផុត។

សូម **សម្តេចព្រះមហាក្សត្រ ព្រះវររាជមាតាជាតិខ្មែរ** ព្រមទាំង **ព្រះរាជវង្សានុវង្ស** ប្រកបដោយព្រះរាជសុខភាពល្អ សុភមង្គល និង វិបុលសុខ។ សូម **សម្តេចព្រះមហាក្សត្រ ព្រះវររាជមាតាជាតិខ្មែរ** ទ្រង់ព្រះមេត្តា ទទួលនូវគោរវភក្តីភាពដ៏ស្មោះត្រង់បំផុតនិងការគោរពដ៏ខ្ពង់ខ្ពស់អំពីទូលព្រះបង្គំជាខ្ញុំ។

អណាតូលី ប៊ូរ៉ូវីក

Lao People's Democratic Republic
Peace Independence Democracy Unity and Prosperity

ສະຖານເອກອັກຄະລັດຖະທູດ ແຫ່ງ ສາທາລະນະລັດ ປະຊາທິປະໄຕ ປະຊາຊົນລາວ ປະຈຳ ຣາຊະອານາຈັກກຳປູເຈຍ

Embassy of the Lao People's Democratic Republic to the Kingdom of Cambodia

Her Majesty Samdech Norodom Monineath Sihanouk
Queen Mother of the Kingdom of Cambodia
Phnom Penh.

Your Majesty,

On the auspicious occasion of Your Majesty's 89th Birthday, on behalf of the Embassy of the Lao People's Democratic Republic to the Kingdom of Cambodia and on my own behalf, I would like to convey our heartfelt congratulations and our best wishes for Your Majesty's continued good health, longevity and happiness forever!

Please accept, Your Majesty, the renewed assurances of my highest consideration and the warm regards and esteem of the Embassy of the Lao People's Democratic Republic.

Phnom Penh, 17 June 2025

H.E. Mr. Buakeo PHUMVONGSAY
Ambassador of the Lao People's Democratic
Republic to the Kingdom of Cambodia



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សមាគមស្ត្រីនិងមេធាវីកម្ពុជា ស.ស.ក
Association Women and Law Women of Cambodia (AWLC)
លេខ: ០៩/០៥ ស.ជ.ឧ.ក

លិខិតថ្វាយ

សម្តេច ព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ
ព្រះវររាជមាតាជាតិ ខ្មែរក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល
ព្រះប្រធានកិត្តិយស សមាគមស្ត្រីនិងមេធាវីកម្ពុជរដ្ឋ

ទូលព្រះបង្គំ ខ្ញុំម្ចាស់ គណៈកម្មាធិការប្រតិបត្តិ និងសមាជិកា សមាគមស្ត្រីនិង មេធាវីកម្ពុជរដ្ឋ សូមលើកហត្ថ ឱនកាយក្រាបថ្វាយបង្គំ សម្តេចម៉ែជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត។

នាព្រះវរឱកាស ដ៏មហានក្ខត្តឫក្សឧត្តង្គឧត្តម ក្នុងព្រះរាជពិធីចំពោះព្រះជន្ម សម្តេចម៉ែជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុតចំពោះព្រះជន្ម ៨៩ យាងចូល ៩០ ព្រះវស្សា នៅថ្ងៃ ១៨ មិថុនា ខាងមុខ ខ្ញុំម្ចាស់ទាំងអស់គ្នា សូមលំអោនកាយក្រាបថ្វាយបង្គំ ព្រះបរមរាជានុញ្ញាតដ៏ខ្ពង់ខ្ពស់បំផុត ប្រារព្ធពិធីចំពោះព្រះជន្មថ្វាយនៅក្នុងមណ្ឌលរបស់សមាគមក្នុងភូមិ ធម្មត្រ័យ ឃុំផ្សារដែក ស្រុកពញាឮ ខេត្តកណ្តាល។

ទូលព្រះបង្គំខ្ញុំម្ចាស់ទាំងអស់គ្នា សូមលំអោនកាយ ក្រាបថ្វាយបង្គំ ព្រះបរមរាជានុញ្ញាតដ៏ខ្ពង់ខ្ពស់បំផុត ថ្វាយព្រះពរសម្តេចម៉ែជាអង្គម្ចាស់ ព្រះអង្គប្រកបដោយព្រះរាជសុខភាពល្អបរិបូណ៌ ព្រមទាំងព្រះជន្មាយុយឺនយូរជោងរយព្រះវស្សា ។

គួរពុំគួរ សូមទ្រង់ព្រះមេត្តាប្រោស។

ថ្ងៃចន្ទ ១៨កើត ខែ ជេស្ឋ ឆ្នាំម្សាញ់ សប្តស័ក ព.ស ២៥៦៩
ត្រូវនិងថ្ងៃច័ន្ទ ទី ៩ ខែ មិថុនា ឆ្នាំ ២០២៥
នាយិកាប្រតិបត្តិស្តីទី

ជូនដី ហើល ហិន

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សារលិខិតថ្វាយព្រះពរ
សូមក្រាបបង្គំទូលថ្វាយ

សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ
ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល

សម្តេចព្រះមហាក្សត្រ ព្រះវររាជមាតាជាតខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល

ក្នុងឱកាសព្រះរាជពិធីបុណ្យចំពោះព្រះជន្មវស្សា **សម្តេចព្រះមហាក្សត្រ ព្រះវររាជមាតាជាតខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត គម្រប់ ៨៩ យាងចូល ៩០ ព្រះវស្សា ទូលព្រះបង្គំជាខ្ញុំ មានបិតិសោមនស្សរំភើបរីករាយឥតឧបមា និង សូមព្រះបរមរាជានុញ្ញាតដ៏ខ្ពង់ខ្ពស់ ចូលរួមអបអរសាទរយ៉ាងកក់ក្តៅ ហើយសូមប្រសិទ្ធិពរជ័យ សិរីសួស្តី ជ័យមង្គល វិបុលសុខ បវរមហាប្រសើរថ្លៃថ្លា ថ្វាយ **សម្តេចព្រះវររាជមាតាជាតខ្មែរ** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត សូមព្រះអង្គស្តេចបានប្រកបនូវព្រះរាជកាយពលមាំមួន ព្រះរាជសុខភាពល្អបរិបូណ៌ ព្រះរាជជន្មាយុយឺនយូរ ព្រះរាជបញ្ញាញាណឈ្លាសវៃ ជានិច្ចនិរន្តរ៍ ។

ឆ្លៀតក្នុងឱកាសដ៏វិសេសវិសាលនេះ ទូលព្រះបង្គំជាខ្ញុំ សូមលើកហត្ថប្រណមបួងសួងដល់ គុណបុណ្យព្រះរតនត្រ័យកែវទាំងបី ទេវតាថែរក្សាព្រះមហាស្វេតច្ឆត្រ ព្រះបារមីនៃអតីតព្រះមហាក្សត្រ ព្រះមហាក្សត្រយានីខ្មែរគ្រប់ព្រះអង្គ ព្រមទាំងវត្ថុស័ក្តិសិទ្ធិទាំងឡាយក្នុងលោក និង ទេវតាឆ្នាំថ្មី ព្រះនាម **គោរាគៈទេវី** សូមព្រះមេត្តាអភិបាលរក្សា និងប្រោសប្រទានពរជ័យ ថ្វាយចំពោះ **សម្តេចព្រះវររាជមាតាជាតខ្មែរ និង ព្រះករុណា ព្រះមហាក្សត្រ** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត សូមព្រះអង្គស្តេចបានប្រកបនូវព្រះបរមសុខគ្រប់ប្រការ ប្រោសចាកព្រះរោគាព្យាធិទាំងឡាយ ឈ្នះអស់មាសត្រូវគ្រប់ទិសទី ដើម្បីគង់ប្រថាប់ក្នុងព្រះមរមារាជសម្បត្តិដ៏ត្រជាក់ត្រជុំសម្រាប់ប្រជានុកូរខ្មែរ និង ព្រះរាជវង្សានុវង្សរបស់ព្រះអង្គ បានជ្រកកោនជាយូរអង្វែងតរៀងទៅ ។

សូម **សម្តេចព្រះវររាជមាតាជាតខ្មែរ** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ព្រះរាជមេត្តាស្តេចទទួលនូវអភិវន្ទនកិច្ច និង ស្វាមីភក្តិបំផុតពីទូលព្រះបង្គំជាខ្ញុំ ។

សេចក្តីគួរពុំគួរ សូមទ្រង់ព្រះរាជមេត្តាប្រោសព្រះរាជទានទោស ។

សូមក្រាបបង្គំទូលថ្វាយនៅ ថ្ងៃចន្ទ ១៨កើត ខែជេស្ឋ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០២៥

ទូលព្រះបង្គំជាខ្ញុំ

នរោត្តម ប្រ៊ីយសោភ័ណ្ឌ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា
សីល សមាធិ បញ្ញា

ស្ថាប័នសិក្សាដើម្បីឧត្តមភាព

លិខិតថ្វាយព្រះពរ

សម្តេចព្រះមហាក្សត្រី នរោត្តម មុនីនាថ សីហនុ

ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល

ក្នុងឱកាសព្រះរាជពិធីចម្រើនព្រះជន្ម ៨៩ ឃាងចូល ៩០ ព្រះវស្សា

សម្តេចព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព ជាទីសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត

តាងនាមក្រុមប្រឹក្សាភិបាល សមាជិក សមាជិកា សាស្ត្រាចារ្យ បុគ្គលិកសិក្សា និងនិស្សិត នៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជាទាំងអស់ ទូលព្រះបង្គំ សូមព្រះបរមរាជានុញ្ញាត លំអិនកាយក្រាបបង្គំទូលថ្វាយនូវព្រះសព្ទសាធុការពរបវរមហាប្រសើរ សិរីសួស្តី ជ័យមង្គល វិបុលសុខគ្រប់ប្រការចំពោះ **សម្តេចព្រះមហាក្សត្រី នរោត្តម សីហនុ ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល** *ជាទីសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ក្នុងឱកាសព្រះរាជពិធីចម្រើនព្រះជន្ម ៨៩ យាងចូល ៩០ព្រះវស្សា។*

ទូលព្រះបង្គំជាកូន ចៅ ចៅទួតទាំងអស់គ្នា តែងចងចាំជានិច្ចនូវព្រះមហាករុណាទីគុណដ៏ជ្រាលជ្រៅជាទីបំផុតនៃព្រះរាជបេសកកម្មដ៏ប្រសើរលើសលប់ ដែលសម្តេចក្សត្រីដង្កែរតាមព្រះរាជអគ្គមគ្គុទេសដ៏ឧត្តុង្គឧត្តមនៃ **ព្រះករុណា ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ ព្រះមហាវីរក្សត្រ ព្រះវររាជបិតាឯករាជ្យ បូរណភាពទឹកដី និងឯកភាពជាតិខ្មែរ "ព្រះបរមរតនកោដ្ឋ"** *ជាទីសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ក្នុងការស្វែងរកសុខសន្តិភាព ការផ្សះផ្សា បង្រួបបង្រួមជាតិ និងបូរណភាពទឹកដី ជូនប្រជារាស្ត្រខ្មែរ និងមាតុភូមិជាទីស្នេហា ជាពិសេស* **សម្តេចព្រះវររាជមាតាជាតិខ្មែរ** *តែងតែយកព្រះរាជហឫទ័យទុកដាក់ដ៏ខ្ពង់ខ្ពស់បំផុតក្នុងវិស័យអប់រំសិក្សាធិការជាតិ និងមនុស្សធម៌ ដើម្បីពង្រឹងជាតិ សាសនា ព្រះមហាក្សត្រ ប្រកបដោយព្រហ្មវិហារធម៌ដ៏បរិសុទ្ធ និងទសពិធរាជធម៌ដ៏ខ្ពស់បំផុត។*

ក្នុងឱកាសដ៏មានសិរីសួស្តី និងមហោឡារិកនេះ ដោយបុញ្ញកុសលដែល ទូលព្រះបង្គំយើងខ្ញុំទាំងអស់គ្នាបានសាងជាបន្តបន្ទាប់ សូមលើកហត្ថប្រណម បួងសួងដល់គុណបុណ្យព្រះរតនត្រ័យ និងសូមបារមីនៃព្រះសម្មាសម្ពុទ្ធទាំង៦៨ព្រះអង្គផង ៦ម៉ឺន៤ពាន់ព្រះអង្គផង ១លានព្រះអង្គផង ១០៥ព្រះអង្គផង ៤ម៉ឺន៨ពាន់ព្រះអង្គផង ២លានព្រះអង្គផង អំណាចនៃគុណព្រះធម៌ទាំង ៨ម៉ឺន៤ពាន់ព្រះធម្មខន្ធ តេជានុភាពនៃគុណធម៌នៃព្រះអរិយសង្ឃ និងសមត្តិសង្ឃរបស់ព្រះសម្មាសម្ពុទ្ធទាំងឡាយនោះ ព្រមទាំងបារមីនៃអតីតព្រះមហាក្សត្រ ព្រះមហាក្សត្រីយានីគ្រប់ព្រះអង្គ ទេវតាថែរក្សាព្រះមហាស្វេតច្ឆត្រ ទេវតាថែរក្សាព្រះរាជាណាចក្រកម្ពុជា ស្តេចចតុមហារាជកាដែលរក្សាលោកទាំងមូល ព្រមទាំងវត្ថុសក្តិសិទ្ធិទាំងឡាយក្នុងលោក ជាពិសេសបារមីនៃ **ព្រះករុណា ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ ព្រះបរមរតនកោដ្ឋ** *សូមព្រះអង្គតាមថែរក្សា និងប្រោះព្រំព្រះពរមហាប្រសើរថ្វាយ* **សម្តេចព្រះវររាជមាតាជាតិ** *ជាទីសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត។សូម* **សម្តេចព្រះវររាជមាតាជាតិ** *ជាទីសក្ការៈដ៏ខ្ពង់ខ្ពស់បំផុតព្រះរាជមេត្តាទទួលនូវគារវកិច្ច កតញ្ញូតាធម៌ និងស្វាមីភក្តិអំពីទូលព្រះបង្គំយើងខ្ញុំទាំងអស់គ្នា។*

សេចក្តីគួរពុំគួរ សូម **សម្តេចព្រះវររាជមាតាជាតិ** *ជាទីសក្ការៈព្រះមេត្តាប្រោសព្រះរាជទានទោសដោយព្រះរាជហឫទ័យករុណាអនុគ្រោះដ៏ខ្ពង់ខ្ពស់បំផុត។*

ថ្ងៃច័ន្ទ ៦រោច ខែជេស្ឋ ឆ្នាំម្សាញ់ សប្តស័ក ពុទ្ធសករាជ ២៥៦៩

ត្រូវនឹងថ្ងៃទី១៦ ខែមិថុនា គ.ស.២០២៥

ប្រធានសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា

កុល ផេង

ចុតប្បាយថ្វាយព្រះពរ
សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ
ព្រះវររាជមាតាជាតិខ្មែរ
ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល
ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត

បពិត្រសម្តេចព្រះមហាក្សត្រី

ក្នុងឧកាសដ៏មហានក្ខត្តឫក្សនៃព្រះរាជពិធីបុណ្យចម្រើនព្រះជន្ម សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ គម្រប់៨៩ យាងចូល ៩០ ព្រះវស្សា ទូលព្រះបង្គំជាខ្ញុំ សូមលំឱនកាយវាចាចិត្ត ក្រាបបង្គំថ្វាយនូវព្រះសព្វសាធុការពរជ័យ បវរសួស្តីសិរីមង្គលមហាប្រសើរ និងសូមបួងសួងដល់គុណបុណ្យព្រះរត្នត្រ័យ ទេវតារក្សាព្រះស្វេតច្ឆត្រ ដួងព្រះវិញ្ញាណក្ខន្ធអតីតព្រះមហាក្សត្រ ព្រះមហាក្សត្រិយានី គ្រប់ព្រះអង្គ ជាពិសេសដួងព្រះវិញ្ញាណក្ខន្ធ ព្រះករុណាព្រះបាទសម្តេច ព្រះនរោត្តម សីហនុ ព្រះមហាវីរក្សត្រ ព្រះបរមរតនៈកោដ្ឋ សូមទ្រង់ព្រះមេត្តាតាមជួយបីបាច់ថែរក្សាប្រោះព្រំ ប្រសិទ្ធពរជ័យ ថ្វាយ ព្រះវររាជមាតាជាតិខ្មែរ ជាទីសក្ការៈរបស់ប្រជានុរាស្ត្រខ្មែរ សូមទ្រង់ប្រកបដោយព្រះរាជសុខភាពល្អបរិបូរណ៌ ព្រះជន្មាយុយឺនយូរ ព្រះបញ្ញាញាណវាងវៃ ដើម្បីបន្តគង់ជាម្លប់ដ៏ត្រជាក់ត្រជុំ ដល់ប្រជានុរាស្ត្រតួចតាច ដែលសព្វថ្ងៃមានតែ អង្គព្រះមហាក្សត្រ ព្រះករុណាជាអម្ចាស់ជីវិតតម្កល់លើត្បូង និងអង្គព្រះវររាជមាតាជាតិខ្មែរជាទីសក្ការៈ ទេដែលជាទីពឹងរបស់គេទាំងអស់ និងជានិមិត្តរូប ជាគ្រឹះនៃឯកភាពជាតិខ្មែរទាំងមូល ។

ទូលព្រះបង្គំជាខ្ញុំក៏សុំលំឱនកាយថ្លែងថ្វាយ ព្រះវររាជមាតាជាតិខ្មែរ នូវកតញ្ញូតាដ៏ជ្រាលជ្រៅបំផុត ដែលព្រះមហាក្សត្រីយ៍ ព្រះវររាជមាតាជាតិខ្មែរ និងព្រះករុណាជាអម្ចាស់ជីវិតតម្កល់លើត្បូង តែងតែសន្តោសប្រោសប្រណី មកលើទូលព្រះបង្គំជាខ្ញុំ ជាងសាមសិបឆ្នាំមកហើយ។ ទូលព្រះបង្គំជាខ្ញុំមិនងាយភ្លេចទេ នូវគុណូបការៈរបស់ ព្រះមហាក្សត្រីយ៍ ព្រះវររាជមាតាជាតិខ្មែរ មកលើក្រុមគ្រួសារទូលព្រះបង្គំជាខ្ញុំ ពេលបុណ្យសពឪពុកមាទូលព្រះបង្គំជាខ្ញុំ ទ្រង់សុងដេត កាលពីឆ្នាំ ១៩៩៤។

សេចក្តីគួរពុំគួរ ទូលព្រះបង្គំជាខ្ញុំសូមព្រះមហាក្សត្រីយ៍ព្រះវររាជមាតាជាតិខ្មែរ ទ្រង់ព្រះមេត្តាប្រោះក្រោមល្អងធូលីព្រះបាទ ។

សូម ព្រះមហាក្សត្រីយ៍ព្រះវររាជមាតា តិខ្មែរទ្រង់ព្រះមេត្តាទទួល នូវគារវភក្តីភាពដ៏ជ្រាលជ្រៅបំផុតពីទូលព្រះបង្គំជាខ្ញុំ។

ក្រាបបង្គំថ្វាយព្រះពរនារាជធានីភ្នំពេញ, ថ្ងៃទី១៨ ខែមិថុនាឆ្នាំ២០២៥

ទូលព្រះបង្គំជាខ្ញុំ នរោត្តម នរិន្ទវិថ្វីវង្ស

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សារលិខិតថ្វាយព្រះពរ

សូមក្រាបបង្គំទូលថ្វាយ
សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ
ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល

សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត !

ក្នុងឱកាសដ៏វិសេសវិសាល នៃព្រះរាជពិធីបុណ្យចម្រើនព្រះជន្ម **សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិ ខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត គម្រប់៨៩ យាងចូល៩០ ព្រះវស្សា ដែលនឹងឈានមកដល់នៅថ្ងៃពុធ ៨រោច ខែជេស្ឋ ឆ្នាំម្សាញ់ សប្តស័ក ពុទ្ធសករាជ ២៥៦៩ ត្រូវនឹងថ្ងៃទី១៨ ខែមិថុនា ឆ្នាំ ២០២៥ ខាងមុខនេះ ខ្ញុំម្ចាស់ **រស់ ព្រីឃ្លិន អ៊ឹងគៀត** សូមព្រះបរមរាជានុញ្ញាតសម្តែងនូវក្តីកតញ្ញូតវេទិតាធម៌ដ៏ជ្រាលជ្រៅបំផុត ថ្វាយ **សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ** និងសូមឧទ្ទិសបួងសួងដល់គុណបុណ្យព្រះរតនត្រ័យ កែវទាំងបី ទេវតាថែរក្សាព្រះមហាស្វេតច្ឆត្រ ព្រះបារមីនៃព្រះវិញ្ញាណក្ខន្ធអតីតព្រះមហាក្សត្រ ព្រះមហាក្សត្រិយានីខ្មែរគ្រប់ ព្រះអង្គ ជាពិសេសតេជៈបារមីនៃដួងព្រះវិញ្ញាណក្ខន្ធ **ព្រះបរមរតនកោដ្ឋ** សូមជួយទ្រទ្រង់បីបាច់ថែរក្សា **សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ** សូមព្រះអង្គមានព្រះជន្មាយុយឺនយូរ ព្រះរាជសុខភាពល្អបរិបូណ៌ ព្រះកាយ ពលមាំមួន ព្រះបញ្ញាញាណភ្លឺថ្លា ជានិច្ចនិរន្តរ៍តរៀងទៅ។

ឆ្លៀតក្នុងឱកាសដ៏ថ្លៃថ្លានេះ ខ្ញុំម្ចាស់ សូមព្រះបរមរាជានុញ្ញាតសម្តែងនូវអំណរព្រះរាជគុណដ៏ជ្រាលជ្រៅបំផុតថ្វាយ **សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ដែលព្រះអង្គសព្វព្រះរាជ ហឫទ័យ ប្រោសព្រះរាជទាននូវនំអន្សមដ៏មានឱជារស និងសៀវភៅព្រះរាជសកម្មភាព និងព្រះរាជសមិទ្ធផល **ព្រះករុណា ជាអម្ចាស់ជីវិតលើត្បូង** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ដល់ខ្ញុំម្ចាស់។

សេចក្តីគួរពុំគួរ សូម **សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ** ទ្រង់ព្រះមេត្តាប្រោស។

ក្រាបបង្គំទូលថ្វាយ ថ្ងៃ ពុធ ៨ រោច ខែជេស្ឋ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែមិថុនា ឆ្នាំ២០២៥

ខ្ញុំម្ចាស់ **រស់ ព្រីឃ្លិន អ៊ឹងគៀត**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សារលិខិតថ្វាយព្រះពរ

សម្តេចព្រះមហាក្សត្រ នរោត្តម មុនីនាថ សីហនុ

ព្រះវររាជអាគារជាតិខ្មែរក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល

ក្នុងឱកាសព្រះរាជពិធីបុណ្យចំរើនព្រះជន្មវស្សា **សម្តេចព្រះមហាក្សត្រ ព្រះវររាជអាគារជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត គម្រប់ ៨៩ យាងចូល ៩០ ព្រះវស្សា នាថ្ងៃពុធ៨រោជ ខែជេស្ឋ ឆ្នាំម្សាញ់ សប្តស័កព.ស២៥៩៦ ត្រូវនឹងថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០២៥ខាងមុខនេះ ទូលព្រះបង្គំជាខ្ញុំ និងខ្ញុំស្រី សូមលំនិនកាយក្រាបថ្វាយបង្គំ **សម្តេចព្រះវររាជអាគារជាតិខ្មែរ** ជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុត និងសូមព្រះបរមរាជានុញ្ញាតលំនិនកាយវាចាចិត្ត គ្រាបបង្គំថ្វាយនូវព្រះពរសព្វសាធុការពរជ័យ បវរសួស្តី សិរីវឌ្ឍនា មហាប្រសើរគ្រប់ប្រការដោយកតញ្ញូតាធម៌ និងកតវេទិតាធម៌ដ៏ឧត្តុង្គឧត្តមដោយសុទ្ធចិត្តបំផុត ថ្វាយចំពោះ **សម្តេចព្រះវររាជអាគារជាតិខ្មែរ** ដែលបានចំណាយព្រះកាយពល និងព្រះបញ្ញាញាណ ក្នុងព្រះរាជសកម្មភាពដ៏ថ្លៃថ្លាប្រកបដោយទសពិធរាជធម៌ លើកស្ទួយវិស័យព្រះពុទ្ធសាសនា អប់រំសិក្សាធិការ សង្គមកិច្ច មនុស្សធម៌ សុខមាលភាពជាពិសេសការលើកកម្ពស់តម្លៃ និងតួនាទីរបស់ស្ត្រីក្នុងព្រះរាជាណាចក្រកម្ពុជា។

ឆ្លៀតក្នុងឱកាសដ៏វិសេសវិសាលនេះ ទូលព្រះបង្គំជាខ្ញុំ និងខ្ញុំស្រី សូមលើកហត្ថប្រណមបួងសួងដល់ គុណបុណ្យព្រះរតនត្រ័យកែវទាំងបី ទេវតាថែរក្សាព្រះមហាស្វេតច្ឆត្រ ព្រះបារមីនៃអតីតព្រះមហាក្សត្រ ***បារមីអតីតៈព្រះមហាក្សត្រ ព្រះបរមរតនកោដ្ឋ*** ព្រះមហាក្សត្រយានីខ្មែរគ្រប់ព្រះអង្គ ព្រមទាំងវត្ថុស័ក្តិសិទ្ធិទាំងឡាយក្នុងលោក សូមព្រះមេត្តាអភិបាលរក្សា និងប្រោសប្រទានពរជ័យថ្វាយចំពោះ **សម្តេចព្រះវររាជអាគារជាតិខ្មែរ** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត សូមព្រះអង្គបាន ប្រកបនូវព្រះបរមសុខគ្រប់ប្រការ ប្រាសចាកព្រះរោគាព្យាធិទាំងឡាយ ឈ្នះអស់មាសត្រូវគ្រប់ទិសទី ដើម្បី គង់ប្រថាប់ក្នុង ព្រះមរមរាជសម្បត្តិដ៏ត្រជាក់ត្រជុំសម្រាប់ប្រជារាស្ត្រខ្មែរ របស់ព្រះអង្គ បានជ្រកកោនជាយូរអង្វែង តរៀងទៅ។

សូម **សម្តេចព្រះវររាជអាគារជាតិខ្មែរ** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ព្រះរាជមេត្តា ទទួលនូវអភិវន្ទនកិច្ច និងស្វាមីភក្តិបំផុតពីទូលព្រះបង្គំ ជាខ្ញុំ និងខ្ញុំស្រី។

ថ្ងៃសុក្រ ៣រោច ខែជេស្ឋ ឆ្នាំម្សាញ់ សប្តស័ក ពុទ្ធសករាជ ២៥៦៩

ក្រាបបង្គំទូលថ្វាយនៅរាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០២៥

ទូលព្រះបង្គំជាខ្ញុំ នរោត្តម សិរិវុឌ្ឍ

ខ្ញុំស្រី ថេត

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ស្ថានឯកអគ្គរាជទូតកម្ពុជា
ប្រចាំសាធារណរដ្ឋប្រជាមានិតចិន

សារលិខិតថ្វាយព្រះពរ
សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ
ព្រះវររាជអាគារជាតិខ្មែរក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល

សម្តេចព្រះមហាក្សត្រី ព្រះវររាជអាគារជាតិខ្មែរ ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត។

នៅក្នុងឱកាសដ៏មហានក្ខត្តឫក្សប្រកបដោយសិរីមង្គលាភិសម្យឧត្តុង្គឧត្តមថ្លៃថ្លា នៃព្រះរាជពិធីបុណ្យចម្រើនព្រះជន្មគម្រប់ ៨៩ យាងចូល ៩០ ព្រះវស្សា នាថ្ងៃពុធ ទី១៨ ខែមិថុនា ឆ្នាំ២០២៥ ខាងមុខនេះ៖ តាងនាមមន្ត្រីការទូត និងបុគ្គលិកទាំងអស់ នៃស្ថានឯកអគ្គរាជទូតកម្ពុជា ប្រចាំសាធារណរដ្ឋប្រជាមានិតចិន និងក្នុងនាមខ្ញុំម្ចាស់ផ្ទាល់ និងស្វាមី ខ្ញុំម្ចាស់សូមព្រះបរមរាជានុញ្ញាតលំនិនកាយ ក្រាបបង្គំទូលថ្វាយនូវព្រះសព្វសាធុការពរជ័យ បវរសួស្តី សិរីវឌ្ឍនា វិបុលសុខ មហាប្រសើរគ្រប់ប្រការ ថ្វាយចំពោះ **សម្តេចព្រះមហាក្សត្រី ព្រះវររាជអាគារជាតិខ្មែរ ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត** សូមស្តេចទ្រង់ព្រះប្រកបដោយព្រះរាជសុខភាពល្អបរិបូណ៌ ព្រះកាយពលមាំមួន ព្រះបញ្ញាញាណវាងវៃ ព្រះជន្មាយុយឺនយូរដោងរយព្រះវស្សា ដើម្បីគង់ប្រថាប់ជាម្លប់ដ៏ត្រជាក់ត្រជុំដល់ប្រជានុរាស្ត្ររបស់ព្រះអង្គរស់ក្នុងសុខសន្តិភាពតរៀងទៅ។

ខ្ញុំម្ចាស់ និងទូលព្រះបង្គំយើងខ្ញុំទាំងអស់គ្នា សូមព្រះបរមរាជានុញ្ញាតលំនិនកាយ ថ្វាយនូវកតញ្ញូតាធម៌ និងកតវេទិតាធម៌ដ៏ជ្រាលជ្រៅបំផុត ចំពោះ **សម្តេចព្រះមហាក្សត្រី ព្រះវររាជអាគារជាតិខ្មែរ** ដែលជានិច្ចកាលស្តេចទ្រង់សព្វព្រះរាជហឫទ័យលះបង់ព្រះកាយពល ព្រះបញ្ញាញាណ និងព្រះរាជទ្រព្យផ្ទាល់របស់ព្រះអង្គ បំពេញព្រះរាជបុជនីយកិច្ច បម្រើឧត្តមប្រយោជន៍ជាតិ សាសនា និងប្រជានុរាស្ត្ររបស់ព្រះអង្គ តាមរយៈការលើកស្ទួយវិស័យព្រះពុទ្ធសាសនា សង្គមកិច្ច អប់រំសិក្សាធិការ និងសុខុដុមនាសង្គម ប្រកបដោយទសពិធរាជធម៌ ព្រះព្រហ្មវិហារធម៌ និងមនុស្សធម៌។

ខ្ញុំម្ចាស់ និងទូលព្រះបង្គំយើងខ្ញុំទាំងអស់គ្នា សូមព្រះបរមាជានុញ្ញាតលំនិនកាយលើកហត្ថប្រណម្យបួងសួងជល់គុណបុណ្យ ព្រះរតនត្រ័យ គុណកែវទាំងបី វត្ថុស័ក្តិសិទ្ធិទាំងឡាយក្នុងលោក មានទេវតារក្សាព្រះមហាស្វេតច្ឆត្រ ទេវតាថែរក្សាទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ព្រះតេជៈបារមីនៃដួងព្រះវិញ្ញាណក្ខន្ធអតីតព្រះមហាក្សត្រ ព្រះមហាក្សត្រីយានីខ្មែរគ្រប់ព្រះអង្គ ជាពិសេស **ព្រះបរមរតនកោដ្ឋ** សូមព្រះអង្គតាមជួយថែរក្សា និងប្រោះព្រំនូវសព្វសាធុការពរជ័យគ្រប់ប្រការ ថ្វាយចំពោះ **សម្តេចព្រះមហាក្សត្រី ព្រះវររាជអាគារជាតិខ្មែរ និង ព្រះករុណាជាអម្ចាស់ជីវិតលើក្បាល ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត** សូមព្រះអង្គទាំងទ្វេទ្រង់សមប្រកបដោយព្រះពុទ្ធពរទាំងប្រាំប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ និងបដិភាណៈជានិរន្តរ៍តរៀងទៅ។

សូម **សម្តេចព្រះមហាក្សត្រី ព្រះវររាជអាគារជាតិខ្មែរ ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត** ទ្រង់ព្រះមេត្តាទទួលនូវព្រះរាជកិត្តិភាពដ៏ជ្រាលជ្រៅបំផុតពីខ្ញុំម្ចាស់ និងទូលបង្គំយើងខ្ញុំទាំងអស់គ្នា។

ថ្ងៃព្រហស្បតិ៍ ២រោច ខែជេស្ឋ ឆ្នាំម្សាញ់ សប្តស័ក ព.ស ២៥៦៩

ក្រាបបង្គំទូលថ្វាយនៅរដ្ឋធានីប៉េកាំង ថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២៥

ឯកអគ្គរាជទូត

បណ្ឌិត សឿង រដ្ឋាធី

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សូមក្រាបបង្គំទូលថ្វាយ
សម្តេចព្រះមហាក្សត្រ នរោត្តម មុនិនាថ សីហនុ
ព្រះចរះរាជអាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល

ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត!

ក្នុងឱកាសដ៏មហោឦក្ខត្តឫក្សឧត្តុង្គឧត្តមប្រសើរថ្លៃថ្លា ប្រកបដោយក្តីសោមនស្សរីករាយ នៃព្រះរាជពិធីបុណ្យចម្រើនព្រះជន្ម **សម្តេចព្រះមហាក្សត្រី ព្រះចរះរាជអាតាជាតិខ្មែរ** គម្រប់ព្រះជន្ម៨៩ យាងចូល ៩០ព្រះវស្សា ដែលនឹងប្រព្រឹត្តទៅនាថ្ងៃពុធ ៨រោច ខែជេស្ឋ ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៩ ត្រូវនឹងថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០២៤ខាងមុខនេះ: **ខ្ញុំម្ចាស់ព្រមទាំងបុត្រី** សូមលំឱនកាយក្រាបថ្វាយបង្គំ និងសូមព្រះបរមរាជានុញ្ញាតថ្វាយព្រះពរស័ព្ទសាធុការ បវរមហាប្រសើរថ្វាយ **សម្តេចព្រះមហាក្សត្រី ព្រះចរះរាជអាតាជាតិខ្មែរ** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត សូមព្រះអង្គទ្រង់ប្រកបដោយព្រះរាជបញ្ញាញាណភ្លឺថ្លា ព្រះកាយពលសិរីវឌ្ឍនា ព្រះរាជសុខភាពល្អបរិបូរណ៌ ព្រះជន្មាយុយឺនយូរជាងរយព្រះវស្សា និងចាកផុតពីព្រះរោគាព្យាធិនានាជាអង្វែងតរៀងទៅ។

ក្នុងឱកាសដ៏មហាវិសេសថ្លៃថ្លានេះ: **ខ្ញុំម្ចាស់ព្រមទាំងបុត្រី** សូមលើកហត្ថប្រណមបួងសួងដល់វត្ថុសក្តិសិទ្ធិទាំងឡាយក្នុងលោក គុណបុណ្យព្រះរតនត្រ័យ គុណកែវទាំងបី ទេវតាថែរក្សាព្រះមហាស្វេតច្ឆត្រ ឫទ្ធិបារមីខ្លាំងក្លានៃជួងព្រះវិញ្ញាណក្ខន្ធអតីតព្រះមហាក្សត្រ ព្រះមហាក្សត្រីយានីខ្មែរគ្រប់ព្រះអង្គ ជាពិសេសបុណ្យបារមីនៃជួងព្រះវិញ្ញាណក្ខន្ធព្រះបរមរតនកោដ្ឋ សូមព្រះអង្គតាមជួយថែរក្សាអភិបាលប្រោសព្រំនូវព្រះសព្វសាធុការពរជ័យគ្រប់ប្រការ ថ្វាយចំពោះ: **សម្តេចព្រះមហាក្សត្រី ព្រះចរះរាជអាតាជាតិខ្មែរ** ជាទីគោរពសក្ការៈ ដើម្បីគង់ប្រថាប់ដឹកនាំប្រទេសជាតិឆ្ពោះទៅកាន់ភាពរុងរឿងសម្បូណ៌សប្បាយដូចប្រទេសនានាលើសកលលោក និងជាម្លប់ដ៏សុខក្សេមក្សាន្ត ត្រជាក់ត្រជុំរបស់ប្រទេសជាតិ និងប្រជារាស្ត្រខ្មែរជាកិយ្យោភាពតរៀងទៅ។

សូម **សម្តេចព្រះមហាក្សត្រី ព្រះចរះរាជអាតាជាតិខ្មែរ** ព្រះមេត្តាប្រោសទទួលនូវស្វាមីភ័ក្តិដ៏ស្មោះស្ម័គ្រ និងសេចក្តីគោរពដ៏ខ្ពង់ខ្ពស់បំផុតអំពីខ្ញុំម្ចាស់ ព្រមទាំងបុត្រី ។

សេចក្តីគួរជំគួរ **សូមសម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ** ព្រះមេត្តាប្រោសព្រះរាជទានទោសៗ

ថ្ងៃអង្គារ ១៥កើត ខែជេស្ឋ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
សូមក្រាបបង្គំទូលថ្វាយនៅរាជធានីភ្នំពេញ ថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២៥

ហត្ថលេខា

ស៊ីសុវត្ថិ កន្ធីរ៉ែត

ព្រះរាជាណាចក្រកម្ពុជា
KINGDOM OF CAMBODIA
ជាតិ សាសនា ព្រះមហាក្សត្រ
NATION RELIGION KING

គណៈជីកនាំជាន់ខ្ពស់នៃសាសនាឥស្លាមកម្ពុជា
المجلس الأعلى للشؤون الإسلامية في كمبوديا
HIGHEST COUNCIL FOR ISLAMIC RELIGIOUS AFFAIRS CAMBODIA
លេខ: ២៤៧.៣.../...ចគជឥក...HICIRAC
២៤

សារលិខិតថ្វាយព្រះពរ
សូមក្រាបបង្គំទូលថ្វាយ
សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ
ព្រះចរះរាជអាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល

សម្តេចព្រះមហាក្សត្រី ព្រះចរះរាជអាតាជាតិខ្មែរ ជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុត!

ក្នុងឱកាសដ៏មហានក្ខត្តឫក្សអធិកអធមឧត្តុង្គឧត្តមប្រសើរថ្លៃថ្លា នៃព្រះរាជពិធីបុណ្យចម្រើនព្រះជន្ម **សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះចរះរាជអាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល** ជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុត ក្នុងគម្រប់ ៨៩ព្រះវស្សា យាងចូល៩០ព្រះវស្សា តាងនាមគណៈដឹកនាំជាន់ខ្ពស់នៃសាសនាឥស្លាមកម្ពុជា គណៈអ៊ីមុាំរាជធានី ខេត្ត-ក្រុង ស្រុក-ខណ្ឌ គណៈអ៊ីមុាំ ម៉ាស្ជិទ គ្រូបង្រៀនខ្មែរឥស្លាម បងប្អូនប្រជាពលរដ្ឋសាសនិកឥស្លាម និងក្នុងនាមទូលព្រះបង្គំជាខ្ញុំផ្ទាល់ព្រមទាំងភរិយា មានមហាកិត្តិយសប្រកបដោយបីតិសោមនស្សរីករាយជាអនេក សូមព្រះបរមរាជានុញ្ញាតក្រាបបង្គំថ្វាយព្រះពរ បវរមហាប្រសើរថ្វាយ **សម្តេចព្រះមហាក្សត្រី ព្រះចរះរាជអាតាជាតិខ្មែរ** ជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុត។

ក្នុងទិវាដ៏មហានក្ខត្តឫក្សនេះ ទូលព្រះបង្គំយើងខ្ញុំទាំងអស់គ្នា សូមព្រះបរមរាជានុញ្ញាតសម្តែងនូវកតញ្ញូតាធម៌ដ៏ជ្រាលជ្រៅ និងស្មោះត្រង់បំផុតថ្វាយ**សម្តេចព្រះមហាក្សត្រី ព្រះចរះរាជអាតាជាតិខ្មែរ** ដែលព្រះអង្គតែងយកអស់ព្រះរាជហឫទ័យទុកដាក់ ចំណាយអស់ព្រះបញ្ញាញាណ ព្រះកាយពល បំពេញព្រះរាជកិច្ចដ៏ថ្លៃថ្លា ដើម្បីជាតិមាតុភូមិ និងប្រជានុរាស្ត្រខ្មែរទូទាំងប្រទេស សម្រាប់វឌ្ឍនភាពសង្គមភាពសុខដុមរមនា និងសេចក្តីសុខក្សេមក្សាន្តនៅគ្រប់ទិសទី។

ឆ្លៀតក្នុងឱកាសនៃព្រះរាជពិធីបុណ្យចម្រើនព្រះជន្មដ៏ឧត្តុង្គឧត្តមនេះ ទូលព្រះបង្គំ យើងខ្ញុំទាំងអស់គ្នា សូមព្រះបរមរាជានុញ្ញាតបួងសួងដល់ **អល់ឡោះជាម្ចាស់** សូមប្រទានចំពោះ: **សម្តេចព្រះមហាក្សត្រី ព្រះចរះរាជអាតាជាតិខ្មែរ** ជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុតនូវព្រះរាជសុខភាពល្អបរិបូរណ៌ ព្រះកាយពលមាំមួន ព្រះបញ្ញាញាណវាងវៃ ព្រះជន្មាយុយឺនយូរ ដើម្បីគង់ប្រថាប់ជាម្លប់ដ៏ត្រជាក់ត្រជុំសុខដុមរមនាដល់មាតុភូមិកម្ពុជាជានិច្ចនិរន្តរ៍តរៀងទៅ។

សូម **សម្តេចព្រះមហាក្សត្រី ព្រះចរះរាជអាតាជាតិខ្មែរ** ជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុត ទ្រង់ព្រះរាជមេត្តាសន្តោសប្រោសប្រណីដោយព្រះទ័យករុណា និងព្រះរាជមេត្តាទទួលនូវអភិវន្ទនកិច្ចដ៏ខ្ពង់ខ្ពស់បំផុតពីទូលព្រះបង្គំជាខ្ញុំ។ ២៧

ថ្ងៃ[illegible] ខែ[illegible] ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
ក្រាបបង្គំទូលថ្វាយនៅរាជធានីភ្នំពេញ ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២៥

គណៈជីកនាំជាន់ខ្ពស់នៃសាសនាឥស្លាមកម្ពុជា
ចាងហ្វាង

អ្នកឧកញ៉ា សុះ កាំរ៉ី

M & Mme Yanda OUM
Villa Me Prey
Phum Svay Thom
Khum Kraing Ampil
Ville de Kampot
Province de Kampot

Paris le 26 Juin 2025

S.M NORODOM Monineath Sihanouk
Reine Mère du Cambodge.
Palais Royal
Phnom Penh
Royaume du Cambodge

N.Réf. SM.YO.250601

Bien respectueuse Luong Mè,

Nous avons la douleur d'annoncer à Votre Majesté le décès de notre bien-aimée benjamine Ariya Juliette OUM, survenu à Paris le 25 Juin 2025, à l'âge de 36 ans.

Notre Ariya adorée a perdu la bataille qu'elle a menée depuis novembre 2017 contre le cancer du côlon.

Presque huit années de souffrance, d'espoir vain et de combat a toutes épreuves, ont façonné sa volonté, sa force, et son opiniâtreté. Mais le sort ne lui était pas favorable, il a détruit son courage et son amour pour la VIE.

Une vie si courte est insoutenable pour ses parents et les autres membres de sa famille. Cela a creusé un trou béant et incommensurable qui ne se refermera jamais dans notre cœur meurtri.

Ariya est partie paisiblement. Elle n'a pas trop souffert dans ses derniers instants inhérents à son état comateux.

Ariya est en paix maintenant, elle ne souffre plus. Mais son absence pour ses parents, son frère et sa sœur, est douloureux à supporter. Et pour nous qui l'ont vue partir, ce sera une longue pente et un chemin de rémission que seul le temps guérira.

Que Votre Majesté daigne se joindre à nous pour prier pour l'âme de notre bien-aimée Ariya. Qu'elle trouve la paix éternelle dans le sillon de Notre Auguste Bouddha.

Nous présentons à Luong Mè ainsi qu'à Sa Majesté Le Roi Votre fils bien-aimé notre profond respect et notre indéfectible affection. Et nous souhaitons à Vos Augustes Personnes une excellente santé et dont la longévité continuera d'apporter la paix à notre patrie.

Yanda OUM

Thony CHHEM-KIETH OUM

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សមាគមតន្ត្រីសំនៀងជនពិការ
MUSICAL ASSOCIATION FOR PERSON WITH DISABILITY
លេខ: ✓ ស.ត.ជ.

សារលិខិតថ្វាយព្រះពរ

សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ
ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល

សម្តេចព្រះមហាក្សត្រី ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត!

ក្នុងឱកាសដ៏មហានក្ខត្តឫក្ស សិរីសួស្តី ជ័យមង្គល ក្នុងព្រះរាជពិធីបុណ្យចម្រើនព្រះជន្មាយុគម្រប់ ៨៩ព្រះវស្សា យាងចូល ៩០ព្រះវស្សារបស់ **សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ** នៅថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០២៥ ខាងមុខនេះ ខ្ញុំម្ចាស់ ទូលព្រះបង្គំយើងខ្ញុំទាំងអស់គ្នា ជាថ្នាក់ដឹកនាំ គណៈគ្រប់គ្រង បុគ្គលិក សមាជិក សមាជិកា ជនមានពិការភាពភ្នែក និងកាយសម្បទា ចំនួន៧០០នាក់ នៃសមាគមតន្ត្រីសំនៀងជនពិការដែលបានទទួលនូវព្រះរាជទានឧបត្ថម្ភថវិកាដ៏ថ្លៃថ្លាដើម្បីទិញដីសាងសង់អាគារស្នាក់នៅ និងបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈអំពី **សម្តេចព្រះមហាក្សត្រី ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត** សូមព្រះបរមាជានុញ្ញាតលំនឹងកាយវាចាចិត្តក្រាបបង្គំថ្វាយនូវ ព្រះសព្វសាធុការពរជ័យ បវរសួស្តី សិរីមង្គល វិបុលសុខ មហាប្រសើរគ្រប់ប្រការថ្វាយចំពោះ **សម្តេចព្រះមហាក្សត្រី** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត។

ក្នុងឱកាសដ៏វិសេសវិសាលបំផុតនេះ ខ្ញុំម្ចាស់ ទូលព្រះបង្គំ យើងខ្ញុំទាំងអស់គ្នា សូមព្រះបរមាជានុញ្ញាតលើកអញ្ជលីប្រណម្យ បួងសួងដល់គុណបុណ្យ ព្រះរតនត្រ័យកែវទាំងបី វត្ថុស័ក្តិសិទ្ធិទាំងឡាយក្នុងលោក ទេវតារក្សាព្រះរាជាណាចក្រកម្ពុជា ព្រះបារមីអតីតព្រះមហាក្សត្រ ព្រះមហាក្សត្រីយានីគ្រប់ព្រះអង្គ សូមប្រោះព្រំព្រះសព្វសាធុការពរ បវរសួស្តី សិរីមង្គល វិបុលសុខ មហាប្រសើរ ថ្វាយចំពោះ **ព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ** សូមព្រះអង្គមានព្រះជន្មាយុ យឺនយូរដោងរយព្រះវស្សា មានព្រះរាជសុខភាពល្អបរិបូរណ៌ ព្រះកាយពលមាំមួន ព្រះបញ្ញាញាណភ្លឺថ្លា ដើម្បីស្តេចគង់ប្រថាប់ជាម្លប់ដ៏ត្រជាក់ត្រជុំដល់ប្រជារាស្ត្រទូទាំងប្រទេស និងសមប្រកបដោយព្រះពុទ្ធពរដ៏ប្រសើរថ្លៃថ្លាទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ និងពលៈ ជាកិរិយ្យាភាពតរៀងទៅ។

សូម **សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ទ្រង់ព្រះមេត្តាប្រោសទទួលនូវការអរព្រះគុណដ៏ខ្ពង់ខ្ពស់ និងជ្រាលជ្រៅជាទីបំផុត អំពីខ្ញុំម្ចាស់ ទូលព្រះបង្គំ យើងខ្ញុំទាំងអស់គ្នាជាថ្នាក់ដឹកនាំ និងកូនចៅមានពិការភាពភ្នែក និងកាយសម្បទាក្នុងសមាគមដោយសេចក្តីអនុគ្រោះ។

ថ្ងៃចន្ទ ៦រោច ខែជេស្ឋ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២៥

រដ្ឋលេខាធិការ និងជាប្រធានកិត្តិយស

ហ៊ែម-មរកត

អនុរដ្ឋលេខាធិការ និងជាប្រធានសមាគម

ចាប គូ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សារលិខិតថ្វាយព្រះពរ
សូមក្រាបបង្គំទូលថ្វាយ
សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ
ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល
ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត!

ក្នុងឱកាសដ៏សែនមហានក្ខត្តឫក្ស នៃព្រះរាជពិធីបុណ្យចម្រើនព្រះជន្មគម្រប់ ៨៩ព្រះវស្សា ***សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ*** *ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃពុធ ៨រោច ខែជេស្ឋ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី ១៨ ខែ មិថុនា ឆ្នាំ ២០២៥ វាងមុខនេះ* ខ្ញុំម្ចាស់ និងក្រុមគ្រួសារទាំងអស់ សូមព្រះបរមរាជានុញ្ញាតិសំនិនកាយក្រាបបង្គំទូលថ្វាយ នូវព្រះរាជសព្ទសាធុការពរជ័យ វិបុលសុខមហាប្រសើរគ្រប់ប្រការ និងសូមលើកហត្ថប្រណិបួងសួងដល់ទេវតាថែរក្សាទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ទេវតាថែរក្សាព្រះបរមរាជវាំងចតុម្មុខមង្គល ទេវតាថែរក្សាព្រះមហាស្វេតឆត្រ និងបារមីនៃដួងព្រះវិញ្ញាណក្ខន្ធអតីតព្រះមហាក្សត្រ ព្រះមហាក្សត្រិយានីខ្មែរគ្រប់ព្រះអង្គ ដួងព្រះវិញ្ញាណក្ខន្ធព្រះបរមរតនកោដ្ឋ សូមព្រះអង្គតាមជួយគាំពារបីបាច់ថែរក្សា ***សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ*** សូមមានព្រះរាជសុខភាពល្អបរិបូរណ៌ ព្រះកាយពលរឹងមាំ ព្រះជន្មាយុយឺនយូរ ដើម្បីព្រះអង្គគង់ប្រថាប់ជាម្លប់ដ៏ត្រជាក់ដល់កូនចៅទាំងអស់ក្នុងព្រះនគរ ។

សូម ***សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ*** *ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ទ្រង់ព្រះមេត្តាទទួលនូវសេចក្តីគោរពស្ងាមីកក្តីដ៏ស្មោះស្ម័គ្របំផុតពីខ្ញុំម្ចាស់ ។*

សេចក្តីគួរពុំគួរ សូម ***សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ*** *ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ទ្រង់ព្រះមេត្តាប្រោសព្រះរាជទានទោស ។*

ថ្ងៃអង្គារ ៧រោច ខែជេស្ឋ ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៩
ក្រាបបង្គំទូលថ្វាយនៅរាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០២៥

ខ្ញុំស្រី ម៉ែន ច័ន្ទទេវី

សូមក្រាបថ្វាយបង្គំ
សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ
ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត

បពិត្រសម្តេចព្រះមហាក្សត្រី ជាអម្ចាស់ជីវិតតម្កល់លើក្បាល!

នៅក្នុងវារោកាសដ៏មហានក្ខត្តឫក្សប្រកបដោយសិរីជ័យមង្គល នៃទិវាចម្រើនព្រះជន្មព្រះវស្សា **សម្តេចព្រះវររាជមាតា**ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត គម្រប់៨៩ យាងចូល៩០ព្រះវស្សា នាថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០២៥នេះ ទូលព្រះបង្គំជាខ្ញុំ សូមព្រះបរមាជានុញ្ញាតដ៏ខ្ពង់ខ្ពស់បំផុត លំនិនកាយក្រាបថ្វាយបង្គំ សម្តែងនូវមនោសញ្ចេតនាសោមនស្សរីករាយ អបអរសាទរក្នុងទិវាដ៏មហាមង្គលឧត្តុង្គឧត្តមនេះ និងសូមលើកហត្ថប្រណម្យបង្គំអញ្ជលី បួងសួងដល់គុណបុណ្យព្រះរតនត្រ័យកែវទាំងបីតេជៈបារមីនៃវត្ថុស័ក្តិសិទ្ធិទាំងឡាយក្នុងលោក មានទេវតាឆ្នាំថ្មី ទេវតាថែរក្សាព្រះរាជាណាចក្រកម្ពុជា ទេវតាថែរក្សាព្រះមហាស្វេតឆត្រក្នុងព្រះបរមរាជវាំង ដួងព្រះវិញ្ញាណក្ខន្ធអតីតព្រះមហាក្សត្រ ព្រះមហាក្សត្រីយានីខ្មែរគ្រប់ព្រះអង្គ ជាពិសេសព្រះបរមវិញ្ញាណក្ខន្ធ **ព្រះករុណាព្រះបរមរតនកោដ្ឋ** សូមព្រះមេត្តាប្រោសព្រះរាជទាននូវព្រះពរជ័យប្រោះព្រំថ្វាយ **សម្តេចព្រះវររាជមាតា** ជាអម្ចាស់ សូមប្រកបតែនឹងសិរីមង្គលវិបុលសុខគ្រប់ប្រការ មានព្រះរាជសុខភាពល្អបរិបូរណ៌ ព្រះកាយ ពល មាំមួន ព្រះបញ្ញាញាណត្រចះត្រចង់ ព្រះទិឃាយុយឺនយូរ ដើម្បីគង់ប្រថាប់ជាម្លប់ដ៏ត្រជាក់ត្រជុំសុខដុមរមនាជាភិយ្យោភាព ដល់ជនរួមជាតិប្រជានុរាស្ត្រទូទាំងព្រះរាជាណាចក្រកម្ពុជា ដរាបតរៀងទៅ។

ឆ្លៀតក្នុងឱកាសទិវាដ៏មហាមង្គលបវរថ្លៃថ្លានេះ ទូលព្រះបង្គំជាខ្ញុំ សូមព្រះបរមាជានុញ្ញាតសម្តែងថ្វាយនូវកតញ្ញូតាធម៌យ៉ាងជ្រាលជ្រៅបំផុត ចំពោះព្រះរាជសកម្មភាពប្រកបដោយព្រះប្រាជ្ញាវិហារធម៌ សប្បុរសធម៌ សន្តោសប្រោសប្រណីនៃ**សម្តេចព្រះវររាជមាតា**ជាអម្ចាស់ ដែលបានប្រទានដល់កូនចៅ ចៅទួតជាប្រជានុរាស្ត្រគ្រប់និគមជនបទទូទាំងប្រទេស។

សូម**សម្តេចព្រះវររាជមាតា**ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ព្រះមេត្តាទទួលនូវសេចក្តីគោរពនិងភក្តីភាពដ៏ខ្ពង់ខ្ពស់បំផុត ពីទូលព្រះបង្គំជាខ្ញុំ។

ក្រាបបង្គំទូលថ្វាយ នៅភ្នំពេញ ថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០២៥
ទូលព្រះបង្គំជាខ្ញុំ

អ៊ុំ ជាវ៉ាវុធ

N.B. Daigne Luong Me, très respectée permettre à votre très humble serviteur de vous présenter ses vœux pour vos 89 magnifiques années que Luong Me a daigné servir le Cambodge ainsi que le peuple Cambodgien.
Votre très dévoué serviteur Yaek

—— Message transféré ——
De : "Ravivaddhana Monipong Sisowath" <ravisisowath@yahoo.com>
To <roycabeijing@hotmail.com>
Envoyé : mar., juin 17, 2025 à 22:06
Objet : A la Très Haute Attention de Sa Majesté la Reine-Mère Norodom Monineath Sihanouk du Cambodge

A la Très Haute Attention de Sa Majesté la Reine-Mère
Norodom Monineath Sihanouk du Cambodge
Preah Baromma Reach Veang
Preah Reach Damnak Kantha Buppha
Reach Theany Phnom Penh

Monterotondo, le 18 juin 2025

Luong Mè Vénérée,

en cette occasion très heureuse, Vincenzo se joint à moi pour présenter à notre Reine-Mère bien-aimée nos voeux les plus sincères pour un Très Joyeux Anniversaire. Puisse Votre Majesté continuer d'étendre Son ombre protectrice sur tous Ses enfants avec douceur et affection et puissent les Tevodas protéger toujours notre Souveraine révérée, La combler de bonheur et de bienfaits dans tous les domaines.

Comme tous les ans, le 18 juin est une date magique qui me rappelle avec émotion et allégresse l'auguste naissance de notre Reine-Mère adorée, une Grande Dame exceptionelle, dotée d'un immense courage et d'une compassion sincère envers tous celles et ceux qui ont eu la chance de La rencontrer. En ce qui me concerne, je me souviens toujours avec un sentiment de gratitude infinie ce matin d'avril 1996, lorsque Votre Majesté en visite d'Etat en France a rapporté dans Ses bagages ma carte d'identité de membre de la Famille Royale. La sollicitude protectrice que Luong Mè a eue à mon égard m'a permis alors de surmonter avec patience et persévérance la situation de conflit terrible qui s'était créée entre mes parents et moi. Ma reconnaissance infinie et ma fidélité infaillible sont à jamais dévouées à Luong Mè, notre Révéré Roi-Père au Paradis et à Sa Majesté notre Souverain régnant qui m'ont toujours tenu sous Leur Ombre protectrice et je rends très humblement hommage à Leurs Majestés pour Leur augustes mansuétude et affection.

Cette année, le 18 juin sera aussi une date très spéciale pour moi car j'aurai l'honneur d'accompagner dans quelques heures une délégation de jeunes pélerins catholiques cambodgiens de la Préfecture Apostolique de Battambang-Siem Reap, en compagnie de Vincenzo et du Père Totet Banaynal, leur Père Spitrituel Jésuite en la paroisse de Saint Jean de Siem Reap, à une audience privée, concédée par Son Eminence le Cardinal Luis Antonio Tagle, Pro-Préfet du dicastère pour l'évangélisation et qui vient de recevoir de Sa Sainteté le Pape Léon XIV le titre de Cardinal-Eveque d'Albano, le 24 mai dernier. Ce titre prestigieux était en effet destiné au nouveau Pape avant son élection comme Souverain Pontife.

Vincenzo et moi partirons pour le sud de l'Italie à la fin du mois car nous a été confiée la mise en scène de "Rigoletto" de Giuseppe Verdi dans un festival en plein air dans la province de Bari dans les Pouilles. Ensuite, après les Festivals de Spoleto et de Caracalla que nous devons couvrir pour la presse musicale italienne et quelques jours de repos dans la famille du marquis dans les Marches aux alentours de l'Assomption, nous pousuivrons dès la rentrée les préparatifs de notre projet de fin d'année, "Don Giovanni" de Mozart à Phnom Penh. Son Excellence l'Ambassadeur Paolo Dionisi m'a confié sa très grande fierté d'avoir eu l'honneur d'etre reçu tout récemment dans l'ordre cambodgien du Monisaraphon avec rang de Grand Croix et nous a assurés de son soutien moral (et ... financier, nous l'espérons,) pour ce grand opéra, qui pourrait devenir le premier d'une série de rendez-vous lyriques annuels au Cambodge, dans une collaboration culturelle unique entre le Cambodge et l'Italie. Quand nous serons à Phnom Penh en décembre prochain, nous ne manquerons pas de requérir de Votre Majesté l'insigne honneur d'une Audience privée afin de Lui raconter nos dernières aventures artistiques et musicales.

Daigne, Luong Mè Vénérée, Votre Majesté, agréer l'expression très affectueuse de mes hommages profondément respectueux.

Je reste et demeure, Luong Mè Vénérée, de Votre Majesté, le très fidèle et dévoué serviteur et sujet.

Sisowath Ravivaddhana Monipong

캄보쟈왕국주재
조선민주주의인민공화국
대사관

Embassy of the Democratic People's Republic of Korea to the Kingdom of Cambodia

01 August 2025

Her Majesty NORODOM MONINEATH SIHANOUK
Queen Mother
King of Cambodia

Esteemed Your Majesty,

I have the honor to inform that I will conclude my assignment as Ambassador of the Democratic People's Republic of Korea to the Kingdom of Cambodia on 9 August 2025.

I would like to take this opportunity to convey my sincere appreciation for the excellent support and encouragement Your Majesty have extended to me during my 9-years mission in the Kingdom of Cambodia.

I am confident that the friendly relations of cooperation which was established by Comrade **Kim Il Sung**, the President of the DPRK, and His Majesty the Great King **Norodom Sihanouk**, the King Father of the Khmer Nation, will be maintained and further strengthened by wise leadership of Comrade **Kim Jong Un**, the President of State Affairs Committee of the DPRK and His Majesty **Norodom Sihamoni**, the King of Cambodia.

While extending my deep regret for failing to pay farwell visit due to my health problem, I wish Your Majesty for futher happiness, good health and successes in the responsible endeavour.

Please accept, Your Majesty, the assurances of my highest consideration.

Yours Sincerely

장윤곤

Jang Yun Gon

Ambassador

À Sa Majesté la Reine Mère

Majesté Luong Mair,

Je tiens à Vous exprimer ma profonde gratitude pour l'attention que Vous avez bien voulu porter à ma santé en prenant de mes nouvelles par Chum Teav bang Saoroth.

Votre geste m'a profondément touché et m'a apporté un grand réconfort dans une période difficile.

Recevoir un mot de Votre part a été pour moi un honneur et une source d'encouragement. Votre bienveillance et Votre sollicitude témoignent de Votre grandeur d'âme et de l'intérêt que Vous portez à chacun de Vos sujets.

Je Vous adresse mes plus sincères remerciements.

Daignez accepter, Majesté Luong Mair, l'expression de ma très haute considération et de mon profond respect.

La Queue en Brie, le 20 juillet 2025

Kgnom chas
Sarany LY +33 6135160 77
17, route de Combault 94510 La Queue en Brie

Deutsch-Kambodschanische Gesellschaft e.v.

សមាគមខ្មែរ-អាល្លឺម៉ង់

Sitz:
HEUBACH/WÜRTT.

DKG · Adlerstraße 7/1 · 73540 Heubach

Sa Majesté La Reine Mère
NORODOM MONINEATH SIHANOUK
du Cambodge

Palais Royal
Phnom-Penh
Royaume du Cambodge



DKG
Adlerstraße 7/1
D-73540 Heubach
Tel. 07173/92 90 50
Fax: 07173/4586
House.of.Peace@t-online.de
www.friedenshaus-kambodscha.org
www.house-of-peace.org

សូមព្រះបរមរាជានុញ្ញាតដ៏ខ្ពង់ខ្ពស់ក្រាបបង្គំទូលថ្វាយ
សម្តេចព្រះមហាក្សត្រីនរោត្តមមុនីនាថ សីហនុព្រះវរ-
រាជមាតាជាតិខ្មែរគ្រងសេរីភាពស្មោះត្រង់ដែលឆ្លងនឹង
សុភមង្គលជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត

សូមព្រះតេជៈដ៏ពិសិដ្ឋ

ទូលព្រះបង្គំជាខ្ញុំដែលជាកូនសាច៉ារបស់ព្រះអង្គ សូម
បរមរាជានុញ្ញាតក្រាបបង្គំទូលថ្វាយសម្តេចព្រះមហាក្សត្រីព្រះវររាជ
មាតាជាតិខ្មែរនៃព្រះនាដែលណាមួយក្នុងការជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់
បំផុត សូមព្រះមេត្តាសណ្តាប់ព្រះរាជហឫទ័យផង។

ឆ្នាំច រាំង ស ខែមេសា ព្រះវររាជមាតាជាតិខ្មែរ
ជាព្រះរាជានីដ៏ថ្កុំថ្កើងសង្ខែសាលាឡើង "ផ្ទះសន្តិភាព ព្រះសីហនុសន្តិភាពជ្រៃ"
ទូលព្រះបង្គំជាខ្ញុំ សូមសើរក្រាបថ្វាយព្រះអង្គ នូវសិរីមង្គលជាទីគោរពសក្ការៈ
ដ៏ខ្ពង់ខ្ពស់បំផុតជាទីបំផុត ដោយគោរពដ៏ខ្ជាប់ខ្ជួនបំផុត សូមសំដែងថ្វាយជូន
ទូលព្រះបង្គំជាខ្ញុំមានបំណងដែលចង់ឃើញព្រះអង្គ
ជាទីឃើញចំនួន ១០០ដងមកថ្វាយព្រះវររាជមាតាជាតិខ្មែរ។
ទូលព្រះបង្គំជាខ្ញុំនឹងមកបំពេញកិច្ចការនៅថ្ងៃទី ភ្នំពេញ ចាប
ពីថ្ងៃទី ដល់ថ្ងៃ ពាក្យកក្កដា ២០ ដែលមានដូចតទៅនេះ។

(ខ)

ទូលព្រះបង្គំជាខ្ញុំ សូមរាយនាមសហការីគំាងដឹកនាំសាខាផ្សែត
ដែលចូលរួមមកថ្វាយបង្គំព្រះវររាជមាតាជាតិខ្មែរ៖

១- ទូលព្រះបង្គំ ទេជ្ជបណ្ឌិតចន ថ្លៅដ សិរី
២- ទេជ្ជបណ្ឌិត Ludwig Vitbel ទីមួយ (លូដវីច វិបុល សិរី)
អនុប្រធានសមាគមខ្មែរ-អាល្លឺម៉ង់
៣- លោក អ៊ុច សីហា អនុប្រធានសាលាឡើង "ផ្ទះសន្តិភាព
ព្រះសីហនុសន្តិភាពជ្រៃ"

ទូលព្រះបង្គំជាខ្ញុំ សូមអភ័យទោសចំពោះការដែលមិនបានមកគាល់ព្រះអង្គ
ដោយផ្ទាល់ ទូលព្រះបង្គំជាខ្ញុំ តាមលេខទូរស័ព្ទដៃដូចមានក្នុង
ក្រោមនេះ៖ Tel: ០១២ ៩៧ ៨៧ ៧៨ ៩
Tel = 012 928 789

ក្រុមគ្រួសារសមាគមខ្មែរ-អាល្លឺម៉ង់ ក្រុមគ្រួសារសាលាឡើង
"ផ្ទះសន្តិភាពព្រះសីហនុសន្តិភាពជ្រៃ" នឹងក្តីដឹងគុណចំពោះទូលព្រះបង្គំជាខ្ញុំដ៏ជ្រាលជ្រៅ
